ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

ក្រសួងយុត្តិធម៌



# ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន

## ២០១៨ - ២០២០

បោះពុម្ពលើកទី១ ចំនួន ១ ០០០ ក្បាល
នៅខែ សីហា ឆ្នាំ២០១៨

សហការរៀបចំដោយៈ

ក្រសួងយុត្តិធម៌ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# អារម្ភកថា

កុមារ គឺជាធនធានដ៏សំខាន់សម្រាប់បន្តវេនអភិវឌ្ឍប្រទេសជាតិនាថ្ងៃអនាគត ហើយកុមារក៏ជាជនដែលអាចនឹងងាយរងគ្រោះផងដែរ ហេតុនេះហើយ ការគិតគូរអំពី ការធានា ការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ គឺជាកាតព្វកិច្ចចម្បងមួយ ក្នុងចំណោមកាតព្វកិច្ចចម្បងនានាជាច្រើនរបស់រដ្ឋ ។

ទន្ទឹមនឹងនេះ នៅពេលដែលយើងនិយាយអំពីកិច្ចការពាររបស់រដ្ឋចំពោះកុមារ រដ្ឋនីមួយៗត្រូវគិតគូរផងដែរ ចំពោះកុមារដែលជាជនងាយរងគ្រោះ និងកុមារដែលទំនាស់នឹងច្បាប់ ។

បើយើងពិនិត្យមើលទៅលើជ្រុងមួយនៃកិច្ចការកុមារដែលទំនាស់នឹងច្បាប់ យើងពិតជាដឹងហើយថារដ្ឋបានរៀបចំនូវបទប្បញ្ញត្តិគតិយុត្ត និងបង្កើតនូវយន្តការនានាជាច្រើន ដើម្បីធានាការពារសិទ្ធិរបស់កុមារដែលទំនាស់នឹងច្បាប់ ហេតុនេះហើយ ទើបក្រោយពីច្បាប់ស្តីពី « យុត្តិធម៌អនីតិជន » ត្រូវបានរដ្ឋសភាអនុម័តកាលពីខែកក្កដា ឆ្នាំ២០១៦ និងចូលជាធរមាន នៅដើមឆ្នាំ២០១៧ ដើម្បីធានាការអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធភាព តម្រូវឲ្យមានផែនការយុទ្ធសាស្ត្រណែនាំច្បាស់លាស់សម្រាប់ក្រសួង និងស្ថាប័នពាក់ព័ន្ធអនុវត្តទៅតាមភារកិច្ច និងដំណាក់កាល នៃការងារអាទិភាពនីមួយៗរបស់ខ្លួន ដែលជាកត្តាធ្វើឲ្យយើងអាចឈានទៅសម្រេចគោលដៅចុងក្រោយទាក់ទងទៅនឹងកិច្ចការពារកុមារ ។

យើងទទួលស្គាល់ថា ច្បាប់ស្តីពី « យុត្តិធម៌អនីតិជន » គឺជាសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ហើយកម្មវិធីទាំងឡាយដែលបានដាក់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដើម្បីកសាងគ្រឹះដ៏រឹងមាំនិងប្រកបដោយចីរភាពសម្រាប់ប្រព័ន្ធយុត្តិធម៌ទំនើបមួយដែលផ្តោតសំខាន់លើការបង្វែរ ជាជាងការដាក់ទណ្ឌកម្មឲ្យជាប់ឃុំ ដើម្បីផ្តល់ឱកាសដល់អនីតិជនក្នុងការកែប្រែខ្លួន កសាងអនាគត និងក្លាយជាពលរដ្ឋល្អទៅថ្ងៃអនាគត ហើយក៏មានការទទួលស្គាល់ជាអន្តរជាតិថា ការបង្វែរកុមារចេញពីប្រព័ន្ធព្រហ្មទណ្ឌ ចេញពីកន្លែងឃុំឃាំង គឺជាយន្តការមួយដែលអាចបញ្ចៀសកុមារ មិនឲ្យប្រព្រឹត្តិបទល្មើសសារជាថ្មី។ ផែនការយុទ្ធសាស្ត្រនេះ បានកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នារវាង ក្រសួងយុត្តិធម៌ និង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានកិច្ចសហការពីអង្គការ សិទ្ធិកុមារអន្តរជាតិ (CRI) និងអង្គការ UNICEF ប្រចាំនៅកម្ពុជា ។ មិនតែប៉ុណ្ណោះ សិក្ខាសាលាពិគ្រោះយោបល់ធំៗចំនួនពីរលើក ក៏ត្រូវបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ដើម្បីផ្តល់ឱកាសឲ្យស្ថាប័នទាំងអស់បានចូលរួមផ្តល់នូវមតិយោបល់ផងដែរ ។

បន្ទាប់ពីផែនការនេះ ត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្ត ជំហានបន្ទាប់ ស្ថាប័នពាក់ព័ន្ធដែលមានសមត្ថកិច្ចអនុវត្តដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ អាចអនុវត្តភារកិច្ចរបស់ខ្លួនដោយភាពជាម្ចាស់ ឬអាចសហការជាមួយដៃគូអភិវឌ្ឍ នៅក្នុងដំណើរការការងាររបស់ខ្លួន ។

ក្រសួងសង្ឃឹមថា ផែនការយុទ្ធសាស្ត្រនេះ គឺជាជំនួយ និងជាគ្រឹះដ៏សំខាន់ដែលបានកំណត់សកម្មភាព និងពេលវេលាជាក់លាក់ សម្រាប់បង្កលក្ខណៈងាយស្រួលឲ្យស្ថាប័ននីមួយៗអនុវត្ត និងតាមដាននូវសកម្មភាព របស់ខ្លួនទាក់ទងទៅនឹងកិច្ចការពារកុមារ។

ជាមួយគ្នានេះ ក្រសួងសូមសម្តែងនូវអំណរគុណ និងកោតសរសើរខ្ពស់ ចំពោះស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ នានាដែលបានរួមសហការគ្នា ក្នុងកិច្ចការពារ និងលើកស្ទួយសិទ្ធិកុមារ ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៨

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

ថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃ ២៦ ខែមីនា ឆ្នាំ ២០១៨

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

# មាតិកា


អក្សរនិងពាក្យកាត់ 7

១. សេចក្ដីសង្ខេប 8

២. សាវតា 12

៣. វិធីសាស្ត្រ 16

៣.១. ទិដ្ឋភាពទូទៅ 16

៣.២. ការអនុវត្តបទដ្ឋានអន្តរជាតិ 18

៣.៣. ការពិចារណាលើការអនុវត្តល្អពីអន្តរជាតិ 22

៣.៤. ការពិគ្រោះយោបល់ 26

៣.៥. ការវិភាគច្បាប់ស្ដីពីយុត្តិធម៌អនីតិជន 27

៣.៦. តារាងបែងចែកតាមដំណាក់កាល 33

៤. ផែនការយុទ្ធសាស្ត្រ 34

៤.១. ហេតុផល និងគោលបំណង 34

៤.២. វិសាលភាពនៃផែនការ 36

៤.៣. បញ្ហាប្រឈម 37

៤.៤. ទិដ្ឋភាពទូទៅជាយុទ្ធសាស្ត្រ 38

៥. ផែនការប្រតិបត្តិ 40

៥.១. សេចក្ដីផ្ដើម 40

៥.២. គោលការណ៍នៃវិធីសាស្ត្រ 40

៥.៣. កម្មវិធីយុទ្ធសាស្ត្រតាមផ្នែកនីមួយៗ 40

៦. ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ 46

៧. ការប៉ាន់ប្រមាណថវិកា 48

# អក្សរនិងពាក្យកាត់

| | |
|---|---|
| ក.ជ.ក | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ក.យ | ក្រសួងយុត្តិធម៌ |
| ស.អ.យ ឬ ក្រសួងសង្គមកិច្ច | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក្រុមការងារអន្តរក្រសួង | ក្រុមការងារអន្តរក្រសួងទទួលបន្ទុកយុត្តិធម៌អនីតិជន |
| គ.ក.ន.ក | គណៈកម្មាធិការទទួលបន្ទុកកិច្ចការ នារី និងកុមារឃុំ-សង្កាត់ |
| ផែនការយុទ្ធសាស្រ្ត និងប្រតិបត្តិ | ផែនការយុទ្ធសាស្រ្តនិងផែនការប្រតិបត្តិ ច្បាប់យុត្តិធម៌អនីតិជន ២០១៨-២០២០ |
| ម.ផ | ក្រសួងមហាផ្ទៃ |
| អនុសញ្ញា | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| អ.ស.ស | អង្គការសង្គមស៊ីវិល |
| CRI | អង្គការសិទ្ធិកុមារអន្តរជាតិ |
| LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ( Legal Aid of Cambodia ) |
| NGOCRC | សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ( យូនីសេហ្វ ) |

# ១. សេចក្តីសង្ខេប

ការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅក្នុងឆ្នាំ ២០១៦ ដើម្បីអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងច្បាប់អន្តរជាតិផ្សេងទៀតគឺមានសារៈសំខាន់ណាស់សម្រាប់កុមារកម្ពុជា។ ច្បាប់ដែលបានអនុម័តរួចហើយនេះ បង្ហាញអំពីការតាំងចិត្តអនុវត្តតាមអនុសញ្ញា និងមានលក្ខណៈល្អគ្រប់គ្រាន់ ដើម្បីគាំទ្រការបង្កើតប្រព័ន្ធយុត្តិធម៌បរិយាប័នសម្រាប់កុមារនៅកម្ពុជា។

ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជន២០១៨-២០២០(ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិ) មានគោលបំណងផ្តល់នូវផែនការជាក់លាក់សម្រាប់ដំណើរការអនុវត្ត ដើម្បីឲ្យជីវិតអនីតិជនទំនាស់នឹងច្បាប់មានភាពប្រសើរឡើង។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួងសង្គមកិច្ច) ត្រូវបានជ្រើសរើសជាស្ថាប័ននាំមុខគេ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រនេះ ដោយមានទំនាក់ទំនងជាមួយនឹងក្រសួងពាក់ព័ន្ធដទៃទៀត រួមមាន៖ ក្រសួងមហាផ្ទៃ(ម.ផ) និង ក្រសួងយុត្តិធម៌(ក.យ)។ ការរៀបចំផែនការនេះ ទទួលបានការគាំទ្រពីអង្គការUNICEF អង្គការ Plan International អង្គការសិទ្ធិកុមារអន្តរជាតិ (CRI) និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (Legal Aid of Cambodia) ដែលបានចូលរួមក្នុងការរៀបចំផែនការនេះ ។

នេះគឺជាផែនការរយៈពេល៣ឆ្នាំ ដោយមានគោលបំណងធំចំនួនពីរ ៖

### ប្រព័ន្ធយុត្តិធម៌អនីតិជន

កសាងមូលដ្ឋានរឹងមាំប្រកបដោយចីរភាពសម្រាប់ប្រព័ន្ធយុត្តិធម៌អនីតិជនមួយ ដែលអាចអភិវឌ្ឍ និងកែលម្អជាបន្តបន្ទាប់នៅពេលអនាគត។

### ការពារសិទ្ធិរបស់អនីតិជន

ដើម្បីទទួលបានលទ្ធផលជាវិជ្ជមានប្រកបដោយប្រសិទ្ធភាព សម្រាប់អនីតិជនទំនាស់នឹងច្បាប់បច្ចុប្បន្ន និងទៅអនាគត និងដើម្បីកាត់បន្ថយចំនួនអនីតិជននៅក្នុងពន្ធនាគារ ។

ចំណុចអាទិភាព ៖ ចំណុចអាទិភាពជាយុទ្ធសាស្ត្រសម្រាប់អនុវត្តរួមមាន៖

- អភិក្រមសិទ្ធិកុមារ៖ ដើម្បីអនុវត្តអភិក្រមសិទ្ធិកុមារ និងកសាងប្រព័ន្ធមួយដែលកុមារជាអ្នកប្រើប្រាស់ និងអាចចូលរួមយ៉ាងសកម្ម។
- ការអភិវឌ្ឍដោយចីរភាពនិងប្រសិទ្ធភាព៖ ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗក្នុងការអនុវត្ត និងរក្សាភាពជឿនលឿនទៅមុខ។ ដើម្បីបង្កើនការប្រើប្រាស់ធនធានឲ្យបានជាអតិបរិមាក្នុងគោលបំណងកសាងសមត្ថភាព ភាពស៊ីសង្វាក់ និងជំនាញក្នុងការងារ។

- អភិក្រមប្រព័ន្ធតែមួយ៖ ដើម្បីឲ្យអភិក្រមប្រព័ន្ធមជ្ឈការមានតុល្យភាព ដែលជួយឲ្យមានដំណោះស្រាយនៅថ្នាក់មូលដ្ឋាន និងឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ជាមួយនឹងការទទួលខុសត្រូវ តម្លាភាព និងជំនាញរបស់ស្ថាប័ននីមួយៗ។
- ការធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទា៖ ដើម្បីដោះស្រាយមូលហេតុចម្បងៗនៃការប្រព្រឹត្តបទល្មើស ហើយភ្ជាប់ទំនាក់ទំនងរបស់អនីតិជនទំនាស់នឹងច្បាប់ទៅនឹងសង្គម និងភ្ជាប់កុមារជាមួយនឹងផ្នែកសុខុមាលភាពគ្រួសារ។
- គណនេយ្យភាព និងការកែលម្អនៅតែបន្តមាន៖ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត ក្នុងគោលបំណងធានាឲ្យមានវឌ្ឍនភាពឈានទៅដល់ការសម្រេចគោលដៅ និងគណនេយ្យភាពក្នុងការបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

## សកម្មភាព ៖ កម្មវិធីយុទ្ធសាស្ត្រសម្រាប់ការអនុវត្តរួមមាន៖

១. ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង

២. ការអប់រំ និងបណ្តុះបណ្តាល

៣. ភ្នាក់ងារសង្គមកិច្ច

៤. ការបង្វែរ

៥. ការធ្វើសមាហរណកម្ម

៦. ការឃុំខ្លួន

៧. ការទប់ស្កាត់បទល្មើស

៨. ក្របខណ្ឌគោលនយោបាយ និង ប្រព័ន្ធប្រតិបត្តិ

៩. ការពិនិត្យតាមដាន និង វាយតម្លៃ

## វិធីសាស្ត្រសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ រួមមាន៖

- ក្រុមការងារគម្រោង
- ការវិភាគទៅលើច្បាប់ដោយផ្អែកលើកាតព្វកិច្ចរបស់ស្ថាប័ន និងការវាយតម្លៃមួយដែលតម្រូវឲ្យមានការផ្លាស់ប្តូរ
- ការពិគ្រោះយោបល់ដោយមានលក្ខណៈទូលំទូលាយ
- ការអនុវត្តបទដ្ឋានអន្តរជាតិ
- ការពិចារណាលើការអនុវត្តល្អៗរបស់ប្រទេសដទៃ។

ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយផ្អែកលើការពិគ្រោះយោបល់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់រយៈពេល២ថ្ងៃចំនួនពីរលើក ដែលក្នុងមួយលើកៗមានអ្នកចូលរួមប្រមាណ៨០នាក់ ហើយអ្នកចូលរួមបានពិនិត្យចំណុចគោលនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិនេះ។ ការពិគ្រោះយោបល់ទាំងនេះបានបង្ហាញឲ្យឃើញថា មន្ត្រីពាក់ព័ន្ធ បានយល់អំពីភាពស្មុគស្មាញ និងទំហំនៃការផ្លាស់ប្តូរដែលតម្រូវដោយច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ មន្ត្រីពាក់ព័ន្ធដែលបានចូលរួមទាំងអស់ក៏បានបង្ហាញផងដែរនូវសុឆន្ទៈ និងការប្តេជ្ញាចិត្ត បើទោះជាមានការព្រួយបារម្ភអំពីបញ្ហាប្រឈមមួយចំនួនក៏ដោយ។ មានការលើកឡើងជាច្រើនដែលបង្ហាញថាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ។

ការពិគ្រោះយោបល់បានកំណត់ចំណុចប្រឈមមួយចំនួនដែលអាចជួបប្រទះនៅពេលអនុវត្តៈ

- ប្រភពធនធាន និងការចំណាយក្នុងការអនុវត្ត
- ការសម្របសម្រួលរវាងក្រសួងនានា
- ការយល់ និងការទទួលយកយន្តការបង្វែរ របស់សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ
- កង្វះខាតសេវាកម្ម និងទីកន្លែងអប់រំសម្រាប់អនីតិជនទំនាស់នឹងច្បាប់ ព្រមទាំងកុមារស្ថិតក្នុងការបង្វែរ និងបន្ទាប់ពីការឃុំខ្លួន
- កង្វះមេធាវី និងថវិកាឧបត្ថម្ភមេធាវី
- កង្វះអ្នកជំនាញ និងភ្នាក់ងារសង្គមកិច្ច
- កង្វះមណ្ឌលស្តារនីតិសម្បទា ដើម្បីឲ្យកុមារជាប់ឃុំស្នាក់នៅ
- ត្រូវការបណ្តុះបណ្តាល និងការផ្លាស់ប្តូរកម្រិតខ្ពស់
- ខ្វាស់ទៅនឹងចំណុចអាទិភាពផ្សេងទៀតៈ ការទប់ស្កាត់បទល្មើស កុមាររងគ្រោះ និងហេដ្ឋារចនាសម្ព័ន្ធ។

ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិនេះនឹងដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈការបង្កើតមូលដ្ឋានគ្រឹះរយៈពេល៣ឆ្នាំ សម្រាប់ការអនុវត្តច្បាប់អោយជោគជ័យនាពេលអនាគត និងការប្រើប្រាស់ធនធានក្នុងមូលដ្ឋានឲ្យមានប្រសិទ្ធភាព ដើម្បីពង្រឹងសមត្ថភាព។ ផែនការយុទ្ធសាស្ត្រនេះបញ្ជាក់យ៉ាងច្បាស់នូវតម្រូវការចាំបាច់សម្រាប់កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងស្ថាប័ននីមួយៗ និងអ្នកជាប់ពាក់ព័ន្ធផ្សេងទៀតឲ្យមានសមត្ថភាពខ្ពស់ជាងមុន។ នេះជាផែនការថ្នាក់ជាតិ ដែលមានការចូលរួមពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង សង្គមស៊ីវិល។ ស្ថាប័នពាក់ព័ន្ធដែលមានការទទួលខុសត្រូវសំខាន់ជាងគេរួមមានដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី។ ស្ថាប័នពាក់ព័ន្ធសំខាន់ផ្សេងទៀតគឺរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសាសនា ស្ថាប័នអប់រំនិងបណ្តុះបណ្តាលនានា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អង្គការផ្តល់សេវាក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍផ្សេងៗទៀត ។

ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះអនុវត្តចំពោះអនីតិជនទំនាស់នឹងច្បាប់ទាំងអស់ រាប់បញ្ចូលទាំងកុមារកំពុងជាប់ឃុំ កុមារងាយទំនាស់នឹងច្បាប់ កុមារដែលកំពុងប្រឈមទំនាស់នឹងច្បាប់ និងកុមារដែលបានក្លាយជាមនុស្សពេញវ័យក្នុងអំឡុងពេលឃុំខ្លួន។ ក្រុមកុមារទាំងនោះចាំបាច់ត្រូវមានផែនការដោះស្រាយ។

## ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិរួមមាន៖

- ផែនការយុទ្ធសាស្ត្រ
- ការវិភាគច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងតារាងកាតព្វកិច្ច (ឧបសម្ព័ន្ធ ១)
- ផែនការប្រតិបត្តិ (ឧបសម្ព័ន្ធ ២)
- ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ (ឧបសម្ព័ន្ធ៣)
- របាយការណ៍សិក្សាស្រាវជ្រាវស្តីអំពីយុត្តិធម៌អនីតិជន (ឧបសម្ព័ន្ធ៤)
- សេចក្តីស្នើឲ្យមានការប៉ាន់ប្រមាណលើថវិកា (ឧបសម្ព័ន្ធ ៥)។

ឧបសម្ព័ន្ធនីមួយៗគឺជាឯកសារគោលមួយ ដែលត្រូវប្រើប្រាស់ជាឧបករណ៍សម្រាប់គាំទ្រដល់ការអនុវត្ត ច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ឧទាហរណ៍ របាយការណ៍សិក្សាស្រាវជ្រាវ (ឧបសម្ព័ន្ធ ៤) មានការបកស្រាយលម្អិតអំពីអត្ថន័យនៃផ្នែកផ្សេងៗគ្នារបស់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងចរិតនៃច្បាប់ដែលស្របទៅនឹងបទដ្ឋានច្បាប់អន្តរជាតិ។ ឧបសម្ព័ន្ធនោះ ក៏មាននិយាយលម្អិតអំពីការស្រាវជ្រាវដំណាក់កាលនៃការអភិវឌ្ឍខួរក្បាល និងការលូតលាស់របស់កុមារ ថាតើកុមារមានភាពខុសគ្នានឹងមនុស្សពេញវ័យយ៉ាងដូចម្តេច ព្រមទាំងបញ្ហាទាក់ទងនឹងភស្តុតាងនៃការកំណត់អាយុ និងតួនាទីដ៏សំខាន់របស់នគរបាលដែលនៅជួរមុខស្របតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ឯកសារនេះ ក៏បានបកស្រាយអំពីការបង្វែរ សារៈសំខាន់នៃការបង្វែរ និងប្រធានបទពាក់ព័ន្ធជាច្រើនទៀត។ ឯកសារនេះមានប្រយោជន៍ខ្លាំងណាស់ ចំពោះអ្នកដែលចង់ស្វែងយល់ពីច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងផលប៉ះពាល់ដែលអាចកើតមានឡើង ។

ផែនការយុទ្ធសាស្ត្រនេះចង្អុលបង្ហាញ និងណែនាំឲ្យបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនតែមួយសម្រាប់កម្ពុជាដែលអាចការពារ និងលើកកម្ពស់សិទ្ធិកុមារ។ វាជាប្រព័ន្ធមួយដែលប្រើការឃុំខ្លួនគឺជាវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន។

# ២. សាវតា

បើយោងតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ១៩៩២ កុមារទំនាស់នឹងច្បាប់គួរត្រូវបានអនុវត្តទៅតាមអាយុរបស់គេ ហើយត្រូវពិចារណាក្នុងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមវិញ។ អនុសញ្ញានេះបានចែងច្បាស់ថា ការឃុំខ្លួនកុមារគួរតែជាជម្រើសចុងក្រោយនិងសម្រាប់រយៈពេលដ៏ខ្លីតែប៉ុណ្ណោះ (មាត្រា ៣៧)។

វិធានអន្តរជាតិ ដែលកម្ពុជា ជាប្រទេសហត្ថលេខី ក៏មានលើកមកបកស្រាយនៅក្នុងឯកសារនេះផងដែរ។

ស្ថានភាពនៅក្នុងប្រទេសកម្ពុជា ទាក់ទងទៅនឹងយុត្តិធម៌អនីតិជន មុនការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺមិនមានភាពល្អទេ បើទោះជាប្រទេសកម្ពុជាបានទទួលយកអនុសញ្ញានេះយូរហើយក៏ដោយ។ ហេតុផលនៃស្ថានភាពមិនល្អនេះគឺបណ្តាលមកពីការកសាងឡើងវិញទាំងលំបាករបស់ប្រទេសកម្ពុជា បន្ទាប់ពីប្រព័ន្ធរបស់រដ្ឋនៃប្រទេសនេះត្រូវបានបំផ្លិចបំផ្លាញដោយពួកខ្មែរក្រហម ហើយក្នុងពេលកសាងប្រទេសឡើងវិញ កម្ពុជាក៏នៅមានកង្វះធនធាននៅក្នុងការកែទម្រង់ផងដែរ ។

បើទោះជាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ កំណត់អំពីអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅអាយុ ១៨ឆ្នាំក៏ដោយ (មាត្រា ៣៨) តុលាការនៅតែពិចារណាឲ្យកុមារចាប់ពីអាយុ ១៤ឆ្នាំឡើងទៅទទួលខុសត្រូវព្រហ្មទណ្ឌ (មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ) ដោយផ្អែកលើកាលៈទេសៈនៃបទល្មើស និងស្ថានភាពរបស់កុមារ។

ជាគោលការណ៍ កុមារមិនទាន់ចាត់ទុកថាមានភាពចាស់ទុំ ឬមានការទទួលខុសត្រូវគ្រប់គ្រាន់ និងវិនិច្ឆ័យលើអំពើរបស់ខ្លួនដូចជាមនុស្សពេញវ័យនោះទេ។ ទោះបីជាបែបនេះក៏ដោយ ដោយសារតែមិនមានប្រព័ន្ធយុត្តិធម៌អនីតិជនរឹងមាំ និងការមិនទាន់មានច្បាប់ស្តីពីយុត្តិធម៌អនីតិជនជាក់លាក់រយៈពេលយូរ ធ្វើឲ្យកុមារជាជនល្មើសដែលមិនទាន់គ្រប់អាយុទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រួមទាំងកុមារដែលបានប្រព្រឹត្តបទល្មើសតូចតាច ដូចជាលួច ការប្រើប្រាស់គ្រឿងញៀន ត្រូវបានកាត់ទោស និងផ្តន្ទាទោសដូចមនុស្សពេញវ័យដែរ។ បើទោះបី អប្បបរមានៃទោសត្រូវបានបន្ថយពាក់កណ្តាលសម្រាប់កុមារក៏ដោយ ក៏វិធានការបន្ថយទោសនេះ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការករណីរបស់កុមារនៅឡើយ។ គោលការណ៍នេះក៏បានទទួលស្គាល់នៅក្នុងមាត្រា៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះផងដែរ។

បញ្ហានៅកម្ពុជាគឺនៅត្រង់ថា ប្រព័ន្ធចុះសំបុត្រកំណើតមិនល្អគ្រប់គ្រាន់ ដែលចាំបាច់ត្រូវតែកែលម្អ។ គេមិនត្រូវមើលរំលងនូវបញ្ហាដ៏សំខាន់នេះទេ ដើម្បីអនុវត្តគោលការណ៍ចំពោះកុមារឲ្យខុសពីមនុស្សពេញវ័យ វាពិតជាសំខាន់ណាស់ដើម្បីកំណត់អាយុរបស់គេ ថាតើកុមារពិតជាមានអាយុ១៤ឆ្នាំ ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬក៏ពួកគេមានអាយុក្រោម១៨ ឬក៏លើស១៨ឆ្នាំ នៅពេលគេបានប្រព្រឹត្តបទល្មើស។

បញ្ហាកំណត់អាយុកុមារនេះ ត្រូវបានឆ្លើយតបតាមមាត្រា៩ នៃច្បាប់ថ្មីនេះ ដែលចែងថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ ត្រូវកំណត់យកអាយុនៅពេលដែល កុមារនោះប្រព្រឹត្តបទល្មើស ហើយភស្តុតាងនៃអាយុរបស់កុមារត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារបញ្ជាក់ពីអាយុ ឬបើពុំមានទេ ត្រូវជំនួសដោយឯកសារផ្សេងទៀតដែលតុលាការទទួលស្គាល់។ មាត្រានេះតម្រូវឲ្យអាជ្ញាធរមានសមត្ថកិច្ច ស្វែងរកភស្តុតាងអាយុរបស់កុមារឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ហើយប្រសិនបើស្ថិតក្នុងភាពសង្ស័យចំពោះអាយុរបស់កុមារត្រូវដោះស្រាយដោយគិតពីផលប្រយោជន៍របស់កុមារ។

ការលំបាកនៅត្រង់ថា មិនទាន់មានវិធីសាស្ត្របញ្ជាក់ពីអាយុតាមលក្ខណៈវិទ្យាសាស្ត្រ ឬវេជ្ជសាស្ត្រឲ្យបានត្រឹមត្រូវនៅឡើយ។ ជាដំណោះស្រាយដ៏ល្អ និងយូរអង្វែង គួរកំណត់ល័ក្ខខ័ណ្ឌផ្លូវច្បាប់ដល់ឪពុកម្តាយឲ្យចុះសំបុត្រកំណើតដល់កូន បើពុំនោះទេត្រូវផាកពិន័យក្នុងករណីបរាជ័យលើការចុះសបុត្រកំណើតដល់កូន ហើយអាជ្ញាធរត្រូវផ្តល់សេវា ចុះសំបុត្រកំណើតនៅគ្រប់ទីកន្លែង។ ការកំណត់អាយុនៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ គឺជាប្រយោជន៍ក្នុងចំណោមប្រយោជន៍ជាច្រើនដែលចាំបាច់ត្រូវតែមាន។

ការវិវឌ្ឍន៍ថ្មីៗគួរឲ្យកត់សម្គាល់ បានបង្ហាញថាមានការកើនឡើងនូវចំនួនកុមារជាប់នៅក្នុងពន្ធនាគារនៅកម្ពុជា។ ចំនួនកុមារក្នុងពន្ធនាគារបានកើនឡើងពី៣៣៦នាក់នៅក្នុងឆ្នាំ ២០១៤ រហូតដល់ ៩០៧នាក់នៅក្នុងខែមករាឆ្នាំ ២០១៧ ហើយបន្តកើនឡើងរហូតដល់ ១,៥០៥ នាក់ក្នុងខែមេសាឆ្នាំ ២០១៨។ ពីមុនមានការធ្លាក់ចុះពី ៧៧២នាក់ នៅឆ្នាំ២០១០ មកត្រឹម៣៣៦នាក់ នៅឆ្នាំ ២០១៤។

ការធ្លាក់ចុះតួលេខកុមារនៅក្នុងពន្ធនាគារពីឆ្នាំ២០១០ មកដល់ឆ្នាំ២០១៤ គឺមួយផ្នែកជាលទ្ធផលការងាររបស់ក្រសួងយុត្តិធម៌ ដែលបានធ្វើការរួមគ្នាជាមួយនឹងអង្គការសិទ្ធិកុមារអន្តរជាតិ (CRI) និងអង្គការយូនីសេហ្វក្នុងការលើកកម្ពស់ទស្សនៈប្រព័ន្ធយុត្តិធម៌បែបកុមារមេត្រី និងដោយសារមានការបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធជាបន្តបន្ទាប់អំពីទស្សនៈនេះ។ នៅក្នុងឆ្នាំ២០១២ មានទស្សនៈកិច្ចសិក្សារបស់មន្ត្រីជាន់ខ្ពស់មួយក្រុមទៅកាន់ប្រទេសអូស្ត្រាលី ដើម្បីស្វែងយល់អំពីប្រព័ន្ធយុត្តិធម៌អនីតិជន។ ទស្សនៈកិច្ចសិក្សានេះរៀបចំដោយអង្គការសិទ្ធិកុមារអន្តរជាតិ និងគាំទ្រថវិកាដោយទីភ្នាក់ងារជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី ហៅកាត់ថា AusAID។

បន្ទាប់ពីដំណើរទស្សនៈកិច្ច ក្រសួងយុត្តិធម៌ សហការជាមួយនឹងអង្គការសិទ្ធិកុមារអន្តរជាតិ(CRI) និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា(LAC) បានរៀបចំសន្និសីទថ្នាក់ជាតិដែលមានអ្នកចូលរួមចំនួន ៣០០នាក់មកពីស្ថាប័នយុត្តិធម៌ ដែលមានរយៈពេល២ថ្ងៃនៅខេត្តសៀមរាប ដើម្បីបង្ហាញអំពីទស្សនៈទានតុលាការបែបកុមារមេត្រី។ បន្ទាប់មកមានរៀបចំ សិក្ខាសាលាតូចមួយនៅខេត្តបាត់ដំបង ដើម្បីពិនិត្យលម្អិតទៅលើទស្សនៈនេះ។ ថវិកាសម្រាប់ការរៀបចំសិក្ខាសាលាទាំងពីរនេះមានការគាំទ្រដោយអង្គការយូនីសេហ្វ និងជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី ។

សិក្ខាសាលាទាំងពីរនេះទទួលបាននូវការគាំទ្រ និងការចូលរួមរបស់សិក្ខាកាមយ៉ាងក្លៀវក្លា និងមានប្រសិទ្ធភាព។ ប៉ុន្តែគួរឲ្យសោកស្តាយ ភាពរីកចម្រើននេះបានថយចុះទៅវិញនៅក្នុងឆ្នាំ ២០១៣-២០១៤ ដោយហេតុផលមួយចំនួនទាក់ទងនឹងថវិកា បើទោះបីជាមានសិក្ខាសាលាខ្លះបានកើតឡើងនៅចុងឆ្នាំ ២០១៥

ក៏ដោយ។ តែទោះជាយ៉ាងណា សិក្ខាសាលាទាំងនេះ និងដំណើរទស្សនៈកិច្ចសិក្សាទៅកាន់ប្រទេសអូស្ត្រាលី កាលពីខែមីនាឆ្នាំ ២០១៦ ក្រោមជំនួយឧបត្ថម្ភរបស់ UNICEF បានជំរុញឲ្យមានភាពជឿនលឿននៃដំណើរការច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

ការកើនឡើងចំនួនកុមារនៅក្នុងពន្ធនាគារនៅក្នុងឆ្នាំ២០១៥ និង៣ឆ្នាំបន្ទាប់មកនេះ គឺបណ្តាលមកពីកត្តា ជាក់លាក់មួយចំនួន។ អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ បានឲ្យដឹងថា ចាប់តាំងពីមានយុទ្ធនាការបង្ក្រាបគ្រឿងញៀនរបស់រដ្ឋាភិបាលមកមានការកើនឡើងនូវចំនួនអ្នកជាប់ឃុំរួមទាំងកុមារផងដែរ។ ជាការពិត គឺមានកត្តាផ្សេងទៀត ដែលត្រូវការយកចិត្តទុកដាក់ព្រោះថាកត្តាទាំងនោះអាចជាឧបសគ្គចំពោះប្រព័ន្ធយុត្តិធម៌អនីតិជន។

ប្រព័ន្ធយុត្តិធម៌កម្ពុជានាពេលកន្លងមក ផ្តោតលើការផ្តន្ទាទោសជាចម្បង ដែលនាំឲ្យមិនសូវមានភាពជោគជ័យក្នុងការស្តារនីតិសម្បទានៅក្នុងសង្គម និងសហគមន៍។ មានការទទួលស្គាល់ជាទូទៅថា ការផ្តន្ទាទោសកុមារតាមរយៈដំណើរការរឿងក្តីព្រហ្មទណ្ឌ ពិតជាបណ្តាលឲ្យកុមារធ្លាក់ចូលទៅនឹងរឿងព្រហ្មទណ្ឌ និងបង្កឲ្យមានការប្រព្រឹត្តបទល្មើសជាថ្មី ហើយពេលខ្លះបទល្មើសកាន់តែធ្ងន់ធ្ងរទៀតផង។ ហេតុដូច្នេះ ចាំបាច់ត្រូវតែមានអន្តរាគមន៍ឲ្យបានឆាប់ដែលអាចធ្វើទៅបាន ដើម្បីទប់ស្កាត់ ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មកុមារទាំងនោះទៅក្នុងសង្គមវិញប្រកបដោយប្រសិទ្ធភាព។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនដែលបានរង់ចាំជាយូរមកនោះ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលត្រូវចូលជាធរមាននៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧។ វាជាជំហ៊ានដ៏សំខាន់មួយទៀតឆ្ពោះទៅរកកិច្ចការពារកុមារទំនាស់នឹងច្បាប់ និងជាប្រព័ន្ធយុត្តិធម៌អនីតិជនដែលធានាការពារនិងគោរពសិទ្ធិអនីតិជនទំនាស់នឹងច្បាប់។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះ មានសារៈសំខាន់ក្នុងការធានាថា ប្រព័ន្ធយុត្តិធម៌អនីតិជនកម្ពុជាស្របទៅនឹងគោលការណ៍អនុសញ្ញា និងវិធានរបស់អន្តរជាតិ ។

នៅក្នុងខែមេសា ឆ្នាំ២០១៦ តំណាងអង្គការ UNICEF លោកស្រី Debora Comini បានសរសេរទៅកាន់ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយបញ្ជាក់ថា អង្គការ UNICEF និងអង្គការ Plan International ផ្តល់ការគាំទ្រក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ លិខិតបានទទួលស្គាល់ការចូលរួមចំណែកក្នុងដំណើរការរៀបចំច្បាប់ស្តីពីយុត្តិធម៌អនីតិជនកន្លងមក ពីបណ្តាអង្គការជាតិ និងអន្តរជាតិផ្សេងទៀតដូចជា អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) អង្គការ Every Child Cambodia អង្គការសង្គ្រោះកុមារ (Save the Children) អង្គការទស្សនៈពិភពលោក សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC) អង្គការសិទ្ធិកុមារអន្តរជាតិ (CRI) ការិយាល័យរបស់អង្គការសហប្រជាជាតិទប់ស្កាត់បទល្មើស និងគ្រឿងញៀន ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស និងអង្គការពាក់ព័ន្ធដទៃទៀត។ ហើយក្នុងលិខិតនោះក៏បានស្នើឲ្យមានការអញ្ជើញអង្គការទាំងនេះចូលរួមក្នុងដំណើរការរៀបចំផែនយុទ្ធសាស្ត្រ និងប្រតិបត្តិនេះផងដែរ។

ច្បាប់ថ្មីតម្រូវឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ថាតើកិច្ចការពារ និងផ្នែកយុត្តិធម៌ ត្រូវឆ្លើយតបនឹងកុមារជាជនល្មើសយ៉ាងដូចម្តេច។ ច្បាប់នេះតម្រូវឲ្យក្រសួងសំខាន់ៗរបស់រដ្ឋរៀបចំប្រកាស និងនីតិវិធីប្រតិបត្តិជាស្តង់ដាមួយដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាំងអស់ រួមមានការកំណត់អាយុរបស់កុមារ ការចាប់ខ្លួន ការផ្តន្ទាទោស សវនាការ ការបង្វែរ និងការឃុំខ្លួន។ ក្រសួងទាំងនោះ រួមមាន ក្រសួងមហាផ្ទៃ(ម.ផ) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) ក្រសួងយុត្តិធម៌(ក.យ) និងតុលាការ ។

ដោយមានការគាំទ្រពី ក្រសួង ស.អ.យ ក្រសួង ក.យ និងក្រសួងសំខាន់ៗដទៃទៀតរបស់រដ្ឋាភិបាល អង្គការ UNICEF បានផ្តួចផ្តើមគំនិតរៀបចំ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ រយៈពេល ៣ឆ្នាំ ដើម្បីណែនាំការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ សាមីក្រសួងសំខាន់ៗគឺ ក្រសួង ស.អ.យ ក្រសួង ម.ផ និងក្រសួង ក.យ។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះត្រូវបានរៀបចំ ដោយអង្គការ CRI។ CRI គឺជាអង្គការអូស្ត្រាលីដែលមានឯកទេសខាងប្រព័ន្ធយុត្តិធម៌អនីតិជន ដែលបានចូលរួមជាមួយនឹងក្រសួង ក.យ អង្គការ UNICEF អង្គការ LAC នៅក្នុងការលើកកម្ពស់ប្រព័ន្ធយុត្តិធម៌បែបកុមារមេត្រីនៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៦។ គម្រោងរៀបចំផែនការនេះត្រូវបានយកមកពិគ្រោះយោបល់ជាមួយនឹង ក្រសួង ស.អ.យ និងក្រសួង ក.យ តាំងពីខែកញ្ញា ឆ្នាំ២០១៦ ដោយមានការចូលរួមពីអង្គការ UNICEF ដើម្បីទទួលយកមតិយោបល់មុននឹងចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះឡើង។ បន្ទាប់មក ក៏មានការពិភាក្សា និងពិគ្រោះយោបល់បន្ថែមទៀត ដែលបានរៀបចំឡើងកាលពីខែកុម្ភៈ ឆ្នាំ២០១៧ រវាងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះឡើង។ សេចក្តីព្រាងលើកទី១នៃផែនការយុទ្ធសាស្ត្រ ត្រូវបានបង្ហាញនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ហើយបានបញ្ចប់ទៅបន្ទាប់ពីមានការពិគ្រោះយោបល់បន្ថែមទៀត ។

បើទោះជាផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិនេះមានរយៈពេល៣ឆ្នាំក៏ដោយ ក៏មិនមានន័យថាការអនុវត្តពេញលេញនឹងអាចប្រព្រឹត្តទៅបាន ក្នុងកំឡុងពេលបីឆ្នាំនោះដែរ។ នេះជាផែនការមួយមានលក្ខណៈស្មុគស្មាញដែលណែនាំអំពីទស្សនទានដែលមិនធ្លាប់មានពីមុនមកនៅក្នុងច្បាប់កម្ពុជា ហើយថ្មីចំពោះប្រជាពលរដ្ឋ។ ផែនការបន្ថែមទៀតត្រូវធ្វើឡើងដោយមានការពិនិត្យតាមដាន និងវាយតម្លៃឲ្យបានត្រឹមត្រូវ។ ទស្សនទានស្តីពីការដាក់ទោសមិនធ្ងន់ធ្ងរដល់ជនល្មើសជាកុមារ ការបង្វែរ ការស្តារនីតិសម្បទា និងការទទួលយកកុមារត្រឡប់ទៅក្នុងសហគមន៍វិញ មិនអាចធ្វើបានក្នុងពេលខ្លីបានឡើយ គឺចាំបាច់ត្រូវមានការពន្យល់យ៉ាងយកចិត្តទុកដាក់គាំទ្រខ្ពស់ទាំងផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងការចូលរួមពីមន្ត្រីអនុវត្តច្បាប់គ្រប់ជាន់ថ្នាក់ និងពីមហាជន។

ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ នឹងផ្តល់នូវមូលដ្ឋានដើម្បីធានាឲ្យមានការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនយ៉ាងពេញលេញ និងជាប្រព័ន្ធ ល្គឹកណាតែកម្រិតនៃការគាំទ្រដែលបានបញ្ជាក់ខាងលើនៅតែបន្តមានជាច្រើនឆ្នាំតទៅមុខទៀត។ ផែនការនេះក៏បានផ្តល់ការណែនាំដល់ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍផ្សេងទៀតថាតើត្រូវចូលរួមជួយជាថវិកានៅត្រង់ចំណុចណាខ្លះនៅក្នុងផែនការនេះ។ វាពិតជាពិបាកក្នុងការប្រមែប្រមូលម្ចាស់ជំនួយផងដែរ ។

ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះ ផ្តល់ឱកាសសម្រាប់កម្ពុជាដើម្បីបង្ហាញពីការប្តេជ្ញាចិត្តក្នុងការគោរពតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបទដ្ឋានអន្តរជាតិ ។

# ៣. វិធីសាស្ត្រ

## ៣.១. ទិដ្ឋភាពទូទៅ

វិធីសាស្ត្រសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ រួមមាន៥ចំណុច ដោយផ្អែកតាមការរៀបចំគោលការណ៍ដែលបានឯកភាពគ្នា។

សិទ្ធិអនីតិជនទំនាស់នឹងច្បាប់ ត្រូវបានការពារដោយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ហើយក៏មានចែងនៅក្នុងវិធាននិងគោលការណ៍អន្តរជាតិផ្សេងទៀតដែរ។ ឥឡូវនេះ សិទ្ធិទាំងនោះក៏បានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជាផងដែរ។ ដើម្បីឲ្យស្របនឹងលិខិតតុបករណ៍ទាំងនេះ វិធីសាស្ត្រត្រូវបានបង្កើតឡើងដោយរួមបញ្ចូលទាំងការអនុវត្តគោលការណ៍ណែនាំ បទដ្ឋានអន្តរជាតិ ការពិចារណាទៅលើការអនុវត្តល្អៗ ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងការប្រើប្រាស់ក្រុមអ្នកឯកទេសរបស់គម្រោង ។

ជាសង្ខេបមក វិធីសាស្ត្រសម្រាប់ការរៀបចំផែនការនេះ រួមមាន៖

- ក្រុមការងារគម្រោង
- ការវិភាគទៅលើច្បាប់ដោយផ្អែកលើកាតព្វកិច្ចរបស់ស្ថាប័ននីមួយៗ និងការវាយតម្លៃមួយដែលតម្រូវឲ្យមានការផ្លាស់ប្តូរ
- ការពិគ្រោះយោបល់មានលក្ខណៈទូលាយ
- ការអនុវត្តបទដ្ឋានអន្តរជាតិ
- ការពិចារណាលើការអនុវត្តល្អរបស់ប្រទេសដទៃ។

គោលការណ៍សំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិនេះមានគោលបំណងចម្បងធានាឲ្យមានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពក្នុងពេលអនុវត្តជាក់ស្តែង និងមានភាពច្បាស់លាស់។ ការបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយ មានលក្ខណៈស្មុគស្មាញ ដែលតម្រូវឲ្យមានការផ្លាស់ប្តូរក្នុងការអនុវត្ត និងគោលនយោបាយ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ បង្កើតឲ្យមានសិទ្ធិកុមារ ដែលជាគោលការណ៍ក្រមសីលធម៌ដែលត្រូវអនុវត្តចំពោះកុមារ។ ហេតុដូច្នេះហើយ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ត្រូវបានតាក់តែងឡើងដោយផ្អែកលើអភិក្រមសិទ្ធិកុមារ។

ការផ្លាស់ប្តូរផ្នត់គំនិតជាមូលដ្ឋានមួយពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់តម្រូវឲ្យមានទាំងក្នុងស្រទាប់នយោបាយ និងសង្គម ក៏ដូចជាការផ្លាស់ប្តូរនិយាមសង្គមដែលទទួលយកការដាក់ទោសទណ្ឌ និងការឃុំខ្លួនជាដំណោះស្រាយសម្រាប់បទល្មើសកុមារផងដែរ។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះទទួលស្គាល់ថាការបង្កើតឲ្យមានប្រព័ន្ធយុត្តិធម៌អនីតិជន ដែលឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ

នឹងមិនអាចសម្រេចបានក្នុងរយៈពេល៣ឆ្នាំនោះទេ ពីព្រោះវាជាដំណើរការដែលត្រូវការចំណាយថវិកាច្រើន និងបច្ចេកទេសខ្ពស់ហើយតម្រូវឲ្យមានការកែទម្រង់ស្ថាប័នយ៉ាងម៉ត់ចត់ បន្ថែមទៅលើការផ្លាស់ប្តូរផ្នត់គំនិត។ រាល់ចំណុចប្រឈមសំខាន់ៗក្នុងការអនុវត្តច្បាប់នេះ ត្រូវបានកំណត់ក្នុងពេលពិគ្រោះយោបល់។ ផែនការនេះត្រូវបានតាក់តែងឡើង ដើម្បីដោះស្រាយចំណុចប្រឈមទាំងនោះ និងរក្សាជំហរក្នុងការផ្លាស់ប្តូរនេះដរាបណានៅតែមានផលប៉ះពាល់ដល់ចំនួនកុមារទំនាស់នឹងច្បាប់ទាំងពេលបច្ចុប្បន្ននិងអនាគត។ ផែនការនេះកំណត់សកម្មភាពអាទិភាពដែលអាចនាំឲ្យមានការផ្លាស់ប្តូរក្នុងការអនុវត្ត ពីព្រោះវាជាចំណុចសំខាន់ក្នុងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

គោលបំណងជាយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ គឺការបង្កើតឲ្យមានប្រព័ន្ធយុត្តិធម៌អនីតិជនមួយ។ ប្រព័ន្ធនេះនឹងតម្រូវឲ្យមានការអនុវត្តរួមគ្នានូវគោលនយោបាយការផ្លាស់ប្តូរព័ត៌មានកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ និងបុគ្គលដែលមានតួនាទី ឬមានការពាក់ព័ន្ធនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន។ ផែនការនេះ ទទួលស្គាល់ពីសារៈសំខាន់នៃដំណោះស្រាយនៅនឹងកន្លែង។ ដំណោះស្រាយទាំងនេះត្រូវតែអនុវត្តឲ្យមានប្រសិទ្ធភាពនៅតាមសហគមន៍នីមួយៗ។ ដំណោះស្រាយទាំងនេះអាចនឹងមានលក្ខណៈខុសគ្នានៅក្នុងការអនុវត្តជាក់ស្តែងនៅតាមសហគមន៍។ ផែនការនេះ ក៏នឹងបង្កើតឲ្យមានការទទួលខុសត្រូវ និងជំនាញរបស់ស្ថាប័ននីមួយៗក្នុងការគ្រប់គ្រងទាំងការអនុវត្តនិងបុគ្គលិករបស់ខ្លួនឲ្យបានប្រសើរឡើង។

ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ទទួលស្គាល់ថាមានគោលនយោបាយ និងកម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាល កម្មវិធីរដ្ឋាភិបាល និងផែនការគាំទ្រដល់គ្រួសារ និងកុមារ ដែលត្រូវបានគេកេងប្រវ័ញ្ចជួបការលំបាក និងងាយរងគ្រោះ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ផ្តល់នូវដំណោះស្រាយក្រៅពីការឃុំខ្លួនដែលអាចអនុវត្តនៅតាមសហគមន៍ ហើយដែលដំណោះស្រាយនេះគាំទ្រដល់ការបង្វែរកុមារចេញពីប្រព័ន្ធតុលាការ ហើយធ្វើសមាហរណកម្មកុមារដែលត្រូវបានដោះលែងទៅក្នុងសហគមន៍វិញ។ ការទប់ស្កាត់បទល្មើស ការបង្វែរកុមារ និងការធ្វើសមាហរណកម្មតម្រូវឲ្យមានកម្មវិធី និងអ្នកមានវិជ្ជាជីវៈធ្វើការជាមួយនឹងផ្នែកសុខុមាលភាពកុមារនិងគ្រួសារ ជាមួយនឹងកុមារងាយរងគ្រោះ ឬអនីតិជនទំនាស់នឹងច្បាប់។ ការបង្វែរ និងការធ្វើសមាហរណកម្ម ក៏ត្រូវផ្សារភ្ជាប់ជាមួយនឹងអង្គការសង្គមស៊ីវិល និងវិស័យឯកជនផងដែរ ដើម្បីសម្រេចបាននូវអនាគតប្រកបដោយវិជ្ជមានសម្រាប់កុមារ។

## ជាសង្ខេប គោលការណ៍តាក់តែងសំខាន់ៗនៃផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិនេះ រួមមាន៖

- អភិក្រមសិទ្ធិកុមារ
- ដោះស្រាយបញ្ហាប្រឈមដើម្បីឲ្យមានការកែប្រែជានិរន្តរភាព និងការអនុវត្តដ៏មោះមុតរហូតទទួលបានលទ្ធផលល្អសម្រាប់អនីតិជនទំនាស់នឹងច្បាប់
- ធ្វើឲ្យអភិក្រមប្រព័ន្ធមជ្ឈការមួយមានតុល្យភាព ដោយមានដំណោះស្រាយនៅតាមមូលដ្ឋានមានការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ និងជំនាញ
- ផ្សារភ្ជាប់អនីតិជនទំនាស់នឹងច្បាប់ជាមួយនឹងសង្គមស៊ីវិល កុមារដទៃទៀត និងផ្នែកសុខុមាលភាពគ្រួសារ
- ផ្តល់ព័ត៌មានងាយយល់ ច្បាស់លាស់ និងណែនាំសម្រាប់ការអនុវត្ត។

ផែនការនេះ មានចំណុចអាទិភាពជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ កម្មវិធីយុទ្ធសាស្ត្រចំនួន៩ សកម្មភាពរួម និងក្របខណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃមួយ។ ក្រៅពីនេះ ក៏មានឧបករណ៍មួយចំនួនដើម្បីជួយដល់ការធ្វើផែនការ ដែលរួមមាន តារាងវិភាគកាតព្វកិច្ចអ្នកពាក់ព័ន្ធដែលមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន របាយការណ៍សិក្សាស្រាវជ្រាវស្តីពីយុត្តិធម៌អនីតិជន និងការដកស្រង់ឯកសារពាក់ព័ន្ធមួយចំនួនទៀត។

## ៣.២. ការអនុវត្តបទដ្ឋានអន្តរជាតិ

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ អនីតិជនទំនាស់នឹងច្បាប់គួរត្រូវបានអនុវត្តទៅតាមអាយុរបស់គេ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងយ៉ាងទូលំទូលាយអំពីគោលដៅរបស់ច្បាប់ គោលការណ៍ និងសិទ្ធិនៅក្នុងនីតិវិធីសំដៅការពារសិទ្ធិអនីតិជនទំនាស់នឹងច្បាប់។

របាយការណ៍សិក្សាស្តីពីអំពើហិង្សាលើកុមាររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍ថា៖ «ការឃុំខ្លួនកុមារ គួរតែប្រើសម្រាប់កុមារជាជនល្មើសដែលត្រូវបានវាយតម្លៃថាអាចបង្ករការគ្រោះថ្នាក់ដល់អ្នកដទៃហើយគួរតែមានធនធាននៅក្នុងការរៀបចំឲ្យមានជម្រើសផ្សេងទៀត រួមទាំងកម្មវិធីធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទានៅថ្នាក់មូលដ្ឋាន...» (មាត្រា ៦១ ២៩៩ កថាខណ្ឌ ១១២(ខ))។

មាត្រា ៣៧ នៃអនុសញ្ញាបានចែងយ៉ាងច្បាស់ថា ការឃុំខ្លួនកុមារគួរតែត្រូវបានប្រើសម្រាប់ជម្រើសចុងក្រោយ និងសម្រាប់រយៈពេលដ៏ខ្លីបំផុត ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបញ្ជាក់ពីការបង្វែរដែលត្រូវយកមកពិចារណាជាបឋមនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ បានផ្តល់អាទិភាពទៅលើសកម្មភាពការផ្សព្វផ្សាយឲ្យមានការយល់ដឹង ដើម្បីទទួលយកនិងគាំទ្រទៅលើគោលការណ៍នៃការឃុំខ្លួនជាជម្រើសចុងក្រោយ សម្រាប់កុមារ ពីព្រោះថាទស្សនៈនេះកំពុងតែប្រឈមនឹងនិយាមសង្គមកម្ពុជានិងនៅទីកន្លែងដទៃទៀត ដែលនៅតែគិតថាការឃុំខ្លួនកុមារគឺជាការដាក់ទោសទាន់ដ៏ត្រឹមត្រូវសម្រាប់ការប្រព្រឹត្តខុស។ ការផ្លាស់ប្តូរផ្នត់គំនិត គឺជារឿងដ៏សំខាន់សម្រាប់ការអនុវត្តកម្មវិធីបង្វែរ និងការធ្វើសមាហរណកម្ម។

ខាងក្រោមនេះ ជាលិខិតតុបករណ៍អន្តរជាតិដែលមានចែងពាក់ព័ន្ធនឹងសិទ្ធិរបស់អនីតិជនទំនាស់នឹងច្បាប់។ វិធានទាំងអស់នេះផ្តល់នូវសេចក្តីណែនាំក្នុងការអនុវត្ត ដល់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកអនុវត្តច្បាប់ អ្នកធ្វើសេចក្តីសម្រេចចិត្ត ព្រះរាជអាជ្ញា និងចៅក្រម។ លិខិតតុបករណ៍អន្តរជាតិទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើតផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ។

### លិខិតតុបករណ៍អន្តរជាតិ៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)
- គណៈកម្មាធិការសិទ្ធិកុមារ-សេចក្តីពន្យល់ទូទៅលេខ១០ (២០០៧)-សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន សេចក្តីពន្យល់ទូទៅលេខ១២ (២០០៩)-សិទ្ធិបញ្ចេញយោបល់ សេចក្តីពន្យល់ទូទៅលេខ៩ (២០០៦)-សិទ្ធិរបស់កុមារពិការ សេចក្តីពន្យល់ទូទៅលេខ១១ (២០០៩)-កុមារជនជាតិដើមភាគតិច និងសិទ្ធិរបស់គេ ដែលមានចែងក្នុងអនុសញ្ញា។

- វិធានអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន (វិធានប៉េកាំង ១៩៨៥)
- វិធានរបស់អង្គការសហប្រជាជាតិសម្រាប់កិច្ចការពារកុមារ ដែលត្រូវបានដកហូតសេរីភាព (វិធាន Havana ១៩៩០)។
- គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ទប់ស្កាត់បទល្មើសកុមារ (គោលការណ៍ណែនាំទីក្រុង Riyadh ១៩៩០)។
- គោលការណ៍ណែនាំស្តីពីចំណាត់ការលើកុមារស្ថិតនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ (ឧបសម្ព័ន្ធនៃសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ១៩៩៧/៣០ ស្តីពីការគ្រប់គ្រងយុត្តិធម៌អនីតិជន (គោលការណ៍ ណែនាំទីក្រុង Vienna ១៩៩៧)
- អភិក្រមរួមរបស់អង្គការសហប្រជាជាតិស្តីពីយុត្តិធម៌អនីតិជន (២០០៨)

## បទដ្ឋានគតិយុត្តអន្តរជាតិដែលពាក់ព័ន្ធបំផុត ដែលណែនាំពីការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនមាន៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ
- វិធានក្រុងប៉េកាំង
- វិធាន Havana (១៩៩០)

## អនុសញ្ញាស្តីពីសិទ្ធិកុមារ ៖

### មាត្រា ៣៧

- ហាមការធ្វើទារុណកម្ម ឬអំពើឃោរឃៅ អមនុស្សធម៌ ការប្រព្រឹត្ត ឬការដាក់ទណ្ឌកម្ម ដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស
- ហាមមានទោសប្រហារជីវិត ឬដាក់ទោសអស់មួយជីវិត ដោយមិនមានឱកាសដោះលែង
- ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារត្រូវតែស្របទៅនឹងច្បាប់ ហើយត្រូវប្រើសម្រាប់តែជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុត
- កុមារដែលត្រូវបានដកហូតសេរីភាពត្រូវដាក់ឲ្យនៅដោយឡែកពីមនុស្សពេញវ័យ លើកលែងតែផ្ទុយនឹងឧត្តមប្រយោជន៍របស់កុមារ
- សិទ្ធិទទួលបានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារតាមរយៈលិខិតឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ
- សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ភ្លាមៗ និងជំនួយផ្សេងទៀតដែលសមស្រប
- សិទ្ធិជំទាស់នឹងភាពស្របច្បាប់នៃការដកហូតសេរីភាពរបស់ខ្លួននៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច និងទទួលបានសេចក្តីសម្រេចយ៉ាងឆាប់រហ័ស។

### មាត្រា ៤០៖

- សិទ្ធិទទួលបានការប្រព្រឹត្តមកលើខ្លួនប្រកបដោយភាពថ្លៃថ្នូរ
- លើកកម្ពស់ការធ្វើសមាហរណកម្មកុមារក្នុងសង្គមវិញ និងឲ្យកុមារបំពេញតួនាទីស្ថាបនានៅក្នុងសង្គម
- ចាត់ទុកថាគ្មានទោសរហូតដល់ពេលណាដែលពិរុទ្ធភាពរបស់កុមារត្រូវបានវិនិច្ឆ័យស្របតាមច្បាប់
- សិទ្ធិទទួលបានការជូនដំណឹងភ្លាមៗ និងដោយផ្ទាល់អំពីបទចោទប្រកាន់មកលើខ្លួន
- សិទ្ធិរួចផុតពីការបង្ខំឲ្យផ្តល់សក្ខីកម្ម ឬការសារភាពកំហុស
- សិទ្ធិទទួលបានជំនួយអ្នកបកប្រែប្រសិនបើចាំបាច់
- កំណត់អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយកុមារដែលស្ថិតនៅក្រោមអាយុនោះ នឹងត្រូវសន្មត់ថាពុំមានសមត្ថភាពរំលោភច្បាប់ព្រហ្មទណ្ឌឡើយ។

### វិធានប៉េកាំង៖

- ក្នុងករណីសមស្រប ការបង្វែរត្រូវយកមកពិចារណា ដើម្បីដោះស្រាយបញ្ហាកុមារប្រព្រឹត្តបទល្មើស ដោយមិនចាំបាច់មានការជំនុំជម្រះជាផ្លូវការនោះឡើយ។ (វិធាន ១១)
- ដើម្បីអាចបំពេញការងាររបស់ខ្លួនបានល្អ មន្ត្រីនគរបាលដែលធ្វើការងារទប់ស្កាត់បទល្មើសកុមារ ត្រូវទទួលបានការបណ្តុះបណ្តាល និងការណែនាំច្បាស់លាស់ ។ នៅក្នុងទីក្រុងធំៗមួយចំនួន គេបង្កើតឲ្យមានអង្គភាពនគរបាលពិសេសទទួលបន្ទុករឿងកុមារ។ (វិធាន ១២)
- គោលការណ៍សមាមាត្រ៖ ការដោះស្រាយបទល្មើសកុមារ មិនគួរធ្វើឡើងដោយផ្អែកតែទៅលើទម្ងន់នៃបទល្មើសប៉ុណ្ណោះទេ តែក៏ត្រូវថ្លឹងថ្លែងផងដែរពីស្ថានភាពផ្ទាល់ខ្លួនរបស់អនីតិជន និងគ្រួសាររបស់អនីតិជន។ (វិធាន ៥ កំណត់ពន្យល់ក្នុងកឋាខណ្ឌ២)
- វិធានការផ្សេងៗក្រៅពីការទុកដាក់អនីតិជននៅក្នុងមណ្ឌល៖ វិធានការផ្សេងៗក្រៅពីការដាក់អនីតិជនក្នុងមណ្ឌលត្រូវរៀបចំឲ្យមានសម្រាប់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីផ្តល់នូវភាពបត់បែនក្នុងគោលបំណងបញ្ចៀសការទុកដាក់កុមារក្នុងមណ្ឌលឲ្យខាងតែបាន។ (វិធាន ១៨)
- តម្រូវការវិជ្ជាជីវៈ និងការបណ្តុះបណ្តាល៖ ត្រូវមានការអប់រំវិជ្ជាជីវៈការបណ្តុះបណ្តាលក្នុងពេលបំពេញការងារ វគ្គបណ្តុះបណ្តាលឡើងវិញ និងការណែនាំផ្សេងទៀត ដើម្បីឲ្យបុគ្គលិកមានសមត្ថភាពវិជ្ជាជីវៈច្បាស់លាស់ ក្នុងការធ្វើការលើករណីកុមារប្រព្រឹត្តបទល្មើស។ (វិធាន ២២.១)
- ការធ្វើផែនការ៖ ត្រូវមានផែនការផ្តល់សេវាកម្មក្នុងផ្នែកយុត្តិធម៌អនីតិជន ហើយត្រូវយកផែនការនេះមកអនុវត្ត ជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍរបស់ជាតិ។ (វិធាន ៣០.៤)

វិធានរបស់អង្គការសហប្រជាជាតិសម្រាប់កិច្ចការពារកុមារដែលត្រូវបានដកហូតសេរីភាព (វិធាន Havana) (១៩៩០)៖

- ការដាក់ពន្ធនាគារ គឺជាជម្រើសចុងក្រោយ។ (វិធាន ១)
- វិធានទាំងនេះមានគោលបំណងបង្កើតបទដ្ឋានអប្បបរមាស្តីពីការការពារកុមារដែលត្រូវបានគេដកហូតសេរីភាពគ្រប់ប្រភេទទាំងអស់ ហើយដែលត្រូវបានទទួលយកដោយអង្គការសហប្រជាជាតិ ។ (វិធាន ៣)
- វិធាននេះគួរត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិ។ (វិធាន ៦)
- ត្រូវមានវិធានការធ្វើយ៉ាងណាឲ្យសាធារណៈជនយល់ដឹងថាការថែទាំអនីតិជនជាប់ឃុំ និងការត្រៀមរៀបចំពួកគេឲ្យវិលត្រឡប់មកសហគមន៍វិញ គឺជាសេវាសង្គមមួយដ៏មានសារៈសំខាន់ ។ (វិធាន ៨)
- គួរធានាឲ្យកុមារនៅក្នុងទីកន្លែងឃុំឃាំងទទួលបាននូវផលប្រយោជន៍ពីសកម្មភាពនិងកម្មវិធីផ្សេងៗដែលជួយលើកកម្ពស់ដល់សុខភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេប្រកបដោយនិរន្តរភាព ដើម្បីឲ្យពួកគេមានឥរិយាបថល្អនិងជំនាញ ដែលនឹងអាចជួយពួកគេក្នុងការអភិវឌ្ឍសក្តានុពលដើម្បីក្លាយជាសមាជិកល្អនៅក្នុងសង្គម។ (វិធាន ១២)
- កុមារដែលជាប់ឃុំក្នុងដំណាក់កាលរង់ចាំការជំនុំជម្រះ ត្រូវចាត់ទុកថាគ្មានទោស ហើយត្រូវប្រព្រឹត្តមកលើពួកគេដូចជាអ្នកគ្មានទោសដូច្នោះដែរ។ ការឃុំខ្លួនក្នុងដំណាក់កាលរង់ចាំការជំនុំជម្រះនេះ គួរតែជៀសវាងឲ្យបានច្រើនតាមតែអាចធ្វើទៅបាន លើកលែងតែក្នុងកាលៈទេសៈចាំបាច់តែប៉ុណ្ណោះ។ នៅពេលដែលការឃុំខ្លួនក្នុងដំណាក់កាលនេះ មិនអាចជៀសបាន តុលាការ និងស្ថាប័នស៊ើបអង្កេតត្រូវតែផ្តល់អាទិភាពខ្ពស់បំផុតដល់រឿងក្តីកុមារ ដើម្បីធានាឲ្យការឃុំខ្លួននេះមានរយៈពេលខ្លីបំផុត ។ កុមារជាប់ឃុំដែលពុំទាន់បានជំនុំជម្រះ គួរត្រូវដាក់ដោយឡែកពីកុមារដែលទទួលបានការជំនុំជម្រះហើយ។ (វិធាន១៧)
- កុមារមានសិទ្ធិទទួលបានការពិគ្រោះយោបល់ផ្នែកច្បាប់ និងអាចស្នើសុំឲ្យមានជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃ ពីការិយាល័យដែលផ្តល់សេវាផ្នែកច្បាប់ ហើយមានសិទ្ធិទំនាក់ទំនងដោយទៀងទាត់ជាមួយនឹងទីប្រឹក្សាច្បាប់របស់ខ្លួន។ ប្រសិនបើអាចធ្វើទៅបាន កុមារគួរត្រូវបានផ្តល់ឱកាសដើម្បីបន្តការងារដោយមានប្រាក់កម្រៃ និងបន្តការសិក្សា ឬបណ្តុះបណ្តាល។ ការធ្វើការងារ ការសិក្សា ឬបណ្តុះបណ្តាលមិនគួរមានការបន្តការឃុំខ្លួនឡើយ។ ពួកគេគួរបន្តទទួលបានសកម្មភាពលេងកំសាន្តដែលស្របទៅនឹងការគ្រប់គ្រងនៃយុត្តិធម៌អនីតិជន ។ (វិធាន ១៨)
- នៅគ្រប់ទីកន្លែងឃុំខ្លួនទាំងអស់ កុមារត្រូវតែដាក់ឲ្យនៅដោយឡែកពីមនុស្សពេញវ័យ លើកលែងតែពួកគេជាសមាជិកគ្រួសារនឹងគ្នា ។ (វិធាន ២៩)
- ទីកន្លែងឃុំឃាំងចំហសម្រាប់កុមារគួរត្រូវបានបង្កើតឡើង។ ទីកន្លែងឃុំឃាំងចំហជាទីកន្លែងដែលមិនមាន ឬមានវិធានការសន្តិសុខទាប។ ចំនួនកុមារក្នុងកន្លែងប្រភេទនេះ ត្រូវមានចំនួនតិចបំផុតដែលអាចធ្វើទៅបាន។ ចំនួនកុមារនៅក្នុងកន្លែងឃុំឃាំងបិទ គួរមានចំនួនតិចល្មម ដើម្បីឲ្យគេចាត់ចែងរក្សាកុមារម្នាក់ៗបានល្អ។ គួរធ្វើវិមជ្ឈការទីកន្លែងឃុំឃាំងសម្រាប់កុមារ ហើយគួរមានទំហំមួយដែលអាចសម្រួលឲ្យមានការចូលជួប និងការទាក់ទងរវាងកុមារនិងគ្រួសាររបស់ខ្លួន។ ទីកន្លែងឃុំឃាំងខ្នាតតូច គួរត្រូវបានបង្កើតឡើង និងដាក់បញ្ចូលទៅក្នុងបរិស្ថានសង្គមសេដ្ឋកិច្ច និងវប្បធម៌របស់សហគមន៍។ (វិធាន ៣០)

- ការរៀបចំទីកន្លែងឃុំឃាំងសម្រាប់កុមារ និងបរិស្ថានត្រូវសមស្របទៅនឹងគោលដៅស្តារនីតិសម្បទា ដោយយកចិត្តទុកដាក់ខ្ពស់ដល់សេចក្តីត្រូវការរបស់កុមារ ភាពជាឯកជន ការលើកទឹកចិត្ត និង ឱកាសទំនាក់ទំនងជាមួយគ្នានឹងគ្នា ការលេងកីឡា ការហាត់ប្រាណ និង សកម្មភាពកំសាន្តផ្សេងៗ។ (វិធាន ៣២)
- កន្លែងគេងគួរមានបន្ទប់ជាក្រុមតូចៗ ឬមានបន្ទប់សម្រាប់ម្នាក់ៗ ឲ្យស្របតាមកម្រិតបទដ្ឋានក្នុងស្រុក។ (វិធាន ៣៣)
- បន្ទប់ទឹកនិងបង្គន់ត្រូវមានអនាម័យនិងស្អាតជានិច្ច ដើម្បីឲ្យកុមារប្រើប្រាស់តាមសេចក្តីត្រូវការប្រកប ដោយសុវត្ថិភាព និងអនាម័យ។ (វិធាន ៣៤)
- កុមារដែលមានអាយុត្រូវចូលរៀន មានសិទ្ធិទទួលការអប់រំដែលសមស្របតាមសេចក្តីត្រូវការ និង សមត្ថភាពរបស់ខ្លួន ដើម្បីត្រៀមរៀបចំពួកគេឲ្យត្រឡប់ទៅកាន់សង្គមវិញ។ ការអប់រំនោះគួរត្រូវបានផ្តល់ ឲ្យនៅសាលារៀនក្នុងសហគមន៍ តាមដែលអាចធ្វើទៅបាន ហើយត្រូវបង្រៀនដោយគ្រូបង្រៀនដែលមាន គុណភាពស្របតាមកម្មវិធីសាលារដ្ឋ ដើម្បីឲ្យកុមារអាចបន្តការសិក្សារបស់ខ្លួន ដោយគ្មានការពិបាក បន្ទាប់ពី ការដោះលែង។ (វិធាន ៣៨)
- កុមារគ្រប់រូបត្រូវមានសិទ្ធិទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងមុខជំនាញទាំងឡាយណា ដែលអាច ត្រៀមរៀបចំពួកគេឲ្យទទួលបានការងារក្នុងពេលអនាគត។ (វិធាន ៤២)

## ៣.៣. ការពិចារណាលើការអនុវត្តល្អពីអន្តរជាតិ

ខ្លឹមសារខាងក្រោមចង្អុលបង្ហាញពីដំណើរការ និងគោលនយោបាយអន្តរជាតិដែលគាំទ្រដល់ច្បាប់ស្តីពី យុត្តិធម៌អនីតិជនកម្ពុជា ហើយដែលបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវ។ នៅក្រោមចំណងជើងនីមួយៗ មាន ចំណុចពាក់ព័ន្ធសំខាន់ៗរវាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងលិខិតតុបករណ៍អន្តរជាតិមួយចំនួនដូចជា វិធាន បទដ្ឋានអប្បបរមាស្តីពីការគ្រប់គ្រងវិស័យយុត្តិធម៌ (វិធានក្រុងប៉េកាំង) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សកម្មភាព លម្អិតស្តីពីការអនុវត្តមាននៅក្នុងផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ។ របាយការណ៍សិក្សាស្រាវជ្រាវស្តីអំពី យុត្តិធម៌អនីតិជន ជាឯកសារដាច់ដោយឡែកមួយ ដែលមាននៅក្នុងឧបសម្ព័ន្ធ ៤។

### ភាពខុសគ្នារវាងកុមារ និងមនុស្សពេញវ័យ

យោងតាមច្បាប់អន្តរជាតិ គេចាត់ទុកកុមារមានលក្ខណៈខុសពីមនុស្សពេញវ័យ ហើយការប្រព្រឹត្តមកលើ កុមារក៏ត្រូវខុសពីមនុស្សពេញវ័យដែរ។ បញ្ហានេះត្រូវបានលើកឡើងនៅក្នុងវិធានបទដ្ឋានអប្បបរមាស្តីពីការ គ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជា ក៏បានលើកឡើងផងដែរអំពីបញ្ហានេះ ជាពិសេសមាត្រា៥ និង៦ និងជំពូក៥ ៦និងជំពូក៧។

វិធានក្រុងប៉េកាំងបញ្ជាក់ពីសារៈសំខាន់របស់ប្រទេសជាតិនីមួយៗដែលត្រូវបង្កើតឲ្យមានច្បាប់ជាក់លាក់ វិធាន និងបញ្ញត្តិនានាសម្រាប់អនុវត្តចំពោះកុមារជាជនល្មើស ហើយត្រូវមានស្ថាប័ន និងអង្គភាពដែលមានតួនាទី

គ្រប់គ្រងយុត្តិធម៌អនីតិជន ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់កុមារជាជនល្មើស ដោយមានការការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេផង ។

## ការអប់រំ និងការផ្លាស់ប្តូរឥរិយាបថរបស់សហគមន៍

ប្រព័ន្ធយុត្តិធម៌ដោយឡែកមួយសម្រាប់កុមារ (យុត្តិធម៌អនីតិជន) បានរៀបចំដើម្បីធានាថា កុមារទាំងអស់មិនមែនជាកម្មវត្ថុនៃការទទួលយកការឈឺចាប់និងមាក់ងាយឡើយ (Cunneen និង White ២០១១)។ យុត្តិធម៌អនីតិជន ឆ្លុះបញ្ចាំងពីភាពជឿនលឿនខាងមនុស្សធម៌ និងអាចឈានទៅដល់ការលុបបំបាត់ចោលនូវការដាក់ទណ្ឌកម្ម ដោយបំពាន ឬការមាក់ងាយ។ អង្គការស្រាវជ្រាវអន្តរជាតិមួយបានបញ្ជាក់ថា វិធានការដាក់ទណ្ឌកម្មដើម្បីកាត់បន្ថយការប្រព្រឹត្តបទល្មើសរបស់កុមារ ដែលរួមមានការដាក់ពន្ធនាគារ និងការសម្រេចឲ្យជាប់ទោសនោះ មិនបានធ្វើឲ្យអត្រាបទល្មើសថយចុះទេ ថែមទាំងបរាជ័យក្នុងការផ្លាស់ប្តូរអាកប្បកិរិយារបស់កុមារ ហើយមានការចំណាយច្រើន និងប្រើរយៈពេលយូរ ដែលបង្កើននូវលទ្ធភាពឲ្យកុមារក្នុងការប្រព្រឹត្តបទល្មើសនៅពេលធំពេញវ័យទៀតផង ។

## ការចេញសេចក្តីព្រមាន និងការបង្វែរ

នៅក្នុងយុត្តិធម៌អនីតិជន ការចេញសេចក្តីព្រមាន ត្រូវបានប្រើប្រាស់ដើម្បីដាក់ពិន័យកុមារ ដោយមិនបាច់បញ្ជូនទៅឃុំឃាំងទេ។ ជាការពិតណាស់ថាការចេញសេចក្តីព្រមាននេះ អាចធ្វើឲ្យសង្គមមិនពេញចិត្ត ប៉ុន្តែដោយសារតែការមិនពេញចិត្តនេះហើយដែលនាំឲ្យមានផលប៉ះពាល់ដល់ជនល្មើសជាកុមារដែរ។ ការចេញសេចក្តីព្រមាននេះ ត្រូវបានអនុវត្តចំពោះកុមារប្រព្រឹត្តបទល្មើសជាលើកដំបូង។ ការសិក្សាបានបង្ហាញថា ភាគច្រើននៃកុមារជាជនល្មើសដែលទទួលបានការព្រមានចំពោះការប្រព្រឹត្តជាលើកដំបូង គឺកម្រនឹងប្រព្រឹត្តបទល្មើជាលើកទី២ណាស់ (Dennison, Steward and Hurren ២០០៦ Poteas et al ១៩៩០ O'Connor ១៩៩២)។

កម្មវិធីបង្វែរមានគោលបំណងស្រដៀងគ្នានេះដែរ។ ការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅពេលដែលពួកគេបានប្រព្រឹត្តបទល្មើសតូចតាចដូចជាបទល្មើសលួច ត្រូវផ្តល់សេវាអប់រំកែប្រែដ៏សមស្របដោយមានគោលការណ៍ចំនួន៣គឺ ទី១: ផ្តល់សេវាចំពោះករណីដែលមានហានិភ័យខ្ពស់ ទី២: កំណត់ឲ្យដឹងពីឫសគល់នៃបញ្ហាដែលបណ្តាលឲ្យកុមារប្រព្រឹត្តបទល្មើស និងទី៣: ប្រើប្រាស់វិធីសាស្ត្រដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កុមារ (Andrews et al ១៩៩០)។ កម្មវិធីបង្វែរផ្តោតទៅលើការបណ្តុះគំនិតឲ្យចេះជួយសង្គម និងត្រៀមលក្ខណៈកុមារដើម្បីធ្វើសមាហរណកម្មប្រកបដោយជោគជ័យទៅក្នុងសហគមន៍វិញ ។

## សកម្មភាពនគរបាលនៅក្នុងសហគមន៍

"សកម្មភាពនគរបាលនៅក្នុងសហគមន៍" សំដៅដល់វិធីសាស្ត្រផ្សេងៗរបស់នគរបាលក្នុងការធ្វើការងារយ៉ាងសកម្មនិងប្រកបដោយផ្លែផ្កាជាមួយនឹងកុមារ ដើម្បីបង្កើតនូវវប្បធម៌ទុកចិត្តគ្នាមួយ និងបណ្តុះគំនិតឲ្យចេះជួយគ្នាក្នុងសង្គម។ ការផ្សព្វផ្សាយអំពីច្បាប់ព្រហ្មទណ្ឌ ច្បាប់ចរាចរ ការណែនាំស្តីពីការប្រើប្រាស់យានយន្ត ជាសកម្មភាព

ការងាររបស់នគរបាលនៅក្នុងសហគមន៍ និងអង្គការពាក់ព័ន្ធផ្សេងៗទៀត ដើម្បីជាប្រយោជន៍ដល់កុមារ ក៏ដូចជាបង្កើតឲ្យមានការចូលរួមសហការគ្នារវាងនគរបាល នឹងពលរដ្ឋ (Cunneen and White ២០១១) ។

## កម្មវិធីទប់ស្កាត់បទល្មើស

ដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជា ផែនការនេះនឹងផ្តល់នូវអនុសាសន៍មួយចំនួនសម្រាប់កម្មវិធីទប់ស្កាត់បទល្មើស។ កម្មវិធីទប់ស្កាត់បទល្មើសនេះ ផ្តោតលើវិធីសាស្ត្រសម្រុះសម្រួល និងអភិវឌ្ឍន៍ដែលស្របទៅនឹងច្បាប់កម្ពុជា និងលិខិតុបករណ៍អន្តរជាតិ។ វិធីសាស្ត្រអភិវឌ្ឍន៍ បង្កើតឲ្យមានឱកាសសម្រាប់កុមារ និងលើកទឹកចិត្តកុមារឲ្យចេះចូលរួមជួយសង្គម (Polk ១៩៩៧)។ វិធីសាស្ត្រសម្រុះសម្រួល គឺជាការប្រើប្រាស់វិធីសាស្ត្រចូលរួម ក្នុងការកាត់បន្ថយបទល្មើសកុមារ និងកែប្រែឥរិយាបថដែលប្រឆាំងនឹងសង្គម ជាពិសេសការបង្កឲ្យមានភាពភ័យខ្លាចនៅតាមទីសាធារណៈ (White Kosky and Kosky ២០០១) ។

## យុត្តិធម៌សហគមន៍

គោលការណ៍យុត្តិធម៌សហគមន៍ មានបំណងធានាថា សហគមន៍ និងតំណាងរបស់សហគមន៍ ត្រូវបានបញ្ចូលទៅក្នុងបរិបទយុត្តិធម៌អនីតិជន (Clear and Karp ២០០០)។ គោលការណ៍យុត្តិធម៌សហគមន៍អាចត្រូវបានដាក់បញ្ចូលក្នុងស្ថាប័ននគរបាល អយ្យការ និងស្ថាប័នតុលាការ។ យុត្តិធម៌សហគមន៍គឺ ផ្តោតលើការដោះស្រាយរយៈពេលខ្លី និងវែង ជួសជុលការខូចខាតរបស់ជនរងគ្រោះ ស្តារសហគមន៍ និងធ្វើសមាហរណកម្មកុមារប្រព្រឹត្តបទល្មើសទៅក្នុងសហគមន៍ឲ្យមានប្រសិទ្ធភាព ។

## កុមារនៅក្នុងការឃុំខ្លួន

ការឃុំខ្លួនមុន ឬក្រោយពេលផ្តន្ទាទោស គួរតែជាជម្រើសចុងក្រោយសម្រាប់កុមារ។ បញ្ហានេះក៏បានចែងនៅក្នុងច្បាប់កម្ពុជា ហើយក៏ស្របទៅនឹងការអនុវត្តល្អរបស់អន្តរជាតិ និងច្បាប់អន្តរជាតិផងដែរ។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ នឹងរៀបចំលម្អិតអំពីគោលនយោបាយ នីតិវិធី និងដំណើរការសម្រាប់ការអនុវត្តនូវបញ្ញត្តិរបស់ច្បាប់ឲ្យបានត្រឹមត្រូវ និងស្របទៅនឹងគោលបំណងនេះ ។

## ភស្តុតាងកំណត់អាយុ

អនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺ១៨ឆ្នាំ។ ភស្តុតាងក្នុងការកំណត់អាយុគឺជារឿងសំខាន់ ដើម្បីធានាឲ្យមានដំណើរការប្រព័ន្ធយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព និងធានាថាកុមារមិនត្រូវបានគេជំនុំជម្រះ និង ប្រព្រឹត្តមកលើខ្លួនដូចជាមនុស្សពេញវ័យនោះទេ ហើយក៏ត្រូវធានាផងដែរថាមនុស្សពេញវ័យមិនត្រូវកេងចំណេញយកលក្ខខណ្ឌពិសេសរបស់កុមារមកអនុវត្តចំពោះខ្លួននោះដែរ (Smith and Brownless ២០១១)។

ការដំណើរការរឿងក្ដីកុមារដូចមនុស្សពេញវ័យ បានធ្វើឲ្យកុមារកាន់តែមានហានិភ័យខ្ពស់នៅក្នុងប្រព័ន្ធយុត្តិធម៌ ដោយសារតែមិនបានគិតគូរអំពីស្ថានភាពរបស់កុមារ អាយុ ឬភាពចាស់ទុំរបស់កុមារ។ ចំពោះកុមារដែលស្ថិតនៅក្រោមអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ តែត្រូវបានគេកំណត់អាយុជាមនុស្សពេញវ័យដោយមានការភាន់ច្រឡំ ធ្វើឲ្យកុមារនោះបាត់បង់សិទ្ធិក្នុងការទទួលបានការការពារ និងថែទាំពិសេស។ ដូច្នេះការកំណត់អាយុឲ្យបានត្រឹមត្រូវគឺ សំខាន់ណាស់ ដើម្បីឲ្យកុមារទទួលបានការប្រព្រឹត្តមកលើខ្លួនដោយសមរម្យ (UINCEF ១៩៩៥ ទំព័រ ២០) ។

## សមត្ថភាពជំនាញ និងការបណ្តុះបណ្តាលដល់នគរបាល ចៅក្រម ព្រះរាជអាជ្ញា បុគ្គលិកសង្គមកិច្ច តុលាការ និងការត្រួតពិនិត្យរបស់តុលាការ

ច្បាប់ស្ដីពីយុត្តិធម៌អនីតិជនកម្ពុជា សំដៅដល់ « នីតិវិធីបែបកុមារមេត្រី» ដើម្បីលើកកម្ពស់ឲ្យមានការចូលរួមយ៉ាងពេញលេញរបស់កុមារ។ ហេតុដូច្នេះ ការបណ្តុះបណ្តាលជំនាញគឺជារឿងចាំបាច់ ដើម្បីជួយដល់បុគ្គលិកសំខាន់ៗ ឲ្យចេះកែប្រែរបៀបនៃការប្រើភាសា នីតិវិធី និងបរិយាកាសតុលាការ ។ បើតាមការអង្កេតរបស់ស្នងការកំណែទម្រង់ច្បាប់ប្រទេសអូស្រ្តាលី (១៩៩៧) បានកត់សម្គាល់ដូចតទៅ៖ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារបានបញ្ជាក់ពីតម្រូវការនៃការរៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលជាប្រព័ន្ធសម្រាប់មន្ត្រីដែលធ្វើការងារពាក់ព័ន្ធជាមួយកុមារក្នុងវិស័យយុត្តិធម៌កុមារ។ មន្ត្រីទាំងនេះរួមមាន៖ ចៅក្រម មេធាវី បុគ្គលិកសង្គមកិច្ច មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីអន្តោប្រវេសន៍។ ព្រះរាជអាជ្ញាគួរទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកិច្ចការកុមារ ជាពិសេសទាក់ទិននឹងការប្រើប្រាស់ឆន្ទានុសិទ្ធិ ដើម្បីលើកលែងបទចោទក្នុងរឿងក្ដីកុមារ។

វិធានក្រុងប៉េកាំងចែងថា ដំណើរការរឿងក្ដីព្រហ្មទណ្ឌគួរតែត្រូវបានគិតទៅដល់ឧត្តមប្រយោជន៍របស់កុមារ និងប្រព្រឹត្តទៅក្នុង បរិយាកាសមួយដែលអនុញ្ញាតឲ្យកុមារអាចចូលរួមសម្តែងមតិផ្ទាល់ខ្លួនដោយសេរី។ ចៅក្រម និងអ្នកអនុវត្តច្បាប់ខ្លះលើកទឹកចិត្តមិនឲ្យមានការរៀបចំជាផ្លូវការពេកនៅក្នុងតុលាការកុមារ។ នៅក្នុងដំណើរការនីតិវិធីតុលាការ ការប្រើប្រាស់ភាសាច្បាប់ និងភាសាដែលប្លែក ធ្វើឲ្យកុមារពិបាកយល់ ហើយថែមទាំងធ្វើឲ្យកុមារមានភាពភ័យខ្លាចទៀតផង ។

វិធីមួយដែលជួយឲ្យកុមារយល់ដឹងពីដំណើររឿងក្ដីព្រហ្មទណ្ឌ និងជួយឲ្យកុមារចូលរួមដោយពេញលេញបានគឺត្រូវមានមេធាវីពីដំណាក់កាលដំបូង។ វិធីមួយទៀត គឺអាចផ្តល់សិទ្ធិឲ្យកុមារទទួលបានអ្នកគាំទ្រនៅក្នុងតុលាការ។

## ការសារភាពកំហុសដោយកុមារ

ច្បាប់ស្ដីពីយុត្តិធម៌អនីតិជនកម្ពុជាបានចែងថា តុលាការគួរតែពិនិត្យវាយតម្លៃ និងបញ្ជាក់ថាការសារភាពកំហុសរបស់កុមារត្រូវតែស្ម័គ្រចិត្ត និងប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ។ ក្នុងការវាយតម្លៃការសារភាព សំខាន់ត្រូវធ្វើការកត់សម្គាល់អំពីការសិក្សាស្រាវជ្រាវផ្នែកចិត្តសាស្រ្តដែលបញ្ជាក់ថាកុមារងាយនឹងធ្វើការសារភាពខុសដោយសារតែការលូតលាស់ និងបុគ្គលិកលក្ខណៈនៅក្មេងខ្ចីរបស់កុមារ។ ពួកគេងាយនឹងធ្វើតាម និងថាតាមអាជ្ញាធរណាស់ (Kassin ២០១០)។

### តុលាការនិងការគ្រប់គ្រងរឿងក្តីកុមារ និងការធ្វើសមាហរណកម្មកុមារទៅក្នុងសហគមន៍

កុមារត្រូវការគាំទ្រពីសហគមន៍ប្រកបដោយសុវត្ថិភាព ស្ថេរភាព ចីរភាព និងជម្រើសផ្សេងៗដែលមានការគាំទ្រថវិកាជាក់លាក់ មានបុគ្គលិកឯករាជ្យ មានអ្នកគ្រប់គ្រងករណីដែលមានការយល់ដឹងពីកុមារ ដោយមានវិធីសាស្ត្រគ្រប់គ្រងហានិភ័យ ដោយប្រើប្រាស់ការមិនដាក់ទោសទណ្ឌ ផ្តល់ការព្យាបាល ក្របខណ្ឌអនុវត្តមិនតឹងរឹងពេក ដែលជំរុញឲ្យមានការគាំទ្រពីគ្រួសារ និងសេវាកម្មសង្គមពាក់ព័ន្ធផ្សេងៗទៀត (Keyzer and O'Donovan ២០១៤)។ (នៅក្នុងឧបសម្ព័ន្ធ ៤ មាននិយាយលម្អិតអំពីចំណុចនេះ)

## ៣.៤. ការពិគ្រោះយោបល់

ចំណុចសំខាន់បំផុតនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ គឺការពិគ្រោះយោបល់។ មានឯកសារជាច្រើនដែលអាចផ្តល់ការណែនាំក្នុងការបង្កើតឡើង និងការកែលម្អប្រព័ន្ធយុត្តិធម៌អនីតិជន។

ការពិគ្រោះយោបល់រួមមានការសម្ភាសជាមួយនឹងមន្ត្រីនៃស្ថាប័នពាក់ព័ន្ធ ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់មានលក្ខណៈទ្រង់ទ្រាយធំ និងការពិនិត្យមើលសេចក្តីព្រាងផែនការរបស់ស្ថាប័នពាក់ព័ន្ធ។ ចំណុចគោលសំខាន់ៗដែលបានយកមកពិភាក្សាពីដំបូង បានបង្កើតចេញជាគោលការណ៍សម្រាប់ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជន(ចំណុច ៣.១)។ មានការឯកភាពរួមគ្នាមួយទៅលើចំណុចប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ហើយចំណុចទាំងនោះក៏បានដាក់បញ្ចូលទៅក្នុងផែនយុទ្ធសាស្ត្រនិងប្រតិបត្តិនេះដែរ។ ចំណុចប្រឈមទាំងនោះរួមមាន៖ ប្រភពធនធាន ការទទួលយករបស់សហគមន៍ចំពោះការបង្វែរ ការផ្លាស់ប្តូររបៀបរបបអនុវត្តនៅថ្នាក់ជាតិ កិច្ចសហប្រតិបត្តិការល្អដែលចាំបាច់ត្រូវតែមានដើម្បីឈានទៅបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយ ។

### ជាការពិត ចំណុចប្រឈមសំខាន់ៗទាំងអស់នេះ គឺមិនមែនមានតែនៅក្នុងប្រទេសកម្ពុជាទេ ប្រទេសផ្សេងទៀតក៏ជួបបញ្ហាប្រឈមទាំងនេះដែរ៖

- ប្រភពធនធាន
- ការទទួលស្គាល់របស់សហគមន៍ និងការគាំទ្រការបង្វែរ និងអភិក្រមសិទ្ធិកុមារ
- រៀបចំឲ្យមានការផ្លាស់ប្តូរថ្នាក់ជាតិ
- ភាពស្មុគស្មាញ និងតម្រូវការសហប្រតិបត្តិការទូលំទូលាយ។

បញ្ហាចម្បងផ្សេងទៀតដែលបានលើកឡើងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់នោះ គឺពាក់ព័ន្ធនឹងប្រព័ន្ធមជ្ឈការជំនាញ ការទទួលខុសត្រូវ ឬតួនាទីរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធដទៃទៀតដែលត្រូវចូលរួមអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ការធ្វើសមាហរណកម្ម និងការបង្វែរកុមារប្រកបដោយប្រសិទ្ធភាព តម្រូវឲ្យមានដំណោះស្រាយនៅក្នុងសហគមន៍។ ដូច្នេះ ទាមទារឲ្យមានតុល្យភាពរវាងអភិក្រមប្រព័ន្ធមជ្ឈការ និងដំណោះស្រាយនៅថ្នាក់មូលដ្ឋាន ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ជំនាញគ្រប់គ្រងបុគ្គលិក និងការដំណើរការ។

សិក្ខាសាលាពិគ្រោះយោបល់ចំនួន ២លើកត្រូវបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញក្នុងខែមីនា និងមេសា ២០១៧ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ។ ការផ្តោតសំខាន់របស់សិក្ខាសាលាលើកទី១ គឺផ្ទៀងផ្ទាត់ថា តើអ្វីខ្លះដែលត្រូវការដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងពិភាក្សាអំពីបញ្ហាប្រឈម ការផ្លាស់ប្តូរផ្នត់គំនិត និងពិភាក្សាយោបល់របស់ស្ថាប័នពាក់ព័ន្ធដែលបានចូលរួម។ ការវិភាគនិងតារាងបែងចែកកាតព្វកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ គឺជាឯកសារមួយដែលបានចែកជូនដល់សិក្ខាកាមទាំងអស់ ដើម្បីពិនិត្យនិងស្វែងយល់។ ការពិភាក្សាក្រុមតូចៗក្នុងអង្គសិក្ខាសាលានៅថ្ងៃទី១គឺបែងចែកទៅតាមស្ថាប័ននីមួយៗ បន្ទាប់មកមានការបែងចែកជាក្រុមចម្រុះគ្រប់ស្ថាប័នពាក់ព័ន្ធ។ ការពិភាក្សាលើមតិយោបល់ដែលទទួលបានរួមជាមួយការសម្ភាស និងកិច្ចប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ បានផ្តល់ជាគំនិតក្នុងការរៀបចំកម្មវិធីយុទ្ធសាស្ត្រចំនួន១០ចំណុចសម្រាប់ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិ។ អង្គសិក្ខាសាលានៅថ្ងៃទី២ បានបង្ហាញអំពីកម្មវិធីយុទ្ធសាស្ត្រទាំង១០ សកម្មភាពសំខាន់ៗ និងលទ្ធផលអនុវត្តជាក់ស្តែង ដោយផ្អែកតាមការរកឃើញពីការពិគ្រោះយោបល់លើកដំបូង បទដ្ឋានអន្តរជាតិ និងការអនុវត្តល្អ។ កម្មវិធីយុទ្ធសាស្ត្រនីមួយៗត្រូវបានយកមកពិភាក្សាជាក្រុមតូចៗ និងត្រូវបានកត់ត្រា ហើយយោបល់ត្រឡប់មកវិញត្រូវបានផ្តល់ជូនដល់ក្រុមការងារតាក់តែងផែនការ។ មានការផ្តល់យោបល់ជាច្រើនដែលអាចយកមកពិចារណា។ ៨០%នៃយោបល់ត្រឡប់មកវិញ គឺមានភាពវិជ្ជមាន និងឯកភាពគ្នាទៅលើសេចក្តីព្រាងផែនការប្រតិបត្តិ។ យោបល់អវិជ្ជមានជាច្រើនដែលបានលើកឡើង គឺពាក់ព័ន្ធនឹងមន្ទិលសង្ស័យទៅលើសមត្ថភាពក្នុងការអនុវត្ត ដែលនេះក៏ជាបញ្ហាប្រឈមមួយដែលបានលើកឡើងនៅក្នុងសិក្ខាសាលាលើកទី១ដែរ។ នៅក្នុងសិក្ខាសាលាដាក់បង្ហាញសេចក្តីព្រាងផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ កាលពីខែឧសភាឆ្នាំ២០១៧ ក៏មានការផ្តល់ជាយោបល់ដ៏ល្អៗជាច្រើនពីអ្នកចូលរួម ហើយដែលយោបល់ទាំងនោះត្រូវបានយកមកពិចារណាក្នុងការរៀបចំផែននេះដែរ។ សរុបសេចក្តីទៅ យោលបល់ត្រលប់មកវិញទាំងអស់ ត្រូវបានយកមកពិចារណាក្នុងការរៀបចំផែនការចុងក្រោយ។

## ៣.៥. ការវិភាគច្បាប់ស្តីពីយុត្តិធម៌អនីតិជន

### ៣.៥.១. ទិដ្ឋភាពទូទៅ

ការវិភាគច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីកំណត់កាតព្វកិច្ច។ វិធីនេះវិភាគទៅលើមាត្រានីមួយៗនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងបែងចែកកាតព្វកិច្ចដែលច្បាប់បានចែងនៅក្នុងមាត្រានីមួយៗ ដើម្បីឲ្យដឹងថាតើស្ថាប័នណាមានកាតព្វកិច្ចធ្វើអ្វី ហើយអ្នកណានឹងទទួលបានផលពីកាតព្វកិច្ចនោះ។ ភាគច្រើននៃអ្នកជាប់កាតព្វកិច្ចនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺជាមន្ត្រីដែលធ្វើការនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជនដែលមានដូចជា៖ នគរបាល មេធាវី ព្រះរាជអាជ្ញា ចៅក្រម ក្រឡាបញ្ជី និងបុគ្គលិកសង្គមកិច្ច។ តួនាទីថ្មីត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីយុត្តិធម៌អនិតិជន ក្នុងនោះមានភ្នាក់ងារសង្គមកិច្ច អ្នកគ្រប់គ្រងការងារបង្វែរ និងមន្ត្រីទទួលបន្ទុកយុវនីតិសម្បទា។ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ អាចមានបញ្ហាប្រឈមក្នុងការផ្លាស់ប្តូរការអនុវត្តរបស់ខ្លួននាពេលបច្ចុប្បន្ន ដែលចាំបាច់ត្រូវបង្កើត និងតែងតាំងអ្នកជំនាញខាងយុត្តិធម៌អនីតិជន។

ឯកសារស្តីពីការវិភាគច្បាប់ស្តីពីយុត្តិធម៌អនីតិជននិងតារាងកាតព្វកិច្ចអនុវត្ត និងបទដ្ឋាននានា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការបកស្រាយរកអ្នកជាប់កាតព្វកិច្ចនានា។ ឯកសារនេះមាននៅក្នុងឧបសម្ព័ន្ធ ១។

ការវិភាគទៅលើច្បាប់ និងការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ បានរកឃើញគម្លាតនិងភាពមិនច្បាស់លាស់មួយចំនួនរបស់ច្បាប់នេះ ដែលទាមទាឲ្យមានឯកសារពន្យល់បន្ថែមទៅលើចំណុចទាំងនោះ។

### ច្បាប់ស្តីពីយុត្តិធម៌អនីតិជនរួមមានតម្រូវការដូចខាងក្រោម៖

- មាត្រា ១០៖ នីតិវិធីនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។
- មាត្រា ៧៦៖ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ។
- មាត្រា ៧៧ ៧៨ ៨២ ៨៣ និង៨៨៖ មាត្រាទាំងនេះចែងពីបែបបទនិងនីតិវិធីនៃមណ្ឌលយុវនីតិសម្បទា ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ នឹងត្រូវរៀបចំសេចក្តីព្រាងនីតិវិធី និងដំណើរការការងារទៅតាមផ្នែកនៃការទទួលខុសត្រូវរបស់ខ្លួន។

ជាទូទៅរាល់ច្បាប់ថ្មីទាំងអស់តម្រូវឲ្យមានការបកស្រាយ និងបើចាំបាច់ត្រូវធ្វើវិសោធនកម្មនៅពេលខាងមុខ។ ក្រសួងទាំងនេះអាចផ្តល់ការបកស្រាយលើចំណុចដែលមិនច្បាស់លាស់នៅក្នុងពេលអនុវត្ត។ កម្មវិធី និងគោលនយោបាយទាំងឡាយ ត្រូវតែគិតអំពីផលប៉ះពាល់ដល់កុមារដែលកំពុងជាប់ឃុំ និងដល់ការអនុវត្តច្បាប់នេះ។

### សិក្ខាសាលាពិគ្រោះយោបល់បានកំណត់នូវចំណុចដែលត្រូវយកចិត្តទុកដាក់ដូចខាងក្រោម៖

- មាត្រា ៨៨ និយាយពីមណ្ឌលយុវនីតិសម្បទា
- កង្វះគោលការណ៍ណែនាំអំពីការផ្តន្ទាទោស និងការទទួលទោស
- ការកំណត់ពេលវេលាសម្រាប់ដំណើរការរឿងក្តី
- ការបារម្ភអំពីការមិនគោរពគោលការណ៍រក្សាការសម្ងាត់
- ភស្តុតាងនៃការកំណត់អាយុ
- បទប្បញ្ញត្តិស្តីពីតម្រូវការនៃកិច្ចការពារនិងថែទាំ
- សិទ្ធិរបស់នគរបាលដើម្បីចេញសេចក្តីព្រមាន និងបង្វែរ

### ៣.៥.២. ផលប៉ះពាល់នៃមាត្រា៨៨

មាត្រា ៨៨៖ ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជនទំនាស់នឹងច្បាប់ ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា។

អនុក្រិត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលឃុំវនីតិសម្បទា ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីរួចហើយកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។ ប៉ុន្តែ មណ្ឌលឃុំវនីតិសម្បទាដែលស្របតាមលក្ខខណ្ឌរបស់ច្បាប់នេះ មិនទាន់មាននៅឡើយ។

ផលវិបាកនៃការអនុវត្តមាត្រា ៨៨ គឺថា មាត្រា ៧២ និង ៧៣ នៃច្បាប់នេះដែលចែងទាក់ទិនទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ មិនអាចអនុវត្តបានទេរហូតដល់មណ្ឌលឃុំវនីតិសម្បទារួចរាល់។ នេះមានន័យថា រាល់ការដោះលែងដោយមានលក្ខខណ្ឌ នេះនឹងត្រូវអនុវត្តតាមលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ។

ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិក៏តម្រូវឲ្យមានមណ្ឌលឃុំវនីតិសម្បទាបណ្តោះអាសន្ន ដែលជាសកម្មភាពអាទិភាព ដើម្បីដោះស្រាយនូវផលវិបាកដែលបណ្តាលមកពីមាត្រា ៨៨ នៃច្បាប់នេះ។ តម្រូវការនេះកំពុងត្រូវបានត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច ដែលពិចារណាក្នុងការយកមណ្ឌលកុមារកំព្រាមួយចំនួនដែលទុកចោលមកប្រើប្រាស់។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ផ្តល់នូវសកម្មភាពជាច្រើន ក្នុងការវាយតម្លៃ កែលម្អពន្ធនាគារបច្ចុប្បន្នឲ្យមានភាពប្រសើរឡើង និងដំណើរការរៀបចំឲ្យមានមណ្ឌលឃុំវនីតិសម្បទាបណ្តោះអាសន្ន។

បច្ចុប្បន្ននេះកំពុងមានវិបត្តិដោយសារមានអ្នកទោសច្រើនលើសចំណុះ រួមទាំងកំណើនកុមារដែលបានប្រព្រឹត្តបទល្មើសផងដែរ ហើយប្រសិនបើច្បាប់ស្តីពីយុត្តិធម៌អនីតិជនចូលជាធរមាន វាជារឿងដ៏សំខាន់ដែលបទប្បញ្ញត្តិស្តីពីការបង្វែរ ត្រូវយកមកអនុវត្តឲ្យបានឆាប់តាមតែអាចធ្វើទៅបាន។

កត្តាស្មុគស្មាញមួយទៀតដែលទាក់ទងនឹងគម្រោងសាងសង់មណ្ឌលឃុំវនីតិសម្បទាតែមួយ ដើម្បីផ្តល់សេវាឲ្យមានប្រសិទ្ធភាពដោយគ្របដណ្តប់ខេត្តចំនួន៥ នោះ គឺហាក់ដូចជាផ្ទុយនឹងវិធាន៣០ នៃវិធាន Havana ដែលតម្រូវឲ្យទីកន្លែងឃុំខ្លួនកុមារគួរត្រូវបានធ្វើវិមជ្ឈការហើយស្ថិតក្នុងទំហំមួយ ដែលអាចសម្រួលឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងកុមារនិងក្រុមគ្រួសារ។ ទីកន្លែងឃុំឃាំងទ្រង់ទ្រាយតូចគួរត្រូវបានបង្កើតឡើង ដោយផ្សាភ្ជាប់ទៅនឹងបរិយាកាសសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់សហគមន៍។

គម្រោងប្រើប្រាស់បណ្តោះអាសន្ននូវមណ្ឌលឃុំវនីតិសម្បទាមួយចំនួនដែលបានលើកឡើងខាងលើអាចជាមូលដ្ឋានដើម្បីឲ្យស្របទៅនឹងវិធាននេះ។ មណ្ឌលឃុំវនីតិសម្បទាទាំងនោះក៏អាចផ្តល់សេវាដើម្បីធ្វើវិមជ្ឈការមណ្ឌល គឺបង្រួមមណ្ឌលឲ្យតូច និងជួយដល់ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ដែលជាគោលបំណង មួយនៃគោលការណ៍របស់ច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះផង។

ការអនុវត្តមាត្រា ៨៨ មិនមានន័យថា ពន្ធនាគារបច្ចុប្បន្នមិនគួររៀបចំឲ្យបានប្រសើរសម្រាប់កុមារនោះទេ។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិមានសកម្មភាពសម្រាប់ជួយដល់ពន្ធនាគារបច្ចុប្បន្ន ឲ្យបន្តអនុវត្តបទដ្ឋានអន្តរជាតិ ដើម្បីធានាថា លក្ខខណ្ឌដែលកំពុងអនុវត្តចំពោះកុមារក្នុងទីកន្លែងឃុំឃាំងមានលក្ខណៈប្រសើរឡើង។

ផលប៉ះពាល់នៃមាត្រា ៨៨ អាចត្រូវបានកាត់បន្ថយដោយការបង្កើតអនុក្រិត្យដែលអនុញ្ញាតឲ្យមាត្រា ៧២ និង ៧៣ ប្រតិបត្តិទៅបាន ប្រសិនបើកុមារនោះកំពុងស្ថិតនៅក្នុងពន្ធនាគារសព្វថ្ងៃ។

### ៣.៥.៣. កង្វះគោលការណ៍ណែនាំអំពីការផ្តន្ទាទោស និងការទទួលទោស

គោលការណ៍ណែនាំស្តីពីការដាក់ទោសនិងការទទួលទោស បន្តអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត លើកលែងតែមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន (មាត្រា២) ។

### ការកែប្រែមួយចំនួនដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន រួមមាន៖

- ការដាក់ទោសត្រូវតែអនុវត្តនៅក្នុងមណ្ឌលយុវនីតិសម្បទា។ បើទោះជាមិនមានការចែងច្បាស់យ៉ាងណាក៏ដោយ ក៏គោលបំណងទាំងមូលនៃច្បាប់នេះស្នើឲ្យមានការអនុវត្តបែបនេះដែរ (សូមពិនិត្យមើល មាត្រា ៤ ត្រង់ចំណុចនិយមន័យ ១០) ។
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជន ជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន (មាត្រា ៥)។មាត្រានេះ ចង់មានន័យថា នៅពេលមិនទាន់មានមណ្ឌលយុវនីតិសម្បទា កុមារនឹងត្រូវអនុវត្តទោសនៅក្នុងពន្ធនាគារ ប៉ុន្តែក៏អាចបកស្រាយថា ឲ្យមានការដាក់ទោសក្នុងរយៈពេលខ្លីជាងអ្វីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ ។
- នៅក្នុងមាត្រា៥ដដែលក៏មានចែងដែរថា៖ «គ្រប់បុគ្គលដែលបំពេញមុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍មួយចំនួនដូចជា៖ ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា»។ នៅក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ មានការខ្វែងគំនិតគ្នាថាតើមាត្រា៥នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បើទោះបីជាមិនបានសំដៅជាក់លាក់ទៅលើគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោស និងទទួលទោសក៏ដោយ ក៏វាសំដៅដល់លក្ខខណ្ឌដែលត្រូវអនុវត្តសម្រាប់គោលបំណងនៃមាត្រា២ ហេតុដូច្នេះហើយគួរផ្តល់ឆន្ទានុសិទ្ធិទៅឲ្យចៅក្រមដើម្បីកំណត់ទោសផ្សេងគ្នាសម្រាប់កុមារ។

### ៣.៥.៤. ការកំណត់ពេលវេលាចំពោះដំណើរការរឿងក្តី

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មិនទាន់បានកំណត់ពេលវេលាជាក់លាក់នៅឡើយទេ សម្រាប់ដំណើរការនីតិវិធី ដោយប្រើប្រាស់នូវពាក្យពេចន៍មួយចំនួនដូចជា «ឆាប់តាមតែអាចធ្វើទៅបាន» «ឲ្យបានមុនតាមតែអាចធ្វើទៅបាន» និង «ភ្លាមៗ»។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជាក៏ដូចជាប្រព័ន្ធយុត្តិធម៌អនីតិជនភាគច្រើនដែរ គឺបានផ្តល់ទំនុកចិត្តដល់មន្ត្រីអនុវត្តច្បាប់ ដូចជា នគរបាល ព្រះរាជអាជ្ញា ចៅក្រម និងភ្នាក់ងារសង្គមកិច្ច ឲ្យធ្វើការវិនិច្ឆ័យតាមលក្ខណៈវិជ្ជាជីវៈ ដោយមានការកំណត់ពេលវេលាដូចបានបញ្ជាក់ខាងលើ។ ប៉ុន្តែវាអាចមានហានិភ័យផងដែរ ដែលថាកង្វះខាតនៃការកំណត់ពេលវេលាជាក់លាក់នេះ អាចបង្កឲ្យមានការយឺតយ៉ាវនៅក្នុងដំណើរការរឿងក្តី។ សកម្មភាពមួយចំនួននៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ នឹងជួយកាត់បន្ថយហានិភ័យនេះ តាមរយៈការបង្កើត និងចងក្រងប្រព័ន្ធប្រតិបត្តិយុត្តិធម៌អនីតិជន ដែលមានបញ្ចូលការកំណត់ពេលវេលា និងប្រព័ន្ធគ្រប់គ្រងសំណុំរឿង ជាមួយនិងកាលវិភាគពិនិត្យមើលសំណុំរឿង។

### ៣.៥.៥. ទណ្ឌកម្មចំពោះការមិនគោរពគោលការណ៍រក្សាការសម្ងាត់

វាមិនមានការដាក់ទណ្ឌកម្មចំពោះអ្នកដែលមិនគោរពគោលការណ៍រក្សាការសម្ងាត់ទេ លើកលែងតែទណ្ឌកម្ម ដែលមានចែងនៅក្នុងច្បាប់សារព័ត៌មាន (មាត្រា១៥) ដែលហាមបង្ហាញអត្តសញ្ញាណ ឬព័ត៌មានលម្អិតដែលអាច នាំឲ្យដឹងពីអត្តសញ្ញាណអនីតិជនទំនាស់នឹងច្បាប់។ ការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់អាចត្រូវបានពិចារណា នៅពេល មានវិសោធនកម្មច្បាប់ស្តីពីយុត្តិធម៌អនីតិជននាពេលអនាគត។ ជាដំណោះស្រាយក្នុងរយៈពេលដែលពុំទាន់មាន ការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ គួរមានការដាក់ពិន័យចំពោះបុគ្គលិកដែលធ្វើការងារនៅផ្នែកផ្សេងៗ ដូចជា អប់រំ សុខាភិបាល យុត្តិធម៌ អាជ្ញាធរ និងសង្គមកិច្ច។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាកម្មជាច្រើន ក៏គួមានក្រមសីលធម៌រក្សាការសម្ងាត់ដែលត្រូវអនុវត្តដែរ។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ក៏មានការស្នើឲ្យ មានយន្តការដែលត្រូវអនុវត្តដោយបុគ្គលិកក្រសួងពាក់ព័ន្ធ ទាក់ទងនឹងការរក្សាការសម្ងាត់នេះដែរ។

### ៣.៥.៦. ភស្តុតាងកំណត់អាយុ និងសំបុត្រកំណើត

ច្បាប់ស្តីពីយុត្តិធម៌អនិតិជន ផ្តល់ដំណោះស្រាយក្នុងការកំណត់អាយុអនីតិជននៅគ្រប់ដំណាក់កាល នៃនីតិវិធី តុលាការ។ មាត្រា ៩ បានចែងថា «ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបញ្ជាក់ដោយសំបុត្រកំណើត ឬ ឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមាន ភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់ មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរក ភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន។ ក្នុងករណីមានការ សង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ។»

តើអ្វីទៅដែលថា «មធ្យោបាយដែលអាចជឿទុកចិត្តបាន» និងថាតើនរណាខ្លះ «ជាអាជ្ញាធរមានសមត្ថកិច្ច»។ ប្រសិនបើមានការសង្ស័យពាក់ព័ន្ធនឹងអាយុកើតឡើង នៅពេលដែលកុមារស្ថិតនៅក្នុងការគ្រប់គ្រងរបស់នគរបាល យុត្តិធម៌ បញ្ហានេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា (មាត្រា ១៤)។ ប្រសិនបើបញ្ហាអាយុនៅតែមានមន្ទិលសង្ស័យបន្ទាប់ពី ការអង្កេតបឋមដោយព្រះរាជអាជ្ញា បញ្ហានេះនឹងត្រូវបញ្ជូនបន្តទៅចៅក្រមស៊ើបសួរ (មាត្រា២៥)។ មានមាត្រា ជាច្រើន បង្កប់ន័យថាចៅក្រមស៊ើបសួរនឹងធ្វើការកំណត់អាយុ (មាត្រា ៣៣ ៣៩)។ មាត្រា ៤៩ មានន័យថា ចៅក្រម ជំនុំជម្រះអាចស្វែករកអាយុពិត។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ អ្នកចូលរួមមួយចំនួនក៏បានពិភាក្សា ដេញដោលគ្នាដែរ ថាតើអាចនឹងមានផលប៉ះពាល់ដល់អនីតិជនយ៉ាងណា ប្រសិនបើការកំណត់អាយុនេះត្រូវ រងចាំរហូតដល់មានសេចក្តីសម្រេចពីតុលាការ ។

នៅក្នុងឆ្នាំ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយ ចីរភាពដែលជាក្របខណ្ឌអភិវឌ្ឍន៍សាកលដ៏សំខាន់មួយ និងបានកំណត់គោលដៅមួយចំនួន ដែលរដ្ឋជាសមាជិក ទាំងអស់របស់អង្គការសហប្រជាជាតិ អាចប្រើប្រាស់ដើម្បីកំណត់ការងារអាទិភាពរបស់ខ្លួនសម្រាប់ ឆ្នាំ ២០១៦-២០៣០។ គោលដៅមួយក្នុងចំណោមគោលដៅទាំងនោះគឺថា មនុស្សគ្រប់រូបមានអត្តសញ្ញាណ

ស្របច្បាប់មួយ ដែលរួមមានសំបុត្រកំណើត(SDG16.9)។ បញ្ហាភស្តុតាងនៃការកំណត់អាយុនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចាំបាច់ត្រូវពិចារណាថាជារឿងសំខាន់ ព្រោះវាជួយឲ្យសម្រេចបាននូវការចុះសំបុត្រកំណើតឲ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

## ៣.៥.៧. បទប្បញ្ញត្តិដែលចែងអំពីតម្រូវការកិច្ចការពារ និងថែទាំ

នៅក្នុងមាត្រាមួយចំនួននៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងថា ប្រសិនបើកុមារចាំបាច់ត្រូវការកិច្ចការពារ និងថែទាំ កុមារទាំងនោះត្រូវបញ្ជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន (មាត្រា ១៣ ១៤ ២៧ ៣៩ ៤១ និង ៤២)។ ចំណុចនេះទទួលស្គាល់ថា ជារឿយៗដោយសារតែស្ថានភាពដ៏លំបាករបស់កុមារ ទើបបណ្តាលឲ្យកុមារប្រព្រឹត្តបទល្មើស ឬទំនាស់នឹងច្បាប់។

អនុសញ្ញាស្តីពីសិទ្ធិកុមារបញ្ជាក់ថា គ្មានកុមារណាម្នាក់ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តបានឡើយ។ ការចាប់ខ្លួន ការឃាត់ឬឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ គឺត្រូវធ្វើស្របតាមច្បាប់ និងត្រូវអនុវត្តសម្រាប់តែវិធានការចុងក្រោយ និងមានរយៈពេលខ្លីតែប៉ុណ្ណោះ (មាត្រា៣៧)។ ការឃុំខ្លួនដែលជាជម្រើសចុងក្រោយនេះត្រូវយកមកពិចារណាចំពោះកុមារដែលត្រូវបានគេដកហូតសិទ្ធិសេរីភាព ដោយហេតុថាពួកគេត្រូវការកិច្ចការពារនិងការថែទាំជាចាំបាច់។ មន្ត្រីធ្វើការខាងយុត្តិធម៌អនីតិជនចាំបាច់ ត្រូវទទួលបានការបណ្តុះបណ្តាលឲ្យយល់ដឹងថាការបញ្ជូនកុមារត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ ហើយមិនត្រូវអនុវត្តផ្សេងក្រៅពីការបង្វែរនោះទេ។

ក្រសួងសង្គមកិច្ច ជាមួយនឹងផ្នែកសុខុមាលភាពកុមារ និងគ្រួសារ មាននីតិវិធី គោលនយោបាយ និងកម្មវិធីសម្រាប់កុមារដែលត្រូវការកិច្ចការពារនិងថែទាំ ហើយក៏មានគម្រោងសំខាន់ៗមួយចំនួនដូចជា «ការថែទាំកុមារក្នុងគ្រួសារជាអាទិភាព» (Family Care First) ដែលធ្វើការដើម្បីកែលម្អប្រព័ន្ធថែទាំសព្វថ្ងៃ។

## ៣.៥.៨. សិទ្ធិរបស់នគរបាលដើម្បីចេញសេចក្តីព្រមាន និងបង្វែរ

មាត្រា ១៣ ផ្តល់សិទ្ធិដល់នគរបាលក្នុងការបង្វែរកុមារដែលបានប្រព្រឹត្តបទលហុ។ មាត្រានេះក៏តម្រូវឲ្យនគរបាលសរសេររបាយការណ៍ និងបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់។ ក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ មានការស្នើឲ្យមានការផ្តល់ សិទ្ធិទៅមន្ត្រីនគរបាលដើម្បីដោះស្រាយបទលហុដោយមិនចាំបាច់បញ្ជូនទៅតុលាការឡើយ។ ពាក់ព័ន្ធចំណុចនេះ ត្រូវរៀបចំប្រព័ន្ធមួយស្តីពីការចេញសេចក្តីព្រមានសម្រាប់ឲ្យនគរបាលអនុវត្ត។ ការបញ្ជូនរបាយការណ៍ទៅកាន់ព្រះរាជអាជ្ញា អាចផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាពិនិត្យមើលឡើងវិញអំពីការសម្រេចរបស់នគរបាល ដើម្បីធានាអំពីភាពស្របច្បាប់។ ផ្អែកលើការអនុវត្តដ៏ល្អបំផុត មាត្រា១៣នេះ គួរតែជាដំណាក់កាលនីតិវិធីសម្រាប់ការពិនិត្យឡើងវិញ មិនមែនជាការផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាក្នុងការបដិសេធលើសេចក្តីសម្រេចចិត្តរបស់នគរបាលនោះទេ លើកលែងតែនគរបាលស្នើសុំទៅព្រះរាជអាជ្ញាឲ្យជួយពិចារណាលើសំណុំរឿងនោះ។

បញ្ហាទាក់ទងមួយទៀតគឺលិខិតថ្កោលទោស។ របាយការណ៍ដែលបញ្ជូនទៅព្រះរាជអាជ្ញា និងការចុះក្នុងបញ្ជីព្រមានរបស់នគរបាល មិនគួរបង្កើតឲ្យទៅជាផ្នែកមួយនៃលិខិតថ្កោលទោសនោះទេ។ បញ្ជីព្រមានត្រូវរក្សាទុកដាច់ដោយឡែកពីសំណុំរឿងផ្សេងទៀត។

## ៣.៦. តារាងបែងចែកតាមដំណាក់កាល

ឧបសម្ព័ន្ធ១ជាឯកសារវិភាគពេញលេញទៅលើកាតព្វកិច្ចដែលមានចែងក្នុងច្បាប់។ ឯកសារនេះត្រូវបានរៀបចំឡើង ដើម្បីបញ្ជាក់ពីកាតព្វកិច្ចរបស់ស្ថាប័នពាក់ព័ន្ធនីមួយៗដែលមានចែងក្នុងច្បាប់។ ចំណែកឯតារាងខាងក្រោមនេះ គឺជាការបែងចែកមាត្រាទៅតាមដំណាក់កាលនីមួយៗ។




ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវយល់ និងអនុវត្តនូវគោលដៅ គោលបំណង និងគោលការណ៍ដែលគាំទ្រច្បាប់នេះ (មាត្រា ១ ២ ៤ និង ៥)
ច្បាប់នេះអនុវត្តចំពោះកុមារទំនាស់នឹងច្បាប់ទាំងអស់ (មាត្រា ៣) ការពារ និងថែរក្សាសិទ្ធិនៅក្នុងនីតិវិធីតុលាការរបស់ពួកគេ (មាត្រា ៦)
អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពី ១៨ ឆ្នាំ ឡើងទៅ លើកលែងតែតុលាការរកឃើញថា កុមារមានអាយុចាប់ពី១៤មានការទទួលខុសត្រូវ
(មាត្រា ៧) ការទទួលខុសត្រូវរដ្ឋប្បវេណី ចែងក្នុងមាត្រា ៨ ក្រសួងសង្គមកិច្ចតែងតាំង និងផ្តល់នីតិសម្បទានដល់ភ្នាក់ងារសង្គមកិច្ច(មាត្រា ១០) ។

# ៤. ផែនការយុទ្ធសាស្ត្រ

## ៤.១. ហេតុផល និងគោលបំណង

គោលដៅនៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ គឺបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយដែលដំណើរការទៅដោយមានការការពារសិទ្ធិកុមារ និងរៀបចំផែនការសម្រាប់អនាគតកុមារ។

គោលបំណង៖ នេះគឺជាផែនការរយៈពេល ៣ឆ្នាំ និងមានគោលបំណងធំចំនួនពីរ៖

**ប្រព័ន្ធយុត្តិធម៌អនីតិជន**

កសាងមូលដ្ឋានរឹងមាំប្រកបដោយចីរភាព សម្រាប់ប្រព័ន្ធយុត្តិធម៌អនីតិជនមួយ ដែលអាចអភិវឌ្ឍ និងកែលម្អជាបន្តបន្ទាប់នៅពេលអនាគត។

**ការពារសិទ្ធិរបស់អនីតិជន**

ដើម្បីទទួលបានលទ្ធផលជាវិជ្ជមានប្រកបដោយប្រសិទ្ធភាព សម្រាប់អនីតិជនទំនាស់នឹងច្បាប់បច្ចុប្បន្ន និងទៅអនាគត និងដើម្បីកាត់បន្ថយចំនួនអនីតិជននៅក្នុងពន្ធនាគារ ។

ផែនការយុទ្ធសាស្ត្រ មានចំណុចអាទិភាពជាយុទ្ធសាស្ត្រចំនួន៥ ដើម្បីជួយដល់ការសម្រេចចិត្តក្នុងការអនុវត្ត និងមានកម្មវិធីយុទ្ធសាស្ត្រចំនួន០៩ផ្នែកដែលក្នុងផ្នែកនីមួយៗមានសកម្មភាពជាច្រើន។ សកម្មភាពទាំងអស់ត្រូវបានរៀបចំដើម្បីគាំទ្រដល់ចំណុចអាទិភាពជាយុទ្ធសាស្ត្រទាំងនោះ និងដើម្បីសម្រេចគោលបំណងទាំងឡាយរបស់ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ។

ចំណុចអាទិភាព៖

| | |
|---|---|
| ១. អភិក្រមសិទ្ធិកុមារ៖ | ដើម្បីអនុវត្តអភិក្រមសិទ្ធិកុមារ និងកសាងប្រព័ន្ធយុត្តិធម៌អនីតិជនមួយដែលផ្តល់ផលប្រយោជន៍ដល់កុមារ។ |
| ២. ការអភិវឌ្ឍប្រកបដោយចីរភាព និងប្រសិទ្ធភាព៖ | ដើម្បីដោះស្រាយបញ្ហាប្រឈមដែលរាំងស្ទះដល់ការអនុវត្ត និងរក្សាបាននូវភាពជឿនលឿនទៅមុខ។ ប្រើប្រាស់ធនធានឲ្យបានច្រើនជាអតិបរិមា ដើម្បីកសាងសមត្ថភាព ជំនាញ និងស្ថិរភាព។ |

| | |
|---|---|
| ៣. អភិក្រមប្រព័ន្ធតែមួយ៖ | ដើម្បីឲ្យមានតុល្យភាពរវាងប្រព័ន្ធមជ្ឈការ និង ដំណោះស្រាយនៅថ្នាក់មូលដ្ឋាន ដោយមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ គណនេយ្យភាព និងជំនាញរបស់ស្ថាប័ននីមួយៗ។ |
| ៤. ការធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទា៖ | ដើម្បីដោះស្រាយឫសគល់នៃបញ្ហាសំខាន់ៗ ដែលបណ្តាលឲ្យមានបទល្មើស និងភ្ជាប់ទំនាក់ទំនងរបស់អនីតិជនទំនាស់នឹងច្បាប់ទៅនឹងសង្គមស៊ីវិល កុមារដទៃទៀត និងផ្នែកសុខុមាលភាពគ្រួសារ។ |
| ៥. គណនេយ្យភាព និងការកែលម្អជាបន្តបន្ទាប់៖ | ដើម្បីពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត ក្នុងគោលបំណងធានាឲ្យមានវឌ្ឍនភាពឈានទៅរកការសម្រេចគោលដៅ និងគណនេយ្យភាពក្នុងការបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ |

## កម្មវិធីយុទ្ធសាស្ត្រសម្រាប់អនុវត្តរួមមាន៖

១. ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង

២. ការអប់រំ និងបណ្តុះបណ្តាល

៣. ភ្នាក់ងារសង្គមកិច្ច

៤. ការបង្វែរ

៥. ការធ្វើសមាហរណកម្ម

៦. ការឃុំខ្លួន

៧. ការទប់ស្កាត់បទល្មើស

៨. ក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធប្រតិបត្តិ

៩. ការពិនិត្យតាមដាន និងវាយតម្លៃ

កម្មវិធីយុទ្ធសាស្ត្រនីមួយៗ មានគោលបំណងមួយដែលភ្ជាប់ទៅនឹងលទ្ធផល និងសមិទ្ធផល។ តារាងសកម្មភាពផែនការប្រតិបត្តិ មានសកម្មភាពសម្រាប់លទ្ធផលនីមួយៗ និងការរៀបចំអភិបាលកិច្ច (ឧបសម្ព័ន្ធ២)។ សកម្មភាពត្រូវបានជ្រើសរើស និងរៀបចំដោយផ្អែកលើចំណុចអាទិភាពជាយុទ្ធសាស្ត្រចំនួន៥។ នៅក្នុងផែនការទាំងមូលមានសកម្មភាពរួមមួយចំនួន ដែលជួយឲ្យសម្រេចបាននូវចំណុចអាទិភាពជាយុទ្ធសាស្ត្រទាំងនោះ។ សកម្មភាពភាគច្រើនគ្រោងនឹងអនុវត្តនៅក្នុងឆ្នាំទី១ ដើម្បីឲ្យដំណើរការស្របគ្នាជាមួយនឹងសកម្មភាពផ្សព្វផ្សាយ។

តារាងស្ដីពីសកម្មភាពរួមទាំងនោះ ត្រូវបានបង្ហាញនៅផ្នែកខាងដើមនៃតារាងផែនការសកម្មភាពប្រតិបត្តិ។ ខាងក្រោមនេះ ជាឧទាហរណ៍មួយនៃសកម្មភាពរួម។

> ឧទាហរណ៍: សកម្មភាពរួមមួយ
>
> ការរៀបចំឲ្យមានសៀវភៅស្ដីពីសេវាសង្គមថ្នាក់មូលដ្ឋាន ដែលផ្ដល់នូវបញ្ជីសេវា ធនធាន និងកម្មវិធីនានា ក្នុងការជួយគាំទ្រដល់កុមារងាយនឹងប្រព្រឹត្តបទល្មើស កម្មវិធីបង្វែរ និងការធ្វើផែនការសមាហរណកម្ម។ បង្កើតទម្រង់បែបបទផ្សេងៗដើម្បីសម្រួលដល់ការងាររបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត។ សកម្មភាពនេះ គឺជាសកម្មភាពរួមនៅក្នុងកម្មវិធីយុទ្ធសាស្ត្រ ៤ ៥ និង៨ ។ វាជាសកម្មភាពដ៏សំខាន់មួយ ដើម្បីសម្រេចឲ្យបាននូវសមិទ្ធផលនៅក្នុងកម្មវិធីនីមួយៗ ។

## ៤.២. វិសាលភាពនៃផែនការ

ផែនការនេះគឺជាផែនការជាតិ ដែលតម្រូវឲ្យមានការចូលរួមទាំងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល។ ក្នុងពេលសិក្ខាសាលាពិគ្រោះយោបល់ អ្នកចូលរួមទាំងអស់បានទទួលស្គាល់ថា តម្រូវការឲ្យមានការផ្លាស់ប្ដូរក្នុងការអនុវត្តកន្លងមកពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជនជារឿងសំខាន់ តែមានការលំបាក។ ស្ថាប័ននាំមុខគេដែលមានការទទួលខុសត្រូវនៅក្នុងផែនការយុទ្ធសាស្ត្រ នេះមាន៖

- ស្ថាប័ន និងក្រសួងពាក់ព័ន្ធ
- អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អង្គការសាសនានានា
- ស្ថាប័នបណ្ដុះបណ្ដាល និងអប់រំ
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- អង្គការមិនមែនរដ្ឋាភិបាល
- ដៃគូអភិវឌ្ឍ

ផែនការយុទ្ធសាស្ត្រនេះអនុវត្តចំពោះកុមារដែលងាយនឹងក្លាយជាអនីតិជនទំនាស់នឹងច្បាប់រួមទាំងអនីតិជនទំនាស់នឹងច្បាប់ផងដែរ។ អនីតិជនទំនាស់នឹងច្បាប់មិនមែនស្ថិតនៅក្នុងក្រុមតែមួយទេ គឺមានបួនក្រុមផ្សេងៗគ្នា។ ក្រុមនីមួយៗ ខុសគ្នាតាមប្រភេទ អាយុ ភេទ សុខភាព ការអប់រំ ស្ថានភាពវប្បធម៌ សង្គម និងក្រុមគ្រួសាររបស់គេ។ ការអនុវត្តល្អក្នុងរឿងបង្វែរ និងការធ្វើសមាហរណកម្ម បង្កើតបានជាដំណោះស្រាយនៅថ្នាក់មូលដ្ឋានសម្រាប់អនីតិជនទំនាស់នឹងច្បាប់ម្នាក់ៗ ហើយថែមទាំងចូលរួមកាត់បន្ថយការប្រព្រឹត្តបទល្មើសជាថ្មីទៀតផង។ ក្រុមកុមារខុសៗគ្នាទាំងនេះចាំបាច់ត្រូវមានផែនការដើម្បីឆ្លើយតប ។




## ៤.៣. បញ្ហាប្រឈម

នៅក្នុងពេលពិគ្រោះយោបល់ អ្នកចូលរួមបានរកឃើញនូវបញ្ហាប្រឈមមួយចំនួន។ ដោយពិចារណាទៅលើបញ្ហាប្រឈមទាំងនេះ ការងារអាទិភាពជាយុទ្ធសាស្ត្រមួយចំនួន ត្រូវបានរៀបចំឡើងនៅក្នុងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិ។

### បញ្ហាប្រឈមរួមមាន៖

- ប្រភពធនធាន និងការចំណាយក្នុងការអនុវត្ត
- ការងារសម្របសម្រួលរវាងក្រសួងមួយទៅក្រសួងមួយ
- ការយល់ និងការទទួលយកយន្តការបង្វែររបស់សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ
- កង្វះខាតសេវាកម្មនិងទីកន្លែងអប់រំសម្រាប់អនីតិជនទំនាស់នឹងច្បាប់ អនីតិជនស្ថិតក្នុងការបង្វែរ និងអនីតិជនក្រោយពីការដោះលែង
- កង្វះមេធាវី និងថវិកាឧបត្ថម្ភមេធាវី
- កង្វះអ្នកជំនាញ និងភ្នាក់ងារសង្គមកិច្ច
- កង្វះមណ្ឌលស្តារនីតិសម្បទា ដើម្បីជាជម្រកសម្រាប់អនីតិជនដែលត្រូវជាប់ឃុំ
- ត្រូវការការបណ្តុះបណ្តាល និងការផ្លាស់ប្តូរ
- ជាន់គ្នានឹងការងារអាទិភាពផ្សេងទៀតដូចជាការងារទប់ស្កាត់បទល្មើស កុមាររងគ្រោះ និងហេដ្ឋារចនាសម្ព័ន្ធ។

ផែនការយុទ្ធសាស្ត្រមានគោលដៅដោះស្រាយបញ្ហាប្រឈមទាំងនេះតាមរយៈការបង្កើតនូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៃប្រព័ន្ធយុត្តិធម៌អនីតិជន សម្រាប់អនុវត្តប្រកបដោយចីរភាព និងប្រសិទ្ធភាព។ ខាងក្រោមនេះជាឧទាហរណ៍នៃសកម្មភាពសម្របសម្រួលដែលអាចសម្រេចគោលដៅបានច្រើន។

**ឧទាហរណ៍ស្តីពីសកម្មភាពសម្របសម្រួលដែលអាចសម្រេចគោលដៅបានច្រើន៖**

នៅពេលចាប់ផ្តើមបង្ហាញផែនការសកម្មភាពរួមនៃផែនការយុទ្ធសាស្ត្រសំខាន់ ដំបូងគឺការបង្កើតទិន្នន័យដើមគ្រាមួយដើម្បីវាស់វែងវឌ្ឍនភាពនៃការអនុវត្ត។ ផ្នែកមួយនៃទិន្នន័យដើមគ្រានោះអាចជាការប៉ាន់ប្រមាណគ្រប់ជ្រុងជ្រោយមួយទៅលើចំនួនកុមារដែលកំពុងជាប់ឃុំ។ សកម្មភាពសំខាន់ៗនៅក្នុងឆ្នាំទីមួយរួមមានដូចជាការសិក្សាស្វែងយល់ពីការងាររួមមួយ ជាមួយនឹងការបណ្តុះបណ្តាល ការវាយតម្លៃលើកុមារម្នាក់ៗដើម្បីរកឲ្យឃើញអ្នកដែលត្រូវបង្វែរ និងការបង្កើតផែនការសមាហរណកម្មសម្រាប់កុមារម្នាក់ៗ ។

## ៤.៤. ទិដ្ឋភាពទូទៅជាយុទ្ធសាស្ត្រ

តារាងខាងក្រោមនេះជ្រើសរើសផ្នែកសំខាន់ៗ ដែលបង្ហាញពីទិដ្ឋភាពទូទៅជាយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ។

| **គោលដៅនៃផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិសម្រាប់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺដើម្បីបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយដែលដំណើរការទៅដោយមានកិច្ចការពារសិទ្ធិកុមារ និងមានការធ្វើផែនការសម្រាប់កុមារនីមួយៗ។** | |
|---|---|
| គោលបំណង<br>នេះគឺជាផែនការដែលមានរយៈពេល៣ឆ្នាំហើយមានគោលបំណង ធំៗចំនួនពីរ៖<br>• **ប្រព័ន្ធយុត្តិធម៌អនីតិជន៖** កសាងមូលដ្ឋានរឹងមាំប្រកបដោយចីរភាព សម្រាប់ប្រព័ន្ធយុត្តិធម៌អនីតិជនមួយ ដែលអាចអភិវឌ្ឍ និងកែលម្អជាបន្តបន្ទាប់នៅពេលអនាគត។ | **១. អភិក្រមសិទ្ធិកុមារ៖** ដើម្បីអនុវត្តអភិក្រមសិទ្ធិកុមារ និងកសាងប្រព័ន្ធយុត្តិធម៌អនីតិជនមួយដែលផ្តល់ផលប្រយោជន៍ដល់កុមារ។<br>**២. ការអភិវឌ្ឍប្រកបដោយចីរភាព និងប្រសិទ្ធភាព៖** ដើម្បីដោះស្រាយបញ្ហាប្រឈមដែលរាំងស្ទះដល់ការអនុវត្ត និងរក្សាបាននូវភាពជឿនលឿនទៅមុខ។ ប្រើប្រាស់ធនធានឲ្យបានច្រើនជាអតិបរិមាដើម្បីកសាងសមត្ថភាព ជំនាញ និងស្មេរភាព។ |

| | |
|---|---|
| • **ការពារសិទ្ធិអនីតិជន៖** ដើម្បីទទួលបានលទ្ធផលជាវិជ្ជមានប្រកបដោយប្រសិទ្ធភាពសម្រាប់អនីតិជនទំនាស់នឹងច្បាប់បច្ចុប្បន្ន និងទៅអនាគត និងដើម្បីកាត់បន្ថយចំនួនអនីតិជននៅក្នុងពន្ធនាគារ ។ | **៣. អភិក្រមប្រព័ន្ធតែមួយ៖** ដើម្បីឲ្យមានតុល្យភាពរវាងប្រព័ន្ធមជ្ឈការ និងដំណោះស្រាយនៅថ្នាក់មូលដ្ឋាន ដោយមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ គណនេយ្យភាព និងជំនាញរបស់ស្ថាប័ននីមួយៗ។<br>**៤. ការធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទា៖** ដើម្បីដោះស្រាយឫសគល់នៃបញ្ហាសំខាន់ៗ ដែលបណ្តាលឲ្យមានបទល្មើស និងភ្ជាប់ទំនាក់ទំនងរបស់អនីតិជនទំនាស់នឹងច្បាប់ទៅនឹងសង្គមស៊ីវិល កុមារដទៃទៀត និងផ្នែកសុខុមាលភាពគ្រួសារ។<br>**៥. គណនេយ្យភាព និងការកែលម្អជាបន្តបន្ទាប់៖** ដើម្បីពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត ក្នុងគោលបំណងធានាឲ្យមានវឌ្ឍនភាពឈានទៅរកការសម្រេចគោលដៅ និងគណនេយ្យភាពក្នុងការបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ |

## កម្មវិធីយុទ្ធសាស្ត្រ៖

| | | | | |
|---|---|---|---|---|
| ១. ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង | ២. ការអប់រំ និងការបណ្តុះបណ្តាល | ៣. ភ្នាក់ងារសង្គមកិច្ច | ៤. ការបង្វែរ | ៥. ការធ្វើសមហរណកម្ម |
| ៦. ការឃុំខ្លួន | ៧. ការទប់ស្កាត់បទល្មើស | ៨. ប្រព័ន្ធប្រតិបត្តិ និងក្របខណ្ឌគោលនយោបាយ | | ៩. ការពិនិត្យតាមដាន និងការវាយតម្លៃ |

# ៥. ផែនការប្រតិបត្តិ

## ៥.១. សេចក្តីផ្តើម

នៅក្នុងផែនការប្រតិបត្តិ មានសកម្មភាពជាច្រើនតាមផ្នែកកម្មវិធីយុទ្ធសាស្រ្តនីមួយៗ។ ផែនការប្រតិបត្តិកំណត់ស្ថាប័នដឹកនាំអនុវត្តនិងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ។ ផែនការនេះមានទាំងសកម្មភាពដែលជាការទទួលខុសត្រូវរបស់ក្រុមការងារអន្តរក្រសួង និងសកម្មភាពដែលជាការទទួលខុសត្រូវរបស់ស្ថាប័ន ឬក្រសួងពាក់ព័ន្ធទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

## ៥.២. គោលការណ៍នៃវិធីសាស្រ្ត

សកម្មភាពរួមមួយចំនួន អាចត្រូវបានដាក់បញ្ចូលជាថ្មីនៅក្នុងកម្មវិធីយុទ្ធសាស្រ្តមួយចំនួន។ សកម្មភាពរួមទាំងនោះទាក់ទងនឹងការបង្កើតធនធាន ការគ្រប់គ្រងថ្នាក់ជាតិ និងគោលនយោបាយ និងធានាឲ្យមានប្រព័ន្ធមួយដ៏ត្រឹមត្រូវ បញ្ចៀសការធ្វើការងារជាន់គ្នា និងការចំណាយធនធានទ្វេដង។ សកម្មភាពទាំងនោះផ្តោតទៅលើការងារសម្របសម្រួលថ្នាក់ជាតិឲ្យមានប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហាប្រឈមនានា។ សកម្មភាពរួមភាគច្រើនត្រូវអនុវត្តនៅក្នុងរយៈពេល១២ខែដំបូងនៃផែនការ។ ក្រសួងនិងស្ថាប័នពាក់ព័ន្ធអាចចាប់ផ្តើមអនុវត្តសកម្មភាពតាមផ្នែករបស់ខ្លួន ទៅតាមសមត្ថភាពរបស់ស្ថាប័នខ្លួន ។

## ៥.៣. កម្មវិធីយុទ្ធសាស្រ្តតាមផ្នែកនីមួយៗ

### កម្មវិធីយុទ្ធសាស្រ្តតាមផ្នែកនីមួយៗសម្រាប់ការអនុវត្តក្នុងរយៈពេល៣ឆ្នាំរួមមាន៖

1. ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង
2. ការអប់រំ និងបណ្តុះបណ្តាល
3. ភ្នាក់ងារសង្គមកិច្ច
4. ការបង្វែរ
5. ការធ្វើសមាហរណកម្ម
6. ការឃុំខ្លួន
7. ការទប់ស្កាត់បទល្មើស
8. ក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធប្រតិបត្តិ
9. ការពិនិត្យតាមដាន និងវាយតម្លៃ។

តារាងសកម្មភាពលម្អិតនៃផែនការប្រតិបត្តិគឺមាននៅក្នុងឧបសម្ព័ន្ធ២។

## ផ្នែកទី១ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង

**គោលបំណងទូទៅ:** ការទំនាក់ទំនងនិងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ការអនុវត្ត ប្រកបដោយចីរភាព ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការផ្លាស់ប្តូរដោយជោគជ័យលើឥរិយាបថធ្វើការងារ បង្កើនការគាំទ្រ ដល់ផ្នែកផ្សេងៗក្នុងការអនុវត្ត ច្បាប់ស្តីពី យុត្តិធម៌អនីតិជនដោយជោគជ័យ។ ប្រើប្រាស់ក្រុមការងារអន្តរក្រសួងថ្មី និងយន្តការដែលមានស្រាប់ដើម្បីបង្កើនការទំនាក់ទំនងឲ្យមាន ប្រសិទ្ធភាពនៅគ្រប់កម្រិត ប្រើប្រាស់ធនធានដោយប្រសិទ្ធភាព បញ្ចៀសការបំពេញការងារជាន់គ្នា និងសម្របសម្រួលការអនុវត្ត ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ ។

**សមិទ្ធផលទី១៖** ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដែលមានការចូលរួមជាពិសេសពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធឯទៀត។ ក្រុមការងារនេះមានតួនាទី សម្របសម្រួលកិច្ចសហប្រតិបត្តិការ ប្រមូល និងផ្សព្វផ្សាយព័ត៌មាន ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំកម្មវិធី ។

**សមិទ្ធផលទី២៖** មានយុទ្ធសាស្ត្រក្នុងការទំនាក់ទំនង ដើម្បីគាំទ្រឲ្យមានការផ្លាស់ប្តូរទាំងផ្នត់គំនិតនិងការអនុវត្តរបស់សហគមន៍និងប្រព័ន្ធព័ត៌មានចំពោះអនីតិជនទំនាស់នឹងច្បាប់ ស្របតាមអភិក្រមសិទ្ធិកុមារ ។

**សមិទ្ធផលទី៣៖** បានពង្រឹងការផ្សព្វផ្សាយព័ត៌មាន និងការទំនាក់ទំនងផ្តល់ព័ត៌មាន ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឲ្យមានប្រសិទ្ធភាព និងរក្សាឆន្ទៈក្នុងការផ្លាស់ប្តូរការអនុវត្ត ដោយបង្កើតឲ្យមានគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម( Facebook )មួយសម្រាប់បញ្ហាកុមារ។

**សមិទ្ធផលទី៤៖** សមត្ថភាពរបស់គណៈកម្មាធិការដែលមានស្រាប់ ត្រូវបានពង្រឹងក្នុងផ្នែកយុត្តិធម៌និងផ្នែកសុខុមាលភាពកុមារ និងគ្រួសារ ដើម្បីចាត់ចែងការទទួលខុសត្រូវលើការអនុវត្តនិងសហប្រតិបត្តិការ ក្នុងគោលបំណងគាំទ្រដល់អភិក្រមប្រព័ន្ធបែបកុមារមជ្ឈមណ្ឌលឲ្យមានប្រសិទ្ធភាពសម្រាប់ការងារយុត្តិធម៌អនីតិជន ។

## ផ្នែកទី២ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការអប់រំ និងការបណ្តុះបណ្តាល

**គោលបំណងរួម៖**

ដើម្បីរៀបចំនិងប្រើប្រាស់ ធនធាន កម្មវិធីបណ្តុះបណ្តាលនិងអប់រំច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងគាំទ្រដល់ការ ផ្លាស់ប្តូគោលការណ៍និងការអនុវត្ត ការងារ និងពង្រឹងសមត្ថភាពការងាររបស់បុគ្គលិក ។

**សមិទ្ធផលទី៥៖** បានបង្កើនសមត្ថភាពរបស់បុគ្គលិកក្នុងផ្នែកយុត្តិធម៌អនីតិជន តាមរយៈការផ្តល់ការពន្យល់ជាទូទៅ និងលម្អិត តាមរយៈកម្មវិធីបណ្តុះបណ្តាល និងមេរៀនសម្រាប់ការអនុវត្ត។

**សមិទ្ធផលទី៦៖** ទទួលបានប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលស្តីពីច្បាប់យុត្តិធម៌អនីតិជននិងការអនុវត្ត ដែលប្រកបដោយចីរភាព។

## ផ្នែកទី៣ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ភ្នាក់ងារសង្គមកិច្ច

**គោលបំណងទូទៅ៖**

ដើម្បីបង្កើតភ្នាក់ងារសង្គមកិច្ចដែលឆ្លើយតបទៅនឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

**សមិទ្ធផលទី៧៖** បានបង្កើតក្រុបខណ្ឌអនុវត្តការងារ និងការចែងអំពីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច៣ប្រភេទ។

**សមិទ្ធផលទី៨៖** អនុវត្តប្រព័ន្ធផ្តល់នីតិសម្បទា ការតែងតាំង និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច ។

**សមិទ្ធផលទី៩៖** តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច ចូលរួមចំណែកជាវិជ្ជមានដល់កុមារ ដែលឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ និង ជួយដល់ការអនុវត្តអភិក្រមសិទ្ធិកុមារ។

## ផ្នែកទី៤ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការបង្វែរ

**គោលបំណងរួម៖**

ដើម្បីអនុវត្តការបង្វែរ និងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួនប្រកបដោយប្រសិទ្ធភាព និងធានាថា ការឃុំខ្លួនគឺជាជម្រើសចុងក្រោយ និងមានរយៈពេលខ្លីបំផុត។

**សមិទ្ធផលទី១០៖** អនុវត្តយន្តការយុត្តិធម៌នៅថ្នាក់សហគមន៍ដោយផ្តោតលើការបង្វែរ ដើម្បីដោះស្រាយបញ្ហាកុមារទំនាស់នឹងច្បាប់ កាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី ដោយមិនចាំបាច់បញ្ជូនទៅឃុំខ្លួន ឬត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការឡើយ ។

**សមិទ្ធផលទី១១៖** ទទួលបានប្រព័ន្ធបង្វែរ ឬការចេញសេចក្តីព្រមានរបស់នគរបាល ដែលភ្ជាប់ទំនាក់ទំនងកុមារទំនាស់នឹងច្បាប់ទៅនឹងសេវាកម្ម និងមានការគាំទ្រ។

**សមិទ្ធផលទី១២៖** ប្រើប្រាស់កិច្ចប្រជុំដោះស្រាយបញ្ហាដើម្បីប្រមូលព័ត៌មានឲ្យបានត្រឹមត្រូវ និងសម្របសម្រួលផែនការបង្វែរ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព។

## ផ្នែកទី៥ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការធ្វើសមាហរណកម្ម

**គោលបំណងរួម៖**

កម្មវិធីរៀបចំមុនពេលដោះលែង និងផែនការសមាហរណកម្ម ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព ដើម្បីធ្វើសមាហរណកម្មកុមារដែលកំពុងជាប់ឃុំទៅក្នុងសង្គមដោយជោគជ័យ ហើយអត្រាបទល្មើសជាថ្មីនឹងធ្លាក់ចុះ ។

**សមិទ្ធផលទី១៣៖** មានសេវាសង្គមកិច្ច ហើយភ្នាក់ងារសង្គមកិច្ចមានសមត្ថភាពរៀបចំផែនការ និងគ្រប់គ្រងការធ្វើសមាហរណកម្ម។

**សមិទ្ធផលទី១៤៖** មានកម្មវិធីសម្រាប់កុមារកំពុងជាប់ឃុំ ដើម្បីត្រៀមធ្វើសមាហរណកម្មឲ្យបានជោគជ័យក្រោយពេលដោះលែង។

**សមិទ្ធផលទី១៥៖** និយោជក ស្ថាប័នសាសនា និងអប់រំ គាំទ្រដល់ការបង្វែរកុមារទៅក្នុងសហគមន៍វិញ។

## ផ្នែកទី៦ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការឃុំខ្លួនកុមារ

**គោលបំណងរួម៖**

ការផ្តោតយកចិត្តទុកដាក់ក្នុងពេលឃុំខ្លួនអនីតិជន គឺសំដៅទៅលើការស្តារនីតិសម្បទាអនីតិជន និងផ្តល់ឲ្យអនីតិជននូវមុខជំនាញ ដើម្បីធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍ បន្ទាប់ពីមានការដោះលែង និងធ្វើយ៉ាងណាកុំឲ្យមានការប្រព្រឹត្តបទល្មើសសារជាថ្មី ។

**សមិទ្ធផលទី១៦៖** ចំនួនកុមារក្នុងពន្ធនាគារនាពេលបច្ចុប្បន្នត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ដោយសារវាជាបញ្ហាបន្ទាន់ដែលត្រូវដោះស្រាយដើម្បីឲ្យកុមារអាចត្រូវបានបង្វែរចេញពីកន្លែងឃុំឃាំង។

**សមិទ្ធផលទី១៧៖** កម្មវិធីការងារ និងទីកន្លែងស្នាក់នៅ រួមទាំងសម្ភារៈប្រើប្រាស់ផង ត្រូវបានវាយតម្លៃ ហើយលក្ខខណ្ឌមួយចំនួនត្រូវបានកែលម្អសម្រាប់កុមារនៅក្នុងពន្ធនាគារ។

**សមិទ្ធផលទី១៨៖** យន្តការបណ្តោះអាសន្នត្រូវបានកំណត់ដើម្បីស្នើសុំអាគារ ឬផ្នែកមួយចំនួននៃពន្ធនាគារដែលមានស្រាប់ធ្វើជាមណ្ឌលយុវនីតិសម្បទា ដើម្បីធ្វើឲ្យបញ្ញត្តិស្តីពីការស្តារនីតិសម្បទា និងការដោះលែងដោយមានលក្ខខណ្ឌអាចអនុវត្តបាន និងសម្រាប់បញ្ជៀសកុមារដែលទើបតែមកថ្មី មិនឲ្យចូលក្នុងប្រព័ន្ធពន្ធនាគារដែលមានស្រាប់។

**សមិទ្ធផលទី១៩៖** មណ្ឌលយុវនីតិសម្បទាត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីស្តារនីតិសម្បទា និងត្រៀមធ្វើសមាហរណកម្មទៅក្នុងសហគមន៍។

## ផ្នែកទី៧ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការទប់ស្កាត់បទល្មើស

**គោលបំណងរួម៖**

ដើម្បីកៀរគរ អប់រំ និងជួយសហគមន៍ឲ្យចេះកំណត់អត្តសញ្ញាណ និងកសាងប្រព័ន្ធការពារ ដើម្បីគាំទ្របុគ្គលម្នាក់ៗ និងកាត់បន្ថយការប្រព្រឹត្តបទល្មើស ។

**សមិទ្ធផលទី២០៖** បានបង្កើនសមត្ថភាពផ្នែកសុខុមាលភាពកុមារ និងផ្នែកសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណកុមារងាយនឹងប្រព្រឹត្តបទល្មើស ហើយបញ្ជូនកុមារ និងគ្រួសារទៅទទួលសេវាសមរម្យ។

**សមិទ្ធផលទី២១៖** បានពង្រឹងកម្មវិធីដែលមានស្រាប់សម្រាប់ជួយដល់គ្រួសារ និងកុមារងាយរងគ្រោះ ឲ្យយល់ដឹងពីអាកប្បកិរិយាវិជ្ជមាន និងទំនាក់ទំនងល្អ ដែលអាចជួយពួកគេមិនឲ្យប្រព្រឹត្តបទល្មើស ហើយពង្រីកកម្មវិធីជាក់លាក់ ឬក៏បង្កើតកម្មវិធីថ្មីសម្រាប់កុមារប្រសិនបើចាំបាច់។

**សមិទ្ធផលទី២២៖** បានពង្រឹងទំនាក់ទំនងរវាងសហគមន៍ និងនគរបាលតាមរយៈការបង្កើតឲ្យមានយន្តការដោះស្រាយជម្លោះនៅសហគមន៍ដោយនគរបាលនៅថ្នាក់មូលដ្ឋាន ដើម្បីកាត់បន្ថយបទល្មើសដែលប្រព្រឹត្តដោយកុមារ និងកាត់បន្ថយអត្រាប្រព្រឹត្តបទល្មើសជាថ្មី។

## ផ្នែកទី៨ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធប្រតិបត្តិ

**គោលបំណងរួម៖** ដើម្បីបង្កើតអភិក្រមប្រព័ន្ធតែមួយសម្រាប់អនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលធានាការគ្រប់គ្រងកុមារនីមួយៗឲ្យមានប្រសិទ្ធភាព ។

**សមិទ្ធផលទី២៣៖** ប្រព័ន្ធយុត្តិធម៌អនីតិជនមួយត្រូវបានបង្កើតឡើង ដែលបង្កើនការគ្រប់គ្រងកុមារម្នាក់ៗឲ្យមានប្រសិទ្ធភាពដោយប្រើប្រាស់អភិក្រមសិទ្ធិកុមារជាមូលដ្ឋាន ។

**សមិទ្ធផលទី២៤៖** មានប្រព័ន្ធគ្រប់គ្រងសំណុំរឿងឬករណីកុមារ ដែលមានប្រសិទ្ធភាពក្នុងការប្រមូលនិងផ្តល់ព័ត៌មាន ។

**សមិទ្ធផលទី២៥៖** ធានារក្សាការសម្ងាត់នៃអត្តសញ្ញាណ និងកំណត់ហេតុរបស់កុមារ។

**សមិទ្ធផលទី២៦៖** ការបង្វែររបស់សាលាដំបូង ត្រូវបានអនុវត្តតាមនីតិវិធីកុមារមេត្រី និងស្របតាមការអនុវត្តល្អរបស់ប្រទេសដទៃ ។

## ផ្នែកទី៩ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការពិនិត្យតាមដាន និងវាយតម្លៃ

**គោលបំណងទូទៅ៖** ដើម្បីរៀបចំប្រព័ន្ធប្រមូលទិន្នន័យ ពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ពីការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ និងពីបទពិសោធន៍របស់កុមារទំនាស់នឹងច្បាប់។

**សមិទ្ធផលទី២៧៖** អនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងប្រមូលនិន្នន័យដើម្បីគាំទ្រដល់ការអនុវត្តដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ។

**សមិទ្ធផលទី២៨៖** បានពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធផ្នែកប្រព័ន្ធយុត្តិធម៌អនីតិជន ក្នុងការធ្វើផែនការគ្រប់គ្រងការផ្លាស់ប្តូរ ពិនិត្យតាមដានការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្រផ្អែកលើភស្តុតាងក្នុងការសម្រេចចិត្ត ។

# ៦. ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃគឺជាផ្នែកកម្មវិធីយុទ្ធសាស្ត្រដោយឡែកមួយ (ផ្នែកកម្មវិធីយុទ្ធសាស្ត្រទី៩) នៅក្នុងផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ។ វាក៏ជាសកម្មភាពដ៏សំខាន់មួយនៅក្នុងការអនុវត្តប្រព័ន្ធថ្មីមួយដែលមានលក្ខណៈស្មុគស្មាញ និងតម្រូវឲ្យមានការផ្លាស់ប្តូរកម្រិតខ្ពស់។ មានសកម្មភាពមួយចំនួនដែលត្រូវបានគ្រោងធ្វើក្នុងគោលបំណងកសាងសមត្ថភាពពិនិត្យតាមដាន និងវាយតម្លៃឲ្យមានប្រសិទ្ធភាព ដោយធានាថាការវិភាគទិន្នន័យអាចផ្តល់ព័ត៌មានដល់អ្នកសម្រេចចិត្ត និងប៉ាន់ប្រមាណវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវគោលបំណងរបស់ផែនការ។ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនេះក៏ត្រូវការប៉ាន់ប្រមាណទៅលើការអនុវត្តនិងប្រសិទ្ធភាពរបស់វាផងដែរ។ ការបង្កើតនូវទិន្នន័យដើមគ្រាដើម្បីវាស់វែងទៅលើវឌ្ឍនភាពនៃការអនុវត្តន៍គម្រោង គឺជាសកម្មភាពសំខាន់មុនគេនៅក្នុងតារាងសកម្មភាពផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ។ តារាងពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិ មាននៅក្នុងឧបសម្ព័ន្ធ ៣ ។

ផ្នែកកម្មវិធីយុទ្ធសាស្ត្រទី៩នេះ ធ្វើឲ្យយើងដឹងថា តាមរយៈការបង្កើតប្រព័ន្ធល្អមួយសម្រាប់ប្រមូលទិន្នន័យការពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍អំពីការអនុវត្តផែនការយុទ្ធសាស្ត្រនិងអំពីបទពិសោធន៍របស់កុមារទំនាស់នឹងច្បាប់ទាំងចំណុចខ្វះខាតនិងជោគជ័យ នឹងអាចនាំឲ្យមានការសម្រេចចិត្តល្អនៅពេលខាងមុខ។ ក្រុមការងារអន្តរក្រសួង ជាអ្នកទទួលខុសត្រូវរៀបចំសម្របសម្រួលអនុវត្តគម្រោង និងធ្វើរបាយការណ៍។

ប្រព័ន្ធវាយតម្លៃអំពីវឌ្ឍនភាព នឹងអាចជួយដល់ការធ្វើអន្តរាគមន៍ ក្នុងអំឡុងពេលអនុវត្តផែនការ នៅពេលមានការរាយការណ៍អំពីចំណុចខ្វះខាត។ ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនតម្រូវឲ្យមានការផ្លាស់ប្តូរមួយដែលត្រូវពឹងផ្អែកពីផ្នែកមួយទៅផ្នែកមួយ និងមានលក្ខណៈស្មុគស្មាញ នោះទើបអាចដំណើរការទៅជាលក្ខណៈប្រព័ន្ធបាន។ ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពផ្តល់នូវយន្តការមួយដែលអាចកំណត់ឲ្យយើងដឹងពីផ្នែកនៃកម្មវិធីណាមួយដែលមិនដំណើរការ ដោយសារតែសកម្មភាពមួយចំនួនដែលមានទំនាក់ទំនងគ្នាមិនស៊ីសង្វាក់គ្នា ឬមិនសម្របសម្រួលបានល្អ។ ប្រព័ន្ធតាមដាន និងវាយតម្លៃនៃផែនការនេះ មានរបាយការណ៍ប្រចាំខែស្តីពីវឌ្ឍនភាពរយៈពេល៦ខែ និងមានការពិនិត្យវាយតម្លៃឡើងវិញ បន្ទាប់ពីបានអនុវត្តរយៈពេល ២ និង ៣ឆ្នាំមក។ យើងរំពឹងថាការពិនិត្យមើលគម្រោងឡើងវិញបន្ទាប់ពី២ឆ្នាំ នឹងបង្ហាញនៅក្នុងដំណាក់កាលទី២នៃផែនការ ។ ការវាយតម្លៃប្រកបដោយប្រសិទ្ធភាព នឹងផ្តល់នូវអភិក្រមដោយផ្អែកលើភស្តុតាងសម្រាប់ជួយដល់ការប្តេជ្ញាចិត្ត និងការបែងចែកធនធាន គោលនយោបាយ និងការសម្រេចចិត្តក្នុងការបង្កើតកម្មវិធីដោយរដ្ឋាភិបាលគ្រប់កម្រិត និងអង្គការសង្គមស៊ីវិល ។

## ក្របខណ្ឌការងាររួម មានពកម្រិត៖

១. កម្រិតទី១៖ កម្មវិធីដោយឡែកនិងសាកល្បង ដើម្បីវាយតម្លៃប្រសិទ្ធភាពនិងការអោក់អួលរបស់គម្រោង។ ការរកឃើញនឹងត្រូវបង្ហាញទុកជាមេរៀននិងបទពិសោធន៍ដ៏ល្អសម្រាប់ចែករំលែក និងសម្រាប់ធ្វើសេចក្តីសម្រេចចិត្តនាពេលអនាគត ។

២. កម្រិតទី២៖ ជាផលដែលកើតមានដល់កុមារ ដោយប្រើប្រាស់កម្រងសូចនាករជាមួយនឹងការកំណត់គោលដៅច្បាស់លាស់សម្រាប់សូចនាករនីមួយៗ។ វឌ្ឍនភាពនៅថ្នាក់ខេត្តដែលធៀបទៅនឹងគោលដៅនីយមួយៗ នឹងត្រូវបង្ហាញ ។

៣. កម្រិតទី៣៖ ជាវឌ្ឍនភាពដែលធៀបទៅនឹងសូចនាករថ្នាក់ជាតិលើគ្រប់ផ្នែកនៃប្រព័ន្ធយុត្តិធម៌អនីតិជនដោយផ្អែកតាមបទដ្ឋានអន្តរជាតិ។ វឌ្ឍនភាពធៀបទៅនឹងគោលដៅថ្នាក់ជាតិ  និងថ្នាក់ខេត្តនឹងត្រូវដាក់បង្ហាញ ។

# ៧. ការប៉ាន់ប្រមាណថវិកា

ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ តម្រូវឲ្យមានធនធានថវិកាពីបណ្តាស្ថាប័ន និងក្រសួងផ្សេងៗ។ ក្រសួង និងស្ថាប័ននីមួយៗ នឹងត្រូវប៉ាន់ប្រមាណការចំណាយលើសកម្មភាពនីមួយៗ ទៅតាមកម្រិតនៃការផ្លាស់ប្តូរក្នុងរង្វង់នៃការទទួលខុសត្រូវអនុវត្តរបស់ខ្លួន។ ដើម្បីធានាឲ្យមាននិរន្តរភាព ក្រសួងនិងស្ថាប័នពាក់ព័ន្ធនីមួយៗ ត្រូវដាក់បញ្ចូលសកម្មភាពពាក់ព័ន្ធរបស់ខ្លួននៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។ បន្ថែមលើថវិកាជាតិដែលបានដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួននេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធអាចគៀរគរថវិកាពីដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងម្ចាស់ជំនួយ។

# ឧបសម្ព័ន្ធ១

# ការវិភាគច្បាប់យុត្តិធម៌អនីតិជន
# និង
# តារាងកាតព្វកិច្ច

២០១៨ - ២០២០

# មាតិកា

## ឧបសម្ព័ន្ធ១


១. ការវិភាគច្បាប់ស្តីពីយុត្តិធម៌អនីតិជន 52

១.១. ទិដ្ឋភាពទូទៅ 52

១.២. ផលប៉ះពាល់នៃមាត្រា៨៨ 53

១.៣. កង្វះគោលការណ៍ណែនាំអំពីការផ្តន្ទាទោស និងការទទួលទោស 54

១.៤. ការកំណត់ពេលវេលាចំពោះដំណើរការរឿងក្តី 55

១.៥. ទណ្ឌកម្មចំពោះការមិនគោរពគោលការណ៍រក្សាការសម្ងាត់ 55

១.៦. ភស្តុតាងកំណត់អាយុ និងសំបុត្រកំណើត 56

១.៧. បទប្បញ្ញត្តិដែលចែងអំពីតម្រូវការកិច្ចការពារ និងថែទាំ 56

១.៨. សិទ្ធិរបស់នគរបាលដើម្បីចេញសេចក្តីព្រមាន និងបង្វែរ 57

១.៩. តារាងបែងចែកតាមដំណាក់កាល 58

# ១. ការវិភាគច្បាប់ស្ដីពីយុត្តិធម៌អនីតិជន

## ១.១. ទិដ្ឋភាពទូទៅ

ការវិភាគច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីកំណត់កាតព្វកិច្ច។ វិធីនេះវិភាគទៅលើមាត្រានីមួយៗនៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន និងបែងចែកកាតព្វកិច្ចដែលច្បាប់បានចែងនៅក្នុងមាត្រានីមួយៗ ដើម្បីឲ្យដឹងថាតើស្ថាប័នណាមានកាតព្វកិច្ចធ្វើអ្វី ហើយអ្នកណានឹងទទួលបានផលពីកាតព្វកិច្ចនោះ។ ភាគច្រើននៃអ្នកជាប់កាតព្វកិច្ចនៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន គឺជាមន្ត្រីដែលធ្វើការនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជនដែលមានដូចជាៈ នគរបាល មេធាវី ព្រះរាជអាជ្ញា ចៅក្រម ក្រឡាបញ្ជី និងបុគ្គលិកសង្គមកិច្ច។ តួនាទីថ្មីត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីយុត្តិធម៌អនិតិជន ក្នុងនោះមានភ្នាក់ងារសង្គមកិច្ច អ្នកគ្រប់គ្រងការងារបង្វែរ និងមន្ត្រីទទួលបន្ទុកយុវនីតិសម្បទា។ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ អាចមានបញ្ហាប្រឈមក្នុងការផ្លាស់ប្ដូរការអនុវត្តរបស់ខ្លួននាពេលបច្ចុប្បន្ន ដែលចាំបាច់ត្រូវបង្កើត និងតែងតាំងអ្នកជំនាញខាងយុត្តិធម៌អនីតិជន។

ឯកសារស្ដីពីការវិភាគច្បាប់ស្ដីពីយុត្តិធម៌អនីតិជននិងតារាងកាតព្វកិច្ចអនុវត្ត និងបទដ្ឋាននានា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការបកស្រាយរកអ្នកជាប់កាតព្វកិច្ចនានា។ ឯកសារនេះមាននៅក្នុងឧបសម្ព័ន្ធ ១។

ការវិភាគទៅលើច្បាប់ និងការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយនឹងស្ថាប័នពាក់ព័ន្ធ បានរកឃើញគម្លាត និងភាពមិនច្បាស់លាស់មួយចំនួនរបស់ច្បាប់នេះ ដែលទាមទាឲ្យមានឯកសារពន្យល់បន្ថែមលើចំណុចទាំងនោះ។

### ច្បាប់ស្ដីពីយុត្តិធម៌អនីតិជនរួមមានតម្រូវការដូចខាងក្រោមៈ

- មាត្រា ១០ៈ និតិវិធីនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។
- មាត្រា ៧៦ៈ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ។
- មាត្រា ៧៧ ៧៨ ៨២ ៨៣ និង៨៨ៈ មាត្រាទាំងនេះចែងពីបែបបទនិងនីតិវិធីនៃមណ្ឌលយុវនីតិសម្បទា ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ នឹងត្រូវរៀបចំសេចក្ដីព្រាងនីតិវិធី និងដំណើរការការងារទៅតាមផ្នែកនៃការទទួលខុសត្រូវរបស់ខ្លួន ។

ជាទូទៅ រាល់ច្បាប់ថ្មីទាំងអស់តម្រូវឲ្យមានការបកស្រាយ និងបើចាំបាច់ត្រូវធ្វើវិសោធនកម្មនៅពេលខាងមុខ។ ក្រសួងទាំងនេះអាចផ្តល់ការបកស្រាយលើចំណុចដែលមិនច្បាស់លាស់នៅក្នុងពេលអនុវត្ត។ កម្មវិធី និងគោលនយោបាយទាំងឡាយ ត្រូវតែគិតអំពីផលប៉ះពាល់ដល់កុមារដែលកំពុងជាប់ឃុំ និងដល់ការអនុវត្តច្បាប់នេះ។

## សិក្ខាសាលាពិគ្រោះយោបល់បានកំណត់នូវចំណុចដែលត្រូវយកចិត្តទុកដាក់ដូចខាងក្រោម៖

- មាត្រា ៨៨ និយាយពីមណ្ឌលយុវនីតិសម្បទា
- កង្វះគោលការណ៍ណែនាំអំពីការផ្តន្ទាទោស និងការទទួលទោស
- ការកំណត់ពេលវេលាសម្រាប់ដំណើរការរឿងក្តី
- ការបារម្ភអំពីការមិនគោរពគោលការណ៍រក្សាការសម្ងាត់
- ភស្តុតាងនៃការកំណត់អាយុ
- បទប្បញ្ញត្តិស្តីពីតម្រូវការនៃកិច្ចការពារនិងថែទាំ
- សិទ្ធិរបស់នគរបាលដើម្បីចេញសេចក្តីព្រមាន និងបង្វែរ

## ១.២. ផលប៉ះពាល់នៃមាត្រា៨៨

មាត្រា ៨៨៖ ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជនទំនាស់នឹងច្បាប់ ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា ។

អនុក្រិត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីរួចហើយកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។ ប៉ុន្តែ មណ្ឌលយុវនីតិសម្បទាដែលស្របតាមលក្ខខណ្ឌរបស់ច្បាប់នេះ មិនទាន់មាននៅឡើយ។

ផលវិបាកនៃការអនុវត្តមាត្រា ៨៨ គឺថា មាត្រា ៧២ និង ៧៣ នៃច្បាប់នេះដែលចែងទាក់ទិនទៅនឹងការដោះលែងដោយមានលក្ខខណ្ឌ មិនអាចអនុវត្តបានទេរហូតដល់មណ្ឌលយុវនីតិសម្បទារួចរាល់។ នេះមានន័យថា រាល់ការដោះលែងដោយមានលក្ខខណ្ឌ នេះនឹងត្រូវអនុវត្តតាមលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ។

ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិក៏តម្រូវឲ្យមានមណ្ឌលយុវនីតិសម្បទាបណ្តោះអាសន្នដែលជាសកម្មភាពអាទិភាព ដើម្បីដោះស្រាយនូវផលវិបាកដែលបណ្តាលមកពីមាត្រា ៨៨ នៃច្បាប់នេះ។ តម្រូវការនេះកំពុងត្រូវបានត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច ដែលពិចារណាក្នុងការយកមណ្ឌលកុមារកំព្រាមួយចំនួនដែលទុកចោលមកប្រើប្រាស់។ ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ផ្តល់នូវសកម្មភាពជាច្រើន ក្នុងការវាយតម្លៃ កែលម្អពន្ធនាគារបច្ចុប្បន្នឲ្យមានភាពប្រសើរឡើង និងដំណើរការរៀបចំឲ្យមានមណ្ឌលយុវនីតិសម្បទាបណ្តោះអាសន្ន ។

បច្ចុប្បន្ននេះកំពុងមានវិបត្តិដោយសារមានអ្នកទោសច្រើនលើសចំណុះ រួមទាំងកំណើនកុមារដែលបានប្រព្រឹត្តបទល្មើសផងដែរ ហើយប្រសិនបើច្បាប់ស្តីពីយុត្តិធម៌អនីតិជនចូលជាធរមាន វាជារឿងដ៏សំខាន់ដែលបទប្បញ្ញត្តិស្តីពីការបង្វែរ ត្រូវយកមកអនុវត្តឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។

កត្តាស្មុគស្មាញមួយទៀតដែលទាក់ទងនឹងគម្រោងសាងសង់មណ្ឌលយុវនីតិសម្បទាតែមួយ ដើម្បីផ្តល់សេវាឲ្យមានប្រសិទ្ធភាពដោយគ្របដណ្តប់ខេត្តចំនួន៥នោះ គឺហាក់ដូចជាផ្ទុយនឹងវិធាន៣០ នៃវិធាន Havana ដែលតម្រូវឲ្យទីកន្លែងឃុំខ្លួនកុមារគួរត្រូវបានធ្វើវិមជ្ឈការហើយស្ថិតក្នុងទំហំមួយ ដែលអាចសម្រួលឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងកុមារនិងក្រុមគ្រួសារ។ ទីកន្លែងឃុំឃាំងទ្រង់ទ្រាយតូចគួរត្រូវបានបង្កើតឡើងដោយផ្សាភ្ជាប់ទៅនឹងបរិយាកាសសង្គម សេដ្ឋកិច្ច និងវប្បធម៌របស់សហគមន៍។

គម្រោងប្រើប្រាស់បណ្តោះអាសន្ននូវមណ្ឌលយុវនីតិសម្បទាមួយចំនួនដែលបានលើកឡើងខាងលើអាចជាមូលដ្ឋាន ដើម្បីឲ្យស្របទៅនឹងវិធាននេះ។ មណ្ឌលយុវនីតិសម្បទាទាំងនោះក៏អាចផ្តល់សេវាដើម្បីធ្វើវិមជ្ឈការមណ្ឌលគឺបង្រួមមណ្ឌលឲ្យតូច និងជួយដល់ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ដែលជាគោលបំណងមួយនៃគោលការណ៍របស់ច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះផង ។

ការអនុវត្តមាត្រា៨៨ មិនមានន័យថា ពន្ធនាគារបច្ចុប្បន្នមិនគួររៀបចំឲ្យបានប្រសើរសម្រាប់កុមារនោះទេ។ ផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិមានសកម្មភាពសម្រាប់ជួយដល់ពន្ធនាគារបច្ចុប្បន្ន ឲ្យបន្តអនុវត្តបទដ្ឋានអន្តរជាតិ ដើម្បីធានាថា លក្ខខណ្ឌដែលកំពុងអនុវត្តចំពោះកុមារក្នុងទីកន្លែងឃុំឃាំងមានលក្ខណៈប្រសើរឡើង។

ផលប៉ះពាល់នៃមាត្រា ៨៨ អាចត្រូវបានកាត់បន្ថយដោយការបង្កើតអនុក្រឹត្យដែលអនុញ្ញាតឲ្យមាត្រា ៧២ និង ៧៣ ប្រតិបត្តិទៅបាន ប្រសិនបើកុមារនោះកំពុងស្ថិតនៅក្នុងពន្ធនាគារសព្វថ្ងៃ ។

## ១.៣. កង្វះគោលការណ៍ណែនាំអំពីការផ្តន្ទាទោស និងការទទួលទោស

គោលការណ៍ណែនាំស្តីពីការដាក់ទោសនិងការទទួលទោស បន្តអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត លើកលែងតែមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន (មាត្រា២) ។

### ការកែប្រែមួយចំនួនដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន រួមមាន៖

- ការដាក់ទោសត្រូវតែអនុវត្តនៅក្នុងមណ្ឌលយុវនីតិសម្បទា។ បើទោះជាមិនមានការចែងច្បាស់យ៉ាងណាក៏ដោយ ក៏គោលបំណងទាំងមូលនៃច្បាប់នេះស្នើឲ្យមានការអនុវត្តបែបនេះដែរ (សូមពិនិត្យមើល មាត្រា ៤ ត្រង់ចំណុចនិយមន័យ ១០) ។
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជន ជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន (មាត្រា ៥)។ មាត្រានេះ ចង់មានន័យថា នៅពេលមិនទាន់

មានមណ្ឌលឃុំនីតិសម្បទា កុមារនឹងត្រូវអនុវត្តទោសនៅក្នុងពន្ធនាគារ ប៉ុន្តែក៏អាចបកស្រាយថា ឲ្យមានការដាក់ទោសក្នុងរយៈពេលខ្លីជាងអ្វីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ ។

- នៅក្នុងមាត្រា ៥ដដែលក៏មានចែងដែរថា៖ «គ្រប់បុគ្គលដែល បំពេញ មុខងារណាមួយពាក់ព័ន្ធនឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍មួយចំនួនដូចជា៖ ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធនឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា»។ នៅក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ មានការខ្វែងគំនិតគ្នាថាតើមាត្រា៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បើទោះបីជាមិនបានសំដៅជាក់លាក់ទៅលើគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោស និងទទួលទោសក៏ដោយ ក៏វាសំដៅដល់លក្ខខណ្ឌដែលត្រូវអនុវត្តសម្រាប់គោលបំណងនៃមាត្រា២ ហេតុដូច្នេះហើយគួរផ្តល់ឆន្ទានុសិទ្ធិទៅឲ្យចៅក្រមដើម្បីកំណត់ទោសផ្សេងគ្នាសម្រាប់កុមារ។

## ១.៤. ការកំណត់ពេលវេលាចំពោះដំណើរការរឿងក្តី

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មិនទាន់បានកំណត់ពេលវេលាជាក់លាក់នៅឡើយទេ សម្រាប់ដំណើរការនីតិវិធី ដោយប្រើប្រាស់នូវពាក្យពេចន៍មួយចំនួនដូចជា «ឆាប់តាមតែអាចធ្វើទៅបាន» «ឲ្យបានមុនតាមតែអាចធ្វើទៅបាន» និង «ភ្លាមៗ»។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជាក៏ដូចជាប្រព័ន្ធយុត្តិធម៌អនីតិជនភាគច្រើនដែរ គឺបានផ្តល់ទំនុកចិត្តដល់មន្ត្រីអនុវត្តច្បាប់ ដូចជា នគរបាល ព្រះរាជអាជ្ញា ចៅក្រម និងភ្នាក់ងារសង្គមកិច្ច ឲ្យធ្វើការវិនិច្ឆ័យតាមលក្ខណៈវិជ្ជាជីវៈ ដោយមានការកំណត់ពេលវេលាដូចបានបញ្ជាក់ខាងលើ។ ប៉ុន្តែវាអាចមានហានិភ័យផងដែរ ដែលថាកង្វះខាតនៃការកំណត់ពេលវេលាជាក់លាក់នេះ អាចបង្កឲ្យមានការយឺតយ៉ាវនៅក្នុងដំណើរការរឿងក្តី។ សកម្មភាពមួយចំនួននៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ នឹងជួយកាត់បន្ថយហានិភ័យនេះ តាមរយៈការបង្កើត និងចងក្រងប្រព័ន្ធប្រតិបត្តិយុត្តិធម៌អនីតិជន ដែលមានបញ្ចូលការកំណត់ពេលវេលា និងប្រព័ន្ធគ្រប់គ្រងសំណុំរឿងជាមួយនិងកាលវិភាគពិនិត្យមើលសំណុំរឿង។

## ១.៥. ទណ្ឌកម្មចំពោះការមិនគោរពគោលការណ៍រក្សាការសម្ងាត់

វាមិនមានការដាក់ទណ្ឌកម្មចំពោះអ្នកដែលមិនគោរពគោលការណ៍រក្សាការសម្ងាត់ទេ លើកលែងតែទណ្ឌកម្មដែលមានចែងនៅក្នុងច្បាប់សារព័ត៌មាន (មាត្រា១៥) ដែលហាមបង្ហាញអត្តសញ្ញាណ ឬព័ត៌មានលម្អិតដែលអាចនាំឲ្យដឹងពីអត្តសញ្ញាណអនីតិជនទំនាស់នឹងច្បាប់។ ការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់អាចត្រូវបានពិចារណា នៅពេលមានវិសោធន៍កម្មច្បាប់ស្តីពីយុត្តិធម៌អនីតិជននាពេលអនាគត។ ជាដំណោះស្រាយក្នុងរយៈពេលដែលពុំទាន់មានការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ គួរមានការដាក់ពិន័យចំពោះបុគ្គលិកដែលធ្វើការងារនៅផ្នែកផ្សេងៗ ដូចជា អប់រំ សុខាភិបាល យុត្តិធម៌ អាជ្ញាធរ និងសង្គមកិច្ច ។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាកម្មជាច្រើន ក៏គួមានក្រមសីលធម៌រក្សាការសម្ងាត់ដែលត្រូវអនុវត្តដែរ។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ក៏មានការស្នើឲ្យមានយន្តការដែលត្រូវអនុវត្តដោយបុគ្គលិកក្រសួងពាក់ព័ន្ធ ទាក់ទងនឹងការរក្សាការសម្ងាត់នេះដែរ។

## ១.៦. ភស្តុតាងកំណត់អាយុ និងសំបុត្រកំណើត

ច្បាប់ស្តីពីយុត្តិធម៌អនិតិជន ផ្តល់ដំណោះស្រាយក្នុងការកំណត់អាយុអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី តុលាការ។ មាត្រា ៩ បានចែងថា «ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន។ ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ។»

តើអ្វីទៅដែលថា «មធ្យោបាយដែលអាចជឿទុកចិត្តបាន» និងថាតើនរណាខ្លះ «ជាអាជ្ញាធរមានសមត្ថកិច្ច»។ ប្រសិនបើមានការសង្ស័យពាក់ព័ន្ធនឹងអាយុកើតឡើង នៅពេលដែលកុមារស្ថិតនៅក្នុងការគ្រប់គ្រងរបស់នគរបាលយុត្តិធម៌ បញ្ហានេះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា (មាត្រា ១៤)។ ប្រសិនបើបញ្ហាអាយុនៅតែមានមន្ទិលសង្ស័យបន្ទាប់ពីការអង្កេតបឋមដោយព្រះរាជអាជ្ញា បញ្ហានេះនឹងត្រូវបញ្ជូនបន្តទៅចៅក្រមស៊ើបសួរ (មាត្រា២៥)។ មានមាត្រាជាច្រើន បង្កប់ន័យថាចៅក្រមស៊ើបសួរនឹងធ្វើការកំណត់អាយុ (មាត្រា ៣៣ ៣៩)។ មាត្រា ៤៩ មានន័យថា ចៅក្រមជំនុំជម្រះអាចស្វែករកអាយុពិត។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ អ្នកចូលរួមមួយចំនួនក៏បានពិភាក្សាដេញដោលគ្នាដែរ ថាតើអាចនឹងមានផលប៉ះពាល់ដល់អនីតិជនយ៉ាងណា ប្រសិនបើការកំណត់អាយុនេះត្រូវរង់ចាំរហូតដល់មានសេចក្តីសម្រេចពីតុលាការ ។

នៅក្នុងឆ្នាំ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលជាក្របខណ្ឌអភិវឌ្ឍន៍សាកលដ៏សំខាន់មួយ និងបានកំណត់គោលដៅមួយចំនួន ដែលរដ្ឋជាសមាជិកទាំង អស់របស់អង្គការសហប្រជាជាតិ អាចប្រើប្រាស់ដើម្បីកំណត់ការងារអាទិភាពរបស់ខ្លួនសម្រាប់ឆ្នាំ២០១៦-២០៣០។ គោលដៅមួយក្នុងចំណោមគោលដៅទាំងនោះគឺថា មនុស្សគ្រប់រូបមានអត្តសញ្ញាណស្របច្បាប់មួយ ដែលរួមមានសំបុត្រកំណើត(SDG16.9)។ បញ្ហាភស្តុតាងនៃការកំណត់អាយុនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចាំបាច់ត្រូវពិចារណាថាជារឿងសំខាន់ ព្រោះវាជួយឲ្យសម្រេចបាននូវការចុះសំបុត្រកំណើតឲ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

## ១.៧. បទប្បញ្ញត្តិដែលចែងអំពីតម្រូវការកិច្ចការពារ និងថែទាំ

នៅក្នុងមាត្រាមួយចំនួននៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងថា ប្រសិនបើកុមារចាំបាច់ត្រូវការកិច្ចការពារ និងថែទាំ កុមារទាំងនោះត្រូវបញ្ជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន (មាត្រា ១៣ ១៤ ២៧ ៣៩ ៤១ និង ៤២)។ ចំណុចនេះទទួលស្គាល់ថា ជារឿយៗដោយសារតែស្ថានភាពដ៏លំបាករបស់កុមារ ទើបបណ្តាលឲ្យកុមារប្រព្រឹត្តបទល្មើស ឬទំនាស់នឹងច្បាប់។

អនុសញ្ញាស្តីពីសិទ្ធិកុមារបញ្ជាក់ថា គ្មានកុមារណាម្នាក់ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តបានឡើយ។ ការចាប់ខ្លួន ការឃាត់ឬឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ គឺត្រូវធ្វើស្របតាមច្បាប់ និងត្រូវអនុវត្តសម្រាប់តែវិធានការចុងក្រោយ និងមានរយៈពេលខ្លីតែប៉ុណ្ណោះ (មាត្រា៣៧)។ ការឃុំខ្លួនដែលជាជម្រើសចុងក្រោយនេះត្រូវយកមកពិចារណាចំពោះកុមារដែលត្រូវបានគេដកហូតសិទ្ធិសេរីភាពដោយហេតុថា ពួកគេត្រូវការកិច្ចការពារនិងការថែទាំជាចាំបាច់។ មន្ត្រីធ្វើការផ្នែកយុត្តិធម៌អនីតិជនចាំបាច់ ត្រូវទទួលបានការបណ្តុះបណ្តាលឲ្យយល់ដឹងថាការបញ្ជូនកុមារត្រូវធ្វើឡើងដោយយកចិត្តទុកដាក់ ហើយមិនត្រូវអនុវត្តផ្សេងក្រៅពីការបង្វែរនោះទេ។

ក្រសួងសង្គមកិច្ចជាមួយនឹងផ្នែកសុខុមាលភាពភាពកុមារ និងគ្រួសារ មាននីតិវិធី គោលនយោបាយ និងកម្មវិធីសម្រាប់កុមារដែលត្រូវការកិច្ចការពារនិងថែទាំ ហើយក៏មានគម្រោងសំខាន់ៗមួយចំនួនដូចជា «ការថែទាំកុមារក្នុងគ្រួសារជាអាទិភាព» (Family Care First) ដែលធ្វើការដើម្បីកែលម្អប្រព័ន្ធថែទាំសព្វថ្ងៃ។

## ១.៩. សិទ្ធិរបស់នគរបាលដើម្បីចេញសេចក្តីព្រមាន និងបង្វែរ

មាត្រា ១៣ ផ្តល់សិទ្ធិដល់នគរបាលក្នុងការបង្វែរកុមារដែលបានប្រព្រឹត្តបទលហុ។ មាត្រានេះក៏តម្រូវឲ្យនគរបាលសរសេររបាយការណ៍ និងបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់។ ក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ មានការស្នើឲ្យមានការផ្តល់សិទ្ធិទៅមន្ត្រីនគរបាលដើម្បីដោះស្រាយបទលហុ ដោយមិនចាំបាច់បញ្ជូនទៅតុលាការឡើយ។ ពាក់ព័ន្ធចំណុចនេះ ត្រូវរៀបចំប្រព័ន្ធមួយស្តីពីការចេញសេចក្តីព្រមានសម្រាប់ឲ្យនគរបាលអនុវត្ត។ ការបញ្ជូនរបាយការណ៍ទៅកាន់ព្រះរាជអាជ្ញា អាចផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាត្រួតពិនិត្យឡើងវិញអំពីការសម្រេចរបស់នគរបាល ដើម្បីធានាអំពីភាពស្របច្បាប់។ ផ្អែកលើការអនុវត្តដ៏ល្អបំផុត មាត្រា១៣នេះ គួរតែជាដំណាក់កាលនីតិវិធីសម្រាប់ការពិនិត្យឡើងវិញ មិនមែនជាការផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាក្នុងការបដិសេធលើសេចក្តីសម្រេចចិត្តរបស់នគរបាលនោះទេ លើកលែងតែនគរបាលស្នើសុំទៅព្រះរាជអាជ្ញាឲ្យជួយពិចារណាលើសំណុំរឿងនោះ។

បញ្ហាទាក់ទងមួយទៀតគឺលិខិតថ្កោលទោស។ របាយការណ៍ដែលបញ្ជូនទៅព្រះរាជអាជ្ញា និងការចុះក្នុងបញ្ជី ព្រមានរបស់នគរបាល មិនគួរបង្កើតឲ្យទៅជាផ្នែកមួយនៃលិខិតថ្កោលទោសនោះទេ។ បញ្ជីព្រមានត្រូវរក្សាទុកដាច់ដោយឡែកពីសំណុំរឿងផ្សេងទៀត។

## ១.៩. តារាងបែងចែកតាមដំណាក់កាល

បន្ទាប់ពីតារាងខាងក្រោមនេះ (ដែលជាការបែងចែកមាត្រាទៅតាមដំណាក់កាលនីមួយៗ) គឺជាឯកសារវិភាគពេញលេញទៅលើកាតព្វកិច្ចដែលមានចែងក្នុងច្បាប់។



| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 1 | គោលបំណងរបស់ច្បាប់ | 1 | អ្នកទាំងឡាយណាដែលមានតួនាទី ឬការទទួលខុសត្រូវចំពោះ អនីតិជនប្រព្រឹត្តបទល្មើស ត្រូវគោរពសិទ្ធិនិងឧត្តមប្រយោជន៍របស់អនីតិជន។ | គ្រប់ភាគីពាក់ព័ន្ធ | សហគមន៍ និងអនីតិជនទំនាស់នឹងច្បាប់ | | | |
| | | 2 | សកម្មភាពរបស់អ្នកពាក់ព័ន្ធទាំងអស់ត្រូវគាំទ្រដល់ការស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទំនាស់នឹងច្បាប់ទៅក្នុងសហគមន៍វិញ។ | គ្រប់ភាគីពាក់ព័ន្ធ | ដូចចំណុច១ខាងលើ | | | |
| | | 3 | ច្បាប់នេះការពារផលប្រយោជន៍ដល់សង្គម។ | គ្រប់ភាគីពាក់ព័ន្ធ | ដូចចំណុច១ខាងលើ | | | |
| 2 | គោលដៅ | 1 | ច្បាប់យុត្តិធម៌អនីតិជនត្រូវអនុវត្តឲ្យបានហ្មត់ចត់ នៅពេលអនីតិជនបានប្រព្រឹត្តបទល្មើស។ | គ្រប់ភាគីពាក់ព័ន្ធ | អនីតិជនទំនាស់នឹងច្បាប់ | អនុវត្តដោយហ្មត់ចត់ | | ក្រមព្រហ្មទណ្ឌ<br>ក្រមនីតិវិធីព្រហ្មទណ្ឌ<br>ក្រមរដ្ឋប្បវេណី |
| | | 2 | ប្រសិនបើមិនមានចែងនៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន នោះក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ឬច្បាប់ផ្សេងទៀតនឹងត្រូវយកមកអនុវត្ត។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ភាគីពាក់ព័ន្ធ | ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌនឹងត្រូវយកមកបំពេញបន្ថែម នៅពេលមានចំណុចខ្វះខាតក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 3 | វិសាលភាព | 1 | ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ភាគីពាក់ព័ន្ធ | អនីតិជនទំនាស់នឹងច្បាប់ | | |
| 4 | និយមន័យ | 1 | វាក្យសព្ទសំខាន់នៅក្នុងច្បាប់នេះត្រូវបានពន្យល់។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ភាគីពាក់ព័ន្ធ | | | |
| 5 | គោលការណ៍ជាមូលដ្ឋាន | 1 | គោលការណ៍ជាមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់នេះ អនុវត្តបានគ្រប់កាលៈទេសៈ។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ភាគីពាក់ព័ន្ធ | | | |
| 6 | សិទ្ធិជាមូលដ្ឋាននៅក្នុងនីតិវិធី | 1 | សិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងមាត្រានេះ ត្រូវយកមកអនុវត្តគ្រប់កាលៈទេសៈ។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ភាគីពាក់ព័ន្ធ | | | |
| 7 | ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន | 1 | នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវកំណត់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុ ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត។ | តុលាការ និងនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | ប្រសិនបើកាលៈទេសៈនៃបទល្មើសឬបុគ្គលិកលក្ខណៈតម្រូវ | តើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនដែលតុលាការនឹងត្រូវប្រើនោះមានន័យយ៉ាងដូចម្តេច ? | ក្រមព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 8 | ការទទួលខុសត្រូវសំណងរដ្ឋប្បវេណីរបស់អនីតិជន | 1 | ច្បាប់នេះផ្តល់សំណងជំងឺចិត្តដល់ជនរងគ្រោះក្នុងកាលៈទេសៈជាក់លាក់មួយ។ | តុលាការ | អ្នកតំណាងដែលច្បាប់បានកំណត់ | | ក្នុងករណីគ្មានអ្នកតំណាង តើអ្នកណាជាអ្នកទទួលខុសត្រូវសំណង ? ហើយប្រសិនបើអ្នកតំណាងមានជីវភាពក្រីក្រ តើត្រូវដោះស្រាយសំណងយ៉ាងដូចម្តេច ? | ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ |
| 9 | ការកំណត់អាយុ | 1 | ការកំណត់អាយុកុមារដើម្បីទទួលខុសត្រូវរឿងព្រហ្មទណ្ឌ រាប់គិតចាប់ពីពេលដែលបទល្មើសបានកើតឡើង។ | មន្ត្រីនគរបាលយុត្តិធម៌ និងតុលាការ | អនីតិជនទំនាស់នឹងច្បាប់ | | | |
| | | 2 | សំបុត្រកំណើត គឺជាឯកសារផ្លូវការក្នុងការកំណត់អាយុអនីតិជន។ | គ្រប់ភាគីពាក់ព័ន្ធ | អ្នកតំណាងដែលច្បាប់កំណត់ និងអនីតិជនទំនាស់នឹងច្បាប់ | សំបុត្រកំណើតដែលមានសុពលភាព | | |
| | | 3 | ប្រសិនបើគ្មានសំបុត្រកំណើត ឬលិខិតបញ្ជាក់សំបុត្រកំណើត អាចប្រើប្រាស់ឯកសារដែលអាចជឿជាក់បានក្នុងការកំណត់អាយុអនីតិជន។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ភាគីពាក់ព័ន្ធ | ឯកសារដែលអាចជឿជាក់បានគឺជាឯកសារដែលតុលាការទទួលយកជាបានការ | តើមានឯកសារអ្វីខ្លះដែលតុលាការទទួលយកជាបានការ ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 4 | អាជ្ញាធរមានសមត្ថកិច្ចត្រូវខិតខំរកភស្តុតាងបញ្ជាក់ពីអាយុរបស់ អនីតិជនឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន។ | អាជ្ញាធរមានសមត្ថកិច្ច | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ចមន្ត្រីនគរបាលយុត្តិធម៌ព្រះរាជអាជ្ញាតុលាការ អ្នកតំណាងដែលច្បាប់បានកំណត់ | អាជ្ញាធរមានសមត្ថកិច្ចត្រូវរកភស្តុតាងអោយបានឆាប់តាមតែអាចធ្វើទៅបាន។ | តើអ្នកណាជាអាជ្ញាធមានសមត្ថកិច្ច? តើពាក្យថាឆាប់តាមតែអាចធ្វើទៅបាន មានរយៈពេលប៉ុន្មានថ្ងៃ? | មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 5 | ក្នុងករណីមានការសង្ស័យលើអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជន។ | មន្ត្រីនគរបាលយុត្តិធម៌និងតុលាការ | អនីតិជនទំនាស់នឹងច្បាប់ | ក្នុងករណីមានការសង្ស័យលើអាយុរបស់អនីតិជនវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជន | តើអ្នកណាជាអ្នកកំណត់វិមតិសង្ស័យនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ? | |
| 10 | ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច | 1 | តួនាទីរបស់ក្រសួងសង្គមកិច្ចជាអ្នកតែងតាំងនិងទទួស្គាល់ភ្នាក់ងារសង្គមកិច្ច។ | ក្រសួងសង្គមកិច្ច | ភ្នាក់ងារសង្គមកិច្ច | ការតែងតាំងត្រូវមានភាពច្បាស់លាស់ការទទួលស្គាល់និងការតាមដានវាយតម្លៃ | តើត្រូវកំណត់លក្ខណៈសម្បត្តិអ្វីខ្លះ? តើមានការ ពង្រីកការតាមដាននិងវាយតម្លៃយ៉ាងដូចម្តេច? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 11 | ភ្នាក់ងារសង្គមកិច្ច | 1 | ភ្នាក់ងារសង្គមកិច្ចនឹងជួបជាមួយអនីតិជននៅគ្រប់ដំណាក់កាលនីតិវិធី ចាប់ពីការឃាត់ខ្លួន រហូតដល់បញ្ជូនទៅពន្ធនាគារ និងផ្តល់សេវាដល់អនីតិជន។ | ភ្នាក់ងារសង្គមកិច្ច | គ្រប់ភាគីពាក់ព័ន្ធ | | តើសេវាកម្មមានគ្រប់២៤ម៉ោងដែរឬទេ ? | ផែនការយុទ្ធសាស្ត្រ របស់ក្រសួងសង្គមកិច្ច និងបទដ្ឋានអប្បរមារបស់ក្រសួងនេះ |
| | | 2 | ភ្នាក់ងារសង្គមកិច្ចនឹងប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយាប្រវត្តិអប់រំការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព៌តមានពាក់ព័ន្ធផ្សេងទៀត ដើម្បីរៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រមព្រះរាអាជ្ញា និងតុលាការ។ | ភ្នាក់ងារសង្គមកិច្ច | គ្រប់ភាគីពាក់ព័ន្ធ | រៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម ព្រះរាជអាជ្ញានិងតុលាការ | តើមានទម្រង់សរសេររបាយការណ៍នេះហើយឬនៅ ហើយថាតើមានភ្នាក់ងារសង្គមកិច្ចដែលមានជំនាញច្បាស់លាស់លើការងារនេះហើយឬនៅ ? | ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច និងបទដ្ឋានអប្បរមារបស់ក្រសួងនេះ |
| | | 3 | ភ្នាក់ងារសង្គមកិច្ចនឹងផ្តល់ការគាំទ្រខាងផ្លូវចិត្តដល់កុមារនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។ | ភ្នាក់ងារសង្គមកិច្ច | គ្រប់ភាគីពាក់ព័ន្ធ | ផ្តល់ការគាំទ្រខាងផ្លូវចិត្តដល់កុមារនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ | ភ្នាក់ងារសង្គមកិច្ចតម្រូវអោយមានជំនាញច្បាស់លាស់តាមដំណាក់កាលនីមួយៗ | ផែនការយុទ្ធសាស្ត្រ របស់ក្រសួងសង្គមកិច្ច និងបទដ្ឋានអប្បរមារបស់ក្រសួងនេះ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 4 | ភ្នាក់ងារសង្គមកិច្ចនឹងរៀបចំនិងផ្តល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីពិនិត្យនិងសម្រេច។ | ភ្នាក់ងារសង្គមកិច្ច | គ្រប់ភាគីពាក់ព័ន្ធ | ភ្នាក់ងារសង្គមកិច្ចនឹងរៀបចំផែនការបង្វែរ | ការរៀបចំផែនការបង្វែរដែលអាចទទួលជោគជ័យបាន តម្រូវឲ្យមានជំនាញច្បាស់លាស់ | ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច និងបទដ្ឋានអប្បបរមារបស់ក្រសួងនេះ |
| | | 5 | ភ្នាក់ងារសង្គមកិច្ចនឹងផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន។ | ភ្នាក់ងារសង្គមកិច្ច | គ្រប់ភាគីពាក់ព័ន្ធ | | ភ្នាក់ងារសង្គមកិច្ចត្រូវមានជំនាញច្បាស់លាស់ | |
| 12 | សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងកាពិនិត្យបទឧក្រិដ្ឋនិងបទមជ្ឈឹម | 1 | មន្ត្រីនគរបាយុត្តិធម៌ដែលមានជំនាញខាងកុមារ មានអំណាចក្នុងការពិនិត្យបទល្មើសឃាត់ខ្លួនអនីតិជន និងប្រមូលភស្តុតាង។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់ | មន្ត្រីនគរបាលយុត្តិធម៌ដែលមាននីតិសម្បទា | តើសមត្ថភាពអ្វីខ្លះដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវមាន ដើម្បីក្លាយខ្លួនជាមន្ត្រីជំនាញខាងកុមារ ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 2 | នគរបាលដែលចាប់ និងឃាត់ខ្លួនអនីតិជនត្រូវបញ្ជូនអនីតិជនបន្តទៅមន្ត្រីនគរបាលយុត្តិធម៌ដែលមានជំនាញខាងអនីតិជន។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់ | មន្ត្រីនគរបាលយុត្តិធម៌ដែលមាននីតិសម្បទា | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | នគរបាលដែលចាប់ និងឃាត់ខ្លួនអនីតិជនត្រូវដាក់របាយការណ៍ចាប់ខ្លួន និងចុះក្នុងកំណត់ហេតុ នៅពេលដែលអនីតិជនត្រូវបញ្ជូនទៅមន្ត្រីនគរបាលយុត្តិធម៌។ | នគរបាលទាំងអស់ | កុមារទំនាស់នឹងច្បាប់ មន្ត្រីនគបាលយុត្តិធម៌ | ត្រូវសរសេររបាយការណ៍ស្ដីពីការចាប់ខ្លួន | តើព័ត៌មានអ្វីខ្លះដែលត្រូវដាក់ក្នុងរបាយការណ៍? | |
| 13 | អំណាចរបស់ មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យនិងដោះស្រាយបទល្មើសលហុ | 1 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវផ្ដល់ការណែនាំ និងចេញសេចក្ដីព្រមានជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ដល់អនីតិជនដែលបានប្រព្រឹត្តបទលហុ ហើយត្រូវបញ្ជូនអនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ និងអ្នកតំណាងដែលច្បាប់ចាត់តាំង | ត្រូវផ្ដល់ការព្រមាន និងណែនាំ។ ត្រូវបញ្ជូនអនីតិជនឲ្យបានឆាប់ទៅអ្នកតំណាងរបស់ពួកគេ | តើគួរមានការណែនាំអ្វីខ្លះ? តើគួរមានការព្រមានអ្វីខ្លះ? | អនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| | | 2 | មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការសម្របសម្រួល រវាងគូភាគីដើម្បីដោះស្រាយបទល្មើសតូចតាច ប្រសិនបើអនីតិជនសារភាពថាបានប្រព្រឹត្តបទល្មើស។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងភាគីជនរងគ្រោះ | | តើស្ថិតក្នុងកាលៈទេសៈណា ដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការសម្របសម្រួល? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវចាប់ផ្តើមពិនិត្យសំណុំរឿង ប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស សរសេររបាយការណ៍ និងបញ្ជូនរបាយការណ៍ទៅព្រះរាជអាជ្ញា។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់ចាត់តាំង និងអាជ្ញាធរដែលត្រូវបង្វែរ | | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 4 | ព្រះរាជអាជ្ញានឹងពិចារណា ប្រសិនបើរឿងក្តីនឹងបន្ត។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់ចាត់តាំង | | | |
| | | 5 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅការិយាល័យសង្គមកិច្ច ប្រសិនបើអនីតិជននោះត្រូវការកិច្ចការពារ និងថែទាំ។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា កុមារទំនាស់នឹងច្បាប់ និងអ្នកតំណាងដែលច្បាប់ចាត់តាំង | | តើកត្តាអ្វីខ្លះដែលត្រូវយកមកពិចារណា ដើម្បីវាយតម្លៃ ប្រសិនបើកុមារត្រូវការកិច្ចការពារនិងថែទាំ ? | ក្រមនីតិវិធីព្រហ្មទណ្ឌនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 6 | មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវចាត់វិធានការនានា ប្រសិនបើកុមារត្រូវការកិច្ចការពារ និងថែទាំ។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 7 | មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវវាយតម្លៃអនីតិជនដែលគេបញ្ជូនមក និងប្រាកដថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ហើយត្រូវដាក់របាយការណ៍ទៅព្រះរាអាជ្ញា។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ និងមន្ត្រីនគរបាលយុត្តិធម៌ | | តើមានទម្រង់វាយតម្លៃ និងទម្រង់របាយការណ៍សម្រាប់ប្រើប្រាស់ហើយឬនៅ? | |
| | | 8 | ប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវស្នើទៅតុលាការ ដើម្បីព្យួរ ឬដកហូតអ្នកតំណាងដែលច្បាប់កំណត់ អំណាចមេបា ឬ អ្នកអាណាព្យាបាល។ | មន្ទីរ/ការិយាល័យសង្គមកិច្ច និងតុលាការ | ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ | | | |
| | | 9 | ប្រសិនបើអនីតិជនមិនមានអ្នកតំណាងដែលច្បាប់កំណត់ទេ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវស្នើទៅតុលាការ ដើម្បីសម្រេចពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ | មន្ទីរ/ការិយាល័យសង្គមកិច្ច តុលាការ | មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងអនីតិជនទំនាស់នឹងច្បាប់ | | | ក្រមព្រហ្មទណ្ឌ អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 14 | នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ ឆ្នាំ | 1 | អនីតិជនអាយុក្រោម ១៤ ឆ្នាំ ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសមិនត្រូវបានឃុំខ្លួនឡើយ ហើយត្រូវបញ្ជូនទៅអ្នកតំណាងដែលច្បាប់កំណត់។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់អ្នកតំណាងដែលច្បាប់កំណត់ | | តើត្រូវធ្វើដូចម្តេចបើនៅទីនោះមិនមានអ្នកតំណាងដែលច្បាប់បានកំណត់? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវចាប់ផ្តើមដោះស្រាយភ្លាម ប្រសិនបើអនីតិជនមានអាយុក្រោម១៤ឆ្នាំដែលបានប្រព្រឹត្តបទល្មើសហើយផ្ញើកំណត់ហេតុទៅព្រះរាជអាជ្ញា។ | មន្ត្រីនគរបាលយុត្តិធម៌ | ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់អ្នកតំណាងដែលច្បាប់កំណត់ | | តើព័ត៌មានលម្អិតអ្វីខ្លះដែលត្រូវដាក់ក្នុងកំណត់ហេតុ ហើយថាតើគេអាចចូលមើលកំណត់ហេតុនេះបានដែរឬទេ ? | |
| | | 3 | ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅកាន់មន្ទីរ/ការិយាល័យសង្គមកិច្ច ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ហើយមន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវធ្វើរបាយការណ៍ទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា។ | មន្ត្រីនគរបាលយុត្តិធម៌មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ព្រះរាជអាជ្ញា | នៅពេលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ | តើមានកត្តាអ្វីខ្លះដែលតម្រូវឲ្យធ្វើការប៉ាន់ប្រមាណដើម្បីដឹងថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ? | ក្រមនីតិវិធីព្រហ្មទណ្ឌនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 4 | មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវធ្វើការប៉ាន់ប្រមាណលើអនីតិជនដែលគេបញ្ជូនមកដើម្បីកំណត់ឲ្យច្បាស់ថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ហើយត្រូវដាក់របាយការណ៍នៃការប៉ាន់ប្រមាណនេះទៅព្រះរាអាជ្ញា។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ព្រះរាជអាជ្ញា | | តើមានទម្រង់វាយតម្លៃ និងទម្រង់របាយការណ៍សម្រាប់ប្រើប្រាស់ហើយឬនៅ ? | |
| | | 5 | ប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវស្នើទៅតុលាការដើម្បីព្យួរ ឬដកហូតអំណាចមេបា ឬអ្នកតំណាងដែលច្បាប់កំណត់ ឬអ្នកអាណាព្យាបាល។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់កំណត់ | នៅពេលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ | | ក្រមនីតិវិធីព្រហ្មទណ្ឌនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 6 | ប្រសិនបើអនីតិជនពុំមានអ្នកតំណាងដែលច្បាប់កំណត់ទេ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវស្នើទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់កំណត់ | នៅពេលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 7 | ប្រសិនបើអនីតិជនដែលប្រព្រឹត្តបទល្មើសមានអាយុក្រោម ១៤ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំនុំរឿងទៅព្រះរាជអាជ្ញា។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាសនឹងច្បាប់ នគរបាល | | តើកំណត់ហេតុស្តីពីអនីតិជនអាយុក្រោម១៤ឆ្នាំប្រព្រឹត្តបទល្មើស នឹងត្រូវប្រើប្រាស់យ៉ាងដូចម្តេចទៅថ្ងៃអនាគត ? | |
| | | 8 | ប្រសិនបើមានការសង្ស័យលើអាយុរបស់អនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនរឿងទៅព្រះរាជអាជ្ញា។ | មន្ត្រីនគរបាលយុត្តិធម៌ | នគរបាល | បញ្ជូនសំណុំរឿងភ្លាមទៅព្រះរាជអាជ្ញា | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| 15 | ការចាប់ខ្លួន | 1 | នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំដល់ក្រោម ១៨ឆ្នាំបាន ប្រសិនបើអនីតិជនប្រព្រឹត្តិបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែង។ | នគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | នគរបាលយុត្តិធម៌ត្រូវតែរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 2 | នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនអាយុ១៤ឆ្នាំដល់ក្រោម១៦ឆ្នាំបាន ប្រសិនបើអនីតិជនប្រព្រឹត្តិបទមជ្ឈិមដោយចេតនាតែប៉ុណ្ណោះ។ | នគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | នគរបាលយុត្តិធម៌ត្រូវតែរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា | តើត្រូវកំណត់ចេតនារបស់អនីតិជនដោយរបៀបណា ? | ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | នៅពេលចាប់ខ្លួនអនីតិជន នគរបាលយុត្តិធម៌ត្រូវជៀសវាងការធ្វើឲ្យអាម៉ាស់មុខ និងបាត់បង់សេចក្ដីថ្លៃថ្នូរបស់អនីតិជន។ | នគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 4 | នៅពេលអនីតិជនត្រូវបានចាប់ខ្លួន ពួកគេត្រូវបានបញ្ជូនទៅផ្នែក ឬអង្គភាពនៅជិតបំផុត ដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន។ | នគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | | តើមានអង្គភាពនគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនហើយឬនៅ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 16 | ការឆែកឆេរលើខ្លួនបុគ្គល | 1 | មន្ត្រីនគរបាលអាចឆែកឆេរលើខ្លួនអនីតិជនបាន ដោយធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនជាប់ទាក់ទងនឹងបទល្មើសពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និតជាមួយអនីតិជននោះលើកលែងតែក្នុងករណីមិនអាចជៀសវាងបាន។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ច ឪពុក ម្ដាយ ឬអាណាព្យាបាល | ការឆែកឆេរលើខ្លួនអនីតិជនធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនជាប់ទាក់ទងនឹងបទល្មើសពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និតជាមួយអនីតិជននោះលើកលែងតែក្នុងករណីមិនអាចជៀសវាងបាន | តើមានលក្ខខណ្ឌអ្វីខ្លះដែលអាចចាត់ចូលក្នុងករណីមិនអាចជៀសវាងបាន? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសអំពីលក្ខខណ្ឌដែលចាត់ចូលក្នុងករណីមិនអាចជៀសវាងបាន។ | មន្ត្រីនគរបាលយុត្តិធម៌ | មន្ត្រីនគរបាលយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ចឪពុកម្ដាយ ឬអាណាព្យាបាល | ចុះនិទ្ទេសអំពីលក្ខខណ្ឌដែលចាត់ចូលក្នុងករណីមិនអាចជៀសវាងបាន | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 17 | ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស | 1 | មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី១៤ឆ្នាំដល់ក្រោម១៨ឆ្នាំ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថា អនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការការពារសុវត្ថិភាពអនីតិជននោះ។ ប៉ុន្តែការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ចឪពុក ម្ដាយ ឬអាណាព្យាបាល | ការឃាត់ខ្លួននេះសម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ | តើមានកត្តាអ្វីខ្លះដែលកំណត់ដឹងថាការឃាត់ខ្លួននេះជាជម្រើសចុងក្រោយ ? | ក្រមនីតិវិធីព្រហ្មទណ្ឌនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 2 | នគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី១៤ឆ្នាំដល់ក្រោម១៦ឆ្នាំ តែក្នុងករណីអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនាប៉ុណ្ណោះ។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ចឪពុកម្ដាយ ឬអាណាព្យាបាលសាក្សី និងជនរងគ្រោះ | | | |
| | | 3 | ការឃាត់ខ្លួនអនីតិជនត្រូវតែរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។ | មន្ត្រីនគរបាលយុត្តិធម៌ | ព្រះរាជអាជ្ញា | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 4 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុត ប្រសិនបើអនីតិជននៅក្នុងការឃាត់ខ្លួន។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ច ឪពុកម្តាយ ឬអាណាព្យាបាល | ពន្លឿនដំណើរការស៊ើបអង្កេតតាមដែលអាចធ្វើទៅបាន | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 18 | ការជូនដំណឹងបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជន | 1 | នគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជនអំពីមូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ និងសិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ច ឪពុកម្តាយ ឬអាណាព្យាបាល | ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជន | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 2 | ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់មិនអាចទាក់ទងបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយនគរបាលយុត្តិធម៌ ដែលមានការយល់ព្រមពីអនីតិជន។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | ប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុង | តើការខិតខំប្រឹងប្រែងក្នុងកម្រិតណាដើម្បីធ្វើការទាក់ទងទៅអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ?តើត្រូវធ្វើយ៉ាងដូចម្តេចប្រសិនបើអនីតិជនមិនសហការ ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងភ្លាមផងដែរទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជនត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គម។ | មន្ត្រីនគរបាលយុត្តិធម៌ | ភ្នាក់ងារសង្គមកិច្ច | ជូនដំណឹងទៅភ្នាក់ងារសង្គមកិច្ចភ្លាម ដើម្បីទទួលបានការគាំទ្រផ្លូវចិត្ត និងសង្គម | តើសេវាគាំទ្រផ្លូវចិត្ត និងសង្គមរបស់ភ្នាក់ងារសង្គមកិច្ចអាចឆ្លើយតបទាន់ពេលវេលាដែរឬទេ ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 4 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជនប្រសិនបើមាន។ ហើយប្រសិនបើគ្មាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ | មន្ត្រីនគរបាលយុត្តិធម៌ | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន | លទ្ធភាពទទួលបានមេធាវីដោយមិនយកកម្រៃ | លក្ខន្តិកៈគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| | | 5 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវផ្តល់បញ្ជីឈ្មោះមេធាវីឲ្យអនីតិជន ដើម្បីធ្វើការជ្រើសរើស។ | នគរបាលយុត្តិធម៌ | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ត្រូវផ្តល់បញ្ជីឈ្មោះមេធាវីឲ្យអនីតិជនដើម្បីធ្វើការជ្រើសរើស | តើមានបញ្ជីឈ្មោះមេធាវីមិនយកកម្រៃហើយឬនៅ ហើយតើព័ត៌មានអ្វីខ្លះដែលត្រូវផ្តល់ឲ្យអនីតិជនដើម្បីជួយដល់ការជ្រើសរើសរបស់គាត់ ? | លក្ខន្តិកៈគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 6 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីអនីតិជនពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់សង្គមកិច្ច ឪពុកម្ដាយ ឬអាណាព្យាបាល | | តើមានអ្នកបកប្រែមិនយកកម្រៃដែរឬទេ ? ប្រសិនបើគ្មាន អ្នកណាជាអ្នកចេញថ្លៃបកប្រែ ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| | | 7 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹងឬការព្យាយាមជូនដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច និងស្វែងរកមេធាវីនិងអ្នកទំនុកបម្រុង ទោះបីជាការជូនដំណឹង ឬការព្យាយាមជូនដំណឹងនោះមិនបានទទួលលទ្ធផលក្តី។ | មន្ត្រីនគរបាលយុត្តិធម៌ | | | | |
| 19 | ការពិនិត្យសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្ត | 1 | នគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនដែលមានបញ្ហាសុខភាព ឬរងរបួសទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត។ | នគរបាលយុត្តិធម៌ | មណ្ឌលសុខភាព និងមន្ទីរពេទ្យ | បញ្ជូនអនីតិជនដែលមានបញ្ហាសុខភាព ឬរងរបួសទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត | តើសេវាកម្ម និងគុណភាពនៃការព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុតអាចឆ្លើយតបទៅតម្រូវការជាក់ស្ដែងដែរឬទេ ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
| --- | --- | --- | --- | --- | --- | --- | --- | --- |
| | | 2 | ការចំណាយលើការព្យាបាលជាបន្ទុករបស់រដ្ឋ ប្រសិនបើឪពុកម្ដាយរបស់អនីតិជនគ្មានលទ្ធភាព។ | រដ្ឋ | អ្នកតំណាងដែលច្បាប់បានកំណត់ ក្រសួងសង្គមកិច្ច អ្នកផ្ដល់សេវាសុខាភិបាល | ការព្យាបាលជាបន្ទុករបស់រដ្ឋ ប្រសិនបើឪពុកម្ដាយរបស់អនីតិជនគ្មានលទ្ធភាព | តើភាពដែលអាចទទួលបានការចំណាយពីរដ្ឋអាចត្រូវបានទទួលដោយរបៀបណា ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| | | 3 | របាយការណ៍ ឬកំណត់ហេតុនៃការពិនិត្យសុខភាពត្រូវបញ្ចូលទៅក្នុងសំណុំរឿងអនីតិជន។ | នគរបាលយុត្តិធម៌ | អ្នកផ្ដល់សេវាសុខាភិបាល | | ត្រូវកំណត់ឲ្យបានច្បាស់ពីអ្វីដែលត្រូវដាក់ចូលក្នុងរបាយការណ៍ពិនិត្យសុខភាព | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| 20 | កំណត់ហេតុនៃការចាប់ខ្លួន ឬ ឃាត់ខ្លួនអនីតិជន | 1 | ច្បាប់ចម្លងនៃកំណត់ហេតុស្ដីពីការចាប់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនត្រូវផ្ដល់ឲ្យមេធាវីតាមការស្នើសុំ។ | នគរបាលយុត្តិធម៌ | កុមារទំនាស់នឹងច្បាប់ និងមេធាវី | | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| | | 2 | នៅតាមអង្គភាពនគរបាលយុត្តិធម៌នីមួយៗត្រូវមានបញ្ជីដោយឡែកស្ដីពីការឃាត់ខ្លួនអនីតិជន។ | នគរបាលយុត្តិធម៌ | នគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា | ត្រូវមានបញ្ជីដោយឡែកស្ដីពីការឃាត់ខ្លួនអនីតិជន | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 21 | នីតិវិធីមុនការស្តាប់ចម្លើយ | 1 | ប្រសិនបើមានការស្នើសុំ នគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យអនីតិជនជួបជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវីជាលក្ខណៈឯកជននិងជាសម្ងាត់រយៈពេល៣០នាទី មុនពេលស្តាប់ចម្លើយ។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច មេធាវី និង អនីតិជនទំនាស់នឹងច្បាប់ | ត្រូវមានការស្នើសុំ។ ការជួបត្រូវធ្វើឡើងជាលក្ខណៈឯកជន និងសម្ងាត់។ អ្នកដែលជាប់ទាក់ទងនឹងបទល្មើស មិនអនុញ្ញាតឲ្យចូលជួបបានទេ។ | | ក្រមនីតិវិធីព្រហ្មទណ្ឌ (មាត្រា ៩៨) |
| 22 | ការស្តាប់ចម្លើយ | 1 | មុនពេលស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋាន ( មើលទៅមាត្រា ៦ )ជាពិសេសសិទ្ធិមិន ផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច មេធាវី និង អនីតិជនទំនាស់នឹងច្បាប់ | ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋាន (មើលទៅមាត្រា ៦) ជាពិសេសសិទ្ធិមិនឆ្លើយ នៅពេលគ្មានឬមានវត្តមានមេធាវី | តើធ្វើយ៉ាងណាដើម្បីធានាថាអនីតិជនយល់អំពីសិទ្ធិទាំងនោះ? | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 2 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមានវត្តមានមេធាវីរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចចូលរួមក្នុងការស្តាប់ចម្លើយ និងផ្តល់ការគាំទ្រ។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច មេធាវី និងកុមារទំនាស់នឹងច្បាប់ | ការស្តាប់ចម្លើយត្រូវធ្វើឡើងជាលក្ខណៈឯកជនជាសម្ងាត់ និងតាមបែបនីតិវិធីកុមារមេត្រី | | អនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | មន្ត្រីនគរបាលយុត្តិធម៌អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមក្នុងការស្ដាប់ចម្លើយ ប្រសិនបើវត្តមានរបស់ពួកគាត់ផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច មេធាវី និងកុមារទំនាស់នឹងច្បាប់ | ការមិនអនុញ្ញាតត្រូវតែមានការពិគ្រោះយោបល់ជាមួយមេធាវីរបស់អនីតិជន ឬមន្ត្រីសង្គមកិច្ច និងអនីតិជន | | |
| | | 4 | ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់មិនអាចចូលរួម ត្រូវអនុញ្ញាតឲ្យអ្នកទំនុកបម្រុងរបស់អនីតិជនចូលរួមជំនួសប្រសិនបើមាន។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច មេធាវី និងកុមារទំនាស់នឹងច្បាប់ | មើលទៅមាត្រា១៨ (ការជ្រើសរើសដោយអនីតិជន ឬការជ្រើសរើសដោយនគរបាលយុត្តិធម៌ដោយមានការយល់ព្រមពីអនីតិជន) | | |
| | | 5 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់អំពីមូលហេតុនៃអវត្តមានរបស់មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ហើយបញ្ចូលកំណត់ហេតុនោះក្នុងសំណុំរឿង។ | មន្ត្រីនគរបាលយុត្តិធម៌ | មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង | ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ ដោយបញ្ជាក់អំពីមូលហេតុនៃអវត្តមានរបស់អ្នកដែលត្រូវចូលរួម | | ក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 6 | មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យអនីតិជនអានកំណត់ហេតុនៃការស្តាប់ចម្លើយ បន្ទាប់ពីការស្តាប់ចម្លើយត្រូវបានបញ្ចប់។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | អានភ្លាមៗបន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 7 | ប្រសិនបើអនីតិជនមិនអាចអានកំណត់ហេតុនៃការស្តាប់ចម្លើយបាន មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអានកំណត់ហេតុនៃការស្តាប់ចម្លើយនេះជូនអនីតិជនស្តាប់។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកបកប្រែ និងអនីតិជនទំនាស់នឹងច្បាប់ | | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 8 | បន្ទាប់ពីអនីតិជនបានអានកំណត់ហេតុស្តាប់ចម្លើយរួច មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬ ភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយនេះ។ | មន្ត្រីនគរបាលយុត្តិធម៌ | អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច មេធាវី និង អនីតិជនទំនាស់នឹងច្បាប់ | អនុញ្ញាតឲ្យមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬ ភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 9 | អនីតិជនអាចកែប្រែ និងបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន។ | មន្ត្រីនគរបាលយុត្តិធម៌ | ដូចចំណុច ៨ខាងលើ | អាចកែប្រែ និងបន្ថែមបន្ថយចម្លើយមុនពេលចុះហត្ថលេខា ឬផ្ដិតស្រាមដៃ | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 10 | អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុស្តាប់ចម្លើយ។ | មន្ត្រីនគរបាលយុត្តិធម៌ | ដូចចំណុច ៨ខាងលើ | ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុស្តាប់ចម្លើយ | | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 11 | ប្រសិនបើអ្នកចូលរួមណាមួយបដិសេធមិនចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសអំពីការបដិសេធនេះនៅលើកំណត់ហេតុ។ | មន្ត្រីនគរបាលយុត្តិធម៌ | ដូចចំណុច៨ខាងលើ | ត្រូវចុះនិទ្ទេសអំពីការបដិសេធនៃការចុះហត្ថលេខា ឬផ្តិតម្រាមដៃក្នុងកំណត់ហេតុ | | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 12 | វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។ | មន្ត្រីនគរបាលយុត្តិធម៌ | ដូចចំណុច៨ខាងលើ | វិធានដែលបានបញ្ញត្តពីចំណុច ១ដល់១១ត្រូវគោរពតាមដាច់ខាតបើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី | តើមានអ្វីកើតឡើងប្រសិន បើនីតិវិធីនៃការស្តាប់ចម្លើយត្រូវបានមោឃភាព ? | |
| 23 | ការប្រព្រឹត្តលើអនីតិជនដែលត្រូវបានឃាត់ខ្លួន | 1 | មន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តល់ព័ត៌មានអំពីអនីតិជនដល់អ្នកសារព័ត៌មានឡើយ។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ចអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី | មិនអាចផ្តល់ព័ត៌មានអំពីអនីតិជនដល់អ្នកសារព័ត៌មាន | តើមានរឿងអ្វីកើតឡើងប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌បានធ្វើយ៉ាងដូច្នេះ ? | អនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាផ្លូវឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជន ការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង។ ក្នុងករណីអនីតិជនយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃ។ | មន្ត្រីនគរបាលយុត្តិធម៌ | ដូចចំណុច១ខាងលើ | ការយល់ព្រមអាចធ្វើទៅបានបន្ទាប់ពីមានការពិគ្រោះយោបល់។ ការយល់ព្រមត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃ។ | ប្រសិនបើមានការយល់ព្រម តើនឹងមានផលវិបាកអ្វីខ្លះកើតឡើងដល់អនីតិជន ? | |
| | | 3 | ការឃុំខ្លួនអនីតិជនត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងបែងចែកទៅតាមភេទ។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | ដាក់ដាច់ដោយឡែកពីនីតិជន និងបែងចែកទៅតាមភេទ | តើគួរមានវិធានការបែបណាបើពុំមានការបែងចែងបែបនេះដោយសារតែស្ថានភាពពិបាក ? | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 4 | អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ។ | មន្ត្រីនគរបាលយុត្តិធម៌ | អនីតិជនទំនាស់នឹងច្បាប់ | | | អនុសញ្ញាស្តីពីសិទ្ធិកុមារ និងក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 5 | វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។ | មន្ត្រីនគរបាលយុត្តិធម៌ | ដូចចំណុច១ខាងលើ | វិធានដែលបានបញ្ញត្តពីចំណុច១ដល់៤ត្រូវគោរពតាមដាច់ខាត បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី | | |
| 24 | សមត្ថកិច្ចរបស់អង្គការអយ្យការ | 1 | បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ សហគមន៍ ជនរងគ្រោះ | | តើអ្វីទៅជាផលប្រយោជន៍ទូទៅ ? | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 2 | ព្រះរាជអាជ្ញាដែលទទួលបន្ទុករឿងក្តីអនីតិជន ត្រូវមានជំនាញ និងទទួលបានការបណ្តុះបណ្តាល អំពីសិទ្ធិកុមារ ច្បាប់និងបញ្ញត្តផ្សេងទៀត ដែលពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន។ | ព្រះរាជអាជ្ញា | កុមារទំនាស់នឹងច្បាប់ | ព្រះរាជអាជ្ញាដែលមានជំនាញខាងកុមារ | តើត្រូវមានសមត្ថភាពអ្វីខ្លះ ដើម្បីក្លាយខ្លួនជាព្រះរាជអាជ្ញាឯកទេសខាងកុមារ ? | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 25 | ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន | 1 | ព្រះរាជអាជ្ញាត្រូវផ្ទៀងផ្ទាត់អាយុរបស់អនីតិជនបន្ទាប់ពីទទួលរឿងក្តីពីមន្ត្រីនគរបាលយុត្តិធម៌។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ | ផ្ទៀងផ្ទាត់អាយុរបស់អនីតិជន | | ក្រមព្រហ្មទណ្ឌ |
| | | 2 | ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់រហ័ស។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ | បើកការស៊ើបអង្កេតបឋម ឲ្យបានឆាប់រហ័ស | | ក្រមព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | ប្រសិនបើអាយុកុមារនៅតែមិនមានភាពច្បាស់លាស់ ក្រោយពីព្រះរាជអាជ្ញាបានស៊ើបអង្កេតបឋម ព្រះរាជអាជ្ញាត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ និងចៅក្រម | ត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ | តើត្រូវយកមាត្រា៩ មកអនុវត្តដែរឬទេ ប្រសិនបើការស៊ើបអង្កេតបន្ថែមនៅតែមានភាពមិនច្បាស់លាស់? | ច្បាប់រដ្ឋម្មនុញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌ |
| 26 | ការស្តាប់ចម្លើយ | 1 | ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយអំពីសិទ្ធិដែលមានចែងក្នុងមាត្រា៦នៃច្បាប់នេះ ដោយភាសានិងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជនមុននឹងធ្វើការស្តាប់ចម្លើយ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង | ត្រូវអនុវត្តបច្ចេកទេសកុមារមេត្រីក្នុងការស្តាប់ចម្លើយ | តើមានព្រះរាជអាជ្ញាប៉ុន្មាននាក់ដែលមានជំនាញខាងបច្ចេកទេសកុមារមេត្រី? | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 2 | ប្រសិនបើអនីតិជនមិនមានលទ្ធភាពរកមេធាវីបានទេ ព្រះរាជអាជ្ញាត្រូវចាត់តាំងមេធាវីមិនយកកម្រៃ ដើម្បីតំណាងឲ្យអនីតិជន។ | ព្រះរាជអាជ្ញា | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ចាត់តាំងមេធាវីមិនយកកម្រៃ | លទ្ធភាពក្នុងការផ្តល់មេធាវីមិនយកកម្រៃនៅមានកម្រិត | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | ការស្តាប់ចម្លើយរបស់អនីតិជនត្រូវធ្វើឡើងជាសម្ងាត់និងប្រើប្រាស់នីតិវិធីកុមារមេត្រី ដោយមានវត្តមានរបស់មេធាវីអនីតិជន ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់អ្នកទំនុកបម្រុងរបស់អនីតិជន។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ មេធាវី ភ្នាក់ងារសង្គមកិច្ចអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង | ការស្តាប់ចម្លើយធ្វើឡើងជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី | តើមានគោលការណ៍ណែនាំស្តីពីនីតិវិធីកុមារមេត្រីសម្រាប់ឲ្យតុលាការអនុវត្តហើយឬនៅ? | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| | | 4 | ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ដោយមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង | មិនអនុញ្ញាតឲ្យអ្នកតំណាងចូលរួមស្តាប់ចម្លើយ ប្រសិនបើផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន តែត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន | | អនុសញ្ញាស្តីពីសិទ្ធិកុមារ និងក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 5 | ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ អំពីមូលហេតុនៃអវត្តមានមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច។ | ព្រះរាជអាជ្ញា | ដូចចំណុច ៤ខាងលើ | ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ អំពីមូលហេតុនៃអវត្តមានរបស់អ្នកដែលត្រូវចូលរួម | | |
| | | 6 | អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ | អានកំណត់ហេតុស្តាប់ចម្លើយភ្លាមបន្ទាប់ការស្តាប់ចម្លើយត្រូវបានបញ្ចប់ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 7 | ក្រឡាបញ្ជី និងអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យ អនីតិជនស្តាប់ ប្រសិនបើអនីតិជនមិនអាចអានបាន។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ ក្រឡាបញ្ជី និងអ្នកបកប្រែ | អានកំណត់ហេតុស្តាប់ចម្លើយភ្លាមបន្ទាប់ការស្តាប់ចម្លើយត្រូវបានបញ្ចប់ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 9 | អនីតិជនអាចកែប្រែ និងបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុនពេលចុះហត្ថលេខា ឬផ្តិតម្រាមដៃ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ | អាចកែប្រែ និងបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយ មុនពេលចុះហត្ថលេខា ឬផ្តិតម្រាមដៃ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 10 | ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឲ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ច | ត្រូវអនុញ្ញាតឲ្យមេធាវីអ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយ | | |
| | | 11 | មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ចត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ស្តាប់ចម្លើយ។ | ព្រះរាជអាជ្ញា | ដូចចំណុច ១០ខាងលើ | | | |
| | | 12 | ប្រសិនបើមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ចបដិសេធមិនចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុស្តាប់ចម្លើយ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។ | ព្រះរាជអាជ្ញា | ដូចចំណុច ១០ខាងលើ | ត្រូវចុះនិទ្ទេសក្នុងកំណត់ ហេតុ ប្រសិនបើមានការបដិសេធនៃការចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 13 | វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង | វិធានដែលបានបញ្ញត្តពីចំណុច ១ដល់១២ត្រូវគោរពតាម ដាច់ខាត បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី | តើត្រូវធ្វើដូចម្តេចនៅពេលមានមោឃភាពនៃនីតិវិធី ? | ក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 27 | ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម ១៤ឆ្នាំ | 1 | ប្រសិនបើអនីតិជនអាយុក្រោម១៤ឆ្នាំ ព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ការ និងប្រគល់អនីតិជនឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង | ប្រសិនបើអនីតិជនអាយុក្រោម១៤ឆ្នាំ ព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ការ | | ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ |
| | | 2 | ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជនទៅមន្ទីរសង្គមកិច្ច ប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ និងក្រសួងសង្គមកិច្ច | ត្រូវបញ្ជូនអនីតិជនទៅមន្ទីរសង្គមកិច្ចប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ | | ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច និងបទដ្ឋានអប្បរមា |
| | | 3 | ប្រសិនបើយល់ឃើញថាអនីតិជនចាំបាច់ត្រូវការកិច្ចការពារ និងថែទាំ មន្ទីរសង្គមកិច្ចត្រូវស្នើសុំតុលាការ ឲ្យព្យួរ ឬដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាល ឬអ្នកអាណាព្យាបាលទូទៅ។ | មន្ទីរសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង តុលាការ | ត្រូវស្នើសុំតុលាការឲ្យព្យួរ ឬដកហូតអំណាចមេបា បើអនីតិជនចាំបាច់ត្រូវការកិច្ចការពារ និងថែទាំ | | ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច និងបទដ្ឋានអប្បរមា |
| | | 4 | ប្រសិនបើអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរសង្គមកិច្ចត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ | មន្ទីរសង្គមកិច្ច | ដូចចំណុច៣ខាងលើ | ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាល | ក្នុងចន្លោះពេលរង់ចាំសេចក្ដីសម្រេចរបស់តុលាការ តើអនីតិជនត្រូវទុកដាក់នៅកន្លែងណា ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 5 | ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ | ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ | អនីតិជនទំនាស់នឹងច្បាប់ | ដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី | | |
| 28 | អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ | 1 | ករណីអនីតិជនអាយុចាប់ពី ១៤ ដល់ក្រោម ១៨ឆ្នាំប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ | ការបង្វែរត្រូវបានពិចារណាជាបឋម | មិនទាន់មានគោលការណ៍ណែនាំស្តីពីការបង្វែរ | ជំពូកទី ១០ នៃច្បាប់នេះអនុសញ្ញាស្តីពី សិទ្ធិកុមារ និងលិខិតបទដ្ឋានផ្សេងទៀតដែលទាក់ទងនឹងកុមារ |
| | | 2 | ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ប្រសិនបើព្រះរាជអាជ្ញាសម្រេចបង្វែរអនីតិជន។ | ព្រះរាជអាជ្ញា | តុលាការ អនីតិជនទំនាស់នឹងច្បាប់ ជនរងគ្រោះ | ត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ប្រសិនបើព្រះរាជអាជ្ញាសម្រេចបង្វែរអនីតិជន | | ដូចចំណុច១ខាងលើ |
| | | 3 | ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់និងបង្គាប់ឲ្យប្រគល់អនីតិជនឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរសង្គមកិច្ច ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ រហូតដល់ការរៀបចំផែនការបង្វែរត្រូវបានបញ្ចប់។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី មន្ទីរសង្គមកិច្ច | ត្រូវផ្អាកនីតិវិធីចោទប្រកាន់ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា | តើមានបទដ្ឋានអប្បរមានៃការគ្រប់គ្រងនិងថែទាំដែរឬទេ ? | ដូចចំណុច១ខាងលើ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 4 | ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ឬមេធាវីជនរងគ្រោះ ប្រសិនបើនីតិវិធីចោទប្រកាន់ត្រូវផ្អាក។ | ព្រះរាជអាជ្ញា | ជនរងគ្រោះ មេធាវីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ | ត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ឬ មេធាវីជនរងគ្រោះ | | |
| | | 5 | ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ | ជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់ មេធាវី | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី | ដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី | | |
| | | 6 | ប្រសិនបើការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។ | ព្រះរាជអាជ្ញា | ជនរងគ្រោះមេធាវីជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ | ចេញដីកាតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | តើភាពជោគជ័យត្រូវបានពិចារណាដោយរបៀបណា? តើអ្នកណាជាអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ? | ដូចចំណុច១ខាងលើ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 7 | ប្រសិនបើការអនុវត្តផែនការបង្វែរមិនទទួលបានជោគជ័យ ព្រះរាជអាជ្ញាអាចសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យរបស់អនីតិជន អ្នកតំណាងដែលច្បាប់កំណត់ និងភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។ | ព្រះរាជអាជ្ញា | កុមារទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី មន្ទីរសង្គមកិច្ច | សម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យ របស់អនីតិជន | តើមានលក្ខខណ្ឌអ្វីខ្លះ ដែលអាចឈានដល់ការសម្រេចមិនធ្វើការបង្វែរជាថ្មី ឬចាត់វិធានការតាមនីតិវិធី ? | ដូចចំណុច១ខាងលើ |
| 29 | ការឲ្យដំណឹងអំពីការចោទប្រកាន់ | 1 | ប្រសិនបើព្រះរាជអាជ្ញាសម្រេចចោទប្រកាន់អនីតិជន ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវី។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី ភ្នាក់ងារសង្គមកិច្ច | ជូនដំណឹងអនីតិជន ឬតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវី | | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 30 | ការបំបែកសំណុំរឿង | 1 | ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបំបែកសំណុំរឿង នៅពេលមានសហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង។ | ព្រះរាជអាជ្ញា | អនីតិជនទំនាស់នឹងច្បាប់ និងនីតិជនប្រព្រឹត្តបទល្មើស | បំបែកសំណុំរឿងនៅពេលមានសហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 31 | សមត្ថកិច្ចនៃការស៊ើបសួរ | 1 | ការស៊ើបសួរករណីអនីតិជនត្រូវបានស៊ើបសួរដោយចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងនឹងអនីតិជន។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | ត្រូវមានជំនាញទាក់ទងនឹងអនីតិជន | តើចៅក្រមជំនាញខាងអនីតិជនត្រូវការសមត្ថភាពអ្វីខ្លះ ? | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| 32 | ការបើកការស៊ើបសួរ | 1 | ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាមបន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | បើកការស៊ើបសួរភ្លាម | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 2 | ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ មេធាវី និង គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយ | | |
| | | 3 | ក្នុងករណីគ្មានការជ្រើសរើស ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ | ចៅក្រម | ដូចចំណុចទី២ខាងលើ | ត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី | | ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 33 | ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ | 1 | ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន និងប្រាប់អនីតិជនឲ្យដឹងអំពីការចោទប្រកាន់ ឈ្មោះបទល្មើស និងសិទ្ធិក្នុងនីតិវិធីស៊ើបសួរ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី ភ្នាក់ងារសង្គមកិច្ច | ពិនិត្យអត្តសញ្ញាណអនីតិជននិងប្រាប់អនីតិជនឲ្យដឹងអំពីការចោទប្រកាន់ ឈ្មោះបទល្មើស និងសិទ្ធិក្នុងនីតិវិធីស៊ើបសួរ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 2 | ចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច។ | ចៅក្រម | ដូចចំណុច១ ខាងលើ | | | |
| | | 3 | វិធានដែលបានបញ្ញត្តចាប់ពី ១ ដល់ ២ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។ | ចៅក្រម | ដូចចំណុច១ ខាងលើ | ប្រសិនបើបញ្ញត្តិក្នុងចំណុច ១ និង ២ មិនត្រូវបានគោរពតាមទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី | | ក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 34 | ការផ្ដល់អាទិភាពចំពោះរឿងក្ដីអនីតិជន | 1 | ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្ដីអនីតិជនមកចាត់ការជាអាទិភាព។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងមេធាវី | ការផ្ដល់អាទិភាពខ្ពស់ចំពោះរឿងក្ដីអនីតិជនពិសេសអនីតិជនកំពុងជាប់ឃុំបណ្ដោះអាសន្ន | | អនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| 35 | ការស្ដាប់ចម្លើយអនីតិជន | 1 | ការស្ដាប់ចម្លើយអនីតិជនត្រូវមានវត្តមានមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ភ្នាក់ងារសង្គមកិច្ច និងមេធាវី | ការស្ដាប់ចម្លើយត្រូវធ្វើជាសម្ងាត់ជាមួយនឹងវត្តមានមេធាវីអ្នកតំណាង និងភ្នាក់ងារសង្គមកិច្ច ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី | តើមានចៅក្រមប៉ុន្មាននាក់ដែលមានជំនាញខាងបច្ចេកទេសកុមារមេត្រី ហើយតើបច្ចេកទេសកុមារមេត្រីត្រូវបានអនុវត្តនៅគ្រប់តុលាការហើយឬនៅ? | អនុសញ្ញាស្ដីពីសិទ្ធិកុមារ |
| | | 2 | ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យមានវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងការស្ដាប់ចម្លើយ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ហើយយល់ឃើញថាវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ច និងមេធាវី | ប្រសិនបើវត្តមានពួកគាត់ផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់ពីមូលហេតុនៃអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី ភ្នាក់ងារសង្គមកិច្ច | ក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច | តើអវត្តមានរបស់មេធាវីគួរចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយដែរឬទេ ? | |
| | | 4 | ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យអនីតិជនអានកំណត់ហេតុស្តាប់ចម្លើយ បន្ទាប់ពីការស្តាប់ចម្លើយត្រូវបានបញ្ចប់។ ប្រសិនបើអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយ ក្រឡាបញ្ជីត្រូវអានឲ្យអនីតិជនស្តាប់។ | ចៅក្រម និងក្រឡាបញ្ជី | ដូចចំណុច៣ខាងលើ | ឲ្យអនីតិជនអានកំណត់ហេតុស្តាប់ចម្លើយភ្លាមបន្ទាប់ពីការស្តាប់ចម្លើយត្រូវបានបញ្ចប់ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 5 | អនីតិជនអាចស្នើសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយបាន មុនពេលចុះហត្ថលេខា ឬផ្តិតស្រាមដៃ។ | ចៅក្រម និងអនីតិជនទំនាស់នឹងច្បាប់ | អ្នកតំណាងដែលច្បាប់បានកំណត់ ក្រឡាបញ្ជី មេធាវី ភ្នាក់ងារសង្គមកិច្ច | សុំកែប្រែ ឬបន្ថែមបន្ថយចម្លើយបាន មុនពេលចុះហត្ថលេខា ឬផ្តិតស្រាមដៃ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 6 | នៅពេលមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចស្នើសុំអានកំណត់ហេតុស្តាប់ចម្លើយ ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យពួកគាត់អាន។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ភ្នាក់ងារសង្គមកិច្ច ក្រឡាបញ្ជី និង មេធាវី | អនុញ្ញាតមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចស្នើសុំអានកំណត់ហេតុស្តាប់ចម្លើយ | | |
| | | 7 | ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ប្រសិនបើអនីតិជន ឬមេធាវី ឬអ្នកតំណាង ដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចបដិសេធចុះហត្ថលេខា ឬផ្តិតម្រាមដៃ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ក្រឡាបញ្ជី និងមេធាវី | ចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ប្រសិនបើអនីតិជន ឬមេធាវី ឬអ្នកតំណាងឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចបដិសេធចុះហត្ថលេខា ឬផ្តិតម្រាមដៃ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 8 | វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។ | | | វិធានដែលបានបញ្ញត្តពីចំណុច ១ដល់៧ត្រូវគោរពតាម ដាច់ខាត បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី | | |
| 36 | ការលើកពេលស្តាប់ចម្លើយ | 1 | លើកលែងតែមានករណីបន្ទាន់ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ស្លាប់ឬបាត់បង់តម្រុយនៃភស្តុតាង ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយរហូតមានវត្តមានមេធាវីរបស់អនីតិជន។ ប្រភេទនៃការបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់និងមេធាវី | លើកពេលស្តាប់ចម្លើយរហូតមានវត្តមានមេធាវីរបស់អនីតិជន លើកលែងករណីបន្ទាន់ ហើយករណីបន្ទាន់នេះត្រូវចុះក្នុងកំណត់ហេតុ។ | | |
| | | 2 | ប្រសិនបើការស្តាប់ចម្លើយធ្វើដោយគ្មានវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ មេធាវី | អវត្តមានមេធាវី ចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | វត្តមាន ឬអវត្តមានមេធាវីមិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការឃុំខ្លួន ឬមិនឃុំខ្លួនអនីតិជនឡើយ។ | ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាង ដែលច្បាប់ បានកំណត់ និងមេធាវី | សម្រេចអំពីការ ឃុំខ្លួន ឬមិន ឃុំខ្លួនអនីតិជន ដោយមាន ឬ គ្មានវត្តមាន មេធាវី | តើចំណុច៣នេះ អាចផ្ទុយគ្នានឹង ចំណុច១ ដែរឬទេ ? | |
| 37 | ការព្យួរការសិក្សា និងការងារសម្រាប់ អនីតិជន | 1 | ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនទេ ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬការងារអនីតិជន។ | ចៅក្រម | អនីតិជនទំនាស់ នឹងច្បាប់ នាយកសាលា និងនិយោជក | | | |
| | | 2 | ប្រសិនបើអនីតិជនត្រូវបានឃុំខ្លួន ឬអនុវត្តផែនការបង្វែរ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យគ្រឹះស្ថានសិក្សា ឬនិយោជកព្យួរការសិក្សា ឬការងារអនីតិជន។ | ចៅក្រម | ដូចចំណុចទី១ ខាងលើ | | | |
| | | 3 | ប្រសិនបើអនីតិជនរួចផុតពីការចោទប្រកាន់ គ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលរៀន ឬធ្វើការដូចធម្មតាវិញ។ | ចៅក្រម | ដូចចំណុចទី១ ខាងលើ | | | |
| 38 | អំណាចរបស់ ចៅក្រមស៊ើបសួរ ក្នុងការបង្វែរ | 1 | ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមលើការបង្វែរ ប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើសមជ្ឈិម ឬបទល្មើសមជ្ឈិមមានស្ថានទម្ងន់ទោស។ | ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាង ដែលច្បាប់បាន កំណត់ | ពិចារណាជា បឋមលើការបង្វែរ សម្រាប់បទល្មើស មជ្ឈិមឬបទល្មើស មជ្ឈិមមានស្ថាន ទម្ងន់ទោស | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | ក្នុងករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ | ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ភ្នាក់ងារសង្គមកិច្ច | ត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរក្នុងករណីសម្រេចបង្វែរ | | ជំពូក១០នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| | | 3 | អនីតិជននឹងត្រូវប្រគល់ទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬទៅមន្ទីរសង្គមកិច្ចសម្រាប់ថែទាំ និងគ្រប់គ្រងដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីជាផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ។ | ចៅក្រម មន្ទីរសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ | ប្រគល់ទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬទៅមន្ទីរសង្គមកិច្ចសម្រាប់ថែទាំនិងគ្រប់គ្រង | | |
| | | 4 | ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅជនរងគ្រោះ អ្នកតំណាងស្របច្បាប់ ឬមេធាវីរបស់ជនរងគ្រោះអំពីការផ្អាកនីតិវិធីនៃការស៊ើបសួរ។ | ចៅក្រម ជនរងគ្រោះ | ជនរងគ្រោះ អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ និងមេធាវីជនរងគ្រោះ | | | |
| | | 5 | ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ | ជនរងគ្រោះ អ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ និងមេធាវីជនរងគ្រោះ | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងស្របច្បាប់ និងមេធាវី | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 6 | ប្រសិនបើផែនការបង្វែរត្រូវបានអនុវត្តដោយជោគជ័យ ចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងចោទប្រកាន់ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ភ្នាក់ងារសង្គមកិច្ច អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ចេញដីកាលើកលែងចោទប្រកាន់ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | | |
| | | 7 | ក្នុងករណីការអនុវត្តផែនការបង្វែរបរាជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាលើមូលហេតុដែលនាំឲ្យបរាជ័យ និងពិភាក្សាជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ ភ្នាក់ងារសង្គមកិច្ច មេធាវី និង អ្នកតំណាងដែលច្បាប់បានកំណត់ | ចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាលើមូលហេតុដែលនាំឲ្យបរាជ័យ និងពិភាក្សាជាមួយអ្នកដែលពាក់ព័ន្ធ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 39 | ការឃុំខ្លួនបណ្ដោះអាសន្ន | 1 | បន្ថែមពីលើបទបញ្ញត្តិស្ដីពីលក្ខខណ្ឌមូលហេតុនៃការឃុំខ្លួន បណ្ដោះអាសន្នដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចៅក្រមស៊ើបសួរត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន មុននឹងធ្វើការសម្រេចឃុំខ្លួន អនីតិជនបណ្ដោះអាសន្ន។ | ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ ភ្នាក់ងារសង្គមកិច្ច មេធាវី និង អ្នកតំណាងដែលច្បាប់បានកំណត់ | របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនត្រូវបានពិចារណា | របាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនត្រូវដាក់ជូនតុលាការទាន់ពេលវេលា | |
| | | 2 | អនីតិជនអាយុក្រោម១៤ឆ្នាំមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ។ | ចៅក្រម | ដូចចំណុចទី១ខាងលើ | អនុវត្តដោយម៉ត់ចត់ | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 3 | ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម១៤ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជនជាបន្ទាន់ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ភ្នាក់ងារសង្គមកិច្ច និង អ្នកតំណាងដែលច្បាប់បានកំណត់ | ដោះលែងអនីតិជនជាបន្ទាន់ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ | | |
| | | 4 | ប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរសង្គមកិច្ច។ | ចៅក្រម | ដូចចំណុច៣ខាងលើ | ត្រូវការកិច្ចការពារនិងថែទាំ | | |
| | | 5 | ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវសុំទៅតុលាការ ដើម្បីព្យួរ ឬដកអំណាចមេបា ឬបញ្ជប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ | មន្ទីរ/ការិយាល័យសង្គមកិច្ច | ដូចចំណុច៣ខាងលើ | សុំទៅតុលាការដើម្បីព្យួរ ឬដកអំណាចមេបាក្នុងករណីត្រូវការកិច្ចការពារ និងថែទាំ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 6 | ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | ដូចចំណុច៣ខាងលើ | សុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលបើគ្មានអ្នកតំណាង | | |
| | | 7 | ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ | ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់មេធាវី | អនីតិជនទំនាស់នឹងច្បាប់ មេធាវី និងអ្នកតំណាងស្របច្បាប់ | | | |
| 40 | ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ | 1 | ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ មេធាវី និងអ្នកតំណាងដែលច្បាប់បានកំណត់ | ដាក់អនីតិជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា | | |
| | | 2 | បន្ថែមពីលើបទបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ( មាត្រា ២២៦ ) ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំគោរពកាតព្វកិច្ចមួយ ឬច្រើនដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ។ | ចៅក្រម | ដូចចំណុច១ខាងលើ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 41 | ការដោះលែងឲ្យនៅក្រៅឃុំ | 1 | ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួន។ | ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ និងអ្នកតំណាងដែលច្បាប់បានកំណត់ | អាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា | | |
| | | 2 | ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ និងព្រះរាជអាជ្ញា | ជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ | | |
| | | 3 | ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត នៅពេលទទួលបានការជូនដំណឹងពីចៅក្រមស៊ើបសួរ។ | ព្រះរាជអាជ្ញា | ចៅក្រម | ផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត | | |
| | | 4 | ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ | ចៅក្រម | ព្រះរាជអាជ្ញា និងអនីតិជនទំនាស់នឹងច្បាប់ | អាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាមក្នុងករណីបន្ទាន់ | តើមានលក្ខខណ្ឌអ្វីខ្លះដែលអាចចាត់ចូលក្នុងករណីបន្ទាន់ ? | |
| | | 5 | ប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរសង្គមកិច្ច។ | ចៅក្រម | មន្ទីរសង្គមកិច្ច | | | |
| | | 6 | មន្ទីរសង្គមកិច្ចត្រូវចាត់វិធានការសមស្របប្រសិនបើអនីតិជនដែលត្រូវបានបញ្ជូនមកត្រូវការកិច្ចការពារ និងថែទាំ។ | មន្ទីរសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 7 | ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវសុំទៅតុលាការ ដើម្បីព្យួរ ឬដកអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងតុលាការ | សុំទៅតុលាការ ដើម្បីព្យួរ ឬដកអំណាចមេបា ក្នុងករណីត្រូវការកិច្ចការពារ និងថែទាំ | | |
| | | 8 | ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងតុលាការ | សុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិ អាណាព្យាបាល បើគ្មានអ្នកតំណាង | | |
| | | 9 | ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង អាចស្នើសុំទៅតុលាការដើម្បីដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។ មេធាវីអាចស្នើសុំបានដោយមានការយល់ព្រមពីអនីតិជន។ | ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់អ្នកទំនុកបម្រុង មេធាវី | ចៅក្រម | ស្នើសុំទៅតុលាការ ដើម្បីដោះលែងអនីតិជនឲ្យនៅក្រៅឃុំបាន គ្រប់ពេលវេលា | | |
| | | 10 | ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | សម្រេចក្នុងរយៈពេល៥ថ្ងៃ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 42 | ដីកា ដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ | 1 | ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន មុននឹងចេញដីកាដំណោះស្រាយ។ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេល១០ថ្ងៃ ប្រសិនបើរបាយការណ៍នៅមិនទាន់គ្រប់គ្រាន់។ | ចៅក្រម និងភ្នាក់ងារសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | ផ្តល់របាយការណ៍បន្ថែមឆាប់បំផុតមិនឲ្យលើសរយៈពេល១០ថ្ងៃ | | |
| | | 2 | ប្រសិនបើចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ អនីតិជនជាប់ឃុំនឹងត្រូវបានដោះលែង ទោះបីជាមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ។ | ចៅក្រម | ព្រះរាជអាជ្ញា អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ភ្នាក់ងារសង្គមកិច្ច | ដោះលែង ទោះបីជាមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ | | |
| | | 3 | ប្រសិនបើអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរសង្គមកិច្ច។ | ចៅក្រម | មន្ទីរសង្គមកិច្ច | បញ្ជូនអនីតិជននោះទៅមន្ទីរសង្គមកិច្ច ក្នុងករណីត្រូវការកិច្ចការពារ និងថែទាំ | | |
| | | 4 | មន្ទីរសង្គមកិច្ចត្រូវចាត់វិធានការសមស្រប ប្រសិនបើអនីតិជនដែលត្រូវបានបញ្ជូនមកត្រូវការកិច្ចការពារ និងថែទាំ។ | មន្ទីរសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 5 | ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវស្នើសុំទៅតុលាការ ដើម្បីព្យួរឬដកអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងតុលាការ | ស្នើសុំទៅតុលាការដើម្បីព្យួរ ឬដកអំណាចមេបា ក្នុងករណីត្រូវការកិច្ចការពារ និងថែទាំ | | |
| | | 6 | ប្រសិនបើអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងតុលាការ | សុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលបើគ្មានអ្នកតំណាង | | |
| 43 | ការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ | 1 | ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជនមុននឹងសម្រេចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។ | ព្រះរាជអាជ្ញា | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងចៅក្រម | | | |
| 44 | សមត្ថកិច្ចនៃការជំនុំជម្រះ | 1 | មានតែសាលាដំបូងដែលមានជំនាញខាងរឿងក្តីកុមារតែប៉ុណ្ណោះដែលមានសមត្ថកិច្ចជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន។ | សាលាដំបូង | ព្រះរាជអាជ្ញា ចៅក្រម អនីតិជន ទំនាស់នឹងច្បាប់ | | តើសាលាដំបូងមានបុគ្គលិកដែលមានជំនាញខាងកុមារហើយឬនៅ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | សាលាដំបូងសម្រេចជាក្រុមសមូហភាព ដោយមានចៅក្រមបីរូបចំពោះបទមជ្ឈិម បទឧក្រិដ្ឋ និងបទលហុដែលជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋ និងមជ្ឈិម។ | សាលាដំបូង | ព្រះរាជអាជ្ញា<br>ចៅក្រម<br>អនីតិជន<br>ទំនាស់នឹងច្បាប់ | | ចៅក្រមនៅតាមសាលាដំបូងនីមួយៗនៅមានចំនួនតិច មិនសមាមាត្រទៅនឹងចំនួនសំណុំរឿង | |
| | | 3 | សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទលហុ។ | សាលាដំបូង | ព្រះរាជអាជ្ញា<br>ចៅក្រម<br>អនីតិជន<br>ទំនាស់នឹងច្បាប់ | | | |
| 45 | អាទិភាពលើរឿងក្តីអនីតិជន | 1 | តុលាការត្រូវតែផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជន ជាពិសេសចំពោះអនីតិជនដែលកំពុងឃុំខ្លួនបណ្តោះអាសន្ន។ | តុលាការ | ព្រះរាជអាជ្ញា<br>ចៅក្រម<br>អនីតិជន<br>ទំនាស់នឹងច្បាប់ | ផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជនជាពិសេសអនីតិជនដែលកំពុងឃុំខ្លួនបណ្តោះអាសន្ន | តើមានកំណត់លក្ខខណ្ឌសម្រាប់ផ្តល់អាទិភាពលើរឿងក្តីហើយឬនៅ? | |
| | | 2 | ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះចៅក្រមត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្ន។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | ក្នុងពេលរង់ចាំការជំនុំជម្រះ និងឧត្តមប្រយោជន៍របស់អនីតិជន | | |
| | | 3 | ករណីដែលរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ ចៅក្រមត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | នៅពេលការជំនុំជម្រះត្រូវបានលើកពេល និងការពិចារណាលើការដោះលែង | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 46 | នីតិវិធីមុនពេលសវនាការ | 1 | មុនពេលសវនាការ ចៅក្រមត្រូវពិនិត្យរបាយការណ៍ និងយោបល់ ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់ អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។ | ភ្នាក់ងារសង្គមកិច្ច ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | មុនពេលសវនាការ ត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន | តើព័ត៌មានអ្វីខ្លះត្រូវដាក់ក្នុងរបាយការណ៍ ? | |
| | | 2 | ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយចៅក្រមត្រូវការព័ត៌មានបន្ថែម ចៅក្រមត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះតាមតម្រូវការ។ | ភ្នាក់ងារសង្គមកិច្ច ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | រៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះតាមតម្រូវការ | | |
| 47 | សវនាការជាអសាធារណៈ | 1 | នៅក្នុងរឿងក្តីអនីតិជន ការពិភាក្សាដេញដោលនិងការប្រកាសសាលក្រមត្រូវធ្វើជាអសាធារណៈ។ | តុលាការ | ភ្នាក់ងារសង្គមកិច្ច អនីតិជនទំនាស់នឹងច្បាប់ មេធាវី ចៅក្រម ព្រះរាជអាជ្ញា | អសាធារណៈ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | មានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬ ផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីតែប៉ុណ្ណោះ ដែលមានសិទ្ធិចូលរួមក្នុងសវនាការ។ | ចៅក្រម | ភ្នាក់ងារសង្គមកិច្ច អនីតិជនទំនាស់នឹងច្បាប់ មេធាវី ព្រះរាជអាជ្ញា ជនរងគ្រោះ | ចូលរួមបានសម្រាប់តែអ្នកដែលពាក់ព័ន្ធនឹងរឿងក្តីតែប៉ុណ្ណោះ | តើត្រូវកំណត់លក្ខខណ្ឌអ្វីខ្លះសម្រាប់អ្នកដែលមានសិទ្ធិចូលរួម ? | |
| | | 3 | អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុងរបស់អនីតិជន ត្រូវចូលរួមក្នុងសវនាការ លើកលែងតែការចូលរួមនោះមិនបម្រើ ឧត្តមប្រយោជន៍របស់អនីតិជន។ | ចៅក្រម មេធាវី ព្រះរាជអាជ្ញា | អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច អនីតិជនទំនាស់នឹងច្បាប់ ជនរងគ្រោះ | | តើអ្នកណាជាអ្នកកំណត់ឧត្តមប្រយោជន៍របស់អនីតិជន ? | |
| 48 | សវនាការ | 1 | សវនាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី។ | តុលាការ | អនីតិជនទំនាស់នឹងច្បាប់ ភ្នាក់ងារសង្គមកិច្ច មេធាវី ព្រះរាជអាជ្ញា អ្នកតំណាងដែលច្បាប់បានកំណត់ | ប្រើប្រាស់នីតិវិធីកុមារមេត្រី | តើមានគោលការណ៍ណែនាំស្តីពីនីតិវិធីកុមារមេត្រីសម្រាប់ឲ្យតុលាការអនុវត្តហើយឬនៅ ? | |
| | | 2 | ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនិតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំចៅក្រមប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។ | ចៅក្រម | មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា | ក្នុងកាលៈទេសៈពិសេស | តើលក្ខខណ្ឌអ្វីខ្លះដែលចាត់ចូលក្នុងកាលៈទេសៈពិសេស ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 49 | ការឲ្យរួចផុតពីបទចោទ | 1 | ប្រសិនបើចៅក្រមរកឃើញថាអនីតិជនមានអាយុក្រោម១៤ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស ចៅក្រមត្រូវលើកលែងការចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជនជាបន្ទាន់ បើទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជនឲ្យទៅអ្នកតំណាងដែលច្បាប់កំណត់។ | ចៅក្រម | មេធាវី ព្រះរាជអាជ្ញា តុលាការ អ្នកតំណាងដែលច្បាប់បានកំណត់ អនីតិជនទំនាស់នឹងច្បាប់ ជនរងគ្រោះ សាក្សី | ត្រូវដោះលែងជាបន្ទាន់ បើទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះអាជ្ញាក៏ដោយ | | |
| | | 2 | ប្រសិនបើចៅក្រមរកឃើញថាអនីតិជនមានអាយុក្រោម១៤ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើសមែន ជនរងគ្រោះអាចប្ដឹងទារសំណងរដ្ឋប្បវេណីបាន។ | ជនរងគ្រោះ អ្នកតំណាងជនរងគ្រោះ មេធាវីជនរងគ្រោះ | មេធាវី ព្រះរាជអាជ្ញា អ្នកតំណាងដែលច្បាប់បានកំណត់ អនីតិជនទំនាស់នឹងច្បាប់ | អាចប្ដឹងទារសំណងរដ្ឋប្បវេណី | | |
| | | 3 | ប្រសិនបើចៅក្រមរកឃើញថា អនីតិជនដែលមានអាយុពី១៤ ដល់ក្រោម១៨ឆ្នាំ មិនបានប្រព្រឹត្តបទល្មើសទេ ចៅក្រមត្រូវលើកលែងការចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម បើទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជនឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់។ | ចៅក្រម | មេធាវី ព្រះរាជអាជ្ញា អ្នកតំណាងដែលច្បាប់បានកំណត់ អនីតិជនទំនាស់នឹងច្បាប់ | ត្រូវដោះលែងជាបន្ទាន់ បើទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 4 | ប្រសិនបើអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមត្រូវបញ្ជូនទៅកាន់មន្ទីរឬការិយាល័យសង្គមកិច្ច ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ | ចៅក្រម | មន្ទីរ ឬ ការិយាល័យសង្គមកិច្ច | ចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន | | |
| | | 5 | ប្រសិនបើអនីតិជននោះចាំបាច់ត្រូវការកិច្ចការពារនិងថែទាំ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាល។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ តុលាការ | ស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាល | | |
| | | 6 | ប្រសិនបើអនីតិជនពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ទេ មន្ទីរសង្គមកិច្ចត្រូវស្នើទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន។ | មន្ទីរ/ការិយាល័យសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ តុលាការ | ស្នើទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជន | | |
| 50 | ជំនួយរបស់មេធាវី | 1 | កុមារត្រូវមានមេធាវីនៅពេលសវនាការ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ មេធាវី គណៈមេធាវី | ដាច់ខាតត្រូវមានមេធាវី | | ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣០០ និង៣០១ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រែតាមគំនិតផ្តើមរបស់ប្រធានតុលាការ ដូចមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ មេធាវី គណៈមេធាវី | ដាច់ខាតត្រូវមានមេធាវី | | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| | | 3 | តុលាការត្រូវតែផ្តល់ពេលវេលា ថតសុំណុំរឿងឲ្យមេធាវីដើម្បីត្រៀមការពារក្តីកុមារ។ | ចៅក្រម និងតុលាការ | អនីតិជនទំនាស់នឹងច្បាប់ មេធាវី គណៈមេធាវី | | | |
| | | 4 | រដ្ឋត្រូវរ៉ាប់រងថ្លៃថតចម្លងសុំណុំរឿងសម្រាប់មេធាវីដែលតុលាការជ្រើសតាំងឲ្យជួយការពារក្តី។ | តុលាការ | មេធាវី | | | |
| | | 5 | មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជនត្រូវបង់ថ្លៃថតចម្លងសំណុំរឿង។ | មេធាវី | តុលាការ | | | |
| 51 | ការផ្តល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជន | 1 | នៅពេលចាប់ផ្តើមសវនាការ ចៅក្រមត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលនីតិជនអាចយល់បាន អំពីសិទ្ធិដូចតទៅ៖<br>១) សិទ្ធិដែលទាក់ទងនឹងដំណាក់កាលនៃការជំនុំជម្រះដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ<br>២) សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី<br>៣) សិទ្ធិទទួលបានការ ការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ<br>៤) សិទ្ធិប្តឹងចៅក្រមជំនុំជម្រះ<br>៥) សិទ្ធិធ្វើសំណូមពរចុងក្រោយ និង៦) សិទ្ធិប្តឹងឧទ្ធរណ៍។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ និងភ្នាក់ងារសង្គមកិច្ច | បច្ចេកទេសកុមារមេត្រីត្រូវយកមកអនុវត្ត | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 52 | អំណាចរបស់តុលាការក្នុងការបង្វែរ | 1 | នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី១៤ ដល់ក្រោម១៨ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម ចៅក្រមត្រូវពិចារណាជាបឋមទៅលើការបង្វែរ។ | ចៅក្រម | គ្រប់ស្ថាប័នពាក់ព័ន្ធ | ការពិចារណាជាបឋមក្នុងការបង្វែរ | | |
| | | 2 | ក្នុងករណីលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញ តុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិន បន្ទាប់មកត្រូវ៖<br>១ ) ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត<br>២ ) រៀបចំផែនការបង្វែរ<br>៣ ) ឲ្យអនីតិជនចុះហត្ថលេខា ឬផ្តិតម្រាមដៃ អនុវត្តផែនការបង្វែរ។ | ចៅក្រម | គ្រប់ស្ថាប័នពាក់ព័ន្ធ | ត្រូវមានកម្រិតលក្ខខណ្ឌសមរម្យ និងមានការពិគ្រោះយោបល់ ទើបអាចពិចារណាការបង្វែរ | | |
| | | 3 | ក្នុងករណីតុលាការសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូក១០នៃច្បាប់នេះត្រូវយកមកអនុវត្ត។ | ចៅក្រម | គ្រប់ស្ថាប័នពាក់ព័ន្ធ | ត្រូវមានការយល់ព្រមពី អនីតិជន ហើយជំពូក១០ នៃច្បាប់នេះត្រូវយកមកអនុវត្ត | | |
| | | 4 | តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ។ | ចៅក្រម | កុមារ<br>ទំនាស់នឹងច្បាប់<br>អ្នកតំណាងដែលច្បាប់បានកំណត់<br>ដើមបណ្តឹងរដ្ឋប្បវេណី | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 5 | ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឲ្យដោះលែង អនីតិជននោះភ្លាម ទោះមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយត្រូវប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់។ | ចៅក្រម | ព្រះរាជអាជ្ញា អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាង ដែលច្បាប់ បានកំណត់ | ត្រូវបង្គាប់ឲ្យ ដោះលែង អនីតិជន នោះភ្លាម ទោះ មានបណ្ដឹង ឧទ្ធរណ៍ ពី ព្រះរាជអាជ្ញា ក៏ដោយ | | |
| | | 6 | ក្នុងករណីអនីតិជនត្រូវការកិច្ចការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរសង្គមកិច្ច ហើយមន្ទីរសង្គមកិច្ចត្រូវចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ | ចៅក្រម មន្ទីរសង្គមកិច្ច | អនីតិជនទំនាស់ នឹងច្បាប់ និងគ្រួសារ | ត្រូវបញ្ជូន អនីតិជននោះ ទៅមន្ទីរសង្គមកិច្ច ក្នុងករណីត្រូវការ កិច្ចការពារ និង ថែទាំ | | |
| | | 7 | ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ទីរឬការិយាល័យសង្គមកិច្ចត្រូវចាត់វិធានការស្នើទៅតុលាការសុំព្យួរ ឬដកហូតឬបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ | មន្ទីរ/ការិយាល័យ សង្គមកិច្ច តុលាការ | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែល ច្បាប់បានកំណត់ | ស្នើទៅតុលាការ សុំព្យួរ ឬដកហូត អំណាចមេបាក្នុង ករណីត្រូវការ កិច្ចការពារនិង ថែទាំ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 8 | ប្រសិនបើកុមារមិនមានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ/ការិយាល័យសង្គមកិច្ចត្រូវស្នើទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ | មន្ទីរ/ការិយាល័យសង្គមកិច្ច តុលាការ | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ | ស្នើទៅតុលាការ ដើម្បីសម្រេច អំពីសិទ្ធិអាណាព្យាបាល ក្នុងករណីគ្មានអ្នកតំណាង | | |
| | | 9 | ប្រសិនបើការបង្វែរទទួលបានជោគជ័យ តុលាការនឹងលើកលែងការចោទប្រកាន់។ | ចៅក្រម | ជនរងគ្រោះ មេធាវីជនរងគ្រោះ ភ្នាក់ងារសង្គមកិច្ច អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ផែនការបង្វែរជោគជ័យត្រូវមានការបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ចនិងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | តើត្រូវកំណត់លក្ខខណ្ឌអ្វីខ្លះសម្រាប់ការជោគជ័យ? | ជំពូក១០នៃច្បាប់នេះ អនុសញ្ញាស្ដីពីសិទ្ធិកុមារ និងច្បាប់សិទ្ធិមនុស្សដទៃទៀត ដែលពាក់ព័ន្ធនឹងកុមារ |
| | | 10 | ក្នុងករណីការអនុវត្តផែនការបង្វែរទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។ | ចៅក្រម | កុមារ ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី ឬភ្នាក់ងារសង្គមកិច្ច | អាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យដោយមានការពិគ្រោះយោបល់ | តើមានលក្ខខណ្ឌអ្វីខ្លះ ដែលមិនអាចរៀបចំផែនការបង្វែរជាថ្មី ហើយត្រូវចាត់វិធានការតាមនីតិវិធី? | ជំពូក ១០ នៃច្បាប់នេះអនុសញ្ញាស្ដីពី សិទ្ធិកុមារ និងច្បាប់សិទ្ធិមនុស្សដទៃទៀត ដែលពាក់ព័ន្ធនឹងកុមារ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 53 | ចម្លើយសារភាពនៅពេលសវនាការ | 1 | ចៅក្រមត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថា ចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងបានយល់អំពីផលវិបាកនៃការសារភាពនេះ។ | ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាង មេធាវី ភ្នាក់ងារសង្គមកិច្ច មន្ត្រីនគរបាលយុត្តិធម៌ | | តើត្រូវមាននីតិវិធីអ្វីខ្លះដើម្បីការពារកុមារដែលមិនបានសារភាពកំហុសដោយស្ម័គ្រចិត្ត ? | |
| | | 2 | ចម្លើយសារភាពដែលបានមកពីការគំរាមកំហែង ការបង្ខិតបង្ខំ ឬការមិនយល់ដឹងអំពីផលវិបាកនៃការសារភាព មិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពឡើយ។ | ចៅក្រម | ដូចចំណុច១ខាងលើ | | | |
| | | 3 | ការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ។ | ចៅក្រម | ដូចចំណុច១ខាងលើ | | | |
| | | 4 | ក្នុងពេលសវនាការ តុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។ | ចៅក្រម | ដូចចំណុច១ខាងលើ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 54 | ការប្រកាសសាលក្រម | 1 | សាលក្រមត្រូវប្រកាសនៅពេលសវនាការក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ | | | |
| | | 2 | ជាគោលការណ៍ ការប្រកាសសាលក្រមត្រូវធ្វើជាអសាធារណៈ ដោយមានវត្តមានភាគីពាក់ព័ន្ធ មេធាវី និងអ្នកដែលមានប្រយោជន៍ក្នុងរឿងក្តីនេះ។ | ចៅក្រម | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍ក្នុងរឿងក្តី | | ថាតើបញ្ហានេះពាក់ព័ន្ធនឹងមាត្រា៤៧ យ៉ាងដូចម្តេច ?អ្នកណាជាអ្នកមានប្រយោជន៍ក្នុងរឿងក្តី តើពាក្យថាជាគោលការណ៍មានឥទ្ធិពលទៅលើការអនុវត្តរបស់មាត្រានេះយ៉ាងម៉េច ? | |
| | | 3 | សាលក្រមអាចប្រកាសដោយមិនមានវត្តមានអនីតិជន។ | ចៅក្រម | កុមារទំនាស់នឹងច្បាប់ | ប្រសិនបើមិនមែនជាឧត្តមប្រយោជន៍របស់កុមារចំពោះវត្តមានរបស់កុមារ | | |
| 55 | សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ | 1 | ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍ និងតុលាការកំពូល ត្រូវមានសមាសភាពជាចៅក្រមជំនាញខាងអនីតិជនម្នាក់។ | សាលាឧទ្ធរណ៍ តុលាការកំពូល | កុមារទំនាស់នឹងច្បាប់ | ត្រូវមានសមាសភាពជាចៅក្រមជំនាញខាងអនីតិជនម្នាក់ | តើត្រូវកំណត់លក្ខខណ្ឌអ្វីខ្លះដើម្បីក្លាយខ្លួនជាចៅក្រមជំនាញអនីតិជន ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 56 | ការបញ្ជូនរឿងក្តីទៅសាលាឧទ្ធរណ៍ និងតុលាការកំពូល | 1 | ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃសាលាដំបូងត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល១០ថ្ងៃ គិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជម្នះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន។ | ក្រឡាបញ្ជីនៃសាលាដំបូង | សាលាឧទ្ធរណ៍ | ត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល១០ថ្ងៃធ្វើការងារ លើកលែងករណីមិនអាចធ្វើទៅកើត | តើអ្វីខ្លះដែលអាចចាត់ចូលក្នុងករណីមិនអាចធ្វើទៅកើត ? | ក្រមនីតិវិធីព្រហ្មទណ្ឌ (មិនបានបញ្ជាក់ច្បាស់អំពីរយៈពេលក្នុងការផ្ទេរសំណុំរឿងពីតុលាការមួយទៅតុលាការមួយទៀត |
| 57 | អាទិភាពចំពោះរឿងក្តីអនីតិជន | 1 | សាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវផ្តល់អាទិភាពចំពោះរឿងក្តីអនីតិជន ជាពិសេសរឿងក្តីអនីតិជនដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ | សាលាឧទ្ធរណ៍ តុលាការកំពូល | កុមារទំនាស់នឹងច្បាប់ អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច មេធាវី | ផ្តល់អាទិភាពចំពោះរឿងក្តីកុមារទាំងអស់ដែលកំពុងឃុំខ្លួនបណ្តោះអាសន្ន | | ក្រមនីតិវិធីព្រហ្មទណ្ឌ (មិនមានបញ្ជាក់ពីរយៈពេលសវនាការរឿងក្តីអនីជន) |
| | | 2 | សាលាឧទ្ធរណ៍ត្រូវជំនុំជម្រះក្នុងរយៈពេល ៣ខែ ដោយគិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តមិនអាចជម្នះបាន។ | សាលាឧទ្ធរណ៍ តុលាការកំពូល | កុមារទំនាស់នឹងច្បាប់ អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច មេធាវី | ក្នុងរយៈពេល ៣ខែ លើកលែងតែមានមូលហេតុសត្យានុម័តមិនអាចជម្នះបាន | តើអ្វីជាមូលហេតុសត្យានុម័តមិនអាចជម្នះបាន ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំជំនុំជម្រះ សាលាឧទ្ធរណ៍ ឬតុលាការកំពូលត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព។ | សាលាឧទ្ធរណ៍ តុលាការកំពូល | កុមារ ទំនាស់នឹងច្បាប់ អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច មេធាវី | ដើម្បីឧត្តមប្រយោជន៍អនីតិជន ត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្ន | | |
| 58 | សមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ក្នុងការបង្វែរ | 1 | សាលាឧទ្ធរណ៍មានសមត្ថកិច្ចបង្វែរអនីតិជនយោងតាមមាត្រា ៥២។ | សាលាឧទ្ធរណ៍ | កុមារ ទំនាស់នឹងច្បាប់ អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច មេធាវី | | | |
| 59 | ការពន្លាតវិធានចំពោះតុលាការជាន់ខ្ពស់ | 1 | វិធានដែលអនុវត្តចំពោះសាលាដំបូង ក៏ត្រូវអនុវត្តនៅសាលាឧទ្ធរណ៍ និងតុលាការកំពូល លើកលែងតែវិធាននោះផ្ទុយនឹងវិធានរបស់តុលាការជាន់ខ្ពស់។ | សាលាឧទ្ធរណ៍ តុលាការកំពូល | កុមារ ទំនាស់នឹងច្បាប់ អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច មេធាវី | លើកលែងតែវិធានផ្ទុយ | តើមានវិធានណាខ្លះដែលផ្ទុយ ? | |
| 60 | ការបង្វែរ | 1 | ការបង្វែរជាវិធានការដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយអាចជឿជាក់ថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗនៃនីតិវិធីតុលាការ។ | តុលាការ | កុមារ ទំនាស់នឹងច្បាប់ អ្នកតំណាង ភ្នាក់ងារសង្គមកិច្ច មេធាវី | | តើអ្វីខ្លះដែលជាមូលដ្ឋានអាចជឿជាក់បាន ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 61 | អាជ្ញាធរទទួលបន្ទុកបង្វែរ | 1 | អាជ្ញាធរទទួលបន្ទុកបង្វែររួមមានតំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍។ | ព្រះរាជអាជ្ញា<br>ចៅក្រម | កុមារ<br>ទំនាស់នឹងច្បាប់<br>អ្នកតំណាង<br>ភ្នាក់ងារសង្គមកិច្ច<br>មេធាវី | | | |
| 62 | គោលបំណងនៃការបង្វែរ | 1 | គោលបំណងនៃការបង្វែររួមមាន៖<br>១) លើកទឹកចិត្តឲ្យអនីតិជនទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបង្កឡើង<br>២) ជំរុញឲ្យមានការសះជារវាងជនរងគ្រោះ និងអនីតិជន<br>៣) លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជំងឺចិត្តដល់ជនរងគ្រោះ<br>៤) អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន<br>៥) ឆ្លើយតបនឹងសេចក្ដីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ<br>៦) ជៀសវាងការមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ និងបញ្ចៀសការទទួលបាននូវបទពិសោធន៍អាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោស និងជៀសវាង ការប្រព្រឹត្តបទល្មើសជាថ្មី<br>៧) បង្ការការរើសអើងលើអនីតិជន និងជៀសវាងមានប្រវត្តិថាបានជាប់ទោសក្នុងបញ្ជីថ្កោលទោស។ | ព្រះរាជអាជ្ញា<br>ចៅក្រម | គ្រប់ស្ថាប័នពាក់ព័ន្ធ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 63 | លក្ខខណ្ឌអប្បបរមានៃការបង្វែរ | 1 | ការបង្វែរត្រូវមានលក្ខខណ្ឌអប្បបរមាដូចតទៅៈ<br>១) មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន<br>២) អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ<br>៣) បទល្មើសដែលបានប្រព្រឹត្តជាបទល្មើសលហុ ឬមជ្ឈិម<br>៤) អនីតិជនយល់ព្រមធ្វើការបង្វែរបន្ទាប់ពីបានទទួលពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ចឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអនុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ។ | ព្រះរាជអាជ្ញា ចៅក្រម | អនីតិជន ទំនាស់នឹងច្បាប់ ភ្នាក់ងារសង្គមកិច្ច មេធាវី និងអ្នកពាក់ព័ន្ធឯទៀត | លក្ខខណ្ឌអប្បបរមាទាំងបួនសំរាប់ការបង្វែត្រូវអនុវត្ត | | |
| 64 | លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ | 1 | ក្នុងករណីរឿងក្តីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរដូចមានចែងនៅក្នុងមាត្រា៦៣នៃច្បាប់នេះ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរត្រូវពិចារណាលើកត្តាដូចខាងក្រោម៖<br>១) កាលៈទេសៈនៃបទល្មើស<br>២) ស្ថានភាពនៃបទល្មើស<br>៣) បុគ្គលិកលក្ខណៈអនីតិជន<br>៤) ការទទួលឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន<br>៥) ព្យសនកម្មរបស់ជនរងគ្រោះ<br>៦) សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម។ ។ | ចៅក្រម និង ព្រះរាជអាជ្ញា | អ្នកពាក់ព័ន្ធទាំងអស់ | ប្រសិនបើរឿងក្តីអនីតិជនត្រូវគ្នានឹងលក្ខខណ្ឌអប្បរមានៃការបង្វែរ | តើការពិចារណាបែបណាដែលកំណត់ថាអនីតិជនមិនសមស្របសម្រាប់ការបង្វែរ ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 65 | វិធានការបង្វែរ | 1 | ផែនការបង្វែរនឹងត្រូវបញ្ចូលវិធានមួយ ឬច្រើនដូចខាងក្រោម៖<br>១) ចំណុចមួយឬច្រើននៃកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ<br>២ ) ទៅសាលារៀនទៀងទាត់តាមផែនការកំណត់<br>៣) ចំណាយពេលជាមួយគ្រួសារ<br>៤) ចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ<br>៥) ធ្វើការងារសហគមន៍ដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងដែលអាចសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ<br>៧) ចូលរួមកម្មវិធីក្នុងសហគមន៍ ឬមណ្ឌលដែលបង្ការអនីតិជនប្រព្រឹត្តបទល្មើសម្តងទៀត<br>៨) ស្នាក់នៅក្នុងទីកន្លែងជាក់លាក់ជាមួយពេលវេលាជាក់លាក់<br>៩) ជួសជុលសំណងខូចខាតរបស់ជនរងគ្រោះ<br>១០) វិធានផ្សេងទៀតដែលសមស្របនឹងការបង្វែរ។ | ចៅក្រម និង ព្រះរាជអាជ្ញា | អ្នកពាក់ព័ន្ធទាំងអស់ | | | មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
| --- | --- | --- | --- | --- | --- | --- | --- | --- |
| | | 2 | វិធានការបង្វែរទាក់ទងនឹងការងារត្រូវអនុលោមតាមបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិស្តីពីការងារដែលមានជាធរមាន។ | ចៅក្រម និងព្រះរាជអាជ្ញា | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់កំណត់ និងមេធាវី | ត្រូវអនុលោមតាមបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិស្តីពីការងារដែលមានជាធរមាន | | |
| 66 | ការរៀបចំផែនការបង្វែរ | 1 | ភ្នាក់ងារសង្គមកិច្ចមានរយៈពេល១ខែ សម្រាប់រៀបចំផែនការបង្វែរ លើកលែងតែមានស្ថានភាពពិសេស។ | ភ្នាក់ងារសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | រយៈពេល១ខែ លើកលែងតែមានស្ថានភាពពិសេស | តើអ្វីខ្លះជាស្ថានភាពពិសេស? | |
| | | 2 | ការបង្កើតផែនការបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាលើកត្តាដូចខាងក្រោម៖<br>១) ទស្សនៈអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនផ្សេងទៀតដែលទទួលព្យសនកម្មពីបទល្មើស<br>២) សាវតា វប្បធម៌ សាសនា និងភាសារបស់អនីតិជន<br>៣) កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសារអនីតិជន<br>៤) សមាមាត្ររវាងផែនការបង្វែរ ចរិតនៃបទល្មើស និងផលប្រយោជន៍ សង្គម<br>៥) អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន។ | ភ្នាក់ងារសង្គមកិច្ច | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ជនរងគ្រោះ និងអ្នកពាក់ព័ន្ធឯទៀត | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | ផែនការបង្វែររបស់អនីតិជនត្រូវ៖<br>១) ផ្តល់អត្ថប្រយោជន៍ដល់អនីតិជន<br>២) ឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអំពើល្មើសទៅលើជនរងគ្រោះ<br>៣) កែតម្រូវកំហុសដែលបង្កឡើងដោយអំពើល្មើស និងរួមបញ្ចូលនូវសំណងខូចខាត<br>៤) អនុវត្តនៅទីកន្លែងសមស្រប<br>៥) ជៀសវាងការធ្វើអាជីវកម្ម កេងប្រវ័ញ្ចឬបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយអនីតិជន<br>៦) មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សា<br>៧) មិនពាក់ព័ន្ធនឹងការដកហូតសិទ្ធិសេរីភាពនៅក្នុងទម្រង់នៃការដាក់ទោស។ | ភ្នាក់ងារសង្គមកិច្ច | ចៅក្រម និងអ្នកឯទៀតដូចបានបញ្ជាក់ក្នុងចំណុច២ខាងលើ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 67 | និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ | 1 | ផែនការបង្វែរត្រូវមាននិទ្ទេសដូចខាងក្រោម៖<br>១) វិធានការបង្វែរ និងរយៈពេលនៃការអនុវត្តវិធានបង្វែរ<br>២) បញ្ជាក់លម្អិតពីសេវានិងជំនួយដែលផ្តល់ឲ្យអនីតិជន<br>៣) បញ្ជាក់ឲ្យច្បាស់ពីបុគ្គល ឬអង្គការផ្តល់សេវា និងជំនួយ<br>៤) បញ្ជាក់ពីការទទួលខុសត្រូវអនីតិជនអ្នកតំណាងដែលច្បាប់បានកំណត់<br>៥) បញ្ជាក់ពីគោលបំណងអនីតិជនអ្នកតំណាងដែលច្បាប់បានកំណត់<br>៦) បញ្ចូលកម្មវិធីអប់រំ ការបម្រើការងារការកម្សាន្ត និងសុខុមាលភាពអនីតិជនទៅតាមស្ថានភាព<br>៧) បញ្ជាក់ពីអាជ្ញាធរ ឬជនដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ<br>៨) បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកត្រួតពិនិត្យតាមដាននិងអនុវត្តផែនការបង្វែរ<br>៩) បញ្ជាក់ពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ។ | ភ្នាក់ងារសង្គមកិច្ច | កុមារទំនាស់នឹងច្បាប់ ចៅក្រម អ្នកតំណាង ដែលច្បាប់បានកំណត់ នគរបាល បុគ្គលិក អង្គការ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រូបង្រៀន សមាជិកសមស្រប ណាមួយនៅក្នុងសហគមន៍ | | តើអ្នកផ្សេងទៀតអាចត្រូវបានផ្តល់អំណាចឲ្យទទួលខុសត្រូវនៅក្នុងផ្នែកនៃផែនការបង្វែរដែរ ឬទេ ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | ផែនការបង្វែរត្រូវចុះដូចខាងក្រោម៖<br>១) អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច<br>២) អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន<br>៣) អត្តសញ្ញាណ ហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកពាក់ព័ន្ធផ្សេងទៀត។ | ភ្នាក់ងារសង្គមកិច្ច | ដូចគ្នានឹងចំណុច១ខាងលើ | | | |
| | | 3 | ច្បាប់ថតចម្លងនៃផែនការបង្វែរត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច។ | ភ្នាក់ងារសង្គមកិច្ច | ដូចគ្នានឹងចំណុច២ខាងលើ | | អ្នកពាក់ព័ន្ធទាំងអស់ត្រូវយល់ច្បាស់ពីការសម្ងាត់នៃផែនការបង្វែរ | |
| 68 | ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ | 1 | ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរបង្វែរ ដើម្បីពិនិត្យ និងសម្រេច។ | ភ្នាក់ងារសង្គមកិច្ច | អាជ្ញាធរទទួលបន្ទុកបង្វែរ | | | |
| | | 2 | ប្រសិនបើយល់ស្រប អាជ្ញាធរបង្វែរត្រូវចេញដីកាសម្រេចបង្គាប់ឲ្យអនុវត្តផែនការង្វែរនេះ។ | អាជ្ញាធរទទួលបន្ទុកបង្វែរ | អនីតិជនទំនាស់នឹងច្បាប់ តុលាការ ភ្នាក់ងារសង្គមកិច្ច និងអ្នកពាក់ព័ន្ធផ្សេងទៀត | | | |
| | | 3 | ប្រសិនបើផែនការបង្វែរមិនសមស្រប អាជ្ញាធរបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំផែនការបង្វែរឡើងវិញក្នុងអំឡុងពេល១ខែ លើកលែងតែមានស្ថានភាពពិសេស។ | អាជ្ញាធរទទួលបន្ទុកបង្វែរ | អនីតិជនទំនាស់នឹងច្បាប់ និងភ្នាក់ងារសង្គមកិច្ច | រយៈពេល១ខែ លើកលែងតែមានស្ថានភាពពិសេស | តើអ្វីខ្លះជាស្ថានភាពពិសេស ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
| --- | --- | --- | --- | --- | --- | --- | --- | --- |
| 69 | ការអនុវត្តផែនការបង្វែរ | 1 | ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរត្រូវធានាថាបរាជ័យអនុវត្តសេចក្តីសម្រេចនិងផែនការបង្វែរក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជន។ | ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | អនីតិជនទំនាស់នឹងច្បាប់ | | | |
| | | 2 | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផល ឬឧបសគ្គនៅក្នុងការអនុវត្តផែនការបង្វែរទៅភ្នាក់ងារសង្គមកិច្ច។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ភ្នាក់ងារសង្គមកិច្ច | | តើការធ្វើរបាយការណ៍ត្រូវធ្វើប៉ុន្មានដង ? ហើយវានឹងត្រូវបញ្ចូលទៅក្នុងផែនការបង្វែរដែរឬទេ ? | |
| | | 3 | ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះ រួមទាំងយោបល់របស់ខ្លួនទៅអាជ្ញាធរបង្វែរ និងចម្លងជូនមន្ទីរសង្គមកិច្ច។ | ភ្នាក់ងារសង្គមកិច្ច | តុលាការព្រះរាជអាជ្ញា និងមន្ទីរសង្គមកិច្ច | | តើការធ្វើរបាយការណ៍ត្រូវធ្វើប៉ុន្មានដង ? ហើយវានឹងត្រូវបញ្ចូលទៅក្នុងផែនការបង្វែរដែរឬទេ ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
| --- | --- | --- | --- | --- | --- | --- | --- | --- |
| 70 | ការកែប្រែវិធានការបង្វែរ | 1 | អាជ្ញាធរបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬសំណើរបស់ភ្នាក់ងារសង្គមកិច្ច ដោយស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | អនីតិជនទំនាស់នឹងច្បាប់ និងភ្នាក់ងារសង្គមកិច្ច | ប្រសិនបើការកែប្រែនោះជាឧត្តមប្រយោជន៍សម្រាប់អនីតិជន | | |
| | | 2 | អាជ្ញាធរបង្វែរត្រូវសម្រេចពីសំណើកែប្រែផែនការបង្វែររបស់ភ្នាក់ងារសង្គមកិច្ចក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | អនីតិជនទំនាស់នឹងច្បាប់ ភ្នាក់ងារសង្គមកិច្ច និងអ្នកពាក់ព័ន្ធផ្សេងទៀត | | | |
| | | 3 | ប្រសិនបើអាជ្ញាធរបង្វែរមិនសម្រេចលើសំណើរបស់ភ្នាក់ងារសង្គមកិច្ចក្នុងរយៈពេល ៥ថ្ងៃទេ នោះមានន័យថាសំណើនេះត្រូវបានយល់ព្រម។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | អនីតិជនទំនាស់នឹងច្បាប់ ភ្នាក់ងារសង្គមកិច្ច និងអ្នកពាក់ព័ន្ធផ្សេងទៀត | ការកែប្រែផែនការបង្វែរមិនចាត់ទុកថាជាការបរាជ័យលើការអនុវត្តផែនការបង្វែរនោះទេ | | |
| 71 | បរាជ័យក្នុងការអនុវត្តផែនការបង្វែរ | 1 | ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពីលទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបានកំណត់ក្នុងវិធានការបង្វែររួមទាំងយោបល់របស់ខ្លួនជូនទៅអាជ្ញាធរបង្វែរ និងមន្ទីរសង្គមកិច្ច។ | ភ្នាក់ងារសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ អាជ្ញាធរបង្វែរ និងមន្ទីរសង្គមកិច្ច | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | អាជ្ញាធរបង្វែរត្រូវពិនិត្យរបាយការណ៍ និងកោះហៅអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរឲ្យចូលបង្ហាញខ្លួនក្នុងរយៈពេល១៥ថ្ងៃ។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ជាលាយលក្ខណ៍អក្សរ | | |
| | | 3 | នៅពេលពួកគាត់បង្ហាញខ្លួន អាជ្ញាធរបង្វែរត្រូវសាកសួរពីមូលហេតុដែលអនីតិជនមិនគោរពតាមវិធានការបង្វែរ។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ដូចគ្នានឹងចំណុច២ | | | |
| | | 4 | បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច អាជ្ញាធរ បង្វែរអាចចេញដីកាបង្វែរជាថ្មី ឬចាត់ការតាម នីតិវិធីព្រហ្មទណ្ឌជាធរមាន។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ដូចគ្នានឹងចំណុច៣ | ការពិគ្រោះយោបល់ត្រូវតែធ្វើ | តើហេតុផលអ្វីខ្លះដែលនាំឲ្យមិនបន្តការបង្វែរ ? | |
| | | 5 | អាជ្ញាធរបង្វែរត្រូវបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ប្រសិនបើអនីតិជនមិនចូលបង្ហាញ និងគ្មានមូលហេតុសមស្រប។ | អ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ | ដូចគ្នានឹងចំណុច៤ | មូលហេតុសមស្រប | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 72 | ការដោះលែងដោយមានលក្ខខណ្ឌ | 1 | ការដោះលែងដោយមានលក្ខខណ្ឌអាចត្រូវផ្តល់ជូនអនីតិជនក្នុងមណ្ឌលស្តារនីតិសម្បទាទៅតាមលក្ខខណ្ឌកំណត់ជាក់លាក់។ | តុលាការ | អនីតិជនទំនាស់នឹងច្បាប់ និងមណ្ឌលស្តារនីតិសម្បទា | ក្នុងករណីដូចជា៖<br>១) មួយភាគបីនៃទោស ប្រសិនបើទោសតិចជាង ឬស្មើ១ឆ្នាំ<br>២) ពាក់កណ្តាលនៃទោសករណីផ្សេងទៀត | តើមានការគិត ឬគណនាយ៉ាងម៉េចប្រសិនបើនៅក្នុងពន្ធនាគារផ្សេងទៀត? | មាត្រា៥១៣ និង ៥១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ |
| 73 | បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងដោយមានលក្ខខណ្ឌ | 1 | បុគ្គលដែលរៀបរាប់ខាងក្រោម មានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ៖<br>១) ទណ្ឌិតជាអនីតិជន ឬមេធាវីរបស់ខ្លួន<br>២) អ្នកតំណាងដែលច្បាប់បានកំណត់<br>៣) ប្រធានមណ្ឌលយុវនីតិសម្បទា<br>៤) ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ<br>៥) បេសកកម្មការទូត ឬកុងស៊ុលបរទេសក្នុងករណីអនីតិជនជាជនបរទេស។ | អនីតិជនទំនាស់នឹងច្បាប់ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ប្រធានមណ្ឌលយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច បេសកកម្មការទូត ឬកុងស៊ុលបរទេស | ចៅក្រម និង ប្រធានមណ្ឌលយុវនីតិសម្បទា | | តើមានការគិត ឬគណនាយ៉ាងម៉េចប្រសិនបើនៅក្នុងពន្ធនាគារផ្សេងទៀត? | |
| 74 | លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ | 1 | ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញអាចដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យ លុះត្រាតែផុតរយៈពេលដូចតទៅ៖<br>១) ២ឆ្នាំ ចំពោះបទល្មើសឧក្រិដ្ឋ<br>២) ៦ខែ ចំពោះបទល្មើសមជ្ឈិម<br>៣) ១ខែ ចំពោះបទល្មើសលហុ។ | សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់និងមេធាវី | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 2 | រយៈពេលចាប់ផ្តើមគិតពីពេលអនុវត្តទោសរួច ឬពេលទោសត្រូវផុតអាជ្ញាយុកាល។ | សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងមេធាវី | | | |
| | | 3 | ពាក្យសុំអាចត្រូវធ្វើដោយៈ<br>១) ទណ្ឌិតជានីតិជន ដែលបានប្រព្រឹត្តបទល្មើសកាលខ្លួននៅជាអនីតិជន<br>២) អ្នកតំណាងដែលច្បាប់បានកំណត់របស់ទណ្ឌិតជាអនីតិជន។ | សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ | អនីតិជន ទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ និងមេធាវី | | | |
| 75 | ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់ | 1 | ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់ ត្រូវធ្វើឡើងនៅពេលផុតរយៈពេលដូចតទៅៈ<br>១) ៣ឆ្នាំ ចំពោះបទឧក្រិដ្ឋ<br>២) ១ឆ្នាំ ចំពោះបទមជ្ឈិម<br>៣) ៣ខែ ចំពោះបទលហុ។ | អនីតិជន ទំនាស់នឹងច្បាប់ | ក្រសួងយុត្តិធម៌ | រយៈពេលចាប់ផ្តើមគិតពេលអនុវត្តទោសរួច ឬ ពេលទោសត្រូវផុតអាជ្ញាយុកាល | | |
| 76 | ការបង្កើតមណ្ឌលយុវនីតិសម្បទា | 1 | មណ្ឌលយុវនីតិសម្បទាត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រងអនីតិជន និងក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច។ | ក្រសួងសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | ត្រូវកំណត់ដោយអនុក្រឹត្យ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 77 | ការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា | 1 | មណ្ឌលឃុំនីតិសម្បទាត្រូវបានបែងចែកជា ៣ផ្នែកដាច់ដោយឡែកពីគ្នា៖<br>១) ផ្នែកឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន<br>២) ផ្នែកឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្ដារនីតិសម្បទា<br>៣) ផ្នែកត្រៀមដោះលែងអនីតិជនដើម្បីទទួលកម្មវិធីសមាហរណកម្ម។ | ក្រសួងសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | | | |
| | | 2 | បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ | មណ្ឌលឃុំនីតិសម្បទា | ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | |
| 78 | បញ្ជីឈ្មោះអនីតិជន | 1 | គ្រប់មណ្ឌលឃុំនីតិសម្បទាត្រូវមានបញ្ជីឈ្មោះ នីតិវិធី និងព័ត៌មានផ្សេងទៀតដាច់ដោយឡែកពីគ្នាសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន។ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ | មណ្ឌលឃុំនីតិសម្បទា | ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 79 | គោលបំណងនៃការឃុំខ្លួន | 1 | គោលបំណងនៃការឃុំខ្លួនអនីតិជនត្រូវធ្វើឡើងដើម្បីស្តារនីតិសម្បទា រួមបញ្ចូលទាំងការបណ្តុះបណ្តាល ការព្យាបាលការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈ។ | ក្រសួងសង្គមកិច្ច | មណ្ឌលឃុំនីតិសម្បទា | គោលបំណងគឺជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិតនិងមានប្រយោជន៍ដល់សង្គមជាតិ | | |
| | | 2 | មន្ត្រីមណ្ឌលឃុំនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជនត្រូវទទួលបានការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រសុខុមាលភាព បទដ្ឋានជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងកុមារនិងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព។ | ក្រសួងសង្គមកិច្ច | មណ្ឌលឃុំនីតិសម្បទា | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 80 | សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ | 1 | សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំមានដូចជា៖<br>១) សិទ្ធិទទួលបានការសិក្សាអប់រំ<br>២) សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្មរួមមានការដាក់ឲ្យនៅឯកាការដាក់កំហិតឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ<br>៣) សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជន<br>៤) សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុងអំពីសិទ្ធិនិងកាតព្វកិច្ច<br>៥) សិទ្ធិផ្ដល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី<br>៦) សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្ដល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់អ្នកទំនុកបម្រុង និងមេធាវី<br>៧) សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្ដិ<br>៨) សិទ្ធិទទួលបានយន្តការបណ្ដឹងប្រកបដោយប្រសិទ្ធភាពនិងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន<br>៩) សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។ | មណ្ឌលឃុំរនីតិសម្បទា | អនីតិជនទំនាស់នឹងច្បាប់ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 81 | សេវាសម្រាប់អនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា | 1 | អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាត្រូវផ្ដល់សេវាដល់អនីតិជនដែលជាប់ឃុំ ដូចខាងក្រោម៖<br>១) ការពារ ថែទាំ និងផ្ដល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន<br>២) ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល<br>៣) សិក្សាអប់រំ បណ្ដុះបណ្ដាល វិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ<br>៤) សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប<br>៥) ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជនជាប់ឃុំនូវព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។<br>៦) សេវាផ្សេងទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលជួយអនីតិជនក្នុងការអភិវឌ្ឍសក្ដានុពលរបស់ខ្លួនឲ្យក្លាយជាពលរដ្ឋល្អម្នាក់ក្នុងសង្គម និងជួយឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង។ | ក្រសួងសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ អ្នកតំណាងដែលច្បាប់បានកំណត់ មេធាវី ចៅក្រម និងព្រះរាជអាជ្ញា | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 82 | ការរក្សាអនីតិជន | 1 | អនីតិជនត្រូវរក្សាក្នុងមណ្ឌលឃុំនីតិសម្បទាដូចខាងក្រោម៖<br>១) អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន<br>២) អាគារដាច់ដោយឡែកតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន<br>៣) អនីតិជនភេទស្រីត្រូវបានថែទាំដោយបុគ្គលិកស្រី<br>៤) អនីតិជនមានជំងឺឆ្លង ត្រូវនៅក្នុងអគារដោយឡែក និងដឹកជញ្ជូនដោយមធ្យោបាយដោយឡែក។ | ក្រសួងសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | | | |
| | | 2 | ប្រសិនបើអនីតិជនឈានដល់អាយុ ១៨ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសក្នុងមណ្ឌលឃុំនីតិសម្បទា ត្រូវបន្តនៅក្នុងមណ្ឌលរហូតដល់អាយុក្រោម ២៤ឆ្នាំ។ | ក្រសួងសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | បែបបទនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| | | 3 | នៅពេលអនីតិជនឈានចូលអាយុ ២៤ឆ្នាំ ត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន។ | ក្រសួងសង្គមកិច្ច | អនីតិជនទំនាស់នឹងច្បាប់ | បែបបទនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិតត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | |
| 83 | ចំណាត់ថ្នាក់សន្តិសុខនៅក្នុងមណ្ឌលយុវនីតិសម្បទា | 1 | ចំណាត់ថ្នាក់សន្តិសុខសម្រាប់អនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុតនិងត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ | មណ្ឌលយុវនីតិសម្បទា | ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | |
| 84 | ភ្នាក់ងារក្នុងមណ្ឌលយុវនីតិសម្បទា | 1 | ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវតែទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិ កុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវដកហូតសិទ្ធិសេរីភាព។ | ក្រសួងសង្គមកិច្ច | មណ្ឌលយុវនីតិសម្បទា | | តើកម្រិតអប្បបរមានៃការបណ្តុះបណ្តាលនៅត្រឹមណា ? តើការបណ្តុះបណ្តាលនេះត្រូវធ្វើប៉ុន្មានដង ? | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 85 | ការធ្វើអធិការកិច្ចមណ្ឌលឃុំនីតិសម្បទា | 1 | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលឃុំនីតិសម្បទា ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន។ | អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ | មណ្ឌលឃុំនីតិសម្បទា | ធ្វើអធិការកិច្ចជាប្រចាំ | តើពាក្យថាជាប្រចាំនេះស្ថិតក្នុងកម្រិតណា ? | |
| | | 2 | មន្ត្រីមានសមត្ថកិច្ចធ្វើការទូទាំងប្រទេស ដែលអនុញ្ញាតដោយច្បាប់ មានសិទ្ធិធ្វើទស្សនៈកិច្ចក្នុងមណ្ឌលឃុំនីតិសម្បទាបាន។ | មណ្ឌលឃុំនីតិសម្បទា | មណ្ឌលឃុំនីតិសម្បទា និងកុមារទំនាស់នឹងច្បាប់ | មន្ត្រីមានសមត្ថកិច្ចគ្រប់ពេលវេលា | | |
| 86 | បទបញ្ញត្តិទាក់ទិននឹងចៅក្រម | 1 | ចៅក្រម និងព្រះរាជអាជ្ញាដែលត្រូវបានចាត់តាំងឲ្យទទួលបន្ទុករឿងក្តីកុមារតាមបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់មានចៅក្រមជំនាញទាក់ទិននឹងកុមារ។ | ព្រះរាជអាជ្ញា ចៅក្រម | គ្រប់ស្ថាប័នពាក់ព័ន្ធ | | | |
| 87 | នគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកអនីតិជន | 1 | នគរបាលយុត្តិធម៌ដែលកំពុងចាត់ការរឿងក្តីអនីតិជនតាមបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវចាត់ការបន្តរហូតដល់មាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន។ | មន្ត្រីនគរបាលយុត្តិធម៌ | គ្រប់ស្ថាប័នពាក់ព័ន្ធ | | | |

| មាត្រា | ចំណងជើងមាត្រា | ចំណុច | កាតព្វកិច្ច | អ្នកចូលរួមអនុវត្ត | អ្នកដែលពាក់ព័ន្ធ | វិធានការអនុវត្ត | បញ្ហា | ច្បាប់ដែលពាក់ព័ន្ធ |
|---|---|---|---|---|---|---|---|---|
| 88 | មណ្ឌលយុវនីតិសម្បទា | 1 | វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា។ | | | បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | តើនេះមានន័យថា មាត្រាទាំងអស់មិនអនុវត្ត ឬក៏មាត្រាណាដែលអាចអនុវត្តចំពោះមណ្ឌលស្តារនីតិសម្បទា? | |
| 89 | អវសានប្បញ្ញត្តិ | 1 | ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយ រយៈពេល៦ខែ ទើបយកមកអនុវត្ត។ | គ្រប់ភាគីពាក់ព័ន្ធ | គ្រប់ស្ថាប័នពាក់ព័ន្ធ | បន្ទាប់ពីចូលជាធរមានទូទាំងប្រទេស | | |

# ឧបសម្ព័ន្ធ២

# តារាងសកម្មភាព
# នៃ
# ផែនការប្រតិបត្តិ

២០១៨ - ២០២០

# មាតិកា

## ឧបសម្ព័ន្ធ២


១. ផែនការប្រតិបត្តិ 142

១.១. សេចក្តីផ្តើម 142

១.២. គោលការណ៍នៃអភិក្រម 142

១.៣. កម្មវិធីយុទ្ធសាស្រ្តតាមផ្នែកនីមួយៗ 142

# ១. ផែនការប្រតិបត្តិ

## ១.១. សេចក្តីផ្តើម

នៅក្នុងផែនការប្រតិបត្តិ មានសកម្មភាពជាច្រើនតាមផ្នែកកម្មវិធីយុទ្ធសាស្ត្រនីមួយៗ។ ផែនការប្រតិបត្តិកំណត់ស្ថាប័នដឹកនាំអនុវត្តនិងពេលវេលាសម្រាប់អនុវត្តសកម្មភាពនីមួយៗ។ ផែនការនេះមានទាំងសកម្មភាពដែលជាការទទួលខុសត្រូវរបស់ក្រុមការងារអន្តរក្រសួង និងសកម្មភាពដែលជាការទទួលខុសត្រូវរបស់ស្ថាប័នឬក្រសួងពាក់ព័ន្ធទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

## ១.២. គោលការណ៍នៃអភិក្រម

សកម្មភាពរួមមួយចំនួន អាចត្រូវបានដាក់បញ្ចូលជាថ្មីនៅក្នុងកម្មវិធីយុទ្ធសាស្ត្រមួយចំនួន។ សកម្មភាពរួមទាំងនោះទាក់ទងនឹងការបង្កើតធនធាន ការគ្រប់គ្រងថ្នាក់ជាតិ និងគោលនយោបាយ និងធានាឲ្យមានប្រព័ន្ធមួយដ៏ត្រឹមត្រូវ បញ្ចៀសការធ្វើការងារជាន់គ្នា និងការចំណាយធនធានទ្វេដង។ សកម្មភាពទាំងនោះផ្តោតទៅលើការងារសម្របសម្រួលថ្នាក់ជាតិឲ្យមានប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហាប្រឈមនានា។ សកម្មភាពរួមភាគច្រើនត្រូវអនុវត្តនៅក្នុងរយៈពេល១២ខែដំបូងនៃផែនការ។ ក្រសួងនិងស្ថាប័នពាក់ព័ន្ធអាចចាប់ផ្តើមអនុវត្តសកម្មភាពតាមផ្នែករបស់ខ្លួន ទៅតាមសមត្ថភាពរបស់ស្ថាប័នខ្លួន ។

## ១.៣. កម្មវិធីយុទ្ធសាស្ត្រតាមផ្នែកនីមួយៗ

កម្មវិធីយុទ្ធសាស្ត្រតាមផ្នែកនីមួយៗសម្រាប់ការអនុវត្តក្នុងរយៈពេល ៣ឆ្នាំរួមមាន៖

១. ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង
២. ការអប់រំ និងបណ្តុះបណ្តាល
៣. ភ្នាក់ងារសង្គមកិច្ច
៤. ការបង្វែរ
៥. ការធ្វើសមាហរណកម្ម
៦. ការឃុំខ្លួន
៧. ការទប់ស្កាត់បទល្មើស
៨. ក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធប្រតិបត្តិ
៩. ការពិនិត្យតាមដាន និងវាយតម្លៃ

## កម្មវិធីយុទ្ធសាស្ត្រទី១៖ ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង

**គោលបំណងទូទៅ៖**

ដើម្បីឲ្យមានការទំនាក់ទំនង និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព សន្ទុះនៃការអនុវត្តប្រកបដោយចីរភាព ការប្រើប្រាស់ធនធានដោយប្រសិទ្ធភាព និងបង្កើនការគាំទ្រដល់ផ្នែកផ្សេងៗសម្រាប់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនដោយជោគជ័យ។ ប្រើប្រាស់ក្រុមការងារអន្តរក្រសួងថ្មី និងយន្តការដែលមានស្រាប់ ដើម្បីបង្កើនការទំនាក់ទំនងឲ្យមានប្រសិទ្ធភាពនៅគ្រប់កម្រិត ប្រើប្រាស់ធនធានដោយប្រសិទ្ធភាព បញ្ជៀសការបំពេញការងារជាន់គ្នា និងសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិស្កត ។

**សមិទ្ធផលទី១៖** ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដែលមានការចូលរួមជាពិសេសពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធឯទៀត។ ក្រុមការងារនេះមានតួនាទីសម្របសម្រួលកិច្ចសហប្រតិបត្តិការ ប្រមូលនិងផ្សព្វផ្សាយព័ត៌មាន ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំកម្មវិធី។

**សមិទ្ធផលទី២៖** មានយុទ្ធសាស្ត្រក្នុងការទំនាក់ទំនង ដើម្បីគាំទ្រឲ្យមានការផ្លាស់ប្តូរទាំងផ្នត់គំនិត និងការអនុវត្តរបស់សហគមន៍និងប្រព័ន្ធព័ត៌មានចំពោះអនីតិជនទំនាស់នឹងច្បាប់ ស្របតាមអភិក្រមសិទ្ធិកុមារ ។

**សមិទ្ធផលទី៣៖** បានពង្រឹងការផ្សព្វផ្សាយព័ត៌មាន និងការទំនាក់ទំនងផ្តល់ព័ត៌មាន ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឲ្យមានប្រសិទ្ធភាព និងរក្សាសន្ទុះក្នុងការផ្លាស់ប្តូរការអនុវត្ត ដោយបង្កើតឲ្យមានគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម (Facebook) មួយសម្រាប់បញ្ហាកុមារ។

**សមិទ្ធផលទី៤៖** សមត្ថភាពរបស់គណៈកម្មាធិការដែលមានស្រាប់ ត្រូវបានពង្រឹងនៅក្នុងផ្នែកយុត្តិធម៌ ក៏ដូចជាផ្នែកសុខុមាលភាពកុមារនិងគ្រួសារ ដើម្បីចាត់ចែងការទទួលខុសត្រូវលើការអនុវត្ត និងសហប្រតិបត្តិការ ក្នុងគោលបំណងគាំទ្រដល់អភិក្រមប្រព័ន្ធបែបកុមារមជ្ឈមណ្ឌលឲ្យមានប្រសិទ្ធភាពសម្រាប់ការងារយុត្តិធម៌អនីតិជន។

## កម្មវិធីយុទ្ធសាស្ត្រទី២ ៖ ការអប់រំ និងការបណ្តុះបណ្តាល

**គោលបំណងរួម៖**

ដើម្បីរៀបចំនិងប្រើប្រាស់ ធនធាន កម្មវិធីបណ្តុះបណ្តាលនិងអប់រំច្បាប់ស្តីពីយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងគាំទ្រដល់ការផ្លាស់ប្តូរគោលការណ៍និងការអនុវត្តការងារ និងពង្រឹងសមត្ថភាពការងាររបស់បុគ្គលិក ។

**សមិទ្ធផលទី៥៖** បានបង្កើនសមត្ថភាពរបស់បុគ្គលិកក្នុងផ្នែកយុត្តិធម៌អនីតិជន តាមរយៈការផ្តល់ការពន្យល់ជាទូទៅ និងលម្អិត តាមរយៈកម្មវិធីបណ្តុះបណ្តាល និងមេរៀនសម្រាប់ការអនុវត្ត។

**សមិទ្ធផលទី៦៖** ទទួលបានប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលស្តីពីច្បាប់យុត្តិធម៌អនីតិជននិងការអនុវត្ត ដែលប្រកបដោយចីរភាព។

## កម្មវិធីយុទ្ធសាស្ត្រទី៣៖ ភ្នាក់ងារសង្គមកិច្ច

**គោលបំណងទូទៅ៖** ដើម្បីបង្កើតភ្នាក់ងារសង្គមកិច្ចដែលឆ្លើយតបទៅនឹងការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

**សមិទ្ធផលទី៧៖** បានបង្កើតក្របខណ្ឌអនុវត្តការងារ និងការចែងអំពីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច ៣ប្រភេទ។

**សមិទ្ធផលទី៨៖** អនុវត្តប្រព័ន្ធផ្តល់នីតិសម្បទា ការតែងតាំង និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច។

**សមិទ្ធផលទី៩៖** តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច ចូលរួមចំណែកជាវិជ្ជមានដល់កុមារ ដែលឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ និងជួយដល់ការអនុវត្តអភិក្រមសិទ្ធិកុមារ។

## កម្មវិធីយុទ្ធសាស្ត្រទី៤៖ ការបង្វែរ

**គោលបំណងរួម៖** ដើម្បីអនុវត្តការបង្វែរ និងវិធានការផ្សេងទៀតក្រៅពីការឃុំខ្លួនប្រកបដោយប្រសិទ្ធភាព និងធានាថាការឃុំខ្លួនគឺជាជម្រើសចុងក្រោយ និងមានរយៈពេលខ្លីបំផុត។

**សមិទ្ធផលទី១០៖** អនុវត្តយន្តការយុត្តិធម៌នៅថ្នាក់សហគមន៍ដោយផ្ដោតលើការបង្វែរ ដើម្បីដំណោះស្រាយបញ្ហាកុមារទំនាស់នឹងច្បាប់ កាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី ដោយមិនចាំបាច់បញ្ជូនទៅឃុំខ្លួន ឬត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការឡើយ។

**សមិទ្ធផលទី១១៖** ទទួលបានប្រព័ន្ធបង្វែរ ឬការចេញសេចក្តីព្រមានរបស់នគរបាល ដែលភ្ជាប់ទំនាក់ទំនងកុមារទំនាស់នឹងច្បាប់ទៅនឹងសេវាកម្ម និងមានការគាំទ្រ។

**សមិទ្ធផលទី១២៖** ប្រើប្រាស់កិច្ចប្រជុំដោះស្រាយបញ្ហាដើម្បីប្រមូលព័ត៌មានឲ្យបានត្រឹមត្រូវ និងសម្របសម្រួលផែនការបង្វែរ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព។

## កម្មវិធីយុទ្ធសាស្ត្រទី៥៖ ការធ្វើសមាហរណកម្ម

**គោលបំណងរួម៖**

កម្មវិធីរៀបចំមុនពេលដោះលែង និងផែនការសមាហរណកម្ម ត្រូវបានអនុវត្ត យ៉ាងមានប្រសិទ្ធភាព ដើម្បីធ្វើសមាហរណកម្មកុមារដែលកំពុងជាប់ឃុំទៅក្នុងសង្គមដោយជោគជ័យ ហើយអត្រាបទល្មើសជាថ្មីនឹងធ្លាក់ចុះ។

**សមិទ្ធផលទី១៣៖** មានសេវាសង្គមកិច្ច ហើយភ្នាក់ងារសង្គមកិច្ចមានសមត្ថភាពរៀបចំផែនការ និងគ្រប់គ្រងការធ្វើសមាហរណកម្ម។

**សមិទ្ធផលទី១៤៖** មានកម្មវិធីសម្រាប់កុមារកំពុងជាប់ឃុំ ដើម្បីត្រៀមធ្វើសមាហរណកម្មឲ្យបានជោគជ័យក្រោយពេលដោះលែង។

**សមិទ្ធផលទី១៥៖** និយោជក ស្ថាប័នអប់រំ និងស្ថាប័នសាសនា គាំទ្រដល់ការបង្វែរកុមារទៅក្នុងសហគមន៍វិញ។

## កម្មវិធីយុទ្ធសាស្ត្រទី៦៖ ការឃុំខ្លួនអនីតិជន

**គោលបំណងរួម៖**

ការផ្តោតយកចិត្តទុកដាក់ក្នុងពេលឃុំខ្លួនអនីតិជន គឺសំដៅទៅលើការស្តារនីតិសម្បទាអនីតិជន និងផ្តល់ឲ្យអនីតិជននូវមុខជំនាញ ដើម្បីធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍ បន្ទាប់ពីមានការដោះលែង និងធ្វើយ៉ាងណាកុំឲ្យមានការប្រព្រឹត្តបទល្មើសសារជាថ្មី ។

**សមិទ្ធផលទី១៦៖** ចំនួនកុមារក្នុងពន្ធនាគារនាពេលបច្ចុប្បន្នត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ដោយសារវាជាបញ្ហា បន្ទាន់ដែលត្រូវដោះស្រាយដើម្បីឲ្យកុមារអាចត្រូវបានបង្វែរចេញពីកន្លែងឃុំឃាំង។

**សមិទ្ធផលទី១៧៖** កម្មវិធីការងារ និងទីកន្លែងស្នាក់នៅ រួមទាំងសម្ភារៈប្រើប្រាស់ផង ត្រូវបានវាយតម្លៃ ហើយ លក្ខខណ្ឌមួយចំនួនត្រូវបានកែលម្អសម្រាប់កុមារនៅក្នុងពន្ធនាគារ។

**សមិទ្ធផលទី១៨៖** យន្តការបណ្តោះអាសន្នត្រូវបានកំណត់ដើម្បីស្នើសុំអាគារ ឬផ្នែកមួយចំនួននៃពន្ធនាគារដែលមានស្រាប់ធ្វើជាមណ្ឌលយុវនីតិសម្បទា ដើម្បីធ្វើឲ្យបញ្ញត្តិស្តីពីការស្តារនីតិសម្បទា និងការដោះលែងដោយមានលក្ខខណ្ឌ អាចអនុវត្តបាន និងសម្រាប់បញ្ជៀសកុមារដែលទើបតែមកថ្មី មិនឲ្យចូលក្នុងប្រព័ន្ធពន្ធនាគារដែលមានស្រាប់។

**សមិទ្ធផលទី១៩៖** មណ្ឌលយុវនីតិសម្បទាត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីស្តារនីតិសម្បទា និងត្រៀមធ្វើសមាហរណកម្មទៅក្នុងសហគមន៍។

## កម្មវិធីយុទ្ធសាស្ត្រទី៧៖ ការទប់ស្កាត់បទល្មើស

**គោលបំណងរួម៖**

ដើម្បីកៀរគរ អប់រំ និងជួយសហគមន៍ឲ្យចេះកំណត់អត្តសញ្ញាណ និងកសាងប្រព័ន្ធការពារ ដើម្បីគាំទ្របុគ្គលម្នាក់ៗ និងកាត់បន្ថយការប្រព្រឹត្តបទល្មើស ។

**សមិទ្ធផលទី២០៖** បានបង្កើនសមត្ថភាពផ្នែកសុខុមាលភាពកុមារ និងផ្នែកសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណកុមារងាយនឹងប្រព្រឹត្តបទល្មើស ហើយបញ្ជូនកុមារ និងគ្រួសារទៅទទួលសេវាសមរម្យ។

**សមិទ្ធផលទី២១៖** បានពង្រឹងកម្មវិធីដែលមានស្រាប់សម្រាប់ជួយដល់គ្រួសារ និងកុមារងាយរងគ្រោះ ឲ្យយល់ដឹងពីអាកប្បកិរិយាវិជ្ជមាន និងទំនាក់ទំនងល្អ ដែលអាចជួយពួកគេមិនឲ្យប្រព្រឹត្តបទល្មើស ហើយពង្រីកកម្មវិធីជាក់លាក់ ឬក៏បង្កើតកម្មវិធីថ្មីសម្រាប់កុមារប្រសិនបើចាំបាច់។

**សមិទ្ធផលទី២២៖** បានពង្រឹងទំនាក់ទំនងរវាងសហគមន៍ និងនគរបាលតាមរយៈការបង្កើតឲ្យមានយន្តការដោះស្រាយជម្លោះនៅសហគមន៍ដោយនគរបាលនៅថ្នាក់មូលដ្ឋាន ដើម្បីកាត់បន្ថយបទល្មើសដែលប្រព្រឹត្តដោយកុមារ និងកាត់បន្ថយអត្រាប្រព្រឹត្តបទល្មើសជាថ្មី។

## កម្មវិធីយុទ្ធសាស្ត្រទី៨៖ ក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធប្រតិបត្តិ

**គោលបំណងរួម៖**

ដើម្បីបង្កើតអភិក្រមប្រព័ន្ធតែមួយសម្រាប់អនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលធានាការគ្រប់គ្រងកុមារនីមួយៗឲ្យមានប្រសិទ្ធភាព។

**សមិទ្ធផលទី២៣៖** ប្រព័ន្ធយុត្តិធម៌អនីតិជនមួយត្រូវបានបង្កើតឡើង ដែលបង្កើនការគ្រប់គ្រងកុមារម្នាក់ៗឲ្យមានប្រសិទ្ធភាពដោយប្រើប្រាស់អភិក្រមសិទ្ធិកុមារជាមូលដ្ឋាន។

**សមិទ្ធផលទី២៤៖** មានប្រព័ន្ធគ្រប់គ្រងសំណុំរឿងឬករណីកុមារ ដែលមានប្រសិទ្ធភាពក្នុងការប្រមូលនិងផ្តល់ព័ត៌មាន។

**សមិទ្ធផលទី២៥៖** ធានាការរក្សាការសម្ងាត់នៃអត្តសញ្ញាណ និងកំណត់ហេតុរបស់កុមារ។

**សមិទ្ធផលទី២៦៖** ការបង្វែររបស់សាលាដំបូង ត្រូវបានអនុវត្តតាមនីតិវិធីកុមារមេត្រី និងស្របតាមការអនុវត្តល្អរបស់ប្រទេសដទៃ។

## កម្មវិធីយុទ្ធសាស្ត្រទី៩៖ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

**គោលបំណងទូទៅ៖** ដើម្បីរៀបចំប្រព័ន្ធប្រមូលទិន្នន័យ ពិនិត្យមើល វាយតម្លៃ និងរាយការណ៍ពីការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ និងពីបទពិសោធន៍របស់កុមារទំនាស់នឹងច្បាប់។

**សមិទ្ធផលទី២៧៖** បានអនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងប្រមូលនិន្នន័យដើម្បីគាំទ្រដល់ការអនុវត្តដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ។

**សមិទ្ធផលទី២៨៖** បានពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធផ្នែកប្រព័ន្ធយុត្តិធម៌អនីតិជន ក្នុងការធ្វើផែនការគ្រប់គ្រងការផ្លាស់ប្តូរពិនិត្យមើលការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្រផ្អែកលើភស្តុតាងក្នុងការសម្រេចចិត្ត។

## កម្មវិធីយុទ្ធសាស្ត្រទី១៖ ការសម្របសម្រួល ការគ្រប់គ្រង និងការទំនាក់ទំនង

**គោលបំណងទូទៅ៖** ដើម្បីឲ្យមានការទំនាក់ទំនង និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព សន្ទុះនៃការអនុវត្តប្រកបដោយចីរភាពការប្រើប្រាស់ធនធានដោយប្រសិទ្ធភាព និងបង្កើនការគាំទ្រដល់ផ្នែកផ្សេងៗសម្រាប់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនដោយជោគជ័យ។ ប្រើប្រាស់ក្រុមការងារអន្តរក្រសួងថ្មី និងយន្តការដែលមានស្រាប់ ដើម្បីបង្កើនការទំនាក់ទំនងឲ្យមានប្រសិទ្ធភាពនៅគ្រប់កម្រិត ប្រើប្រាស់ធនធានដោយប្រសិទ្ធភាព បញ្ចៀសការបំពេញការងារជាន់គ្នា និងសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិស្ថិត ។

**សមិទ្ធផលទី១៖** ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើង ដែលមានការចូលរួមជាពិសេសពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធឯទៀត។ ក្រុមការងារនេះមានតួនាទីសម្របសម្រួលកិច្ចសហប្រតិបត្តិការ ប្រមូលនិងផ្សព្វផ្សាយព័ត៌មាន ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំកម្មវិធី។

**សមិទ្ធផលទី២៖** មានយុទ្ធសាស្ត្រក្នុងការទំនាក់ទំនង ដើម្បីគាំទ្រឲ្យមានការផ្លាស់ប្តូរទាំងផ្នត់គំនិត និងការអនុវត្តរបស់សហគមន៍និងប្រព័ន្ធព័ត៌មានចំពោះអនីតិជនទំនាស់នឹងច្បាប់ស្របតាមអភិក្រមសិទ្ធិកុមារ ។

**សមិទ្ធផលទី៣៖** បានពង្រឹងការផ្សព្វផ្សាយព័ត៌មាន និងការទំនាក់ទំនងផ្តល់ព័ត៌មាន ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឲ្យមានប្រសិទ្ធភាព និងរក្សាឆន្ទៈក្នុងការផ្លាស់ប្តូរការអនុវត្ត ដោយបង្កើតឲ្យមានគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម (Facebook) មួយសម្រាប់បញ្ហាកុមារ។

**សមិទ្ធផលទី៤៖** បានពង្រឹងសមត្ថភាពសមាសភាពគណៈកម្មាធិការដែលមានស្រាប់នៅក្នុងផ្នែកយុត្តិធម៌ និងផ្នែកសុខុមាលភាពកុមារនិងគ្រួសារ ដើម្បីចាត់ចែងការទទួលខុសត្រូវលើការអនុវត្ត និងសហប្រតិបត្តិការ ក្នុងគោលបំណងគាំទ្រដល់អភិក្រមប្រព័ន្ធបែបកុមារមជ្ឈមណ្ឌលឲ្យមានប្រសិទ្ធភាពសម្រាប់ការងារយុត្តិធម៌អនីតិជន។

**សមិទ្ធផលទី ១** ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើង មានការចូលរួមជាពិសេសពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធឯទៀត។ ក្រុមការងារនេះមានតួនាទី សម្របសម្រួលកិច្ចសហប្រតិបត្តិការ ប្រមូលនិងផ្សព្វផ្សាយព័ត៌មាន ពិនិត្យតាមដាន វាយតម្លៃ និងរៀបចំកម្មវិធី។

## សូចនាករ ១.a ភាគរយនៃសូចនាករវាយតម្លៃផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិ ជាវិជ្ជមាន។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១.១. ក្រុមការងារអន្តរក្រសួងបានសម្របសម្រួលឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែល្អក្នុងចំណោមស្ថាប័នពាក់ព័ន្ធរបស់រដ្ឋ បានបង្កើនប្រសិទ្ធភាពការទំនាក់ទំនង និងការអនុវត្តផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិប្រកបដោយប្រសិទ្ធភាព | ១.១.ក. ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើង | ១.១.១. បង្កើតក្រុមការងារអន្តរក្រសួងផ្លូវការមួយដែលមានសមាសភាពតំណាងមកពីក្រសួងពាក់ព័ន្ធនានា | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ | X | | | | | | ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| | ១.១.ខ. លក្ខខណ្ឌការងាររបស់ក្រុមការងារអន្តរក្រសួង ត្រូវបានអនុម័ត | ១.១.២. បង្កើតកិច្ចព្រមព្រៀងលើលក្ខខណ្ឌការងារសម្រាប់ក្រុមការងារអន្តរក្រសួង | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ | X | | | | | | ក្រសួងមហាផ្ទៃ |
| | ១.១.គ. ចំនួនបុគ្គលិករបស់ស្ថាប័នពាក់ព័ន្ធផ្សេងៗដែលត្រូវបានតែងតាំងឲ្យចូលរួមក្នុងក្រុមការងារអន្តរក្រសួង ដោយមានការបែងចែកការទទួលខុសត្រូវ និងចាប់ផ្តើមដំណើរការ | ១.១.៣. តែងតាំងបុគ្គលិកពីស្ថាប័នផ្សេង ឲ្យចូលរួមក្នុងក្រុមការងារអន្តរក្រសួង ដោយមានភារកិច្ចច្បាស់លាស់ និងចាប់ផ្តើមដំណើការ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ | | X | | | | | ក្រសួងមហាផ្ទៃ |
| | ១.១.ឃ. ចំនួនសមាជិកក្រុមការងារអន្តរក្រសួងដែលត្រូវបានបណ្តុះបណ្តាល | ១.១.៤. ពង្រឹងសមត្ថភាពក្រុមការងារអន្តរក្រសួងដើម្បីអាចគ្រប់គ្រងការផ្លាស់ប្តូរនិងសម្របសម្រួលកិច្ចសហប្រតិបត្តិការ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ | | X | | | | | ក្រសួងមហាផ្ទៃ |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១.១.ង. ចំនួនក្រសួងពាក់ព័ន្ធនានាដែលបានដាក់បញ្ចូលសកម្មភាពនៃផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិទៅក្នុងផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ខ្លួន និងផែនការថវិកាប្រចាំឆ្នាំ | ១.១.៥. ក្រសួងពាក់ព័ន្ធដាក់បញ្ចូលសកម្មភាពផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ ទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន | ក្រសួងសង្គមកិច្ច<br>ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ | | X | X | | X | | |
| | ១.១.ច. បានរៀបចំផែនទីស្តីពីប្រព័ន្ធដែលមាននាពេលបច្ចុប្បន្ន និងបានចងក្រងទុកជាឯកសារស្តីពីដំណើរការនៃការអនុវត្ត និងការវិភាគលើការចំណាយ | ១.១.៦. នេះគឺជាសកម្មភាពរួម៖ រៀបចំផែនទីស្តីពីប្រព័ន្ធដែលមានបច្ចុប្បន្ន ដើម្បីរកចំណុចជាន់គ្នា បែបបទហួសសម័យកាល កាតព្វកិច្ចផ្លូវច្បាប់ ឯកសារពាក់ព័ន្ធផ្សេងៗ និងការចំណាយ (អានកម្មវិធីយុទ្ធសាស្ត្រទី៨) | ក្រសួងសង្គមកិច្ច<br>ក្រសួងយុត្តិធម៌<br>ក្រសួងមហាផ្ទៃ | | X | | | | | |
| ១.២. ក្រុមការងារអន្តរក្រសួង បានប្រើប្រាស់គណៈកម្មាធិការផ្សេងទៀត និងយន្តការដែលមានស្រាប់ ដើម្បីផ្សព្វផ្សាយ និងប្រមូលព័ត៌មានប្រកបដោយប្រសិទ្ធភាព | ១.២.ក. ផែនទីស្តីពីគណៈកម្មាធិការ អង្គការពាក់ព័ន្ធ និងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជនត្រូវបានរៀបចំឡើង | ១.២.១. រៀបចំឲ្យមានផែនទីស្តីពីបណ្តាញអង្គការ គណៈកម្មាធិការដែលមានស្រាប់ និងប្រព័ន្ធទិន្នន័យ ដោយផ្តោតជាពិសេសទៅលើយុត្តិធម៌ ផ្លូវច្បាប់ រដ្ឋបាលមូលដ្ឋាន និងផ្នែកសុខុមាលភាពគ្រួសារ និងកុមារ | ក្រុមការងារអន្តរក្រសួង ឬក្រសួងសង្គមកិច្ច | | | X | | | | គកនក |
| ១.៣. ក្រុមការងារអន្តរក្រសួង បានសម្របសម្រួលក្របខណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព | ១.៣.ក. សូចនាករត្រូវបានកំណត់ ហើយឧបករណ៍ប្រមូលទិន្នន័យ និងប្រព័ន្ធចងក្រង ប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យ ត្រូវបានបង្កើត | ១.៣.១. នេះគឺជាសកម្មភាពរួមមួយ៖ កំណត់សូចនាករសម្រាប់ការវាយតម្លៃនីមួយៗ ឧបករណ៍ប្រមូលទិន្នន័យ និងប្រព័ន្ធដើម្បីចងក្រង ប្រមូល និង ផ្ទៀងផ្ទាត់ទិន្នន័យ (អានកម្មវិធីយុទ្ធសាស្ត្រទី៩) | ក្រុមការងារអន្តរក្រសួង | | X | | X | X | X | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១.១.ខ. ទិន្នន័យគោលមួយសម្រាប់ពិនិត្យមើលការចាប់ផ្ដើមការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិត្រូវបានបង្កើតឡើង | ១.៣.២. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតទិន្នន័យគោលមួយ សម្រាប់ការចាប់ផ្ដើមអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ ដោយរួមមានការវិភាគលើការចំណាយនៃប្រព័ន្ធបច្ចុប្បន្ន (អានកម្មវិធីយុទ្ធសាស្ត្រទី៩) | ក្រសួងសង្គមកិច្ច | X | X | | | | | |
| | ១.៣.គ. បោះពុម្ពរបាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្តគម្រោង (សូមមើលកម្មវិធីយុទ្ធសាស្ត្រទី៩) | ១.៣.៣. ការចងក្រង ការប្រមូល ការផ្ទៀងផ្ទាត់ ការវិភាគទិន្នន័យ ការរាយការណ៍ និងការបោះពុម្ពទិន្នន័យ | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |

**សមិទ្ធផលទី ២** មានយុទ្ធសាស្ត្រក្នុងការទំនាក់ទំនង ដើម្បីគាំទ្រឲ្យមានការផ្លាស់ប្ដូរទាំងផ្នត់គំនិតនិងការអនុវត្តរបស់សហគមន៍និងប្រព័ន្ធព័ត៌មានចំពោះអនីតិជនទំនាស់នឹងច្បាប់ ស្របតាមអភិក្រមសិទ្ធិកុមារ

## សូចនាករ ២.ក បង្កើនការផ្សព្វផ្សាយអប់រំ និងការទទួលយករបស់សហគមន៍នូវអភិក្រមសិទ្ធិកុមារក្នុងការអនុវត្តចំពោះអនីតិជនទំនាស់នឹងច្បាប់ គោលការណ៍ ផលប្រយោជន៍ និងការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២.១. សហគមន៍ និងបណ្ដាញសារព័ត៌មានទទួលបានសារនិងព័ត៌មានដែល | ២.១.ក. របាយការណ៍សិក្សាស្រាវជ្រាវត្រូវបានរៀបចំឡើងនិងចែកចាយ | ២.១.១. ធ្វើការសិក្សាស្រាវជ្រាវគំរូមួយដើម្បីកំណត់និងបញ្ជាក់ពីរបៀបនៃការប្រើប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្ននិងឥរិយាបថរបស់សហគមន៍ដើម្បីទុកជាព័ត៌មានសម្រាប់វាស់វែង | ក្រុមការងារអន្តរក្រសួង ក្រសួងសង្គមកិច្ច | X | | | | | | គ.ក.ន.ក ក.ជ.ក. |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ពន្យល់ពីអភិក្រមសិទ្ធិកុមារដែលត្រូវអនុវត្តសម្រាប់យុត្តិធម៌អនីតិជន និងពន្យល់ពីផលប្រយោជន៍ចំពោះសហគមន៍ក្នុងការអនុវត្តអភិក្រមនេះ | ២.១.ខ. ផែនការយុទ្ធសាស្ត្រក្នុងការទំនាក់ទំនងជាមួយសាពត៌មាន និងសង្គមស៊ីវិល ត្រូវបានបង្កើតឡើងហើយឯកសារសំខាន់ៗត្រូវបានរៀបចំ | ២.១.២. បង្កើតផែនការយុទ្ធសាស្ត្រក្នុងាការទំនាក់ទំនងជាមួយសាពត៌មាននិងសង្គមស៊ីវិល ហើយជ្រើសរើសទីប្រឹក្សាដើម្បីរៀបចំឯកសារសំខាន់ៗ | ក្រុមការងារអន្តរក្រសួង | | X | | | | | |
| | ២.១.គ. មានទិន្នន័យអំពីសារដែលមាននៅលើប្រព័ន្ធផ្សព្វផ្សាយ ទាំងវិជ្ជមាន និងអវិជ្ជមាន និងសារដែលផ្ទុយនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ២.១.៣. រៀបចំឯកសារសម្រាប់អ្នកសារព័ត៌មានដោយរួមបញ្ចូលច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងសិទ្ធិកុមារ | ក្រុមការងារអន្តរក្រសួង | | | X | | | | |
| | ២.១.ឃ. %នៃប្រជាពលរដ្ឋដែលបានយល់ដឹងអំពីយុត្តិធម៌អនីតិជន | ២.១.៤. ចែកសម្ភារៈអប់រំដល់សហគមន៍ដោយប្រើប្រាស់បញ្ជីទិន្នន័យស្តីពីសហគមន៍ | ក្រសួងមហាផ្ទៃ ក្រុមការងារអន្តរក្រសួង | | | X | | X | | |
| | ២.១.ង. ចំនួនដងនៃព័ត៌មានដែលបានចុះផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយ | ២.១.៥. ពង្រឹងសមត្ថភាពក្រុមការងារអន្តរក្រសួង ក្នុងការទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្តល់ជូនជាទៀងទាត់នូវព័ត៌មានខ្លីៗ និង សេចក្តីប្រកាសព័ត៌មានពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន | ក្រុមការងារអន្តរក្រសួង | | | X | | | | |
| | ២.១.ច. %នៃអ្នកប្រើប្រាស់ និងអត្រានៃអ្នកពេញចិត្ត (សូម មើលកម្មវិធីយុទ្ធសាស្ត្រទី៩) | ២.១.៦. ពង្រឹងសមត្ថភាពក្រុមការងារអន្តរក្រសួងដើម្បីសម្របសម្រួលនិងគ្រប់គ្រងការងាររៀបចំគេហទំព័រ និងគណនីទំព័រ Facebook ជាលក្ខណៈអាជីព | ក្រុមការងារអន្តរក្រសួង | | | X | | | | |

| សមិទ្ធផលទី ៣ | បានពង្រឹងការផ្សព្វផ្សាយព័ត៌មាន និងការទំនាក់ទំនងផ្តល់ព័ត៌មាន ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឲ្យមានប្រសិទ្ធភាព និងរក្សាឆន្ទៈក្នុងការផ្លាស់ប្តូរការអនុវត្ត ដោយបង្កើតឲ្យមានគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ( Facebook ) មួយសម្រាប់បញ្ហាកុមារ |
|---|---|

## សូចនាករ ៣.ក មានពត៌មាន និង ឯកសារនៅតាមអ៊ីនធឺណែតដែលអ្នកអានអាចទាញយកបានដោយងាយស្រួល ហើយវាយតម្លៃថាមានប្រយោជន៍

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៣.១. គេហទំព័រ និង គណនីទំព័រ Facebook ផ្តល់ពត៌មាន និងឯកសារថ្មីៗស្តីពីការអនុវត្តល្អៗ និងការផ្លាស់ប្តូរ | ៣.១.ក. គេហទំព័រជាផ្លូវការ ត្រូវបានដាក់ឲ្យប្រើប្រាស់ | ៣.១.១. រៀបចំផែនការបង្កើតគេហទំព័រ និងជ្រើសរើសអ្នករចនាគេហទំព័រ | ក្រុមការងារ អន្តរក្រសួង | | X | X | | | | យូនីសេហ្វ អ.ស.ស |
| | ៣.១.ខ. ចំនួនស្ថាប័នពាក់ព័ន្ធចូលអានគេហទំព័រហើយវាយតម្លៃថាមានយោជន៍ | ៣.១.២. ដាក់ឲ្យដំណើរការគេហទំព័រជាផ្លូវការ | ក្រុមការងារ អន្តរក្រសួង | | | X | | | | យូនីសេហ្វ អ.ស.ស |
| | ៣.១.គ. %នៃការធ្វើបច្ចុប្បន្នភាពគេហទំព័រប្រចាំខែនៅក្នុងផ្នែកនីមួយៗ និង%នៃស្ថាប័នពាក់ព័ន្ធដែលចូលរួមផ្តល់ឯកសារ | ៣.១.៣. នេះគឺជាសកម្មភាពរួមមួយ៖ បន្តប្រមូលឯកសារពាក់ព័ន្ធដែលមានដូចជាករណីសិក្សា ឯកសារសម្រាប់អនុវត្ត ឯកសារស្តីពីវគ្គបណ្តុះបណ្តាល លទ្ធផលនៃការវាយតម្លៃ និងព័ត៌មានផ្សេងទៀត ដើម្បីធ្វើបច្ចុប្បន្នភាពប្រចាំខែ | ក្រុមការងារ អន្តរក្រសួង | | | X | X | X | X | អ.ស.ស |
| ៣.២. ពង្រឹងសមត្ថភាពគេហទំព័រ ក្នុងការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន | ៣.២.ក. %នៃវគ្គសិក្សាតាមអ៊ីនធឺណែតទៅតាមផ្នែកនីមួយៗដែលត្រូវបានបញ្ចប់ | 3.2.1. រៀបចំ និងលើកទឹកចិត្ត ឲ្យមានការបង្កើតនិងការចែករំលែកឯកសារបណ្តុះបណ្តាលតាមអ៊ីនធឺណែតនិងឯកសារជាសម្លេងដើម្បីជួយដល់ការបណ្តុះបណ្តាលបុគ្គលិកសង្គមកិច្ចជាលក្ខណៈអាជីព | ក្រុមការងារ អន្តរក្រសួង | | | | | | X | |

| **សមិទ្ធផលទី ៤** | សមត្ថភាពរបស់គណៈកម្មាធិការដែលមានស្រាប់ ត្រូវបានពង្រឹងក្នុងផ្នែកយុត្តិធម៌និងផ្នែកសុខុមាលភាពកុមារ និងគ្រួសារ ដើម្បីចាត់ចែង ការទទួលខុសត្រូវលើការអនុវត្តនិងសហប្រតិបត្តិការ ក្នុងគោលបំណងគាំទ្រដល់អភិក្រមប្រព័ន្ធបែបកុមារមជ្ឈមណ្ឌលឲ្យមានប្រសិទ្ធភាពសម្រាប់ការងារយុត្តិធម៌អនីតិជន |
|---|---|

## សូចនាករ ៤.ក ៖ ចំនួនគណៈកម្មាធិការដែលរៀបចំផែនការសកម្មភាព ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៤.១. ឧត្តមមន្ត្រីអនុវត្តច្បាប់មានការទទួលខុសត្រូវលើការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានទំនាក់ទំនងផ្តល់ការណែនាំបន្តនិងមានការអនុវត្តនៅថ្នាក់មូលដ្ឋាន | ៤.១.ក. ចំនួនខេត្តដែលបានបណ្តុះបណ្តាលឧត្តមមន្ត្រីអនុវត្តច្បាប់ និងចំនួនមន្ត្រីឯកទេសខាងកុមារដែលបានតែងតាំង | ៤.១.១. បង្កើនសមត្ថភាពឧត្តមមន្ត្រីអនុវត្តច្បាប់ឲ្យទទួលយកការអនុវត្ត និងនីតិវិធីដែលតម្រូវដោយច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ក្រសួងយុត្តិធម៌ | | X | X | X | | | |
| ៤.២. គ.ក.ន.ក មានសមត្ថភាពក្នុងការគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ៤.២.ក. ចំនួនគ.ក.ន.ក ដែលបានទទួលការបណ្តុះបណ្តាល | ៤.២.១. ផ្តល់ការបណ្តុះបណ្តាល និង ធនធានដល់ គ.ក.ន.ក ដើម្បីដើរតួនាទី នៅក្នុងសហគមន៍សម្រាប់ការអនុវត្តកម្មវិធីបង្វែរ សមាហរណកម្ម និងកម្មវិធីទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ | ក្រសួងមហាផ្ទៃ | X | X | X | X | | | |
| | ៤.២.ខ. ចំនួនភ្នាក់ងារសង្គមកិច្ច និងអ្នកឯកទេសខាងកុមារដែលបានចូលជា សមាជិក គ.ក.ន.ក | ៤.២.២. បញ្ចូលភ្នាក់ងារសង្គមកិច្ច ដែលបានជ្រើសតាំងហើយ និងអ្នកឯកទេសខាង កុមារទៅក្នុងគ.ក.ន.ក | ក្រសួងមហាផ្ទៃ | | X | X | | | | |

## កម្មវិធីយុទ្ធសាស្រ្តទី២ ៖ ការអប់រំ និងការបណ្តុះបណ្តាល

**គោលបំណងរួម៖**

ដើម្បីរៀបចំនិងប្រើប្រាស់ ធនធាន កម្មវិធីបណ្តុះបណ្តាលនិងអប់រំច្បាប់ស្តីពីយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព ក្នុងគោលបំណងគាំទ្រដល់ការផ្លាស់ប្តូរគោលការណ៍និងការអនុវត្តការងារ និងពង្រឹងសមត្ថភាពការងាររបស់បុគ្គលិក ។

កម្មវិធីយុទ្ធសាស្រ្តនេះទទួលស្គាល់ថា ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឲ្យបានជោគជ័យតម្រូវឲ្យមានការផ្លាស់ប្តូរគោលការណ៍និងការអនុវត្ត មានធនធាន មានកម្មវិធីអប់រំ និង ការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព។ ការផ្លាស់ប្តូរទាំងនេះអាចប្រឆាំងនឹងជំនឿ និងការអនុវត្តពីមុនមក។ ប៉ុន្តែជំនឿ និងការអនុវត្តដែលមិនល្អ គួរត្រូវបានពិចារណាក្នុងការផ្លាស់ប្តូរដើម្បីជាប្រយោជន៍ដល់កុមារនិងសង្គម។ ដើម្បីឈានទៅរកការផ្លាស់ប្តូរនេះ ជំហ៊ានទី១ ត្រូវមានការយល់ដឹងពីសំណាក់មន្រ្តីអនុវត្តច្បាប់និងសហគមន៍តាមរយៈការបង្កើតកម្មវិធីអប់រំផ្សព្វផ្សាយនិងការបណ្តុះបណ្តាល។ ជំហានជាបន្ទាប់ គឺត្រូវបង្កើតអ្នកជំនាញ និងអ្នកបណ្តុះបណ្តាលនៅក្នុងស្ថាប័នពាក់ព័ន្ធនីមួយៗ។ វគ្គបណ្តុះបណ្តាលជំនាញជាន់ខ្ពស់នឹងត្រូវបង្កើតឡើងសម្រាប់អ្នកដែលដើរតួនាទីជាអ្នកជំនាញនីមួយៗ។ សកម្មភាពសម្របសម្រួល និងទំនាក់ទំនងមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីទទួលបានឯកសារនានានិងគាំទ្រដល់ការបង្កើតជំនាញ។ ការអប់រំនៅតាមសហគមន៍ក៏ជារឿងសំខាន់ដើម្បីឲ្យពួកគេព្រមទទួលយក និង ចូលរួមអនុវត្តការបង្វែរ និងសមាហរណកម្ម។ ការអប់រំនៅតាមសហគមន៍នេះ ដែលជាផ្នែកមួយនៃកម្មវិធីយុទ្ធសាស្រ្តទី១ តម្រូវឲ្យមានធនធានចម្រុះ និងការផ្សព្វផ្សាយ។

**សមិទ្ធផលទី៥៖** បានបង្កើនសមត្ថភាពរបស់បុគ្គលិកក្នុងផ្នែកយុត្តិធម៌អនីតិជន តាមរយៈការផ្តល់ការពន្យល់ជាទូទៅ និងលម្អិត តាមរយៈកម្មវិធីបណ្តុះបណ្តាលនិងមេរៀនសម្រាប់ការអនុវត្ត។

---

**សមិទ្ធផលទី៦៖** ទទួលបានប្រព័ន្ធមួយស្តីពីការអប់រំ និងបណ្តុះបណ្តាលពាក់ព័ន្ធនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងការអនុវត្តប្រកបដោយចីរភាព ហើយដែលអាចទទួលយកបាន និងមានតម្លៃនៅគ្រប់ដំណាក់កាល។

**សមិទ្ធផលទី ៥** បានបង្កើនសមត្ថភាពរបស់បុគ្គលិកក្នុងផ្នែកយុត្តិធម៌អនីតិជន តាមរយៈការផ្តល់ការពន្យល់ជាទូទៅ និងលម្អិត តាមរយៈកម្មវិធីបណ្តុះបណ្តាល និងមេរៀនសម្រាប់ការអនុវត្ត

## សូចនាករទី៥.ក៖ សៀវភៅមេរៀនដែលមានការពន្យល់ មេរៀនសម្រាប់បង្រៀន និងមេរៀនសម្រាប់អនុវត្តរបស់បុគ្គលិកទាំងអស់ ដែលធ្វើការជាមួយកុមារ ផ្តល់ការណែនាំយ៉ាងច្បាស់លាស់អំពីកុមារទំនាស់នឹងច្បាប់ និងប្រព័ន្ធយុត្តិធម៌

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៥.១. មានសៀវភៅស្តីពីការអនុវត្ត ពីកម្មវិធីបណ្តុះបណ្តាល និងពីពត៌មានទូទៅនិងជាក់លាក់ ដែលស្របតាមក្របខណ្ឌការងារពង្រឹងសម្ថភាពផ្នែកទំនាក់ទំនងជាមួយកុមារ | ៥.១.ក. ក្របខណ្ឌការងារពង្រឹងសម្ថភាពផ្នែកទំនាក់ទំនងជាមួយកុមារ ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង | ៥.១.១. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតក្របខណ្ឌការងារពង្រឹងសម្ថភាពផ្នែកទំនាក់ទំនងជាមួយកុមារ ដែលមានចែងពីតម្រូវការខាងចំណេះដឹង ជំនាញ អាកប្បកិរិយា (កម្រិតមូលដ្ឋាន ជំនាញ និងឧត្តម) ហើយដែលក្របខណ្ឌការងារនេះនឹងត្រូវប្រើប្រាស់ក្នុងការបង្កើតតំណែងការងារ ការតែងតាំង និតិវិធីផ្តល់នីតិសម្បទា គោលបំណងបណ្តុះបណ្តាល និងការវាយតម្លៃការងារ | ក្រុមការងារអន្តរក្រសួង ក្រសួងសង្គមកិច្ច | X | | | | | | |
| | ៥.១.ខ. ប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង និងដាក់ឲ្យអនុវត្ត | ៥.១.២. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានទាំងតួនាទី ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដំណើរការនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តសាកល្បង | ក្រសួងយុត្តិធម៌ | X | X | | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា ( ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ៥.១.គ. %នៃស្ថាប័ន ដែលបាន ដាក់បញ្ចូលកម្មវិធីអប់រំកម្រិត មូលដ្ឋានស្តីពីយុត្តិធម៌អនីតិជន ចូលក្នុងកម្មវិធីបណ្តុះបណ្តាល | ៥.១.៣. នេះគឺជាសកម្មភាពរួមមួយ៖ ការរៀបចំឲ្យមាន កម្មវិធីអប់រំកម្រិតមូលដ្ឋានស្តីពីយុត្តិធម៌អនីតិជនដែលជា ផ្នែកមួយនៃ ក្របខណ្ឌការងារពង្រឹងសមត្ថភាព ហើយ ដាក់បញ្ចូលកម្មវិធីអប់រំនេះទៅក្នុងកម្មវិធីបណ្តុះបណ្តាល ដែលមានរួចហើយ | ក្រុមការងារ អន្តរក្រសួង | | X | | | | | |
| | ៥.១.ឃ. ចំនួនស្ថាប័ន ដែលបាន ដាក់បញ្ចូលកម្មវិធីអប់រំកម្រិតឧត្តម ស្តីពីយុត្តិធម៌អនីតិជនទៅក្នុងកម្ម វិធីបណ្តុះបណ្តាលដែលមានស្រាប់ | ៥.១.៤. ការរៀបចំឲ្យមានកម្មវិធីអប់រំកម្រិតឧត្តមស្តីពី យុត្តិធម៌អនីតិជនដែលជាផ្នែកមួយនៃ ក្របខណ្ឌការងារ ពង្រឹងសមត្ថភាព ហើយដាក់បញ្ចូលកម្មវិធីអប់រំនេះទៅ ក្នុងកម្មវិធីបណ្តុះបណ្តាលដែលមានស្រាប់ | ក្រុមការងារ អន្តរក្រសួង | | | | | | | |
| | ៥.១.ង. ចំនួនស្ថាប័ន ដែលបាន ដាក់បញ្ចូលកម្មវិធីអប់រំកម្រិត ឯកទេសស្តីពីយុត្តិធម៌អនីតិជន ទៅក្នុងកម្មវិធីបណ្តុះបណ្តាល ដែលមានស្រាប់។ លក្ខខណ្ឌ ផ្តល់នីតិសម្បទា និងការតែងតាំង ត្រូវបានបង្កើតឡើង។ | ៥.១.៥. រៀបចំមេរៀនកម្រិតឯកទេស ដើម្បីជួយគាំទ្រ ដល់មន្ត្រីដែលជាអ្នកគ្រប់គ្រង ប្រធាន គ្រូបង្គោល។ បង្កើតលក្ខខណ្ឌផ្តល់នីតិសម្បទា និងការតែងតាំងអ្នក ឯកទេសដែលច្បាប់ស្តីពីយុត្តិធម៌អនីតិជនតម្រូវឲ្យមាន។ ដាក់បញ្ចូលមេរៀនថ្នាក់ឯកទេសនេះក្នុងកម្មវិធី បណ្តុះបណ្តាលដែលមានស្រាប់។ | ក្រុមការងារ អន្តរក្រសួង | | X | X | | | | |
| | ៥.១.ច. របាយការណ៍ប្រចាំឆ្នាំស្តីពី ធនធានបណ្តុះបណ្តាល និងការ ប្រើប្រាស់ | ៥.១.៦. វាយតម្លៃប្រចាំឆ្នាំលើធនធានបណ្តុះបណ្តាល ទាំងអស់ ដើម្បីកំណត់ផ្នែកដែលត្រូវកែលម្អ និងកង្វះខាត ផ្នែកចំណេះដឹង | ក្រុមការងារ អន្តរក្រសួង | | | X | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៥.២. មានប្រព័ន្ធទិន្នន័យស្ដីពីធនធាននិងការបណ្ដុះបណ្ដាលជាអាជីព ដែលមានការធ្វើបច្ចុប្បន្នភាព មានកម្មវិធីនិងឯកសារបណ្ដុះបណ្ដាលទំនាក់ទំនងផ្សព្វផ្សាយ ឯកសារថ្មីៗការពិនិត្យមើល និងការវាយតម្លៃលើការអនុវត្ត | ៥.២.ក. មានប្រព័ន្ធទិន្នន័យស្ដីពីធនធាននិងការបណ្ដុះបណ្ដាលជាអាជីពដែលបែងចែកតាមស្ថាប័ន | ៥.២.១. រៀបចំទម្រង់អង្កេតមួយសម្រាប់ឲ្យស្ថាប័នពាក់ព័ន្ធទាំងអស់បំពេញ ដើម្បីយល់ដឹងពីចំនួនធនធានដែលមាន កម្មវិធីបណ្ដុះបណ្ដាល និងប្រព័ន្ធយុត្តិធម៌អនីតិជន | ក្រុមការងារអន្តរក្រសួង ក្រសួងសង្គមកិច្ច | X | | | | | | |
| | ៥.២.ខ. ប្រព័ន្ធទិន្នន័យស្ដីពីការអប់រំ និងការបណ្ដុះបណ្ដាលជាអាជីព ត្រូវបានដាក់ឲ្យដំណើរការ | ៥.២.២. វិភាគទិន្នន័យដើម្បីប៉ាន់ប្រមាណពីសេចក្ដីត្រូវការធនធាន និងការបណ្ដុះបណ្ដាល និងចែកចាយព័ត៌មានអំពីធនធាន ការបណ្ដុះបណ្ដាល និងការគាំទ្រ | ក្រុមការងារអន្តរក្រសួង | X | X | | | | | |
| | ៥.២.គ. ប្រព័ន្ធទិន្នន័យស្ដីពីការអប់រំ និងការបណ្ដុះបណ្ដាលជាអាជីពត្រូវបានពិនិត្យមើល | ៥.២.៣. ធ្វើតេស្តពិនិត្យមើលប្រសិទ្ធភាពនៃប្រព័ន្ធទិន្នន័យស្ដីពីការអប់រំនិងបណ្ដុះបណ្ដាលជាអាជីព ដោយមានការវាយតម្លៃលើឯកសារដែលប្រើប្រាស់ និងការឆ្លើយតបតាមសំណើ | ក្រុមការងារអន្តរក្រសួង | | | | X | | | |
| ៥.៣. បុគ្គលិកក្នុងស្ថាប័នពាក់ព័ន្ធមានសមត្ថភាពក្នុងការធ្វើការជាមួយកុមារទំនាស់នឹងច្បាប់ ស្របទៅតាមកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន | ៥.៣.ក. ចំនួនស្ថាប័ន ដែលអនុញ្ញាតឲ្យបុគ្គលិកចូលរួមក្នុងសិក្ខាសាលាបណ្ដុះបណ្ដាល និងកម្រិតនៃការពេញចិត្តរបស់អ្នកចូលរួមមានពិន្ទុ ៧ លើ ១០ | ៥.៣.១. នេះគឺជាសកម្មភាពរួម៖ កំណត់ពេលវេលាសម្រាប់បណ្ដុះបណ្ដាល ដល់អ្នកពាក់ព័ន្ធទាំងអស់ | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី គ.ក.ន.ក ក្រសួងការងារ ក្រសួងអប់រំ ក្រសួងសុខាភិបាល |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ៥.៣.ខ. បទដ្ឋានឯកទេសត្រូវបានបង្កើតឡើង និងអនុវត្តសម្រាប់ប្រព័ន្ធតែងតាំងអ្នកឯកទេស | ៥.៣.២ បង្កើតបទដ្ឋានឯកទេស និងដំណើរការ នៃការតែងតាំង ការពិនិត្យមើល និងដំណើរការតែងតាំងឡើងវិញសម្រាប់នគរបាល ព្រះរាជអាជ្ញារ ចៅក្រម និងបុគ្គលិកធ្វើការនៅកន្លែងឃុំខ្លួន។ ការងារនេះក៏រួមបញ្ចូលបទដ្ឋានសម្រាប់ដឹកនាំ និងការគ្រប់គ្រងអ្នកឯកទេសផងដែរ។ បទដ្ឋាននេះ នឹងត្រូវបានកំណត់ដោយផ្អែកលើក្របខណ្ឌការងារកសាងសមត្ថភាពសម្រាប់ធ្វើការជាមួយកុមារ។ | ក្រុមការងារអន្តរក្រសួង | | x | | | | | ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច |
| | ៥.៣.គ. ក្រុមការងារបណ្តុះបណ្តាលត្រូវបានបង្កើតឡើងសម្រាប់ស្ថាប័នពាក់ព័ន្ធនីមួយៗ | ៥.៣.៣. កំណត់អ្នកជំនាញ និងគ្រូបង្គោល ទៅតាមផ្នែកជំនាញនីមួយៗ និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ថែមទៀតតាមរយៈការបណ្តុះបណ្តាលនិងការប៉ាន់ប្រមាណ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ | | x | | | | | |
| | ៥.៣.ឃ. % នៃបុគ្គលិកដែលទទួលការបណ្តុះបណ្តាលនៅក្នុងស្ថាប័នពាក់ព័ន្ធនីមួយៗ | ៥.៣.៤. ស្ថាប័នពាក់ព័ន្ធនីមួយៗបង្កើត និងកំណត់ពេលវេលាបណ្តុះបណ្តាលដល់បុគ្គលិក | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ | X | X | X | X | | | |
| | ៥.៣.ង. %នៃការធ្វើបច្ចុប្បន្នភាពគេហទំព័រប្រចាំខែនៅក្នុងផ្នែកនីមួយៗ និង%នៃស្ថាប័នពាក់ព័ន្ធដែលចូលរួមផ្តល់ឯកសារ | ៥.៣.៥. នេះគឺជាសកម្មភាពរួមមួយ៖ បន្តប្រមូលឯកសារពាក់ព័ន្ធដែលមានដូចជាករណីសិក្សា ឯកសារសម្រាប់អនុវត្ត ឯកសារស្តីពីវគ្គបណ្តុះបណ្តាល លទ្ធផលនៃការវាយតម្លៃ និងព័ត៌មានផ្សេងទៀត ដើម្បីធ្វើបច្ចុប្បន្នភាពប្រចាំខែ | ក្រុមការងារអន្តរក្រសួង | | | X | X | X | X | ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច |

## សមិទ្ធផលទី ៦ ទទួលបានប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលស្តីពីច្បាប់យុត្តិធម៌អនីតិជននិងការអនុវត្ត ដែលប្រកបដោយចីរភាព

### សូចនាករទី៦.ក៖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៦.១ សមត្ថភាពរបស់ក្រុមការងារអន្តរក្រសួងត្រូវបានពង្រឹង តាមរយៈការបណ្តុះបណ្តាល | ៦.១.ក. មានទិន្នន័យស្តីពីវគ្គបណ្តុះបណ្តាល និងស្ថាប័នដែលពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន | ៦.១.១. កំណត់ឲ្យដឹងពីវគ្គបណ្តុះបណ្តាលពាក់ព័ន្ធទាំងអស់ ដែលមាននិយាយពីយុត្តិធម៌អនីតិជន | ក្រុមការងារអន្តរក្រសួង | X | | | | | | |
| | ៦.១.ខ. ចំនួនអ្នកអប់រំ និងអ្នកគ្រប់គ្រងវគ្គបណ្តុះបណ្តាលដែលបានចូលរួម និង % នៃវគ្គបណ្តុះបណ្តាលដែលដាក់បញ្ចូលករណីសិក្សានិងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ៦.១.២. រៀបចំសន្និសីទសម្រាប់អ្នកអប់រំនិងអ្នកគ្រប់គ្រងវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់យុត្តិធម៌អនីតិជន ឯកសារដែលមាន បទដ្ឋានស្តីពីការអនុវត្ត និងការបង្កើតប្រព័ន្ធ | ក្រុមការងារអន្តរក្រសួង | X | X | X | | | | ស្ថាប័នអប់រំទាំងអស់ |
| | ៦.១.គ. កម្មវិធីបណ្តុះបណ្តាលនិងឯកសារផ្សេងៗ ត្រូវបានបង្កើតឡើងតាមរយៈ ភាពជាដៃគូជាមួយស្ថាប័ជំនាញ | ៦.១.៣. គាំទ្រភាពជាដៃគូជាមួយស្ថាប័នជំនាញក្នុងនិងក្រៅប្រទេស ដើម្បីរៀបចំឯកសារផ្សេងៗ ការបណ្តុះបណ្តាលគ្រូបង្គោល និងសិស្ស ដើម្បីកសាងសមត្ថភាពក្រុមការងារអន្តរក្រសួង | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |

# កម្មវិធីយុទ្ធសាស្ត្រទី៣៖ ភ្នាក់ងារសង្គមកិច្ច

**គោលបំណងទូទៅ៖**

កម្មវិធីយុទ្ធសាស្ត្រផ្នែកនេះ ទទួលស្គាល់តួនាទីដ៏សំខាន់របស់ភ្នាក់ងារសង្គមកិច្ចក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ដែលជាផ្នែកមួយនៃការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងអភិក្រមបែបសិទ្ធិកុមារ។ ជំនាញនិងឯកទេសសម្រាប់តួនាទី និងការទទួលខុសត្រូវផ្សេងៗ ដែលមានចែងនៅក្នុងច្បាប់ តម្រូវឲ្យមានការបង្កើតភ្នាក់ងារសង្គមកិច្ចជា៣ប្រភេទ៖

- អ្នកប្រឹក្សាយោបល់កុមារ៖ ផ្តោតសំខាន់ទៅលើការគាំទ្រកុមារ និងផ្តល់ឲ្យកុមារនូវទំនាក់ទំនងដ៏រឹងមាំ និងការតស៊ូមតិ។
- មន្ត្រីបម្រើការងារនៅតុលាការ៖ ផ្តោតសំខាន់លើការគ្រប់គ្រងកុមារតាមរយៈប្រព័ន្ធយុត្តិធម៌ និងសម្របសម្រួលផ្តល់ព័ត៌មានរវាងសហគមន៍ កុមារ និងមន្ត្រីតុលាការ ។
- បុគ្គលិកសង្គមកិច្ចថ្នាក់ឃុំ៖ ជាអ្នកបម្រើការងារនៅក្នុងសហគមន៍ដើម្បីផ្លាស់ប្តូរអត្តចរិក ពិភាក្សាជាមួយជនរងគ្រោះ ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មកុមារត្រឡប់ទៅសហគមន៍វិញ។

តួនាទីមួយចំនួន (មានបញ្ចាក់រួចហើយនៅក្នុងផ្នែកសុខុមាលភាពកុមារ និងគ្រួសារ និងផ្នែកកសាងសមត្ថភាពថ្នាក់ឃុំ) ដែលតម្រូវឲ្យមានចំណេះដឹង និងជំនាញប្រហាក់ប្រហែលគ្នា ហើយតួនាទីទាំងនេះអាចត្រូវពិនិត្យមើលឡើងវិញ ដើម្បីផ្តល់នីតិសម្បទាក្នុងតួនាទីជាភ្នាក់ងារសង្គមកិច្ចយុត្តិធម៌អនីតិជន។ កាងារនេះនឹងរៀបចំទៅតាមសកម្មភាពរួម ដែលបង្កើតនូវក្របខណ្ឌកាងារកសាងសមត្ថភាពក្នុងការទំនាក់ទំនងជាមួយកុមារ (កម្មវិធីយុទ្ធសាស្ត្រទី២)។ ការជ្រើសរើសនិងតែងតាំងភ្នាក់ងារសង្គមកិច្ច ត្រូវធ្វើឡើងក្នុងដំណាក់កាលដំបូងនៃការកសាងសមត្ថភាពបុគ្គលិកសង្គមកិច្ច និងក្នុងពេលដែលខ្វះខាតទាំងធនធានសេដ្ឋកិច្ចនិងសង្គម។ មានគម្រោងដ៏គួរឲ្យចាប់អារម្មណ៍ជាច្រើនដែលមានបំណងអភិវឌ្ឍន៍បុគ្គលិកសង្គមកិច្ច ដែលផ្សាភ្ជាប់ជាមួយនឹងផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ (ឧទាហរណ៍៖ គម្រោងស្តីពីការមើលថែកុមារនៅក្នុងគ្រួសារជាអាទិភាព អំពើហិង្សាលើកុមារ)។ តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារសង្គមកិច្ចគឺជាផ្នែកមួយដ៏សំខាន់សម្រាប់ប្រព័ន្ធយុត្តិធម៌អនីតិជន។ (កម្មវិធីយុទ្ធសាស្ត្រទី៨)

**សមិទ្ធផលទី៧៖** បានបង្កើតក្របខណ្ឌអនុវត្តការងារ និងការចែងអំពីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច៣ប្រភេទ។

**សមិទ្ធផលទី៨៖** អនុវត្តប្រព័ន្ធផ្តល់នីតិសម្បទា ការតែងតាំង និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច ។

**សមិទ្ធផលទី៩៖** តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច ចូលរួមចំណែកជាវិជ្ជមានដល់កុមារ ដែលឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ និងជួយដល់ការអនុវត្តអភិក្រមសិទ្ធិកុមារ ។

## សមិទ្ធផលទី ៧ បានបង្កើតក្របខណ្ឌអនុវត្តការងារ និងការចែងអំពីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច៣ប្រភេទ

### សូចនាករទី ៧.ក.៖ ភ្នាក់ងារសង្គមកិច្ចមានតួនាទីនិងភារកិច្ចច្បាស់លាស់

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៧.១. តួនាទីនិងភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ចត្រូវបានបង្កើតឡើងស្របតាមប្រព័ន្ធប្រតិបត្តិច្បាប់យុត្តិធម៌អនីតិជន និងបទដ្ឋានអន្តរជាតិ | ៧.១.ក. ប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង និងត្រូវបានអនុវត្ត | ៧.១.១. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានទាំងតួនាទី ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដំណើរការនៃការអនុវត្ត ប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តសាកល្បង | ក្រសួងយុត្តិធម៌ | X | | | | | | ក្រសួងសង្គមកិច្ច |
| | ៧.១.ខ. ក្របខណ្ឌការងារពង្រឹងសម្ថភាពផ្នែកទំនាក់ទំនងជាមួយកុមារ ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង | ៧.១.២. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតក្របខណ្ឌការងារពង្រឹងសម្ថភាពផ្នែកទំនាក់ទំនងជាមួយកុមារ ដែលមានចែងពីតម្រូវការខាងចំណេះដឹង ជំនាញ អាកប្បកិរិយា( កម្រិតមូលដ្ឋាន ឧត្តម និង ជំនាញ) ហើយដែលក្របខណ្ឌការងារនេះនឹងត្រូវប្រើប្រាស់ក្នុងការបង្កើតតំណែងការងារ ការតែងតាំង នីតិវិធីផ្តល់នីតិសម្បទាគោលបំណងបណ្តុះបណ្តាល និងការវាយតម្លៃការងារ | ក្រុមការងារអន្តរក្រសួង | X | | | | | | |
| ៧.២. តំណែងភ្នាក់ងារសង្គមកិច្ចត្រូវបានបង្កើត | ៧.១.គ. លក្ខណៈសម្បត្តិសម្រាប់តំណែងភ្នាក់ងារសង្គមកិច្ច ត្រូវបានអនុម័ត | ៧.១.៣. បង្កើតលក្ខណៈសម្បត្តិសម្រាប់តំណែងភ្នាក់ងារសង្គមកិច្ច ( សូមមើលកម្មវិធីយុទ្ធសាស្ត្រទី២ ) ដែលមានបញ្ជាក់ពីតម្រូវការសមត្ថភាពពាក់ព័ន្ធ | ក្រសួងសង្គមកិច្ច ក្រសួងយុត្តិធម៌ | | X | | | | | |

## សមិទ្ធផលទី ៨ ប្រព័ន្ធផ្តល់នីតិសម្បទា ការតែងតាំង និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច នឹងត្រូវបានអនុវត្តនិងលើកតម្កើង

### សូចនាករលទ្ធផល ៨.កៈ ការផ្តល់នីតិសម្បទា ការតែងតាំង និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច ត្រូវបានអនុវត្ត

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៨.១. មានប្រព័ន្ធផ្តល់នីតិសម្បទាដល់ភ្នាក់ងារសង្គមកិច្ច ដោយបញ្ចូលបុគ្គលិកដែលមាននីតិសម្បទាស្រាប់ បុគ្គលិកសង្គមកិច្ចរបស់អង្គការដែលដើរតួនាទីជាភ្នាក់ងារសង្គមកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជននិងអ្នកមើលការខុសត្រូវផ្នែកសុខភាព | ៨.១.ក. ភ្នាក់ងារសង្គមកិច្ចដែលមានស្រាប់ និងអ្នកមើលការខុសត្រូវផ្នែកសុខភាព ត្រូវបានតែងតាំង | ៨.១.១. រៀបចំនិងប្រើប្រាស់ប្រព័ន្ធផ្តល់នីតិសម្បទា ដើម្បីតែងតាំងភ្នាក់ងារសង្គមកិច្ច អ្នកមើលការខុសត្រូវផ្នែកសុខភាព សម្រាប់រយៈពេល២ឆ្នាំ ដោយផ្អែកលើៈ<br>៨.១.១.១. ការសាកល្បងក្របខណ្ឌការងារប្រតិបត្តិច្បាប់យុត្តិធម៌អនីតិជន<br>៨.១.១.២. ភ្នាក់ងារសង្គមកិច្ចដែលមានស្រាប់<br>៨.១.១.៣. តំបន់ដែលមានប្រភពធនធានសម្រាប់គាំទ្រតួនាទីបុគ្គលិកសង្គមកិច្ច<br>៨.១.១.៤. អ្នកមើលការខុសត្រូវផ្នែកសុខភាព | ក្រុមការងារអន្តរក្រសួង ឬ ក្រសួងសង្គមកិច្ច | | X | X | X | | | |
| | ៨.១.ខ. ក្រុមការងារអន្តរក្រសួងទទួលរបាយការណ៍រៀងរាល់៣ខែម្តង | ៨.១.២. ប្រមូលរបាយការណ៍ រៀងរាល់៣ខែម្តង ស្តីអំពីបុគ្គលិកសង្គមកិច្ច និង លទ្ធផលការងារ។ របាយការណ៍នេះនឹងដាក់បញ្ចូលទៅក្នុងរបាយការណ៍តាមដាន និងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ។ | ក្រសួងសង្គមកិច្ច | | X | X | X | X | X | |
| | ៨.១.គ. របាយការណ៍ស្តីពីការវាយតម្លៃប្រព័ន្ធផ្តល់នីតិសម្បទា | ៨.១.៣. ពិនិត្យមើលប្រព័ន្ធផ្តល់នីតិសម្បទា តាមរយៈការវាយតម្លៃលទ្ធផលការងារ | ក្រសួងសង្គមកិច្ច | | X | | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៨.២. សមត្ថភាពរបស់ភ្នាក់ងារសង្គមកិច្ចក្នុងការបំពេញការងារទៅតាមស្តង់ដា ត្រូវបានពង្រឹងតាមរយៈការពិនិត្យមើល និងការផ្តល់យោបល់ | ៨.២.ក. ចំនួនភ្នាក់ងារ សង្គមកិច្ចដែលវាយតម្លៃលើការងារគ្រប់គ្រងផ្នែកសុខភាព និងការផ្តល់យោបល់របស់អ្នកគ្រប់គ្រងខ្លួន ហើយដែលការវាយតម្លៃនេះ ទទួលបានពិន្ទុ ៥ លើ ៧ ឬបានពិន្ទុលើសនេះ | ៨.២.១. ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចដើម្បីផ្តល់មតិយោបល់និងគាំទ្រដល់ភ្នាក់ងារសង្គមកិច្ច | ក្រសួងសង្គមកិច្ច | | X | X | X | X | X | |
| | ៨.២.ខ. ចំនួនភ្នាក់ងារសង្គមកិច្ចដែលស្វែងរកការគាំទ្រពីអ្នកគ្រប់គ្រងផ្នែកសុខភាព វាយតម្លៃលើការគ្រប់គ្រងនេះនិងលើការផ្តល់យោបល់របស់អ្នកគ្រប់គ្រង ដោយមានពិន្ទុកម្រិត ៤លើ៧ឬលើសនេះ | ៨.២.២. តែងតាំងអ្នកទទួលបន្ទុកគ្រប់គ្រងផ្នែកសុខភាពសង្គមថ្នាក់កណ្តាល ដើម្បីផ្តល់ការគាំទ្រផ្នែកជំនាញឲ្យទាន់ពេលវេលា | ក្រសួងសង្គមកិច្ច | | X | | | | | |
| ៨.៣. ការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ចបានពង្រឹងសមត្ថភាពរបស់ភ្នាក់ងារសង្គមកិច្ចលើវិជ្ជាជីវៈរបស់ខ្លួន | ៨.៣.ក. គំរូនៃការគ្រប់គ្រងផ្នែកសុខភាពត្រូវបានរៀបចំឡើង និងចំនួនភ្នាក់ងារសង្គមកិច្ចដែលបានអនុវត្ត | ៨.៣.១. រៀបចំគំរូនៃការគ្រប់គ្រងផ្នែកសុខភាពសម្រាប់ឲ្យភ្នាក់ងារសង្គមកិច្ចដែលទទួលបាននីតិសម្បទាអនុវត្ត ហើយដាក់បញ្ចូលជាផ្នែកមួយនៃដំណើរការផ្តល់នីតិសម្បទា | ក្រសួងសង្គមកិច្ច | | X | | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ៨.៣.ខ. ប្រព័ន្ធទទួលយកគំនិតស្ថាបនា និងឧបករណ៍វាយតម្លៃការងាររួមមួយ ត្រូវបង្កើតឡើង និងត្រូវបានអនុវត្ត។ ចំនួនគំនិតស្ថាបនាដែលទទួលបានតាមរយៈប្រព័ន្ធនេះ។ ចំនួនភ្នាក់ងារសង្គមកិច្ចដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច។ | ៨.៣.២. បង្កើតប្រព័ន្ធទទួលយកគំនិតស្ថាបនា និងឧបករណ៍វាយតម្លៃការងាររួមមួយ ដើម្បីជួយដល់ក្រសួងសង្គមកិច្ចក្នុងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច រួមទាំងបុគ្គលិកសង្គមដែលមិនស្ថិតក្រោមក្រសួងផងដែរ | ក្រសួងសង្គមកិច្ច | | x | | | | | |
| | ៨.៣.គ. ចំនួនភ្នាក់ងារសង្គមកិច្ចដែលចូលរួមក្នុងកម្មវិធីនានា | ៨.៣.៣. រៀបចំបណ្តាញភ្នាក់ងារសង្គមកិច្ច ដោយមានទំនាក់ទំនងការងារជាមួយក្រុមការងារអន្តរក្រសួង | ក្រសួងសង្គមកិច្ច | | x | | | | | |

## សមិទ្ធផលទី ៩ តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច ចូលរួមចំណែកជាវិជ្ជមានដល់កុមារ ដែលឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ និងជួយដល់ការអនុវត្តអភិក្រមសិទ្ធិកុមារ

### សូចនាករទី៩.ក.៖ តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច ត្រូវបានវាយតម្លៃឲ្យដឹងពីផលវិជ្ជមានទៅលើកុមារទំនាស់នឹងច្បាប់ ដែលជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌អនីជន

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ៩.១. ការងាររបស់ភ្នាក់ងារសង្គមកិច្ច និងផលពីការងាររបស់ពួកគេចំពោះកុមារ ត្រូវបានវាយតម្លៃ និងកែលម្អជាបន្តបន្ទាប់ | ៩.១.ក. ប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង និងដាក់ឲ្យអនុវត្ត | ៩.១.១. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានទាំងតួនាទីការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដំណើរការនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តសាកល្បង | ក្រសួងយុត្តិធម៌ | X | X | X | X | X | X | UNICEF |
| | ៩.១.ខ. របាយការណ៍វាយតម្លៃស្តីពីផលដែលកើតចេញពីការបំពេញការងាររបស់ភ្នាក់ងារសង្គមកិច្ច ដោយមានបញ្ជាក់ពីការពេញចិត្តពីអត្រានៃការប្រព្រឹត្តបទល្មើសជាថ្មី និងពីការអនុវត្តតាមស្តង់ដានៃការបង្វែរ និងការធ្វើសមាហរណកម្ម | ៩.១.២. វាយតម្លៃផលពីសេវារបស់ភ្នាក់ងារសង្គមកិច្ចចំពោះកុមារ | ក្រុមការងារអន្តរក្រសួង | | | x | | | | |

## កម្មវិធីយុទ្ធសាស្ត្រទី៤៖ ការបង្វែរ

**គោលបំណងរួម៖**

ការបង្វែរ និងវិធានការផ្សេងៗក្រៅពីការឃុំខ្លួន ត្រូវបានយកមកអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថា ការឃុំខ្លួនគឺជាជម្រើសចុងក្រោយ និងមានរយៈពេលខ្លីបំផុត ។

កម្មវិធីយុទ្ធសាស្ត្រនេះទទួលស្គាល់ថា ការបង្វែរកុមារចេញពីប្រព័ន្ធតុលាការ និងចេញពីការឃុំខ្លួន គឺជាយន្តការដ៏ចម្បង ដើម្បីរារាំងកុមារកុំឲ្យប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសជាថ្មី។ ភស្តុតាងបានបញ្ជាក់ប្រាប់យើងថា នៅពេលដែលកុមារត្រូវបានឃុំខ្លួន បើទោះជារយៈពេលខ្លីក៏ដោយ ពួកគេទាំងនោះច្រើនតែបន្តប្រព្រឹត្តបទល្មើស និងច្រើនតែក្លាយជាអ្នកប្រព្រឹត្តបទល្មើសបន្តទៀតពេលធំពេញវ័យ។ ការបង្វែរគឺអាចធ្វើបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ។ នៅក្នុងដំណាក់កាលដំបូង នៅពេលដែលកុមារបានប្រព្រឹត្តបទល្មើស នគរបាលអាចចេញសេចក្ដីព្រមានដល់កុមារបាន។ ការបង្វែរកុមារត្រូវបានគេយល់ថាគឺជាយន្តការដ៏មានប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើស ។ ផែនការបង្វែរត្រូវអនុវត្តតាមលក្ខខណ្ឌរបស់កុមារម្នាក់ៗ ហើយវិធីសាស្ត្រដែលត្រូវប្រើ គឺធ្វើឡើងទៅតាមស្ថានភាពរបស់កុមារម្នាក់ៗ និងសហគមន៍។ សហគមន៍ផ្សេងគ្នា ទទួលយកប្រភេទនៃដំណោះស្រាយផ្សេងគ្នា ហើយដើម្បីឲ្យមានការទទួលយកគោលការណ៍បង្វែរពីសហគមន៍ ចាំបាច់ត្រូវតែមានការចូលរួមយ៉ាងសកម្មពីគ្រប់ស្ថាប័នពាក់ព័ន្ធ។ ផែនការបង្វែរអាចជាដំណើរការស្មុគស្មាញ ហើយតម្រូវឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធច្រើននៅពេលមានកិច្ចប្រជុំ។ ការប្រជុំដោះស្រាយបញ្ហាផ្ដល់នូវមធ្យោបាយចែករំលែកគំនិតដ៏មានប្រសិទ្ធភាព ការទទួលបាននូវកិច្ចព្រមព្រៀងបង្វែរ និងជាពិសេសគឺការចូលរួមយ៉ាងសកម្មពីកុមារ និងស្ថាប័នពាក់ព័ន្ធ។

**សមិទ្ធផលទី១០៖** អនុវត្តយន្តការយុត្តិធម៌នៅថ្នាក់សហគមន៍ដោយផ្ដោតលើការបង្វែរ ដើម្បីដោះស្រាយបញ្ហាកុមារទំនាស់នឹងច្បាប់ កាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី ដោយមិនចាំបាច់បញ្ជូនទៅឃុំខ្លួន ឬត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការឡើយ។

**សមិទ្ធផលទី១១៖** ទទួលបានប្រព័ន្ធបង្វែរ ឬការចេញសេចក្ដីព្រមានរបស់នគរបាល ដែលភ្ជាប់ទំនាក់ទំនងកុមារទំនាស់នឹងច្បាប់ទៅនឹងសេវាកម្ម និងមានការគាំទ្រ ។

**សមិទ្ធផលទី១២៖** ប្រើប្រាស់កិច្ចប្រជុំដោះស្រាយបញ្ហា ដើម្បីប្រមូលព័ត៌មានឲ្យបានត្រឹមត្រូវ និងសម្របសម្រួលផែនការបង្វែរ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព ។

## សមិទ្ធផលទី ១០ អនុវត្តយន្តការយុត្តិធម៌នៅថ្នាក់សហគមន៍ដោយផ្តោតលើការបង្វែរ ដើម្បីដោះស្រាយបញ្ហាកុមារទំនាស់នឹងច្បាប់ កាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី ដោយមិនចាំបាច់បញ្ជូនទៅឃុំខ្លួន ឬត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការឡើយ

### សូចនាករទី១០.ក.៖ អត្រាប្រព្រឹត្តបទល្មើសសារជាថ្មីធ្លាក់ចុះដោយការអនុវត្តផែនការបង្វែរដែលមានការចូលរួមគាំទ្រពីសង្គមស៊ីវិលនៅមូលដ្ឋាន

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១០.១. វិស័យយុត្តិធម៌អនីតិជនមានសមត្ថភាពក្នុងការអនុវត្តការបង្វែរ ដោយមានការប៉ាន់ប្រមាណលើកម្មវិធីបង្វែរ ការធ្វើផែនការ ការពិនិត្យតាមដាន ការរីកចម្រើនរបស់កុមារ និងការកែលម្អផែនការបង្វែរ | ១០.១.ក. គោលការណ៍ បង្វែរ ដំណើរការនៃការបង្វែរ និងសេចក្តីណែនាំនៃការបង្វែរ ត្រូវបានរៀបចំ | ១០.១.១. ប្រព័ន្ធប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានគោលការណ៍ និងដំណើរការនៃការបង្វែរ ដែលលើកទឹកចិត្តកុមារឲ្យចូលរួម មានចំណុចដូចខាងក្រោម៖<br>១០.១.១.១. ឯកសារ និងទម្រង់ផ្សេងៗសម្រាប់បំពេញ ដែលរួមមានការវាយតម្លៃលើភាពត្រឹមត្រូវរបស់កុមារក្នុងការបង្វែរ ការរៀបចំផែនការបង្វែរ កិច្ចព្រមព្រៀងទម្រង់រាយការណ៍ទៅព្រះរាជអាជ្ញា និងចៅក្រម ទម្រង់តាមដាន និងវាយតម្លៃពីភាពរីកចម្រើន<br>១០.១.១.២. ផែនទីបង្ហាញពីដំណើរការនៃការបង្វែរ ដើម្បីជួយឲ្យងាយយល់ថា ការបង្វែរនឹងត្រូវយកមកពិចារណានៅគ្រប់ដំណាក់កាលនៃរឿងក្តីរបស់កុមារ<br>១០.១.១.៣. ព្រះរាជអាជ្ញា មេធាវី ចៅក្រម និងភ្នាក់ងារសង្គមកិច្ច ត្រូវចូលរួមរៀបចំសេចក្តីណែនាំ និងករណីសិក្សា ដើម្បីទុកជាឯកសារសម្រាប់ជាចំណេះដឹង | ក្រសួងយុត្តិធម៌ | X | X | X | X | X | X | ក្រុមការងារអន្តរក្រសួង ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១០.១.ខ. ប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង និងត្រូវបានអនុវត្ត | ១០.១.២. នេះគឺជាសកម្មភាពរួមមួយៈ បង្កើតប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានទាំងតួនាទី ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដំណើរការនៃការអនុវត្ត ប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តសាកល្បង | ក្រុមការងារអន្តរក្រសួង | X | X | X | X | X | X | ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ គ.ក.ន.ក |
| | ១០.១.គ. ឯកសារស្តីពីការអនុវត្តល្អៗ ត្រូវបានចងក្រងទុកសម្រាប់ចែករំលែក | ១០.១.៣. ពិនិត្យមើល និងវាយតម្លៃផែនការបង្វែរ។ សរសេរករណីសិក្សាស្តីពីជោគជ័យដែលទទួលបានសម្រាប់ចែករំលែក។ | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | ក្រុមការងារអន្តរក្រសួង |
| | ១០.១.ឃ. ចំនួនកុមារ ដែលស្ម័គ្រចិត្តចែករំលែកបទពិសោធន៍ ឬក៏អាចធ្វើជាអ្នកផ្តល់យោបល ក្នុងរឿងបង្វែរកុមារ | ១០.១.៤. ស្នើសុំកុមារដែលបានបញ្ចប់ផែនការបង្វែរដោយជោគជ័យ ឲ្យធ្វើជាអ្នកស្ម័គ្រចិត្ត ដើម្បីចែករំលែកបទពិសោធន៍ ឬធ្វើជាអ្នកផ្តល់យោបល់ ដើម្បីជួយគាំទ្រដល់កុមារដែលកំពុងអនុវត្តផែនការបង្វែរ | | | | | X | X | X | |
| ១០.២. មានសៀវភៅរាយឈ្មោះអង្គការដែលផ្តល់សេវាសង្គមដែលមានកម្មវិធី និងធនធានសម្រាប់ជួយដល់កុមារទំនាស់នឹងច្បាប់ ហើយត្រូវបានប្រើប្រាស់ ដើម្បីជួយគាំទ្រដល់ផែនការបង្វែរប្រកបដោយប្រសិទ្ធភាព | ១០.២.ក. ចំនួនឃុំដែលបានបញ្ចប់ការពិនិត្យមើលឡើងវិញនូវកម្មវិធីផ្តល់សេវាដែលមានស្រាប់នៅថ្នាក់ឃុំ និងកង្វះខាតដែលត្រូវបំពេញ | ១០.២.១. នេះជាផ្នែកមួយនៃសកម្មភាពរួមៈ ការពិនិត្យមើលឡើងវិញនូវកម្មវិធីផ្តល់សេវាដែលមានស្រាប់នៅថ្នាក់ឃុំ (ដែលគាំទ្រកុមារ និងគ្រួសារ ជាពិសេសកុមារដែលងាយនឹងប្រព្រឹត្តបទល្មើស ឬកុមារដែលកំពុងអនុវត្តផែនការបង្វែរ ឬកំពុងធ្វើសមាហរណកម្ម) ដែលការពិនិត្យនេះត្រូវកំណត់ឲ្យបានច្បាស់នូវកម្មវិធីសម្រាប់ការបញ្ជូន និងសេចក្តីត្រូវការសម្រាប់រៀបចំកម្មវិធីជាក់លាក់នានា ដើម្បីគាំទ្រដល់ការរៀបចំសៀវភៅបញ្ជីឈ្មោះសេវាកម្មសង្គមថ្នាក់មូលដ្ឋាន (អានកម្មវិធីយុទ្ធសាស្ត្រទី៥និង៨) | ក្រសួងសង្គមកិច្ច | | X | X | X | X | X | ក្រុមការងារអន្តរក្រសួង គ.ក.ន.ក |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១០.២.ខ. ចំនួនឃុំដែលបានរៀបចំឲ្យមានសៀវភៅបញ្ជីឈ្មោះអង្គការផ្តល់សេវាកម្មសង្គមថ្នាក់មូលដ្ឋាន | ១០.២.២. នេះគឺជាសកម្មភាពរួម៖ ការរៀបចំសៀវភៅបញ្ជីឈ្មោះអង្គការផ្តល់សេវាកម្មសង្គមថ្នាក់មូលដ្ឋាន ដែលសៀវភៅនេះអាចឲ្យដឹងពីកម្មវិធីផ្តល់សេវាផ្សេងៗ ធនធាននិងកម្មវិធីគាំទ្រដល់កុមារងាយនឹងប្រព្រឹត្តបទល្មើស ការបង្វែរ និងផែនការសមាហរណកម្ម។ (អានកម្មវិធីយុទ្ធសាស្រ្តទី៥និង៨) | ក្រសួង សង្គមកិច្ច | | | X | X | X | X | ក្រុមការងារអន្តរក្រសួង គ.ក.ន.ក |
| | ១០.២.គ. ចំនួនអង្គការ ដែលប្តេជ្ញាចិត្តគាំទ្រ ផែនការបង្វែរ និងផែនការសមាហរណកម្ម និងចំនួនផែនការដែលទទួលបានការគាំទ្រ | ១០.២.៣. នេះគឺជាសកម្មភាពរួម៖ រៀបចំយុទ្ធនាការស្វែងរកការជួយគាំទ្រនៅថ្នាក់ឃុំ ដើម្បីធានាឲ្យមានការជួយផ្តល់ជាកន្លែងស្នាក់នៅ ធនធាន ការអប់រំ ការបណ្តុះបណ្តាល កម្មវិធីសេវាសង្គមផ្សេងៗ និងការផ្តល់ការងារដល់កុមារក្រោយរួចពីឃុំ ព្រមទាំងកុមារទំនាស់នឹងច្បាប់ផ្សេងទៀត ដោយមានការចូលរួមជួយយ៉ាងសកម្មពីស្ថាប័នថ្នាក់ក្រោមជាតិក៏ដូចជាភ្នាក់ងារសង្គមកិច្ចថ្នាក់ឃុំ នគរបាល អាជីវកនៅមូលដ្ឋាន សហគមន៍ និងអ្នកដឹកនាំសាសនា។ (អានកម្មវិធីយុទ្ធសាស្រ្តទី៥) | ក្រសួង សង្គមកិច្ច | | x | | | | | ក្រសួងមហាផ្ទៃ ក្រសួងអប់រំ ក្រសួងកិច្ចការនារី ក្រសួងការងារ ក្រសួងសុខាភិបាល NGOs ស្ថាប័នសាសនា គ.ក.ន.ក |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១០.៣. ប្រព័ន្ធបង្វែរប្រកបដោយប្រសិទ្ធភាពត្រូវបានបង្កើតឡើងនិងត្រូវបានដាក់ឲ្យអនុវត្ត | ១.៣.ក. ចំនួនផែនការបង្វែររយៈពេលខ្លី បានអនុវត្ត ដើម្បីបង្វែរកុមារពីការឃុំខ្លួនបណ្តោះអាសន្ន និងពីការឃាត់ខ្លួននៅដំណាក់កាលនគរបាល | ១០.៣.១. រៀបចំទម្រង់ផែនការបង្វែររយៈពេលខ្លី និងនីតិវិធី ។ ការយឺតយ៉ាវក្នុងការរៀបចំផែនការបង្វែរ នឹងមិនត្រូវយកមកធ្វើជាហេតុផលក្នុងការការឃុំខ្លួននោះទេ ដូច្នេះផែនការបង្វែររយៈពេលខ្លីគឺមានសារៈសំខាន់ណាស់។ ផែនការបង្វែររយៈពេលខ្លីដែលអនុវត្តនៅពេលឃាត់ខ្លួននេះ មានជម្រើសច្រើនសម្រាប់ឲ្យកុមារជ្រើសរើសជំនួសឲ្យការបង្ហាញខ្លួននៅតុលាការ។ | ក្រសួងយុត្តិធម៌ | | | X | X | X | X | ក្រសួងយុត្តិធម៌ |
| | ១០.៣.ខ. %នៃឃុំដែលបានរៀបចំសិក្ខាសាលាស្តីពីផែនការបង្វែរ | ១០.៣.២. ផ្សាភ្ជាប់ផែនការបង្វែរ ទៅនឹងសហគមន៍ ជាមួយនឹងការទទួលស្គាល់អាកប្បកិរិយារបស់កុមារ។ រៀបចំកិច្ចពិភាក្សានៅថ្នាក់ឃុំដោយកំណត់នូវកត្តាប្រឈម និងដំណោះស្រាយសមរម្យ ។ | ក្រសួងមហាផ្ទៃ | | X | X | | | | ក្រុមការងារអន្តរក្រសួង |
| | ១០.៣.គ %នៃផែនការបង្វែរដែលត្រូវបានបញ្ចប់ដោយជោគជ័យដោយមានការចូលរួមពីសង្គមស៊ីវិល | ១០.៣.៣. រៀបចំផែនការបង្វែរដោយមានការចូលរួមពីសង្គមស៊ីវិលនិងអង្គភាពពាក់ព័ន្ធ | ក្រសួងយុត្តិធម៌ | | x | | | | | |
| | ១០.៣.ឃ. ចំនួនកុមារដែលប្រព្រឹត្តបទល្មើសសារជាថ្មី ត្រូវបានយកមកវិភាគដោយផ្តោតលើផែនការបង្វែរ | ១០.៣.៤. ធ្វើការសិក្សាអំពីកុមារដែលត្រូវបានបង្វែរ ដើម្បីពិនិត្យមើលពីប្រសិទ្ធភាពនៃផែនការបង្វែរ និងអត្រាមិនរាងចាល បន្ទាប់មកត្រូវធ្វើការកែលម្អ | ក្រសួងយុត្តិធម៌ | | | x | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១០.៤. ដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការត្រូវបានអនុវត្ត ដើម្បីជួយឲ្យការបង្វែរ និងការធ្វើសមាហរណកម្មទទួលបានជោគជ័យ និងកាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី | ១០.៤.ក. របាយការណ៍វាយតម្លៃលើការអនុវត្តសាកល្បងនូវដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការបានផ្តល់ជាអនុសាសន៍ដោយផ្អែកលើភស្តុតាងសម្រាប់ការអនុវត្តដំណោះស្រាយនេះ | ១០.៤.១. នេះគឺជាសកម្មភាពរួមមួយ៖ អនុវត្តសាកល្បងនូវដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការផ្សេងៗដែលមានដូចជាសន្ទានកម្មដែលដឹកនាំដោយជនរងគ្រោះ កិច្ចពិភាក្សាដោយមានការចូលរួមពីភាគីពាក់ព័ន្ធនិងមានអ្នកសម្របសម្រួល ហើយដាក់បញ្ចូលដំណោះស្រាយនេះទៅក្នុងផែនការបង្វែរ និងផែនការសមាហរណកម្ម (អានកម្មវិធីយុទ្ធសាស្ត្រទី៥ និង៨) | ក្រសួងយុត្តិធម៌ | | | | X | X | X | |
| ១០.៥. សង្គមស៊ីវិលភាគច្រើនទទួលយកការបង្វែរ និងអភិក្រមសិទ្ធកុមារមកអនុវត្តចំពោះកុមារទំនាស់នឹងច្បាប់ | ១០.៥.ក. ករណីសិក្សាអំពីភាពជាដៃគូប្រកបដោយជោគជ័យរវាងក្រសួងយុត្តិធម៌ និងអង្គការនានាត្រូវបានចងក្រង និងផ្សព្វផ្សាយ | ១០.៥.១. ចងក្រងនិងផ្សព្វផ្សាយករណីសិក្សាអំពីភាពជាដៃគូប្រកបដោយជោគជ័យ ក្នុងការគាំទ្រកុមារដែលអនុវត្តផែនការបង្វែរ និងលើកទឹកចិត្តឲ្យមានការចូលរួមផ្តល់សេវាពីអង្គការដទៃទៀត | ក្រសួងយុត្តិធម៌ | | | X | X | X | X | |
| | ១០.៥.ខ. ចំនួនផែនការបង្វែរ និងផែនការសមាហរណកម្មដែលទទួលបានជោគជ័យ | ១០.៥.២. នេះគឺជាសកម្មភាពរួមមួយ៖ ធ្វើការសិក្សាអំពីភាពជោគជ័យនៃការបង្វែរ និងការធ្វើសមាហរណកម្មដោយវិភាគលម្អិតទៅលើកត្តារួមផ្សំផ្សេងៗ ដូចជាការចូលរួមរបស់សង្គមស៊ីវិល រឺគ្រួសារកុមារជាដើម | ក្រសួងយុត្តិធម៌ | | | X | X | X | X | |

**សមិទ្ធផលទី ១១** ទទួលបានប្រព័ន្ធបង្វែរ ឬការចេញសេចក្តីព្រមានរបស់នគរបាល ដែលភ្ជាប់ទំនាក់ទំនងកុមារទំនាស់នឹងច្បាប់ទៅនឹងសេវាកម្ម និងមានការគាំទ្រ។

## សូចនាករទី១១.ក.៖ ប្រព័ន្ធបង្វែរ ឬការចេញសេចក្តីព្រមានដោយនគរបាល ត្រូវបានបង្កើតឡើងនិងត្រូវបានដាក់ឲ្យអនុវត្ត

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១១.១. នគរបាលប្រើប្រាស់ប្រព័ន្ធចេញសេចក្តីព្រមានជាមួយនឹងតរិយាបថបែបកុមារមេត្រី ដើម្បីធ្វើការបង្វែរកុមារ | ១១.១.ក. ចំនួនកុមារ ដែលត្រូវបានបង្វែរ ដោយការព្រមានរបស់នគរបាល និងការវិភាគលើអត្តចរិករបស់កុមារ | ១១.១.១. រៀបចំប្រព័ន្ធចេញសេចក្តីព្រមានដោយនគរបាល ដោយមានការឆ្លើយតបយ៉ាងសមស្របទៅតាមកាលៈទេសៈ និងអាចឲ្យដឹងផងដែរថា តើការព្រមាននោះធ្លាប់មានពីមុនមកដែរឬទេ។ ការព្រមានអាចជា៖<br>១១.១.១.១. ការណែនាំ និងព្រមាន ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ<br>១១.១.១.២. ការចូលរួមរបស់គ្រួសារ នៅក្នុងការស្តាប់ចម្លើយរបស់នគរបាល<br>១១.១.១.៣. ការបញ្ជូនទៅរកសេវា និងកម្មវិធីផ្សេងៗ<br>១១.១.១.៤. ការព្រមានក្នុងដំណាក់កាលចុងក្រោយ | ក្រសួងមហាផ្ទៃ | | X | X | X | X | | ក្រសួងយុត្តិធម៌ |
| | ១១.១.ខ ចំនួននគរបាលដែលទទួលបានការបណ្តុះបណ្តាលស្តីអំពីប្រព័ន្ធចេញសេចក្តីព្រមាន | ១១.១.២. បណ្តុះបណ្តាលនគរបាលទាំងអស់ ឲ្យចេះរកជម្រើសផ្សេងៗក្នុងការចេញសេចក្តីព្រមាន ហើយយល់ពីរបៀបអនុវត្ត និង ធ្វើរបាយការណ៍អំពីការព្រមាននោះ | ក្រសួងមហាផ្ទៃ | | | X | X | X | X | ក្រសួងយុត្តិធម៌ |

<table>
<tr><th rowspan="2">លទ្ធផល</th><th rowspan="2">សូចនាករ</th><th rowspan="2">សកម្មភាព</th><th rowspan="2">ស្ថាប័ន ដឹកនាំ</th><th colspan="6">តារាងពេលវេលា (ឆ្នាំ)</th><th rowspan="2">ស្ថាប័ន ចូលរួមគាំទ្រ</th></tr>
<tr><th colspan="2">១</th><th colspan="2">២</th><th colspan="2">៣</th></tr>
<tr><td rowspan="2">១១.២. ប្រព័ន្ធកត់ត្រាការព្រមានត្រូវបានបំបែកចេញពីលិខិតថ្កោលទោស ដើម្បីការពារសិទ្ធិកុមារ</td><td>១១.២.ក. ប្រព័ន្ធកត់ត្រា ការព្រមាន ត្រូវបានបង្កើតឡើង ដោយមានការរក្សាការសម្ងាត់ ហើយអាចចូលមើលបានសម្រាប់តែនគរបាល និងព្រះរាជអាជ្ញាប៉ុណ្ណោះ</td><td>១១.២.១.បង្កើតប្រព័ន្ធកត់ត្រាការព្រមានដោយមានរក្សាការសម្ងាត់ (ការចេញសេចក្តីព្រមាន គឺមិនរាប់បញ្ចូលថាជាផ្នែកមួយនៃលិខិតថ្កោលទោសរបស់កុមារនោះទេ)</td><td>ក្រសួងមហាផ្ទៃ</td><td></td><td>X</td><td>X</td><td>X</td><td>X</td><td></td><td>ក្រសួងយុត្តិធម៌</td></tr>
<tr><td>១១.២.ខ. %នៃប៉ុស្តិ៍នគរបាលដែលបានរាយការណ៍ដោយប្រើប្រាស់ប្រព័ន្ធកត់ត្រាការព្រមាន</td><td>១១.២.២. ប្រើប្រាស់ប្រព័ន្ធកត់ត្រាការព្រមានក្នុងការរាយការណ៍ទៅព្រះរាជអាជ្ញា</td><td>ក្រសួងមហាផ្ទៃ</td><td></td><td>X</td><td>X</td><td>X</td><td>X</td><td></td><td>ក្រសួងយុត្តិធម៌</td></tr>
</table>

## សមិទ្ធផលទី ១២ ប្រើប្រាស់កិច្ចប្រជុំដោះស្រាយបញ្ហាដើម្បីប្រមូលព័ត៌មានឲ្យបានត្រឹមត្រូវ និងសម្របសម្រួលផែនការបង្វែរ និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាព។

### សូចនាករទី១២.កៈ កិច្ចប្រជុំដោះស្រាយបញ្ហាដោយផ្តោតលើការបង្វែរ និងផែនការសមាហរណកម្ម ត្រូវបានអនុវត្តដោយមានប្រសិទ្ធភាព

<table>
<tr><th rowspan="2">លទ្ធផល</th><th rowspan="2">សូចនាករ</th><th rowspan="2">សកម្មភាព</th><th rowspan="2">ស្ថាប័ន ដឹកនាំ</th><th colspan="6">តារាងពេលវេលា (ឆ្នាំ)</th><th rowspan="2">ស្ថាប័ន ចូលរួមគាំទ្រ</th></tr>
<tr><th colspan="2">១</th><th colspan="2">២</th><th colspan="2">៣</th></tr>
<tr><td rowspan="2">១២.១. ភ្នាក់ងារសង្គមកិច្ចមានសមត្ថភាពពេញលេញក្នុងការសម្របសម្រួលកិច្ចពិភាក្សារកដំណោះស្រាយដោយផ្តោតលើការបង្វែរ ហើយមានការចូលរួមយ៉ាងសកម្មពីអង្គភាពពាក់ព័ន្ធ</td><td>១២.១.ក. ចំនួនភ្នាក់ងារសង្គមកិច្ចប្រើប្រាស់កិច្ចពិភាក្សារកដំណោះស្រាយដើម្បីធ្វើផែនការ និងឈានដល់ការព្រមព្រៀងលើផែនការបង្វែរ និងផែនការសមាហរណកម្ម</td><td>១២.១.១. នេះគឺជាសកម្មភាពរួមមួយៈ បង្កើតគោលការណ៍ ណែនាំសម្រាប់សម្របសម្រួលកិច្ចពិភាក្សារកដំណោះស្រាយដែលផ្តោតលើៈ<br>១២.១.១.១. ផែនការរយៈពេលខ្លី<br>១២.១.១.២ ផែនការបង្វែរ<br>១២.១.១.៣. ការកែសម្រួលផែនការបង្វែរ<br>១២.១.១.៤. ផែនការសមាហរណកម្ម<br>១២.១.១.៥. ការចូលរួមរបស់កុមារ</td><td>ក្រសួងយុត្តិធម៌</td><td></td><td></td><td>X</td><td>X</td><td></td><td></td><td>ក្រសួងសង្គមកិច្ច<br>ក្រសួងមហាផ្ទៃ<br>អ.ស.ស.<br>ស្ថាប័នសាសនា<br>គ.ក.ន.ក</td></tr>
<tr><td>១២.១.ខ. %នៃអ្នកចូលរួមកិច្ចពិភាក្សារកដំណោះស្រាយផ្តល់ការវាយតម្លៃលើបទពិសោធន៍</td><td>១២.១.២. ពិនិត្យមើលបទពិសោធន៍ ដោះស្រាយបញ្ហារបស់អ្នកចូលរួម ដោយមិនបញ្ចេញឈ្មោះអ្នកផ្តល់ចម្លើយ ដើម្បីកែលម្អចំណុចខ្វះខាត</td><td>ក្រុមការងារអន្តរក្រសួង</td><td></td><td></td><td>X</td><td>X</td><td>X</td><td>X</td><td></td></tr>
</table>

# ផ្នែកទី៥ នៃកម្មវិធីយុទ្ធសាស្ត្រ៖ ការធ្វើសមាហរណកម្ម

**គោលបំណងរួម៖**

កម្មវិធីនេះ ទទួលស្គាល់ថា ពេលកុមារស្ថិតនៅក្នុងការឃុំខ្លួន ការរៀបចំផែនការមុនពេលដោះលែងគឺសំខាន់ណាស់ ដើម្បីទទួលបានជោគជ័យក្នុងការជួយកុមារឲ្យត្រឡប់ទៅរស់នៅជាមួយគ្រួសារ ទទួលការសិក្សា ឬប្រកបការងារជាធម្មតាឡើងវិញ។ កុមារដែលមិនត្រូវបានគេត្រៀមរៀបចំឲ្យបានច្បាស់លាស់មុនពេលធ្វើការដោះលែង និងមិនមានការជួយគាំទ្រក្រោយពេលដោះលែងនោះ គឺអាចប្រឈមនឹងការប្រព្រឹត្តបទល្មើសសារជាថ្មី។ជាគំនិតល្អ កុមារត្រូវចាកចេញពីពន្ធនាគារដោយមានការឯកភាពលើផែនការច្បាស់លាស់មួយ ជាមួយនឹងធនធាននិងការគាំទ្រ។

ការធ្វើសមាហរណកម្មឲ្យបានជោគជ័យ តម្រូវឲ្យមានការចូលរួមផ្ទាល់ពីកុមារ និងក្រុមគ្រួសារ ហើយវាក៏តម្រូវឲ្យមានការប្រាស្រ័យទាក់ទងដោយប្រុងប្រយ័ត្នជាមួយនឹងសហគមន៍ដែលកុមារនឹងត្រូវដោះលែងទៅទីនោះ។ ក្រៅពីនេះ ជោគជ័យនៃការធ្វើសមាហរណកម្ម ក៏ពឹងផ្អែកលើការតាមដានលើភាពរីកចម្រើនរបស់កុមារ និងជួយដោះស្រាយបញ្ហាប្រឈមនានាដែលបានកើតឡើងបន្ទាប់ពីដោះលែងផងដែរ។ ភ្នាក់ងារសង្គមកិច្ច និងការផ្តល់សេវាសង្គមកិច្ច ក៏ជាផ្នែកដ៏សំខាន់មួយក្នុងការជួយឲ្យការធ្វើសមាហរណកម្មទទួលបានជោគជ័យ។ ដើម្បីគ្រប់គ្រងការធ្វើសមាហរណកម្ម បុគ្គលិកត្រូវមានចំណេះដឹងនិងជំនាញក្នុងការងារនេះ។ ដោយសារតែចំនួនភ្នាក់ងារសង្គមកិច្ចនៅមានកម្រិត ដូចនេះក្នុងរយៈពេលបីឆ្នាំដំបូងនៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិនេះ ភ្នាក់ងារសង្គមកិច្ចអាចនឹងទទួលខុសត្រូវទាំងការងារបង្វែរ និងសមាហរណកម្ម។ យ៉ាងណាក៏ដោយ ភ្នាក់ងារសង្គមកិច្ចនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការងារសមាហរណកម្ម។

មានករណីមួយចំនួនដែលកុមារមិនចង់ទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍ ហើយចូលចិត្តរស់នៅតំបន់ថ្មី។ ក្នុងករណីបែបនេះ ចាំបាច់ត្រូវមានកន្លែងស្នាក់នៅ និងការជួយគាំទ្រឲ្យបានពេញលេញ ដើម្បីឲ្យកុមារអាចរស់នៅក្នុងសហគមន៍ថ្មីនេះ។ ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នបណ្តុះបណ្តាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត អាចជួយដល់ការអនុវត្តផែនការបង្វែរកុមារ។ ជាការល្អ កុមារគួរទទួលបានការណែនាំ ការបណ្តុះបណ្តាល ឬការអប់រំក្នុងពេលជាប់ឃុំឲ្យហើយមុនពេលដោះលែង។ ជាផ្នែកមួយនៃការត្រៀមរៀបចំកុមារមុនពេលធ្វើការដោះលែង សមត្ថភាពរបស់កុមារគួរត្រូវបានប៉ាន់ប្រមាណ ហើយកុមារគួរត្រូវបានអនុញ្ញាតឲ្យដឹងពីទីកន្លែងដែលខ្លួននឹងត្រូវបានគេបញ្ជូនទៅ និងជួបមនុស្សនៅទីនោះ។ ការធ្វើសមាហរណកម្មដោយជោគជ័យទៅក្នុងសហគមន៍វិញ គឺជាយន្តការបង្ការការប្រព្រឹត្តបទល្មើសប្រកបដោយប្រសិទ្ធភាព។

**សមិទ្ធផលទី១៣៖** មានសេវាសង្គមកិច្ច ហើយភ្នាក់ងារសង្គមកិច្ចមានសមត្ថភាពរៀបចំផែនការ និងគ្រប់គ្រងការធ្វើសមាហរណកម្ម។

**សមិទ្ធផលទី១៤៖** មានកម្មវិធីសម្រាប់កុមារកំពុងជាប់ឃុំ ដើម្បីត្រៀមធ្វើសមាហរណកម្មឲ្យបានជោគជ័យក្រោយពេលដោះលែង។

**សមិទ្ធផលទី១៥៖** និយោជក ស្ថាប័នសាសនា និងអប់រំ គាំទ្រដល់ការបង្វែរកុមារទៅក្នុងសហគមន៍វិញ។

**សមិទ្ធផលទី ១៣** មានសេវាសង្គមកិច្ច ហើយភ្នាក់ងារសង្គមកិច្ចមានសមត្ថភាពរៀបចំផែនការ និងគ្រប់គ្រងការធ្វើសមាហរណកម្ម

## សូចនាករទី ១៣៖ ចំនួនផែនការធ្វើសមាហរណកម្មដែលបានរៀបចំ និងអនុវត្តប្រកបដោយជោគជ័យ

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៣.១. មានគោលនយោបាយ និងដំណើរការគាំទ្រការរៀបចំធ្វើផែនការសមាហរណកម្មដោយលើកទឹកចិត្តឲ្យមានការចូលរួមពីកុមារ ក្រុមគ្រួសារ និងសង្គមស៊ីវិល | ១៣.១.ក. គោលនយោបាយ និងដំណើរការនៃការរៀបចំធ្វើផែនការសមាហរណកម្មត្រូវបានបង្កើតឡើង និងត្រូវបានដាក់ឲ្យអនុវត្ត | ១៣.១.១ បង្កើតគោលនយោបាយ និងដំណើរការសមាហរណកម្ម ដោយផ្ដោតលើ៖<br>១៣.១.១.១. ការប៉ាន់ប្រមាណបឋមលើកុមារនៅពេលឃុំខ្លួន<br>១៣.១.២. ការផ្សាភ្ជាប់គ្នារវាងការប៉ាន់ប្រមាណបឋម និងសកម្មភាពនានាដូចជា ការអប់រំ និងការបណ្ដុះបណ្ដាលកុមារ<br>១៣.១.១.៣. ក្នុងកំឡុងពេល៦ខែមុនពេលធ្វើការដោះលែង ត្រូវមានការប៉ាន់ប្រមាណលើផែនការរបស់កុមារដើម្បីស្វែងយល់ពីបញ្ហាប្រឈមដែលអាចកើតមានឡើងពេលអនុវត្តផែនការ ហើយកែសម្រួលសកម្មភាពបណ្ដុះបណ្ដាលកុមារកំពុងជាប់ឃុំទៅតាមលទ្ធផលនៃការប៉ាន់ប្រមាណនោះ។ ត្រូវទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដែលអាចជួយដល់ការរៀបចំផែនការសមាហរណកម្ម។<br>១៣.១.១.៤. ៣ខែមុនពេលការដោះលែង ត្រូវកំណត់កាលបរិច្ឆេទនៃការរៀបចំផែនការសមាហរណកម្ម ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានាដែលអាចជួយដល់ការអនុវត្តផែនការសមាហរណកម្ម<br>១.១.១.៥ ការគ្រប់គ្រងការដោះលែង ការបញ្ជូន ការតាមដាន និងការពិនិត្យមើលភាពរីកចម្រើន | ក្រសួងមហាផ្ទៃ<br>ក្រសួងសង្គមកិច្ច | X | X | X | | | | ក្រុមការងារអន្តរក្រសួង<br>ក្រសួងយុត្តិធម៌ |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១៣.១.ខ. ចំនួនផែនការសមាហរណកម្មដែលបានវាយតម្លៃ និងចំនួនករណីសិក្សាដែលបានចងក្រងទុកសម្រាប់ចែកចាយ | ១៣.១.២. ពិនិត្យតាមដាន និងវាយតម្លៃផែនការសមាហរណកម្ម និងចងក្រងករណីសិក្សាល្អៗទុកសម្រាប់ចែករំលែក | ក្រសួងសង្គមកិច្ច | | | x | | | | |
| | ១៣.១.គ. ចំនួនកុមារដែលស្ម័គ្រចិត្តចែករំលែកបទពិសោធន៍ និង/ឬក៏ធ្វើការជាអ្នកផ្តល់យោបល់ដល់កុមារ មុនពេល និងក្រោយពេលដោះលែង | ១៣.១.៣. កុមារដែលបានកែប្រែខ្លួនប្រកបដោយជោគជ័យក្រោយការដោះលែង ត្រូវបានស្នើសុំឲ្យធ្វើការជាអ្នកស្ម័គ្រចិត្តដើម្បីចែករំលែកបទពិសោធន៍ និង/ឬក៏ធ្វើការជាអ្នកផ្តល់យោបល់ ដើម្បីជួយគាំទ្រដល់កុមារជាប់ឃុំ ទាំងមុនពេលនិងក្រោយពេលដោះលែង | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |
| | ១៣.១.ឃ. ប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង និងត្រូវបានអនុវត្ត | ១៣.១.៤. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានទាំងតួនាទី ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដំណើរការនៃការអនុវត្ត ប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តសាកល្បង | ក្រសួងយុត្តិធម៌ | X | X | X | X | X | X | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៣.២. អត្រានៃការប្រព្រឹត្តបទល្មើសសារជាថ្មីរបស់កុមារដែលបានធ្វើសមាហរណកម្មរួចហើយត្រូវបានថយចុះ | ១៣.២.ក. ចំនួនកុមារដែលប្រព្រឹត្តបទល្មើសឡើងវិញ ត្រូវបានវិភាគដោយផ្អែកលើផែនការសមាហរណកម្មរបស់ពួកគេ | ១៣.២.១. ធ្វើការសិក្សាលើកុមារដែលត្រូវបានដោះលែងពីការឃុំឃាំង ដើម្បីពិនិត្យមើលប្រសិទ្ធភាពនៃផែនការសមាហរណកម្មដែលបានរៀបចំឡើងមុននិងក្រោយពេលការដោះលែង និងពិនិត្យមើលពីអត្រានៃការប្រព្រឹត្តបទល្មើសដដែលៗ | ក្រុមការងារអន្តរក្រសួង | | | | | x | | |
| ១៣.៣. ដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការត្រូវបានអនុវត្ត ដើម្បីជួយគាំទ្រដល់ការបង្វែរ និងការធ្វើសមាហរណកម្មឲ្យបានជោគជ័យ ហើយជួយកាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី | ១៣.៣.ក. របាយការណ៍វាយតម្លៃលើការអនុវត្តសាកល្បងនូវដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ បានផ្ដល់ជាអនុសាសន៍ដោយផ្អែកលើភស្តុតាងសម្រាប់ការអនុវត្តដំណោះស្រាយនេះ | ១៣.៣.១. នេះគឺជាសកម្មភាពរួមមួយ៖ អនុវត្តសាកល្បងនូវដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការផ្សេងៗដែលមានដូចជាសន្ទានកម្មដែលដឹកនាំដោយជនរងគ្រោះ កិច្ចពិភាក្សាដោយមានការចូលរួមពីភាគីពាក់ព័ន្ធនិងមានអ្នកសម្របសម្រួល ហើយដាក់បញ្ចូលដំណោះស្រាយនេះទៅក្នុងផែនការបង្វែរ និងផែនការសមាហរណកម្ម (អានកម្មវិធីយុទ្ធសាស្ត្រទី៥ និង៨) | ក្រសួងយុត្តិធម៌ | | | x | x | x | | |

## សមិទ្ធផលទី ១៤ មានកម្មវិធីសម្រាប់កុមារកំពុងជាប់ឃុំ ដើម្បីត្រៀមធ្វើសមាហរណកម្មឲ្យបានជោគជ័យក្រោយពេលដោះលែង

### លទ្ធផលទី១៤.ក. កម្មវិធីសមាហរណកម្មដ៏មានប្រសិទ្ធភាពត្រូវបានអនុវត្តសម្រាប់កុមារដែលជាប់ឃុំ

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) ១ | | ២ | | ៣ | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| ១៤.១. កុមារដែលស្ថិតនៅក្នុងពន្ធនាគារត្រូវបានត្រៀមរៀបចំធ្វើសមាហរណកម្មប្រកបដោយជោគជ័យទៅក្នុងសហគមន៍វិញ | ១៤.១.ក. ចំនួនពន្ធនាគារដែលបានត្រៀមរៀបចំផែនការបណ្តុះបណ្តាលដល់កុមារដោយផ្តោតលើជំនាញដែលមានតម្រូវការទីផ្សារការងារខ្ពស់ | ១៤.១.១ ធ្វើការសិក្សាស្វែងយល់អំពីប្រភេទការងារ ឬការបណ្តុះបណ្តាល នៅតាមបណ្តាខេត្តនីមួយៗដើម្បីជួយណែនាំពន្ធនាគារឲ្យមានការរៀបចំកម្មវិធីបណ្តុះបណ្តាលដោយផ្តោតលើជំនាញដែលមានតម្រូវការទីផ្សារការងារខ្ពស់ | ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជន និងកីឡា | | X | X | X | X | | មន្ទីរអប់រំ យុវជន និងកីឡា |
| | ១៤.១.ខ. ចំនួនកុមារក្នុងពន្ធនាគារដែលគ្រប់អាយុត្រូវចូលរៀនបានទទួលការសិក្សា | ១៤.១.២. អនុញ្ញាតឲ្យកុមារក្នុងពន្ធនាគារ (ទាំងកុមារដែលគ្រប់អាយុត្រូវចូលរៀន និងកុមារដែលធ្លាប់បានចូលរៀន) បន្តការសិក្សាទៅតាមសេចក្តីត្រូវការ | ក្រសួងមហាផ្ទៃ ក្រុមការងារអន្តរក្រសួង | | X | X | X | | | មន្ទីរអប់រំ យុវជន និងកីឡា |
| | ១៤.១.គ. %នៃកុមារដែលត្រូវដោះលែង បានរៀនចប់កម្មវិធីជំនាញការងារ និងបំណិនជីវិត | ១៤.១.៣. រៀបចំ និងដាក់ឲ្យអនុវត្តនូវកម្មវិធីជំនាញការងារ និងបំណិនជីវិត ដែលទាក់ទងនឹងការថែរក្សាសុខភាព ជម្រើសមិនល្អ សុវត្ថិភាព ការគ្រប់គ្រងថវិកា ការស្វែងរកការជួយគាំទ្រនៅពេលត្រូវការ។ល។ | ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច | | | | | | | |
| | ១៤.១.ឃ. ចំនួនពន្ធនាគារ ដែលអនុវត្តតាមគោលការណ៍ណែនាំស្តីពីការអនុញ្ញាតឲ្យមានការចូលសួរសុខទុក្ខកុមារ | ១៤.១.៤. បង្កើតគោលការណ៍ណែនាំស្តីពីការ អនុញ្ញាតឲ្យមានការចូលសួរសុខទុក្ខកុមារពីក្រុមគ្រួសារ មេធាវី បុគ្គលិកសង្គម និងស្តីពីកម្មវិធីផ្តល់សេវាផ្សេងៗដល់កុមារ។ គោលការណ៍នេះត្រូវមានលក្ខណៈបត់បែន និងកាត់បន្ថយឧបសគ្គដែលរាំងដល់ទំនាក់ទំនងរវាងកុមារ និងសហគមន៍។ | ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច | X | X | X | X | X | X | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា ( ឆ្នាំ ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១៤.១.ង. ចំនួនផែនការសមាហរណកម្ម ដែលកុមារបានដឹងពីសកម្មភាពទាំងឡាយនៃផែនការសមាហរណកម្មនោះ | ១៤.១.៥. មុនពេលដោះលែង ឲ្យកុមារដឹងពីផែនការសមាហរណកម្មដែលរួមមានសកម្មភាពមួយចំនួនដូចជា៖<br>១៤.១.៥.១. ការចុះទៅមើលកន្លែងធ្វើការ សាលារៀន និងកន្លែងស្នាក់នៅ<br>១៤.១.៥.២. សួរសុខទុក្ខគ្រួសារ<br>១៤.១.៥.៣. ភ្ជាក់ងារសង្គមកិច្ច នគរបាល និងអ្នកជួយគាំទ្រផ្សេងទៀត ឬអ្នកផ្ដល់យោបល់ ដែលត្រៀមលក្ខណៈជួយក្រោយពេលដោះលែង<br>១៤.១.៥.៤. សកម្មភាពបំណិនជីវិតងាយៗរួមមានការពិនិត្យសុខភាព ការចូលផ្សារទិញរបស់របរ ការធ្វើដំណើរ និងសកម្មភាពផ្សេងទៀត | ក្រសួងមហាផ្ទៃ<br>ក្រសួងសង្គមកិច្ច | | x | | | | | |

## សមិទ្ធផលទី ១៥ និយោជក ស្ថាប័នសាសនា និងអប់រំ គាំទ្រដល់ការបង្វែរកុមារទៅក្នុងសហគមន៍វិញ ។

### សូចនាករទី១៥.ក.៖ កុមារស្ថិតក្នុងការឃុំខ្លួន ត្រូវបានធ្វើសមាហរណកម្មទៅក្នុងសង្គមបន្ទាប់ពីដោះលែង ហើយអត្រាប្រព្រឹត្តបទល្មើសសារជាថ្មីថយចុះ ។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) ១ | | ២ | | ៣ | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| ១៥.១. អង្គការសង្គមស៊ីវិល និង ស្ថាប័នឯកជននៅថ្នាក់មូលដ្ឋានបានជួយគាំទ្រផែនការសមាហរណកម្មកុមារដែលត្រៀមដោះលែង និងក្រោយពេលដោះលែង | ១៥.១.ក. ចំនួនអង្គការ ដែលប្តេជ្ញាចិត្តគាំទ្រផែនការបង្វែរ និងផែនការសមាហរណកម្ម និង ចំនួនផែនការដែលទទួលបានការគាំទ្រ | ១៥.១.១. នេះគឺជាសកម្មភាពរួមមួយ៖ រៀបចំយុទ្ធនាការស្វែងរកការជួយគាំទ្រនៅថ្នាក់ឃុំ ដើម្បីធានាឲ្យមានការជួយផ្តល់ជាកន្លែងស្នាក់នៅ ធនធាន ការអប់រំ ការបណ្តុះបណ្តាល កម្មវិធីសេវាសង្គមផ្សេងៗ និងការផ្តល់ការងារដល់កុមារក្រោយរួចពីឃុំ ព្រមទាំងកុមារទំនាស់នឹងច្បាប់ផ្សេងទៀត ដោយមានការចូលរួមជួយយ៉ាងសកម្មពីស្ថាប័នថ្នាក់ក្រោមជាតិក៏ដូចជាភ្នាក់ងារសង្គមកិច្ចថ្នាក់ឃុំ នគរបាល អាជីវកនៅមូលដ្ឋានសហគមន៍ និងអ្នកដឹកនាំសាសនា។ (អានកម្មវិធីយុទ្ធសាស្ត្រទី៥) | ក្រសួងសង្គមកិច្ច | | x | | | | | ក្រសួងមហាផ្ទៃ<br>ក្រសួងអប់រំ<br>ក្រសួងកិច្ចការនារី<br>ក្រសួងការងារ<br>ក្រសួងសុខាភិបាល<br>NGOs<br>ស្ថាប័នសាសនា<br>គ.ក.ន.ក |
| | ១៥.១.ខ. %នៃខេត្តដែលបានរៀបចំឲ្យមានសៀវភៅបញ្ជីឈ្មោះសេវាកម្មសង្គមថ្នាក់មូលដ្ឋាន | ១៥.១.២. នេះគឺជាសកម្មភាពរួមមួយ៖ រៀបចំសៀវភៅបញ្ជីឈ្មោះសេវាកម្មសង្គមតាមខេត្តនីមួយៗ ដោយមានទម្រង់អេឡិចត្រូនិកឬជាក្រដាសសម្រាប់ឲ្យបំពេញ ដើម្បីជួយសម្រួលការងារភ្នាក់ងារសង្គមកិច្ច និងអ្នកផ្សេងទៀតដែលធ្វើការងារសង្គម។ (អានកម្មវិធីយុទ្ធសាស្ត្រទី៥) | ក្រសួងសង្គមកិច្ច | X | X | X | X | | | គ.ក.ន.ក |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១៥.១.គ. ចំនួនផែនការធ្វើសមាហរណកម្ម ដែលរួមមានសេវាកម្ម និងទីកន្លែង | ១៥.១.៣. លើកទឹកចិត្ត និងគាំទ្រទាំងស្ថាប័នរដ្ឋ និងឯកជន ឲ្យចូលរួមរៀបចំផែនការសមាហរណកម្ម និងផ្តល់សេវាដល់កុមារក្រោយពេលដោះលែង<br>១៥.១.៣.១. គោលការណ៍ណែនាំស្តីពីការចូលរួម និងការមើលខុសត្រូវលើកុមារ ដែលត្រូវធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ<br>១៥.១.៣.២. ការគាំទ្ររបស់ភ្នាក់ងារសង្គម<br>១៥.១.៣.៣. ការទទួលស្គាល់ជាសាធារណៈនូវការចូលរួមអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងការការពារកម្មវិធីសិទ្ធិកុមារ | ក្រសួងសង្គមកិច្ច | | | | X | X | X | |
| | ១៥.១.ង. ករណីសិក្សាស្តីពីភាពជាដៃគូដោយជោគជ័យ រវាងក្រសួងសង្គមកិច្ច និង អង្គការផ្សេងៗ ត្រូវបានបោះពុម្ពផ្សព្វផ្សាយ | ១៥.១.៥. ចងក្រងទុកជាឯកសារសម្រាប់ផ្សព្វផ្សាយនូវករណីសិក្សាស្តីពីភាពជាដៃគូដែលទទួលបានជោគជ័យក្នុងការគាំទ្រកុមារក្រោយពេលដោះលែង និងសម្រាប់ទាក់ទាញឲ្យមានការចូលរួមជួយគាំទ្រពីស្ថាប័នផ្សេងទៀត | ក្រុមការងារអន្តរក្រសួង | | | | X | X | X | |
| ១៥.២. មានការកើនឡើងនូវការទទួលយកពីសង្គមស៊ីវិលនូវការស្តារនីតិសម្បទា និងអភិក្រមសិទ្ធិកុមារដែលត្រូវអនុវត្តចំពោះកុមារទំនាស់នឹងច្បាប់ | ១៥.២.ក. ចំនួនផែនការបង្វែរ និងផែនការសមាហរណកម្មដែលទទួលបានជោគជ័យ | ១៥.២.១. នេះគឺជាសកម្មភាពរួមមួយៈ ធ្វើការសិក្សាអំពីភាពជោគជ័យនៃការបង្វែរ និងការធ្វើសមាហរណកម្មដោយវិភាគលម្អិតទៅលើកត្តារួមផ្សំផ្សេងៗ ដូចជាការចូលរួមរបស់សង្គមស៊ីវិល រឺគ្រួសារកុមារជាដើម | ក្រសួងយុត្តិធម៌ | | | | | | X | |

## កម្មវិធីយុទ្ធសាស្ត្រទី៦៖ ការឃុំខ្លួនអនីតិជន

**គោលបំណងរួម៖**

ការផ្តោតយកចិត្តទុកដាក់ក្នុងពេលឃុំខ្លួនអនីតិជន គឺសំដៅទៅលើការស្តារនីតិសម្បទាអនីតិជន និងផ្តល់ឲ្យអនីតិជននូវមុខជំនាញ ដើម្បីធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍ បន្ទាប់ពីមានការដោះលែង និងធ្វើយ៉ាងណាកុំឲ្យមានការប្រព្រឹត្តបទល្មើសសារជាថ្មី ។

កម្មវិធីនេះទទួលស្គាល់ថា ការឃុំខ្លួនអនីតិជនគឺជាជម្រើសចុងក្រោយ។ យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រសិនបើកុមារត្រូវបានគេបញ្ជាឲ្យឃុំខ្លួន គឺត្រូវបញ្ជូនកុមារនោះទៅមណ្ឌលយុវនីតិសម្បទា។ ការអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា គឺជាប្រភេទមួយនៃការឃុំខ្លួនដែលធ្វើឡើងដើម្បីជួយគាំទ្រ និងស្តារនីតិសម្បទាកុមារ ហើយដែលគោលបំណងនៃវិធានការនេះគឺដើម្បីជៀសវាងការផ្តន្ទាទោស។ ការងារសំខាន់នៅក្នុងមណ្ឌលនេះ គឺស្តារនីតិសម្បទារបស់កុមារ ផ្តល់ឲ្យកុមារនូវជំនាញដើម្បីត្រៀមធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញនៅពេលមានការដោះលែង និងដើម្បីជៀសវាងការប្រព្រឹត្តិបទល្មើសឡើងវិញ។

ដោយហេតុថា កុមារគឺខុសពីមនុស្សពេញវ័យ ដូច្នេះការប្រព្រឹត្តមកលើពួកគេត្រូវតែធ្វើតាមលក្ខណៈជាកុមារ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបញ្ជាក់យ៉ាងច្បាស់ពីបទដ្ឋាននៃដំណើរការរបស់មណ្ឌលយុវនីតិសម្បទា។ ប្រការ៣០ នៃវិធានហាវ៉ាណាបានតម្រូវថា «កន្លែងឃុំខ្លួនអនីតិជនគួរត្រូវបានធ្វើវិមជ្ឈការ ដែលអាចផ្តល់ភាពងាយស្រួលដល់ទំនាក់ទំនងរវាងអនីតិជន និងក្រុមគ្រួសាររបស់ពួកគេ។ កន្លែងឃុំខ្លួនកម្រិតតូចៗគួរត្រូវបានសាងសង់ឡើង និងធ្វើយ៉ាងណាឲ្យមានការផ្សាភ្ជាប់ជាមួយនឹងបរិយាកាសសង្គម សេដ្ឋកិច្ច និងវប្បធម៌ក្នុងសហគមន៍»។ បទដ្ឋាននេះអាចជួយគាំទ្រដល់ផែនការការងារ ទីកន្លែងឃុំឃាំងថ្មីនិងចាស់។

បញ្ហាសំខាន់ក្នុងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនគឺថា មានបទបញ្ញត្តិជាច្រើននៃច្បាប់នេះចែងតែអំពីការអនុវត្តទោសចំពោះកុមារ ដែលនៅក្នុងមណ្ឌលយុវនីតិសម្បទា។ នេះអាចប៉ះពាល់ដល់កំណើនកុមារដែលមានស្រាប់ក្នុងពន្ធនាគារ និងកុមារប្រព្រឹត្តបទល្មើសលើកដំបូង។ បច្ចុប្បន្នមានតែមណ្ឌលយុវនីតិសម្បទាតែមួយប៉ុណ្ណោះដែលគ្រោងនឹងបង្កើតឡើង ហើយនឹងត្រូវបានសាងសង់រួចរាល់ក្នុងកំឡុងពេលយ៉ាងហោចណាស់ក៏ ២ ឆ្នាំដែរ។ គម្រោងសាងសង់មណ្ឌលយុវនីតិសម្បទាដំបូងនេះ គឺអាចដាក់កុមារបានប្រហែល ៤០នាក់។ ដូចនេះ ចាំបាច់ត្រូវកំណត់យន្តការជាបណ្តោះអាសន្ន ក៏ដូចជាផែនការសាងសង់ និងប្រតិបត្តិការមណ្ឌលយុវនីតិសម្បទាតូចៗមួយចំនួននៅទូទាំងប្រទេស។ កំណើនកុមារក្នុងពន្ធនាគារនាពេលបច្ចុប្បន្ន តម្រូវឲ្យមានការចុះវាយតម្លៃដ៏ទូលំទូលាយមួយជាបន្ទាន់ ដើម្បីកំណត់ឲ្យដឹងថាតើមានបទបញ្ញត្តិណាខ្លះនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលអាចយកមកអនុវត្តបានក្នុងការកាត់បន្ថយចំនួនកុមារក្នុងពន្ធនាគារតាមរយៈការបង្វែរកុមារដែលកំពុងជាប់ឃុំរង់ចាំការជំនុំជម្រះ និងកុមារដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមក្រមនីតិវិធីព្រហ្មទណ្ឌសម្រាប់ដោះលែងឲ្យបានឆាប់។ ការចុះវាយតម្លៃនេះ ក៏ជាឱកាសមួយសម្រាប់បណ្តុះបណ្តាលបុគ្គលិកផងដែរ ដែលជាការងារមួយដែលត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីបង្រៀន។ លើសពីនេះទៀត កម្មវិធី នៅតាមពន្ធនាគារសព្វថ្ងៃ ក៏ត្រូវវាយតម្លៃផងដែរ ដើម្បីឲ្យដឹងថាតើកម្មវិធីទាំងនោះអាចកែលម្អរបៀបណានៅក្នុងពេលដ៏ខ្លី ដើម្បីឲ្យសមស្របតាម បទដ្ឋានអប្បបរមាអន្តរជាតិ។ (អានកម្មវិធីយុត្តិសាស្ត្រទី៥)

**សមិទ្ធផលទី១៦៖** ចំនួនកុមារក្នុងពន្ធនាគារនាពេលបច្ចុប្បន្នត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ដោយសារវាជាបញ្ហាបន្ទាន់ដែលត្រូវដោះស្រាយដើម្បីឲ្យកុមារអាចត្រូវបានបង្វែរចេញពីកន្លែងឃុំឃាំង។

**សមិទ្ធផលទី១៧៖** កម្មវិធីការងារ និងទីកន្លែងស្នាក់នៅ រួមទាំងសម្ភារៈប្រើប្រាស់ផង ត្រូវបានវាយតម្លៃ ហើយលក្ខខណ្ឌមួយចំនួនត្រូវបានកែលម្អសម្រាប់កុមារនៅក្នុងពន្ធនាគារ។

**សមិទ្ធផលទី១៨៖** យន្តការបណ្តោះអាសន្នត្រូវបានកំណត់ដើម្បីស្នើសុំអាគារ ឬផ្នែកមួយចំនួននៃពន្ធនាគារដែលមានស្រាប់ធ្វើជាមណ្ឌលយុវនីតិសម្បទា ដើម្បីធ្វើឲ្យបញ្ញត្តិស្តីពីការស្តារនីតិសម្បទា និងការដោះលែងដោយមានលក្ខខណ្ឌ អាចអនុវត្តបាន និងសម្រាប់បញ្ជៀសកុមារដែលទើបតែមកថ្មី មិនឲ្យចូលក្នុងប្រព័ន្ធពន្ធនាគារដែលមានស្រាប់។

**សមិទ្ធផលទី១៩៖** មណ្ឌលយុវនីតិសម្បទាត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីស្តារនីតិសម្បទា និងត្រៀមធ្វើសមាហរណកម្មទៅក្នុងសហគមន៍។

| **សមិទ្ធផលទី ១៦** | ចំនួនកុមារក្នុងពន្ធនាគារនាពេលបច្ចុប្បន្នត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ដោយសារវាជាបញ្ហា បន្ទាន់ដែលត្រូវដោះស្រាយដើម្បីឲ្យកុមារអាចត្រូវបានបង្វែរចេញពីកន្លែងឃុំឃាំង។ |
|---|---|

## សូចនាករទី១៦.ក. %នៃកុមារជាប់ឃុំបច្ចុប្បន្នដែលបានវាយតម្លៃត្រឹមត្រូវ មានផែនការបង្វែរដែលបានអនុវត្ត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៦.១. ទិន្នន័យគ្រប់ជ្រុងជ្រោយស្តីពីកុមារ ក្នុងពន្ធនាគារបច្ចុប្បន្ន ត្រូវបានប្រើប្រាស់ ដើម្បីស្នើសុំឲ្យមានការបង្វែរ និងការដោះលែងមុនពេលកំណត់ ក្នុងខណៈពេលមិនទាន់មានមណ្ឌលយុវនីតិសម្បទា និងនៅពេលដែលច្បាប់ស្តីពីយុត្តិធម៌អនីតិជនមិនទាន់ត្រូវបានអនុវត្ត | ១៦.១.ក. ទិន្នន័យគោលមួយសម្រាប់ពិនិត្យមើលការចាប់ផ្តើមការអនុវត្តផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិត្រូវបានបង្កើតឡើង | ១៦.១.១. នេះគឺជាសកម្មភាពរួម៖ បង្កើតទិន្នន័យគោលមួយ សម្រាប់ការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ ដោយរួមមានការវិភាគទៅលើការចំណាយលើប្រព័ន្ធបច្ចុប្បន្ន (សូមមើលកម្មវិធីយុទ្ធសាស្ត្រទី៩) | ក្រុមការងារអន្តរក្រសួង | X | | | | | | |
| | ១៦.១.ខ. ចំនួនផែនការដោះលែងកុមារក្នុងពន្ធនាគារនាពេលបច្ចុប្បន្នដែលសមស្របសម្រាប់ការស្នើសុំដោះលែងដោយមានលក្ខខណ្ឌ និងការដោះលែងមុនពេលកំណត់ត្រូវបានបំពេញ | ១៦.១.២. វិភាគទិន្នន័យស្តីពីកុមារក្នុងពន្ធនាគារបច្ចុប្បន្ន ដើម្បីកំណត់រកកុមារណាដែលអាចបង្វែរក្នុងពេលរង់ចាំសវនាការ និងកុមារដែលអាចទទួលការដោះលែងឆាប់ៗ | ក្រុមការងារអន្តរក្រសួង | X | X | | | | | គណៈមេធាវី |
| | ១៦.១.គ. ប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយក្រុមការងារអន្តរក្រសួង និងត្រូវបានអនុវត្ត | ១៦.១.៣. នេះគឺជាសកម្មភាពរួម៖ បង្កើតប្រព័ន្ធអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរួមមានទាំងតួនាទី ការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗ ដែលមានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដំណើរការនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងករណី និងការអនុវត្តសាកល្បង | ក្រសួងយុត្តិធម៌ | X | X | X | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១៦.១.ឃ. ចំនួនផែនការដោះលែងកុមារក្នុងខេត្តទាំង៥ ត្រូវបានអនុវត្ត | ១៦.១.៤. នៅក្នុងខេត្តទាំង៥ ផែនការដោះលែង ដែលសមស្របសម្រាប់ការស្នើសុំឲ្យមានការដោះលែងដោយមានលក្ខខណ្ឌ និងការដោះលែងមុនពេលកំណត់ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសាកល្បងសម្រាប់អនុវត្ត | ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច | | X | X | | | | |
| | ១.១.ង ចំនួនផែនការដោះលែងកុមារ ត្រូវបានអនុវត្តនៅក្នុងខេត្តផ្សេងក្រៅពីខេត្តគោលដៅ | ១៦.១.៥ អង្គភាពយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងខេត្តផ្សេងក្រៅពីខេត្តគោលដៅទាំង៥ បានសហការជាមួយគណៈមេធាវី និងកម្មវិធីផ្តល់សេវាសង្គមក្នុងមូលដ្ឋានដើម្បីជួយពិនិត្យមើលនិងអនុវត្តផែនការដោះលែងនេះ | ក្រសួងយុត្តិធម៌ | | X | X | | | | |
| | ១៦.១.ច. ចំនួនតុលាការ ដែលមានរៀបចំកាលវិភាគប្រជុំពិនិត្យមើលសំណុំរឿងកុមារ | ១៦.១.៦. នេះគឺជាសកម្មភាពរួមៈ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងមានកាលវិភាគពិនិត្យមើលសំណុំរឿងនីមួយៗរបស់កុមារ ដើម្បីជៀសវាងការមិនអនុវត្តតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន តាមដានមើលភាពរីកចម្រើននៃសំណុំរឿងនីមួយៗ ផ្តល់អាទិភាព និងគ្រប់គ្រងសំណុំរឿងកុមារ។ ភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកខាងយុត្តិធម៌មានតួនាទីកំណត់បញ្ហា វិវាទ និងផ្តល់ព័ត៌មាន។ | ក្រសួងយុត្តិធម៌ | | X | X | X | X | X | |
| | ១៦.១.ឆ. %នៃកាលវិភាគពិនិត្យមើលសំណុំរឿងកុមារ ដោយរួមទាំងការពិនិត្យមើលកុមារកំពុងជាប់ឃុំក្នុងពន្ធនាគារផងដែរ | ១៦.១.៧. ធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីកុមារទាំងអស់ក្នុងពន្ធនាគារនាពេលបច្ចុប្បន្ន ហើយបញ្ចូលផែនការដោះលែងក្នុងកាលវិភាគពិនិត្យមើលសំណុំរឿងកុមារ | ក្រសួងយុត្តិធម៌ | | X | X | | | | |

## សមិទ្ធផលទី ១៧ កម្មវិធីការងារ និងទីកន្លែងស្នាក់នៅ រួមទាំងសម្ភារៈប្រើប្រាស់ផង ត្រូវបានវាយតម្លៃ ហើយលក្ខខណ្ឌមួយចំនួនត្រូវបានកែលម្អសម្រាប់កុមារនៅក្នុងពន្ធនាគារ។

### សូចនាករទី១៧.ក៖ ផែនការកែលម្អកន្លែងឃុំឃាំង កែលម្អកម្មវិធី និងលក្ខខណ្ឌផ្សេងៗ ត្រូវបានអនុវត្ត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៧.១. ការថែរក្សាកុមារនៅក្នុងពន្ធនាគារ ដោយបុគ្គលិក មានភាពប្រសើរឡើង | ១៧.១.ក. ចំនួនពន្ធនាគារ ដែលតែងតាំងប្រធាន និងបុគ្គលិកដែលមានជំនាញផ្នែកកុមារ | ១៧.១.១. តែងតាំងប្រធាន និងបុគ្គលិកដែលមានជំនាញផ្នែកកុមារ ក្នុងពេលមិនទាន់មានមណ្ឌលយុវនីតិសម្បទា | ក្រសួងមហាផ្ទៃ | | X | X | X | X | | |
| | ១៧.១.ខ. %បុគ្គលិកពន្ធនាគារដែលទទួលបានការបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន និងថ្នាក់ឯកទេសខាងកុមារ និងដែលត្រូវបានតែងតាំង | ១៧.១.២. បុគ្គលិកទាំងអស់ដែលទទួលបានការបណ្តុះបណ្តាលស្តីពីការអនុវត្តនីតិវិធីបែបកុមារមេត្រីត្រូវបានតែងតាំងឲ្យធ្វើការជាមួយអនីតិជនជាប់ឃុំ | ក្រសួងមហាផ្ទៃ | | X | X | X | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៧.២. មានការកែលម្អលក្ខខណ្ឌសម្រាប់កុមារក្នុងពន្ធនាគារឲ្យមានការយកចិត្តទុកដាក់ខ្ពស់លើកុមារ ហើយការពារសិទ្ធិរបស់ពួកគេឲ្យស្របតាមបទដ្ឋានអន្តរជាតិ | ១៧.២.ក. ចំនួនពន្ធនាគារ ដែលបានកែសម្រួលនីតិវិធី ដើម្បីលើកកម្ពស់បរិយាកាសកុមារមេត្រី និងការគោរពសិទ្ធិកុមារ | ១៧.២.១. នៅក្នុងពន្ធនាគារក្នុងខេត្តនីមួយៗពិនិត្យមើលសម្ភារៈនិងទីកន្លែងប្រើប្រាស់ នីតិវិធី និងកម្មវិធី ដែលជាកត្តាជំរុញឲ្យមានបរិយាកាសបែបកុមារមេត្រី។ ការពិនិត្យនេះក៏នឹងវាយតម្លៃផងដែរនូវ សក្តានុពលនៃទីកន្លែងណាមួយរបស់អគារ ដែលអាចធ្វើជាមណ្ឌលយុវនីតិសម្បទា។ ការពិនិត្យទាំងនេះ រួមមាន៖<br>១៧.២.១.១. ការបំបែកកុមារចេញពីមនុស្សពេញវ័យ បំបែកកុមារដែលជាប់ឃុំរង់ចាំសវនាការ ចេញពីអ្នកដែលត្រូវបានកាត់ទោស បែងចែកតាមភេទ និងប្រភេទបទល្មើស<br>១៧.២.២. ការកំណត់យកបន្ទប់ដែលអាច ប្រើសម្រាប់កម្មវិធីអប់រំផ្សេងៗ<br>១៧.២.១.៣. ការពិនិត្យមើលសុខភាពជាប្រចាំជាមួយនឹងមណ្ឌលសុខភាពឬមន្ទីរពេទ្យ<br>១៧.២.១.៤. កិច្ចព្រមព្រៀងជាមួយអង្គការនានាលើកម្មវិធីផ្តល់សេវាសង្គម និងការអប់រំ ដែលបានអនុវត្តកន្លងមក<br>១៧.២.១.៥. នីតិវិធីស្តីពីការចុះសួរសុខទុកពីគ្រួសារ មេធាវី ព្រះរាជអាជ្ញា និងអ្នកពាក់ព័ន្ធផ្សេងទៀត<br>១៧.២.១.៦. កម្មវិធីស្តីពីការត្រៀមរៀបចំមុន និងក្រោយការដោះលែង | ក្រសួងមហាផ្ទៃ | X | X | X | X | X | X | |

**សមិទ្ធផលទី ១៨** យន្តការបណ្ដោះអាសន្នត្រូវបានកំណត់ដើម្បីស្នើសុំអាគារ ឬផ្នែកមួយចំនួននៃពន្ធនាគារដែលមានស្រាប់ធ្វើជាមណ្ឌលយុវនីតិសម្បទា ដើម្បីធ្វើឲ្យបញ្ញត្តិស្ដីពីការស្ដារនីតិសម្បទា និងការដោះលែងដោយមានលក្ខខណ្ឌ អាចអនុវត្តបាន និងសម្រាប់បញ្ជៀសកុមារដែលទើបតែមកថ្មី មិនឲ្យចូលក្នុងប្រព័ន្ធពន្ធនាគារដែលមានស្រាប់។

## សូចនាករទី១៨.ក.៖ មណ្ឌលយុវនីតិសម្បទាបណ្ដោះអាសន្នត្រូវបានស្នើសុំឲ្យមាន ដើម្បីគាំទ្រការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន និងបទដ្ឋានអន្តរជាតិផ្សេងទៀត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៨.១. ទីកន្លែងសម្រាប់រៀបចំធ្វើជាមណ្ឌលយុវនីតិសម្បទា ត្រូវបានកំណត់ និងវាយតម្លៃ | ១៨.១.ក. ចំនួនពន្ធនាគារដែលត្រូវបានពិនិត្យមើល ដើម្បីរកកន្លែងធ្វើជាមណ្ឌលយុវនីតិសម្បទា | ១៨.១.១. ពិនិត្យមើលទីធ្លាពន្ធនាគារទាំងអស់ដើម្បីរកកន្លែងធ្វើជាមណ្ឌលយុវនីតិសម្បទា | ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច | X | X | X | | | | |
| | ១៨.១.ខ. តាមខេត្តនីមួយៗបានរៀបចំបញ្ជីទីកន្លែង ឬ មណ្ឌលដែលមានសក្ដានុពលអាចប្រើប្រាស់ធ្វើជាមណ្ឌលយុវនីតិសម្បទា | ១៨.១.២. ពិនិត្យមើលទីតាំងនានារបស់រដ្ឋ (ជាពិសេសមណ្ឌលកុមារកំព្រានិងកន្លែងផ្សេងទៀត) ដែលមានសក្ដានុពលអាចប្រើប្រាស់ធ្វើជាមណ្ឌលយុវនីតិសម្បទា | ក្រសួងសង្គមកិច្ច | X | X | X | | | | |
| | ១៨.១.គ. ចំនួនផែនការបង្កើតមណ្ឌលយុវនីតិសម្បទា ត្រូវបានរៀបចំឡើង | ១៨.១.៣. បង្កើតផែនការទីកន្លែងទាំងអស់ ដែលអាចបង្កើតជាមណ្ឌលយុវនីតិសម្បទាបាន | ក្រសួងសង្គមកិច្ច | | | X | X | X | | |
| | ១៨.១.ឃ. ចំនួនគម្រោងថវិកាត្រូវបានរៀបចំហើយ និងស្នើសុំការអនុម័ត | ១៨.១.៤. បង្កើតគម្រោងថវិកាសម្រាប់រៀបចំទីកន្លែងដែលអាចបង្កើតជាមណ្ឌលយុវនីតិសម្បទា ដើម្បីស្នើសុំការអនុម័ត | ក្រសួងសង្គមកិច្ច | | | | X | X | X | |
| ១៨.២. មណ្ឌលយុវនីតិសម្បទាតាមខេត្ត ត្រូវបានបង្កើតឡើង | ១៨.២.ក. ចំនួនទីកន្លែង ដែលត្រូវបានប្រកាសជាមណ្ឌលយុវនីតិសម្បទា | ១៨.២.១. បង្កើតផែនការប្រើប្រាស់ទីកន្លែងដែលមានសក្ដានុពល ធ្វើជាមណ្ឌលយុវនីតិសម្បទា | ក្រសួងសង្គមកិច្ច | | | | | X | X | |

**សមិទ្ធផលទី ១៩** មណ្ឌលឃុំឃាំងនីតិសម្បទាត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីស្តារនីតិសម្បទា និងត្រៀមធ្វើសមាហរណកម្មទៅក្នុងសហគមន៍។

## សូចនាករទី១៩.ក.៖ មណ្ឌលស្តារនីតិសម្បទាបណ្តោះអាសន្នត្រូវបានស្នើសុំបង្កើត ដើម្បីគាំទ្រការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងបទដ្ឋានអន្តរជាតិផ្សេងទៀត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ១៩.១.ទីតាំងមណ្ឌលឃុំឃាំងនីតិសម្បទាត្រូវបានកំណត់ ហើយប្លង់អាគារ និងផ្នែកនានានៃអាគារត្រូវបានរចនាឡើងនិងត្រូវបានសាងសង់ស្របតាមបទដ្ឋានអន្តរជាតិ | ១៩.១.ក. ទីតាំងមណ្ឌលឃុំឃាំងនីតិសម្បទាត្រូវបានកំណត់ | ១៩.១.១. កំណត់ទីតាំងមណ្ឌលឃុំឃាំងនីតិសម្បទាស្ថិតនៅជិតសហគមន៍ដែលអាចជួយផ្តល់ជាសេវាសង្គម | ក្រសួងសង្គមកិច្ច | | X | X | | | | |
| | ១៩.១.ខ. ប្លង់អាគារដែលស្របតាមបទដ្ឋានអន្តជាតិ ត្រូវបានរចនាចប់សព្វគ្រប់ និងទទួលបានការអនុម័ត | ១៩.១.២. កំណត់លក្ខខណ្ឌសម្រាប់កុមាររស់នៅក្នុងមណ្ឌលឃុំឃាំងនីតិសម្បទាដែលមានដូចជាប្រភេទបទល្មើស ហានិភ័យ អាយុ និងភេទ។ ប្លង់សាងសង់មណ្ឌលឃុំឃាំងនីតិសម្បទាគឺស្របតាមបទដ្ឋានអន្តរជាតិ។ បុគ្គលិកក្នុងមណ្ឌលអាចទាញយកបទពិសោធន៍ពីមណ្ឌលល្អៗនៅក្នុងតំបន់អាស៊ាន និងពីអង្គការអន្តរជាតិនានា។ | ក្រសួងសង្គមកិច្ច | | | X | X | | | |
| | ១៩.១.គ. ផែនការសន្តិសុខ និងសុវត្ថិភាពដែលស្របតាមបទដ្ឋានអន្តរជាតិ ត្រូវបានរៀបចំឡើងនិងត្រូវបានអនុម័ត | ១៩.១.៣. រៀបចំសន្តិសុខ និងសុវត្ថិភាព ស្របតាមបទដ្ឋានអន្តរជាតិ ដោយយកចិត្តទុកដាក់លើសុខភាព តម្រូវការសង្គមនិងតម្រូវការអប់រំរបស់កុមារ បុគ្គលិក និងអ្នកផ្តល់សេវា | ក្រសួងសង្គមកិច្ច | | | | X | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ១៩.១.ឃ. ការជ្រើសរើសក្រុមហ៊ុនសាងសង់អាគារ និងកាលវិភាគបំពេញការងារសាងសង់ ត្រូវបានអនុម័ត ហើយការងារសាងសង់ចាប់ផ្ដើម | ១៩.១.៤. អនុវត្តនីតិវិធីជ្រើសរើសក្រុមហ៊ុនសាងសង់អាគារ ដោយមានកាលវិភាគបំពេញការងារសាងសង់ ហើយទទួលការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ | ក្រសួងសង្គមកិច្ច | | | | X | X | X | |
| ១៩.២. នីតិវិធី និងគោលនយោបាយ បុគ្គលិក និងសេវាគាំទ្រក្នុងមណ្ឌលត្រូវបានរៀបចំឡើង និងចាប់ផ្ដើមអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ | ១៩.២.ក. នីតិវិធី និងគោលនយោបាយសម្រាប់ប្រតិបត្តិក្នុងមណ្ឌលត្រូវបានបង្កើតឡើងស្របតាមបទដ្ឋានអន្តរជាតិ និងត្រូវបានអនុម័ត | ១៩.២.១. បង្កើតនីតិវិធីនិងគោលនយោបាយ សម្រាប់ប្រតិបត្តិក្នុងមណ្ឌល ស្របតាមបទដ្ឋានអន្តរជាតិ ដោយរួមទាំងផែនការផ្តល់សេវាគាំទ្រ និងបុគ្គលិកផងដែរ | ក្រសួងសង្គមកិច្ច | | | | | X | X | |
| | ១៩.២.ខ. កម្មវិធីបណ្ដុះបណ្ដាលបុគ្គលិកត្រូវបានរៀបចំឡើងដោយមានកាលវិភាគច្បាស់លាស់ និងទទួលបានការអនុម័ត | ១៩.២.២. រៀបចំកម្មវិធីបណ្ដុះបណ្ដាលបុគ្គលិក ដែលមានបញ្ចូលបទដ្ឋានអន្តរជាតិ និងអភិក្រមសិទ្ធិកុមារ។ រៀបចំវគ្គបណ្ដុះបណ្ដាលថ្នាក់មូលដ្ឋាន និងថ្នាក់ឯកទេសសម្រាប់បុគ្គលិកគ្រប់តំណែង។ | ក្រសួងសង្គមកិច្ច | | | | | | X | |
| | ១៩.២.គ. សេវាគាំទ្រនានានៅក្នុងមណ្ឌលត្រូវបានផ្ដួចផ្ដើមឡើង ហើយកិច្ចព្រមព្រៀងជាមួយស្ថាប័នពាក់ព័ន្ធត្រូវបានចុះហត្ថលេខា | ១៩.១.៣. ផ្ដួចផ្ដើមសេវាគាំទ្រនានាស្របតាមនីតិវិធី និងគោលនយោបាយ ដែលរួមមានការអប់រំ ការបណ្ដុះបណ្ដាល សុខភាព សេវាសង្គម និងសមាហរណកម្ម | ក្រសួងសង្គមកិច្ច | | | | | X | X | |

## កម្មវិធីយុទ្ធសាស្ត្រទីព៖ ការទប់ស្កាត់បទល្មើស

**គោលបំណងរួម៖** ដើម្បីកៀរគរ អប់រំ និងជួយសហគមន៍ឲ្យចេះកំណត់អត្តសញ្ញាណ និងកសាងប្រព័ន្ធការពារ ដើម្បីគាំទ្របុគ្គលម្នាក់ៗ និងកាត់បន្ថយការប្រព្រឹត្តបទល្មើស។

កម្មវិធីយុទ្ធសាស្ត្រនេះយល់ឃើញថា សហគមន៍ល្អអាចជួយកុមារឲ្យមានទំនាក់ទំនងជាមួយសហគមន៍។ សហគមន៍ល្អអាចកំណត់បាននូវកត្តាហានិភ័យ និងអាចឆ្លើយតបចំពោះកត្តាហានិភ័យទាំងនោះដើម្បីទប់ស្កាត់កុំឲ្យកុមារក្លាយជាកុមារទំនាស់នឹងច្បាប់។

ក្នុងផ្នែកសុខុមាលភាពកុមារ និងគ្រួសារ មានកម្មវិធីជាច្រើនរបស់អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល ដែលជួយដល់កុមារងាយរងគ្រោះ ហើយគោលបំណងគឺពង្រឹងសមត្ថភាពកម្មវិធីទាំងនោះ ដើម្បីអាចជួយដល់កុមារងាយនឹងប្រព្រឹត្តបទល្មើសផងដែរ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការសកម្មភាព ដើម្បីការពារ និងឆ្លើយតបអំពើហិង្សាលើកុមារឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ដែលនៅក្នុងផែនការនេះក៏មានដាក់បញ្ចូលផងដែរនូវសកម្មភាពជួយដល់កុមារដែលងាយនឹងប្រព្រឹត្តបទល្មើស រួមទាំងកុមារដែលត្រូវបានបង្វែរ និងកុមារដែលត្រូវធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។

យន្តការនគរបាលសហគមន៍ ក៏អាចជួយពង្រឹងទំនាក់ទំនងរវាង មន្ត្រីនគរបាល និងសហគមន៍ ដើម្បីទប់ស្កាត់បទល្មើស និងបង្កើនសុវត្ថិភាពសាធារណៈផងដែរ។ ដោយផ្អែកលើអភិក្រមសិទ្ធិកុមារ និង គោលការណ៍អនុវត្តល្អៗនៃការបង្វែរនិងការធ្វើសមាហរណកម្ម កុមារទំនាស់នឹងច្បាប់ និងកុមារងាយនឹងប្រព្រឹត្តបទល្មើសមិនគួរត្រូវបានកំណត់អត្តសញ្ញាណថាជាជនប្រព្រឹត្តបទល្មើសនោះទេ ហើយទាំងកុមារ និងគ្រួសារ គួរទទួលបានសេវាដូចអ្នកដទៃទៀតដែរ។ ការចាប់ខ្លួន ឬឃុំខ្លួនកុមារមិនទទួលបានផលល្អនៅក្នុងការទប់ស្កាត់បទល្មើសកុមារនោះទេ ។

សម្គាល់៖ ការអនុវត្តកម្មវិធីអប់រំផ្នែកសុខុមាលភាពគ្រួសារ និងកុមារ ការបង្កើតឲ្យមានសៀវភៅបញ្ជីឈ្មោះស្ថាប័នផ្តល់សេវាសង្គមនៅថ្នាក់ឃុំ និងការពិនិត្យឡើងវិញនូវកម្មវិធីផ្តល់សេវាទាំងនោះ គឺមាននៅក្នុងសកម្មភាពរួម។

**សមិទ្ធផលទី២០៖** បានបង្កើនសមត្ថភាពផ្នែកសុខុមាលភាពកុមារ និងផ្នែកសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណកុមារដែលងាយនឹងប្រព្រឹត្តបទល្មើស ហើយបញ្ជូនកុមារ និងគ្រួសារទៅទទួលសេវាសមរម្យ។

**សមិទ្ធផលទី២១៖** បានពង្រឹងកម្មវិធីដែលមានស្រាប់សម្រាប់ជួយដល់គ្រួសារ និងកុមារងាយរងគ្រោះ ឲ្យយល់ដឹងពីអាកប្បកិរិយាវិជ្ជមាន និងទំនាក់ទំនងល្អ ដែលអាចជួយពួកគេមិនឲ្យប្រព្រឹត្តបទល្មើស ហើយពង្រីកកម្មវិធីជាក់លាក់ ឬក៏បង្កើតកម្មវិធីថ្មីសម្រាប់កុមារប្រសិនបើចាំបាច់។

**សមិទ្ធផលទី២២៖** បានពង្រឹងទំនាក់ទំនងរវាងសហគមន៍ និងនគរបាលតាមរយៈការបង្កើតឲ្យមានយន្តការដោះស្រាយជម្លោះនៅសហគមន៍ដោយនគរបាលនៅថ្នាក់មូលដ្ឋាន ដើម្បីកាត់បន្ថយបទល្មើសដែលប្រព្រឹត្តដោយកុមារ និងកាត់បន្ថយអត្រាប្រព្រឹត្តបទល្មើសជាថ្មី។

**សមិទ្ធផលទី ២០** បានបង្កើនសមត្ថភាពផ្នែកសុខុមាលភាពភាពកុមារ និងផ្នែកសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណកុមារងាយនឹងប្រព្រឹត្តបទល្មើស ហើយបញ្ជូនកុមារ និងគ្រួសារទៅទទួលសេវាសមរម្យ។

## សូចនាករទី២០.ក.៖ ការវាយតម្លៃលើហានិភ័យ និងយន្តការបញ្ជូនត្រូវប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនៅឯថ្នាក់មូលដ្ឋាន ដើម្បីកំណត់កុមារងាយនឹងប្រព្រឹត្តបទល្មើស ហើយផ្តល់សេវាសមស្របដល់កុមារនិងក្រុមគ្រួសាររបស់គេ ។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា ( ឆ្នាំ ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២០.១. អង្គការសង្គមស៊ីវិល មណ្ឌលថែទាំកុមារតាមបែបសាសនា អង្គការផ្សេងទៀតដែលផ្តល់សេវា និងនគរបាលនៅតាមមូលដ្ឋាន បានប្រើប្រាស់គោលការណ៍ណែនាំស្តីពីការប៉ាន់ប្រមាណហានិភ័យ ដើម្បីកំណត់អត្តសញ្ញាណកុមារងាយនឹងប្រព្រឹត្តបទល្មើស ហើយបានឆ្លើយតបដោយត្រឹមត្រូវ | ២០.១.ក. វិធីសាស្ត្រក្នុងការកំណត់គោលការណ៍ណែនាំស្តីពីការប៉ាន់ប្រមាណហានិភ័យត្រូវបានឯកភាព | ២០.១.១. ពិនិត្យមើលឯកសារដែលពាក់ព័ន្ធនានា ដើម្បីធ្វើការប៉ាន់ប្រមាណលើកុមារ និងគ្រួសារដែលត្រូវការទាំងការគាំទ្រនិងសេវា រួចហើយកំណត់យកវិធីសាស្ត្រដ៏ត្រឹមត្រូវបំផុតក្នុងការដោះស្រាយកុមារងាយនឹងប្រព្រឹត្តបទល្មើស ឬអាចប្រព្រឹត្តបទល្មើសជាថ្មី | ក្រសួងសង្គមកិច្ច ក្រសួងមហាផ្ទៃ | X | | | | | | ក្រុមការងារអន្តរក្រសួង |
| | ២០.១.ខ. គោលការណ៍ណែនាំស្តីពីការប៉ាន់ប្រមាណហានិភ័យត្រូវបានរៀបចំ | ២០.១.២. យកគម្រូនៃការអនុវត្តល្អៗរបស់អន្តរជាតិ ហើយរៀបចំគោលការណ៍ណែនាំស្តីពីការប៉ាន់ប្រមាណហានិភ័យ ដើម្បីឆ្លើយតបជាក់លាក់ ទៅនឹងភាពងាយប្រព្រឹត្តបទល្មើស ឬការប្រព្រឹត្តបទល្មើសជាថ្មី | ក្រុមការងារអន្តរក្រសួង | | X | | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២០.២. បានកសាងសមត្ថភាពអង្គការសង្គមស៊ីវិល មណ្ឌលថែទាំកុមារបែបសាសនា និងអង្គការផ្តល់សេវាសង្គមផ្សេងទៀតនៅថ្នាក់មូលដ្ឋាន ដើម្បីកំណត់អត្តសញ្ញាណកុមារងាយនឹងប្រព្រឹត្តបទល្មើស ហើយធ្វើការឆ្លើយតបដើម្បីទប់ស្កាត់ | ២០.២.ក. ចំនួនឃុំដែលបានបញ្ចប់ការពិនិត្យមើលឡើងវិញនូវកម្មវិធីផ្តល់សេវាដែលមានស្រាប់នៅថ្នាក់ឃុំ និងកង្វះខាតដែលត្រូវបំពេញ | ២០.២.១. នេះជាផ្នែកមួយនៃសកម្មភាពរួម៖ ការពិនិត្យមើលឡើងវិញនូវកម្មវិធីផ្តល់សេវាដែលមានស្រាប់នៅថ្នាក់ឃុំ (ដែលគាំទ្រកុមារ និងគ្រួសារ ជាពិសេសកុមារដែលងាយនឹងប្រព្រឹត្តបទល្មើស ឬកុមារដែលកំពុងអនុវត្តផែនការបង្វែរ ឬកំពុងធ្វើសមាហរណកម្ម) ដែលការពិនិត្យនេះត្រូវកំណត់ឲ្យបានច្បាស់នូវកម្មវិធីសម្រាប់ការបញ្ជូន និងសេចក្តីត្រូវការសម្រាប់រៀបចំកម្មវិធីជាក់លាក់នានា ដើម្បីគាំទ្រដល់ការរៀបចំសៀវភៅបញ្ជីឈ្មោះសេវាកម្មសង្គមថ្នាក់មូលដ្ឋាន (អានកម្មវិធីយុទ្ធសាស្រ្តទី៥និង៨) | ក្រុមការងារអន្តរក្រសួង ក្រសួងសង្គមកិច្ច | X | | | | | | |
| | ២០.២.ខ. ចំនួនឃុំដែលបង្កើតឲ្យមានសៀវភៅបញ្ជីឈ្មោះអង្គការផ្តល់សេវាសង្គម | ២០.២.២. នេះជាផ្នែកមួយនៃសកម្មភាពរួម៖ រៀបចំសៀវភៅបញ្ជីឈ្មោះអង្គការផ្តល់សេវាសង្គមថ្នាក់មូលដ្ឋានដែលមានឈ្មោះកម្មវិធីផ្តល់សេវាកម្ម ធនធាន និងកម្មវិធីជួយដល់កុមារងាយនឹងប្រព្រឹត្តបទល្មើស ជួយដល់ផែនការបង្វែរ និងសមាហរណកម្ម | ក្រសួងសង្គមកិច្ច | | X | | | | | |
| | ២០.២.គ. ចំនួនឃុំដែលបានអនុវត្តកម្មវិធីអប់រំផ្នែកសុខុមាលភាពកុមារ និងគ្រួសារ | ២០.២.៣. នេះជាផ្នែកមួយនៃសកម្មភាពរួម៖ កម្មវិធីអប់រំផ្នែកសុខុមាលភាពកុមារ និងគ្រួសារ ត្រូវបានអនុវត្តដោយ គ.ក.ន.ក | ក្រសួងមហាផ្ទៃ | | | X | | | | ក្រសួងសង្គមកិច្ច |

**សមិទ្ធផលទី ២១** បានពង្រឹងកម្មវិធីដែលមានស្រាប់សម្រាប់ជួយដល់គ្រួសារ និងកុមារងាយរងគ្រោះ ឲ្យយល់ដឹងពីអាកប្បកិរិយាវិជ្ជមាន និងទំនាក់ទំនងល្អ ដែលអាចជួយពួកគេមិនឲ្យប្រព្រឹត្តបទល្មើស ហើយពង្រីកកម្មវិធីជាក់លាក់ ឬក៏បង្កើតកម្មវិធីថ្មីសម្រាប់កុមារប្រសិនបើចាំបាច់។

## សូចនាករទី២១.ក. ៖ ធនធាន ដែលអាចឆ្លើយតបទៅនឹងជម្រើស ឬសម្ពាធដែលនាំឲ្យប្រព្រឹត្តបទល្មើស និងផ្តល់ការណែនាំ ការគាំទ្រ និងព័ត៌មាន ត្រូវបានរៀបចំ និងដាក់បញ្ចូលទៅក្នុងកម្មវិធី និងឯកសារដែលមានស្រាប់។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២១.១. បង្កើនសមត្ថភាពនគរបាល អ្នកអប់រំ អ្នកកាន់កម្មវិធីផ្នែកអប់រំ និងផ្នែកសុខុមាលភាពកុមារ និងគ្រួសារ ដើម្បីជួយកុមារ និងគ្រួសារដែលងាយនឹងប្រព្រឹត្តបទល្មើសកុំឲ្យប្រព្រឹត្តបទល្មើស | ២១.១.ក. ឯកសារអប់រំទប់ស្កាត់ការប្រព្រឹត្តបទល្មើសសម្រាប់កុមារ និងគ្រួសារ និងសេចក្តីណែនាំពីរបៀបប្រើប្រាស់ឯកសារនេះត្រូវបានរៀបចំ | ២១.១.១. រៀបចំឯកសារអប់រំសម្រាប់កុមារ និងគ្រួសារ ដែលនិយាយពីជម្រើសផ្សេងៗ និងសម្ពាធនានាដែលនាំឲ្យកុមារប្រព្រឹត្តបទល្មើស និងសរសេរសេចក្តីណែនាំពីរបៀបប្រើប្រាស់។<br>២១.១.១.១. កុមារអាយុពី ៨ ទៅ១២ ឆ្នាំ<br>២១.១.១.២. កុមារអាយុពី១៣ ទៅ១៨ ឆ្នាំ<br>២១.១.១.៣. កុមារទំនាស់នឹងច្បាប់<br>២១.១.១.៤. សមាជិកគ្រួសារ<br>២១.១.១.៥.ការណែនាំ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ<br>២១.១.១.៦. ឯកសារណែនាំសម្រាប់គ្រូ | ក្រសួងសង្គមកិច្ច | | X | | | | | ក្រុមការងារអន្តរក្រសួង ក្រសួងមហាផ្ទៃ |
| | ២១.១.ខ. ចំនួនសាលារៀនដែលប្រើប្រាស់ឯកសារទាំងនេះ | ២១.១.២. ចែកជូនតាមសាលារៀនសម្រាប់អនុវត្តនូវ ១) ឯកសារអប់រំទប់ស្កាត់ការប្រព្រឹត្តបទល្មើសសម្រាប់កុមារ និងគ្រួសារ ២) សេចក្តីណែនាំពីរបៀបប្រើប្រាស់ឯកសារនេះ និង៣) ឧបករណ៍វាយតម្លៃហានិភ័យ | ក្រុមការងារអន្តរក្រសួង ក្រសួងអប់រំ | | | | X | | | គ្រប់ស្ថាប័នផ្តល់ការអប់រំ |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ២១.១.គ. ឯកសារណែនាំពីការចេញសេចក្តីព្រមានរបស់នគរបាលមានដាក់បញ្ចូលឯសារអប់រំទប់ស្កាត់ការប្រព្រឹត្តបទល្មើសសម្រាប់កុមារ និងគ្រួសារ | ២១.១.៣. ឯកសារអប់រំទប់ស្កាត់ការប្រព្រឹត្តបទល្មើសសម្រាប់កុមារ និងគ្រួសារ ត្រូវបានដាក់បញ្ចូលជាមួយឯកសារណែនាំពីការចេញសេចក្តីព្រមានរបស់នគរបាល | ក្រសួងមហាផ្ទៃ | | X | | | | | |
| | ២១.១.ឃ. ចំនួនកម្មវិធីអប់រំផ្អែកសុខុមាលភាពកុមារ និងគ្រួសារ ដែលដាក់បញ្ចូលឯកសារអប់រំទប់ស្កាត់ការប្រព្រឹត្តបទល្មើសសម្រាប់ប្រើប្រាស់ជាមួយកុមារដែលងាយនឹងប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសសារជាថ្មី | ២១.១.៤. ឯកសារអប់រំទប់ស្កាត់ការប្រព្រឹត្តបទល្មើសសម្រាប់កុមារ និងគ្រួសារ និងសេចក្តីណែនាំពីរបៀបប្រើប្រាស់ឯកសារនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំផ្អែកសុខុមាលភាពកុមារ និងគ្រួសារ ក៏ដូចជាកម្មវិធីអប់រំ និងបណ្តុះបណ្តាលដែលពាក់ព័ន្ធដទៃទៀតដែរ | ក្រុមការងារអន្តរក្រសួង ក្រសួងសង្គមកិច្ច | | X | | | | | |

**សមិទ្ធផលទី ២២** បានពង្រឹងទំនាក់ទំនងរវាងសហគមន៍ និងនគរបាលតាមរយៈការបង្កើតឲ្យមានយន្តការដោះស្រាយជម្លោះនៅសហគមន៍ដោយនគរបាលនៅថ្នាក់មូលដ្ឋាន ដើម្បីកាត់បន្ថយបទល្មើសដែលប្រព្រឹត្តដោយកុមារ និងកាត់បន្ថយអត្រាប្រព្រឹត្តបទល្មើសជាថ្មី។

## សូចនាករទី២២.ក.៖ កម្មវិធីនគរបាលសហគមន៍ត្រូវបានសាកល្បងនៅក្នុងខេត្តចំនួន៥។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) ១ | | ២ | | ៣ | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| ២២.១. កម្មវិធីស្តីពីនគរបាលសហគមន៍ត្រូវបានរៀបចំឡើង ដើម្បីបង្កើតភាពជាដៃគូរវាងនគរបាល និងសហគមន៍ ក្នុងគោលបំណងអនុវត្តយន្តការដោះស្រាយបញ្ហានៅថ្នាក់មូលដ្ឋាន ទប់ស្កាត់បទល្មើស និងបញ្ហាពាក់ព័ន្ធផ្សេងទៀត | ២២.១.ក. ចំនួននគរបាលនិងអ្នកពាក់ព័ន្ធដែលបានយល់ដឹងពីគោលការណ៍នគរបាលសហគមន៍ | ២២.១.១. រៀបចំសិក្ខាសាលាស្តីពីនគរបាលសហគមន៍ ដើម្បីអប់រំនគរបាល និងអ្នកពាក់ព័ន្ធដទៃទៀតឲ្យយល់ដឹងពីគោលការណ៍ ការអនុវត្តការងារ និងគំរូល្អៗស្តីពីការចូលរួមរបស់នគរបាលនៅក្នុងសហគមន៍ | ក្រសួងមហាផ្ទៃ | | | X | | | | អង្គការសាសនា |
| | ២២.១.ខ. ការរៀបចំផែនការអនុវត្តសាកល្បងស្តីពីនគរបាលសហគមន៍ ត្រូវបានបញ្ចប់ | ២២.១.២. រៀបចំផែនការអនុវត្តសាកល្បងស្តីពីនគរបាលសហគមន៍ ដោយរួមមានផែនការច្បាស់លាស់ ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយ | ក្រុមការងារអន្តរក្រសួង មន្ទីរអប់រំ | | | X | X | | | ស្ថាប័នអប់រំឯកជន |
| | ២២.១.គ. របាយការណ៍ស្តីពីវឌ្ឍនភាព និងរបាយការណ៍ចុងក្រោយត្រូវបានរៀបចំឡើង | ២២.១.៣. អនុវត្តនិងវាយតម្លៃគម្រោងសាកល្បងស្តីពីនគរបាលសហគមន៍ | ក្រសួងមហាផ្ទៃ | | | | | X | X | |

## កម្មវិធីយុទ្ធសាស្ត្រទី៨៖ ក្របខណ្ឌគោលនយោបាយ និងប្រព័ន្ធប្រតិបត្តិ

**គោលបំណងរួម៖**

ដើម្បីបង្កើតឡើងនូវអភិក្រមប្រព័ន្ធតែមួយក្នុងការឆ្លើយតបទៅនឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌កុមារ ដែលធានាការគ្រប់គ្រងកុមារនីមួយៗឲ្យមានប្រសិទ្ធភាព។

កម្មវិធីយុទ្ធសាស្ត្រនេះទទួលស្គាល់ថា អភិក្រមប្រព័ន្ធតែមួយក្នុងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន នឹងធានាឲ្យមានការគ្រប់គ្រងកុមារប្រកបដោយប្រសិទ្ធភាព។ គោលការណ៍អនុវត្តប្រព័ន្ធនេះនឹងរៀបចំឡើងដោយផ្អែកលើអភិក្រមសិទ្ធិកុមារ និងផ្អែកលើវិធីសាស្ត្រកុមារមជ្ឈមណ្ឌល។ គោលបំណងនៃគោលការណ៍នេះ គឺដាក់បញ្ចូលបទពិសោធន៍ល្អៗស្តីពីជោគជ័យរបស់កុមារម្នាក់ៗ និងកាត់បន្ថយការឈឺចាប់ដល់កុមារ ។ គោលការណ៍នេះនឹងលើកទឹកចិត្តឲ្យមានការចូលរួមរបស់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ ព្រមទាំងមានការគោរពដល់កុមារជាជនរងគ្រោះ និងសហគមន៍ផងដែរ។ យោងតាមបទដ្ឋានអន្តរជាតិ គឺត្រូវស្វែងរកដំណោះស្រាយឲ្យបានលឿនបំផុត បន្ទាប់ពីកុមារបានប្រព្រឹត្តបទល្មើស ហេតុដូចនេះតុលាការគួរពន្លឿននីតិវិធី។ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងឬករណី នឹងត្រូវបានបង្កើតឡើង ហើយមានប្រសិទ្ធភាពក្នុងការប្រមូលនិងចែករំលែកព័ត៌មាន និង បញ្ចៀសមិនឲ្យមានការងារជាន់គ្នា។ ក្រុមការងារអន្តរក្រសួងនឹងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធដើម្បីរៀបចំប្រព័ន្ធនេះ។ បញ្ហារបស់កុមារត្រូវចែកឲ្យដាច់ពីបញ្ហារបស់មនុស្សពេញវ័យ។ មាត្រា ៤៤ លើកឡើងអំពីការបង្កើតតុលាការកុមារដាច់ដោយឡែក។ ការបង្កើតឲ្យមានរដ្ឋបាលបែបកុមារមេត្រី និងការិយាល័យទទួលបន្ទុកអនីតិជនរបស់តុលាការ នឹងជួយដល់ការដោះស្រាយសំណុំរឿងកុមារដោយត្រឹមត្រូវ។

**សមិទ្ធផលទី២៣៖** ប្រព័ន្ធយុត្តិធម៌អនីតិជនមួយត្រូវបានបង្កើតឡើង ដែលបង្កើនការគ្រប់គ្រងកុមារម្នាក់ៗឲ្យមានប្រសិទ្ធភាពដោយប្រើប្រាស់អភិក្រមសិទ្ធិកុមារជាមូលដ្ឋាន។

**សមិទ្ធផលទី២៤៖** មានប្រព័ន្ធគ្រប់គ្រងសំណុំរឿងឬករណីកុមារ ដែលមានប្រសិទ្ធភាពក្នុងការប្រមូលនិងផ្តល់ព័ត៌មាន។

**សមិទ្ធផលទី២៥៖** ធានារក្សាការសម្ងាត់នៃអត្តសញ្ញាណ និងកំណត់ហេតុរបស់កុមារ។

**សមិទ្ធផលទី២៦៖** ការបង្វែររបស់សាលាដំបូង ត្រូវបានអនុវត្តតាមនីតិវិធីកុមារមេត្រី និងស្របតាមការអនុវត្តល្អរបស់ប្រទេសដទៃ។

## សមិទ្ធផលទី ២៣ ប្រព័ន្ធយុត្តិធម៌អនីតិជនមួយត្រូវបានបង្កើតឡើង ដែលបង្កើនការគ្រប់គ្រងកុមារម្នាក់ៗឲ្យមានប្រសិទ្ធភាពដោយប្រើប្រាស់អភិក្រមសិទ្ធិកុមារជាមូលដ្ឋាន ។

### សូចនាករទី២៣.ក.៖ ប្រព័ន្ធប្រតិបត្តិយុត្តិធម៌អនីតិជនត្រូវបានរៀបចំ និងចងក្រងជាឯកសារ។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា ( ឆ្នាំ ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៣.១. ប្រព័ន្ធប្រតិបត្តិយុត្តិធម៌អនីតិជនមានភាពច្បាស់លាស់ ស្តេរភាព និងប្រសិទ្ធភាព ដោយមានការបង្កើនធនធាន | ២៣.១.ក. ចំនួនអ្នកប្រើប្រាស់សៀវភៅ និង ចំនួនស្ថាប័នដែលជួយបញ្ចូលព័ត៌មានពាក់ព័ន្ធ | ២៣.១.១. រៀចំសៀវភៅសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត ដែលមានការពន្យល់វាក្យស័ព្ទប្រព័ន្ធយុត្តិធម៌អនីតិជន បញ្ជីឈ្មោះកម្មវិធីផ្តល់សេវាគាំទ្រ ទម្រង់ប្រើប្រាស់ផ្សេងៗ សេចក្តីណែនាំនានា ប្រភពធនធាន និងព័ត៌មានផ្សេងទៀត | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |
| | ២៣.១.ខ. %ស្ថាប័នដែលប្រើប្រាស់ឧបករណ៍ វាយតម្លៃហានិភ័យនេះ | ២៣.១.២. បង្កើតឧបករណ៍វាយតម្លៃហានិភ័យរួមមួយដែលអាចប្រើប្រាស់ក្នុងប្រព័ន្ធយុត្តិធម៌អនីតិជ និងអនុវត្តដោយអ្នកពាក់ព័ន្ធ។ ឧបករណ៍វាយតម្លៃនេះនឹងត្រូវប្រើប្រាស់គ្រប់ពេលដែលត្រូវការវាយតម្លៃលើកុមារ។ ឧបករណ៍នេះនឹងរួមបញ្ចូលគ្រប់ផ្នែក ដូចជា សុខាភិបាល អប់រំ ផ្នែកផ្លូវចិត្ត ស្ថានភាពរស់នៅ ទំនាក់ទំនងក្នុងការរស់នៅ អាកប្បកិរិយា និងអនាគតរបស់គេ។ ឧបករណ៍នេះក៏នឹងមានសំណួរពាក់ព័ន្ធនឹងការបង្កហានិភ័យដល់សហគមន៍ផងដែរ។ ( អានកម្មវិធីយុទ្ធសាស្រ្តទី៧.១០ ) | ក្រុមការងារអន្តរក្រសួង | | X | X | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ២៣.១.គ. %នៃការធ្វើបច្ចុប្បន្នភាពគេហទំព័រប្រចាំខែនៅក្នុងផ្នែកនីមួយៗ និង%នៃស្ថាប័នពាក់ព័ន្ធដែលចូលរួមផ្តល់ឯកសារ | ២៣.១.៣. នេះគឺជាសកម្មភាពរួមមួយ៖ បន្តប្រមូលឯកសារពាក់ព័ន្ធដែលមានដូចជាករណីសិក្សា ឯកសារសម្រាប់អនុវត្ត ឯកសារស្តីពីវគ្គបណ្តុះបណ្តាល លទ្ធផលនៃការវាយតម្លៃ និងព័ត៌មានផ្សេងទៀត ដើម្បីធ្វើបច្ចុប្បន្នភាពប្រចាំខែ | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |
| | ២៣.១.ឃ. %ស្ថាប័នដែលប្រើប្រាស់គោលការណ៍ណែនាំនេះ | ២៣.១.៤. រៀបចំគោលការណ៍ណែនាំរួមមួយសម្រាប់អនុវត្ត ដែលស្តីពីរបៀបសម្ភាសកុមារ ការវាយតម្លៃកុមារ និង ការណែនាំដល់កុមារ | ក្រុមការងារអន្តរក្រសួង | | X | | X | | | |
| | ២៣.១.ង. %នៃស្ថាប័នដែលបានដាក់បញ្ចូលកម្មវិធីអប់រំស្តីពីយុត្តិធម៌អនីតិជនទៅក្នុងកម្មវិធីបណ្តុះបណ្តាល ដែលមានស្រាប់ | ២៣.១.៥. នេះគឺជាសកម្មភាពរួមមួយ៖ រៀបចំឲ្យមានកម្មវិធីអប់រំស្តីពីយុត្តិធម៌អនីតិជនដែលជាផ្នែកមួយនៃក្របខណ្ឌការងារពង្រឹងសមត្ថភាព ហើយដាក់បញ្ចូលកម្មវិធីអប់រំនេះទៅក្នុងកម្មវិធីបណ្តុះបណ្តាលដែលមានរួចហើយ (អានកម្មវិធីយុទ្ធសាស្ត្រទី២) | ក្រុមការងារអន្តរក្រសួង | | x | | | | | |
| | ២៣.១.ច. %ស្ថាប័នដែលអនុញ្ញាតឲ្យបុគ្គលិកចូលរួមវគ្គបណ្តុះបណ្តាល ហើយកម្រិតនៃការពេញចិត្តរបស់អ្នកចូលរួមគឺ ៧/១០ | ២៣.១.៦. នេះគឺជាសកម្មភាពរួមមួយ៖ កំណត់ពេលវេលាវគ្គបណ្តុះបណ្តាលរួមគ្នាដែលអ្នកពាក់ព័ន្ធអាចចូលរួមបាន (អានកម្មវិធីយុទ្ធសាស្ត្រទី២) | | | | | | | | |
| | ២៣.១.ឆ. ចំនួនអ្នកដែលបានរៀនចប់វគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណេត | ២៣.១.៧. បង្កើតវគ្គបណ្តុះបណ្តាល និងឯកសារសិក្សាតាមគេហទំព័រ | ក្រុមការងារអន្តរក្រសួង | | | | | X | X | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៣.២. មានផែនទីស្តីពីប្រព័ន្ធការងារ ដែលជួយគាំទ្រដល់ការកសាងសមត្ថភាពក្នុងការសហការ និង គ្រប់គ្រងបញ្ហានៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព | ២៣.២.ក. បានរៀបចំផែនទីស្តីពីប្រព័ន្ធដែលមាននាពេលបច្ចុប្បន្ន ដោយបានចងក្រងទុកជាឯកសារស្តីពីដំណើរការនៃការអនុវត្ត និង ការវិភាគលើការចំណាយ | ២៣.២.១. នេះគឺជាសកម្មភាពរួមមួយ៖ រៀបចំផែនទីស្តីពីប្រព័ន្ធដែលមានបច្ចុប្បន្ន ដើម្បីរកចំណុចជាន់គ្នា បែបបទហួសសម័យកាល កាតព្វកិច្ចផ្លូវច្បាប់ ឯកសារពាក់ព័ន្ធផ្សេងៗ និងការចំណាយ (អានកម្មវិធីយុទ្ធសាស្ត្រទី១) | ក្រសួងយុត្តិធម៌ | X | | | | | | |
| | ២៣.២.ខ. ផែនទីប្រព័ន្ធថ្មី ស្តីពីការងារយុត្តិធម៌អនីតិជនត្រូវបានបង្កើតឡើង | ២៣.២.២. ផែនទីស្តីពីប្រព័ន្ធការងារយុត្តិធម៌អនីតិជនសព្វថ្ងៃ ត្រូវបានប្រើដើម្បីរៀបចំផែនទីស្តីពីប្រព័ន្ធថ្មី និងកំណត់ចំណុចថ្មីៗដែលត្រូវការ ដូចជាដំណើរការគោលនយោបាយ ការអនុវត្ត និងការចងក្រងឯកសារសម្រាប់ប្រព័ន្ធថ្មី។ កំណត់ការងារអាទិភាព និងភ្នាក់ងារនាំមុខ។ | ក្រុមការងារអន្តរក្រសួង ក្រសួងយុត្តិធម៌ | X | X | | | | | |
| | ២៣.២.គ. %ចំណុចថ្មីៗនៅក្នុងប្រព័ន្ធថ្មីត្រូវបានអនុវត្ត | ២៣.២.៣. បង្កើតចំណុចថ្មីៗនៅក្នុងប្រព័ន្ធថ្មីនេះដើម្បីឲ្យស្របតាមការងារអាទិភាព ដោយប្រើប្រាស់វិធីសាស្ត្រ និងភាសារួមតែមួយ | ក្រសួងយុត្តិធម៌ | X | X | | | | | |
| | ២៣.២.ឃ. %នៃការឆ្លើយតបទៅនឹងអនុសាសន៍ | ២៣.២.៤. ផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាព និង វាយតម្លៃលើប្រព័ន្ធប្រតិបត្តិយុត្តិធម៌អនីតិជន ដោយមានអនុសាសន៍សម្រាប់ឲ្យស្ថាប័នពាក់ព័ន្ធផ្សេងៗយកទៅពិចារណាក្នុងការអនុវត្ត | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |

| សមិទ្ធផលទី ២៤ | មានប្រព័ន្ធគ្រប់គ្រងសំណុំរឿងឬករណីកុមារ ដែលមានប្រសិទ្ធភាពក្នុងការប្រមូលនិងផ្តល់ព័ត៌មាន។ |
|---|---|

## សូចនាករទី២៤.ក.៖ ប្រព័ន្ធគ្រប់គ្រងករណី/សុំណុំរឿងកុមារត្រូវបានរៀបចំ និងអនុវត្ត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៤.១. ប្រព័ន្ធគ្រប់គ្រងសំណុំរឿងកុមារត្រូវបានរៀបចំដោយឈរលើឧត្តមប្រយោជន៍កុមារ ដើម្បីគ្រប់គ្រងសំណុំរឿងកុមារឲ្យមានប្រសិទ្ធភាព និងការពារសិទ្ធិកុមារផងដែរ | ២៤.១.ក. បានរៀបចំផែនទីស្តីពីប្រព័ន្ធដែលមាននាពេលបច្ចុប្បន្ន ដោយបានចងក្រងទុកជាឯកសារស្តីពីដំណើរការនៃការអនុវត្ត និងការវិភាគលើការចំណាយ | ២៤.១.១. នេះគឺជាសកម្មភាពរួមមួយ៖ រៀបចំផែនទីស្តីពីប្រព័ន្ធដែលមានបច្ចុប្បន្ន ដើម្បីរកចំណុចជាន់គ្នា បែបបទហួសសម័យកាល កាតព្វកិច្ចផ្លូវច្បាប់ ឯកសារពាក់ព័ន្ធផ្សេងៗ និងការចំណាយ (អានកម្មវិធីយុទ្ធសាស្ត្រទី១) | ក្រសួងយុត្តិធម៌ | | X | X | X | X | X | គ្រប់ស្ថាប័នពាក់ព័ន្ធ |
| | ២៤.១.ខ. ប្រព័ន្ធគ្រប់គ្រងសំណុំរឿងកុមារ ត្រូវបានអនុវត្ត និងត្រូវបានវាយតម្លៃ | ២៤.១.២. រៀបចំប្រព័ន្ធគ្រប់គ្រងសំណុំរឿង ដែលអាចផ្តល់អាទិភាពដល់រឿងក្តីកុមារ និងជួយឲ្យមានការសម្រេចចិត្តស្របទៅនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងបទដ្ឋានអន្តរជាតិ | ក្រសួងយុត្តិធម៌ | | x | | | | | |
| | ២៤.១.គ. ចំនួនតុលាការដែលបានរៀបចំកាលបរិច្ឆេទសវនាការរឿងក្តីកុមារប្រចាំឆ្នាំ | ២៤.១.៣. នេះគឺជាសកម្មភាពរួមមួយ៖ កាលបរិច្ឆេទសវនាការរឿងក្តីកុមារប្រចាំឆ្នាំត្រូវបានរៀបចំ ដោយផ្អែកលើពេលវេលារបស់ចៅក្រមជំនាញ ភ្នាក់ងារសង្គមកិច្ចមេធាវី និងអ្នកផ្តល់សេវាកម្ម | ក្រសួងយុត្តិធម៌ | | x | | | | | |
| | ២៤.១.ឃ. ចំនួនតុលាការ ដែលមានរៀបចំកាលវិភាគប្រជុំពិនិត្យមើលសំណុំរឿងកុមារ | ២៤.១.៤. នេះគឺជាសកម្មភាពរួមមួយ៖ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងមានកាលវិភាគពិនិត្យមើលសំណុំរឿងនីមួយៗរបស់កុមារ ដើម្បីជៀសវាងការមិនអនុវត្តតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន តាមដានមើលភាពរីកចម្រើននៃសំណុំរឿងនីមួយៗ ផ្តល់អាទិភាព និងគ្រប់គ្រងសំណុំរឿងកុមារ។ ភ្នាក់ងារសង្គមកិច្ចដែលទទួលបន្ទុកខាងយុត្តិធម៌មានតួនាទីក្នុងការកំណត់បញ្ហាវិវាទ និងផ្តល់ព័ត៌មាន។ | ក្រសួងយុត្តិធម៌ | | x | | | | | |

## សមិទ្ធផលទី ២៥ ធានារក្សាការសម្ងាត់នៃអត្តសញ្ញាណ និងកំណត់ហេតុរបស់កុមារ។

### សូចនាករទី២៥.ក. ៖ នីតិវិធី និងគោលនយោបាយស្តីពីការការពារភាពជាឯកជនរបស់កុមារត្រូវបានអនុវត្ត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៥.១. ប្រព័ន្ធប្រតិបត្តិយុត្តិធម៌អនីតិជនមានការរក្សាការសម្ងាត់អត្តសញ្ញាណ ព័ត៌មានលម្អិតរបស់កុមារ ប្រភេទបទល្មើស លិខិតថ្កោលទោស ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារ | ២៥.១.ក. ក្រុមសីលធម៌ ស្តីពីការចែករំលែកព័ត៌មាន ត្រូវបានរៀបចំហើយបានដាក់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាល ការអនុវត្ត និងគោលការណ៍ពាក់ព័ន្ធផ្សេងៗ | ២៥.១.១. រៀបចំក្រមសីលធម៌ស្តីពីការចែករំលែកព័ត៌មានពាក់ព័ន្ធនឹងកុមារ | ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | All |
| | ២៥.១.ខ. មានទិន្នន័យអំពីសារដែលមាននៅលើប្រព័ន្ធផ្សព្វផ្សាយទាំងវិជ្ជមាន និងអវិជ្ជមាន និងសារដែលផ្ទុយនឹងច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ២៥.១.២. រៀបចំឯកសារសម្រាប់អ្នកសារព័ត៌មានដោយរួមបញ្ចូលច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងសិទ្ធិកុមារ | ក្រុមការងារអន្តរក្រសួង | | x | x | | | | |
| | ២៥.១.គ. %នៃបុគ្គលិកដែលវាយតម្លៃខ្លួនឯងលើការគ្រប់គ្រងការផ្លាស់ប្តូរព័ត៌មានដើម្បីឧត្តមប្រយោជន៍របស់កុមារ | ២៥.១.៣. រាល់ការបណ្តុះបណ្តាលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ មានដាក់បញ្ចូលសេចក្តីណែនាំអំពីរបៀបនៃការផ្លាស់ប្តូរព័ត៌មាន និងការរក្សាការសម្ងាត់។ ករណីសិក្សានឹងត្រូវបានរៀបចំឡើង ដើម្បីអភិវឌ្ឍជំនាញរក្សាការសម្ងាត់របស់កុមារ ។ | ក្រសួងយុត្តិធម៌ | | X | X | | | | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | ២៥.១.ឃ. %នៃការធ្លាក់ចុះប្រចាំឆ្នាំនៃចំនួនមនុស្ស និងស្ថាប័ន ដែលមិនបានគោរពព័ត៌មានសម្ងាត់របស់កុមារ | ២៥.១.៤. រៀបចំពិធីសារដើម្បីគ្រប់គ្រងការរំលោភលើព័ត៌មានសម្ងាត់របស់កុមារ ដោយមានបញ្ចូលការបណ្តុះបណ្តាលចាំបាច់ និងផ្តល់សិទ្ធិអំណាចដល់តុលាការក្នុងការចោទប្រកាន់ចំពោះអ្នកដែលល្មើសនឹងពិធីសារនេះ។ ពិនិត្យមើលច្បាប់ស្តីពីយុត្តិធម៌អនីតិជនឡើងវិញ និងច្បាប់ដទៃទៀតដែលចែងអំពីអ្នកផ្សព្វផ្សាយព័ត៌មានរបស់កុមារ ដូចជាគ្រូបង្រៀន វេជ្ជបណ្ឌិត ដែលទម្លាយព័ត៌មានសម្ងាត់របស់កុមារ។ | ក្រុមការងារអន្តរក្រសួង | | X | x | x | x | x | |
| ២៥.២. សវនាការរឿងក្តីកុមារត្រូវបានធ្វើឡើងជាអសាធារណៈ ហើយអ្នកចូលរួមត្រូវមានការអនុញ្ញាតពីតុលាការ | ២៥.២.ក. %នៃសវនាការរឿងក្តីកុមារ ដែលបានធ្វើឡើងជាអសាធារណៈ មានការកើនឡើង | ២៥.២.១. កំណត់កាលបរិច្ឆេទសវនាការសម្រាប់រឿងក្តីកុមារ ដោយធ្វើយ៉ាងណាឲ្យមានការចូលរួមពីកុមារនិងធ្វើឡើងជាអសាធារណៈ | ក្រសួងយុត្តិធម៌ | | X | X | | | | |

## សមិទ្ធផលទី ២៦ ការបង្វែររបស់សាលាដំបូង ត្រូវបានអនុវត្តតាមនីតិវិធីកុមារមេត្រី និងស្របតាមការអនុវត្តល្អរបស់ប្រទេសដទៃ

### សូចនាករទី២៦.ក. ៖ ការបង្វែររបស់សាលាដំបូងបានអនុវត្តស្របតាមបទដ្ឋានអន្តរជាតិ

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៦.១. មានផ្នែកជំនាញខាងរឿងក្តីកុមារនៅសាលាដំបូង (មាត្រា៤៤) និងមានរដ្ឋបាលទទួលបន្ទុកតែរឿងក្តីកុមារ | ២៦.១.ក. %នៃសាលាដំបូងដែលបានបង្កើតផ្នែកជំនាញខាង រឿងក្តីកុមារ និងមានបន្ទប់សម្រាប់សវនាការតែរឿងក្តីកុមារ | ២៦.១.១. បង្កើតផ្នែកជំនាញខាងរឿងក្តីកុមារនៅសាលាដំបូង ដោយឈរលើគោលការណ៍កុមារមេត្រី | ក្រសួងយុត្តិធម៌ | | X | X | X | X | X | All |
| | ២៦.១.ខ. បុគ្គលិកទាំងអស់ក្នុងផ្នែកជំនាញខាងរឿងក្តីកុមារទទួលបានការ បណ្តុះបណ្តាល | ២៦.១.២. បណ្តុះបណ្តាលបុគ្គលិកផ្នែកជំនាញខាងរឿងក្តីកុមារ រួមទាំងបុគ្គលិករដ្ឋបាលផង អំពីនីតិវិធី និងការអនុវត្តតាមបែបកុមារមេត្រី | ក្រសួងយុត្តិធម៌ | X | X | X | | | | |
| ២៦.២. សវនាការរឿងក្តីរបស់កុមារត្រូវបានរៀបចំក្នុងបន្ទប់មានលក្ខណៈកុមារមេត្រី | ២៦.២.ខ. %នៃតុលាការដែលបានកែសម្រួលបន្ទប់សវនាការឲ្យមានលក្ខណៈកុមារមេត្រី | ២៦.២.១. ពិនិត្យមើលឧបករណ៍ប្រើប្រាស់និងនីតិវិធីក្នុងសាលាដំបូងនីមួយៗ ដោយធានាឲ្យមានបរិយាកាសបែបកុមារមេត្រី។ បរិយាកាសបែបកុមារមេត្រី រួមមាន៖<br>២៦.២.១.១. កែសម្រួលសម្ភារៈប្រើប្រាស់ក្នុងបន្ទប់សវនាការ ឲ្យមានលក្ខណៈកុមារមេត្រី<br>២៦.២.១.២. បន្ទប់រង់ចាំ និងបន្ទប់សម្ភាស ត្រូវជួសជុលឡើងវិញឲ្យមានលក្ខណៈស្ងាត់ និងមិនមានការរំខានពីខាងក្រៅ<br>២៦.២.១.៣. ជ្រើសរើសយកបន្ទប់សវនាការមួយបន្ទប់នៅជាន់ទី១ ដើម្បីកែសម្រួលឲ្យមានបរិយាកាសល្អ និងងាយស្រួលទំនាក់ទំនង | ក្រសួងយុត្តិធម៌ | X | X | X | X | X | X | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| | | ២៦.២.១.៤. ពិនិត្យមើលបន្ទប់ឃុំខ្លួនដែលកំពុងប្រើប្រាស់ ហើយកែសម្រួលវាឲ្យមានលក្ខណៈស្តង់ដារ បើពុំមានទេ ត្រូវរៀបចំបន្ទប់ឃុំខ្លួនថ្មី ដោយធ្វើយ៉ាងណាឲ្យមានលក្ខណៈកុមារមេត្រី<br>២៦.២.១.៥. នៅសាលាដំបូងដែលធំទូលាយ ត្រូវរៀបចំច្រកចូលនិងកន្លែងរង់ចាំដាច់ដោយឡែកសម្រាប់កុមារ | | | | | | | | |
| ២៦.៣. រាល់គម្រោងសាងសង់និងជួសជុលអគារសាលាដំបូងនានា មានបន្ទប់សម្ភាសន៍ បន្ទប់រង់ចាំ និងឧបករណ៍បែបកុមារមេត្រី | ២៦.៣.ក. %ថវិកាចំណាយលើផ្នែកកុមារមេត្រីនៅក្នុងគម្រោងសាងសង់និងជួសជុលអគារសាលាដំបូង | ២៦.៣.១. រាល់គម្រោងសាងសង់និងជួសជុលអគារសាលាដំបូងនានា ត្រូវរាប់បញ្ចូលនូវបន្ទប់ សម្ភារៈ ឬឧបករណ៍ដែលមានលក្ខណៈកុមារមេត្រី | ក្រសួងយុត្តិធម៌ | | X | X | X | X | X | |
| | ២៦.៣.ខ. មានផែនការ១០ឆ្នាំសម្រាប់បង្កើតឲ្យមាន ទីកន្លែងសម្រាប់រឿងក្តីកុមារនៅក្នុងទីតាំងបច្ចុប្បន្នរបស់សាលាដំបូង ឬនៅទីតាំងថ្មី | ២៦.៣.២. ពិនិត្យមើលពីលទ្ធភាពដែលអាចឲ្យមានតុលាការ ឬអាគារដាច់ដោយឡែកសម្រាប់រឿងក្តីកុមារ ដោយមានច្រកចេញចូលដោយឡែក ព្រមទាំងសម្ភារៈមានក្ខណៈកុមារមេត្រី រួមទាំងការកំណត់អាទិភាពក្នុងការចំណាយ | ក្រសួងយុត្តិធម៌ | | | | | X | X | |

## កម្មវិធីយុទ្ធសាស្ត្រទី៩៖ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

**គោលបំណងទូទៅ៖**

ដើម្បីរៀបចំប្រព័ន្ធប្រមូលទិន្នន័យ ពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ពីការអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ និងពីបទពិសោធន៍របស់កុមារទំនាស់នឹងច្បាប់។

គោលបំណងទូទៅនៃកម្មវិធីយុទ្ធសាស្ត្រនេះយល់ថា ការរៀបចំឲ្យមានប្រព័ន្ធប្រមូលទិន្នន័យ ពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងពីបទពិសោធន៍របស់កុមារទំនាស់នឹងច្បាប់ឲ្យបានច្បាស់លាស់ ជាការងារសំខាន់សម្រាប់ជួយដល់ការសម្រេចចិត្តនាពេលអនាគត។ ក្រុមការងារអន្តរក្រសួងជាអ្នកទទួលខុសត្រូវក្នុងការរៀបចំប្រព័ន្ធនេះ ការអនុវត្ត ការសម្របសម្រួល និងការរាយការណ៍។ ប្រព័ន្ធនេះអាចជួយដល់ការអន្តរាគមន៍ទាន់ពេលវេលានៅពេលដែលមានចំណុចខ្វះខាត និងឲ្យដឹងពីការងារដែលមានភាពរីកចម្រើន។ ប្រព័ន្ធនេះ នឹងបញ្ចូលរបាយការណ៍ប្រចាំខែរយៈពេល០៦ខែស្តីពីភាពរីកចម្រើន(ឬវឌ្ឍនភាព) ការពិនិត្យមើលឡើងវិញបន្ទាប់ពីអនុវត្តបានរយៈពេល២ និង៣ឆ្នាំមក។ ការវាយតម្លៃប្រកបដោយប្រសិទ្ធភាពនឹងផ្តល់នូវភស្តុតាងសម្រាប់រដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ និងអង្គការសង្គមស៊ីវិលក្នុងការសម្រេចចិត្តបានត្រឹមត្រូវ។

ក្របខណ្ឌការងាររួមមាន៣កម្រិត៖
កម្រិតទី១៖ កម្មវិធី និងការសាកល្បង ដើម្បីវាយតម្លៃប្រសិទ្ធភាពនិងការអាក់អន្លួលរបស់កម្មវិធី។ ការរកឃើញនឹងត្រូវបង្ហាញទុកជាមេរៀន និងបទពិសោធន៍ដ៏ល្អសម្រាប់ចែករំលែក និងសម្រាប់ធ្វើសេចក្តីសម្រេចចិត្តនាពេលអនាគត ។
កម្រិតទី២៖ ជាផលដែលកើតមានដល់កុមារ ដោយប្រើប្រាស់កម្រងសូចនាករជាមួយនឹងការកំណត់គោលដៅច្បាស់លាស់សម្រាប់សូចនាករនីមួយៗ។ វឌ្ឍនភាពនៅថ្នាក់ខេត្តដែលធៀបទៅនឹងគោលដៅនីយមួយៗ នឹងត្រូវបង្ហាញ ។
កម្រិតទី៣៖ ជាវឌ្ឍនភាពដែលធៀបទៅនឹងសូចនាករថ្នាក់ជាតិលើគ្រប់ផ្នែកនៃប្រព័ន្ធយុត្តិធម៌អនីតិជន ដោយផ្អែកតាមបទដ្ឋានអន្តរជាតិ។ វឌ្ឍនភាពធៀបទៅនឹងគោលដៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នឹងត្រូវដាក់បង្ហាញ ។

**សមិទ្ធផលទី២៧៖** អនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងប្រមូលនិន្នន័យដើម្បីគាំទ្រដល់ការអនុវត្តឲ្យបានជោគជ័យនូវផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ។

**សមិទ្ធផលទី២៨៖** ពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធផ្នែកប្រព័ន្ធយុត្តិធម៌អនីតិជន ក្នុងការធ្វើផែនការគ្រប់គ្រងការផ្លាស់ប្តូរ ពិនិត្យតាមដានការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្រផ្អែកលើភស្តុតាងក្នុងការសម្រេចចិត្ត។

## សមិទ្ធផលទី ២៧ អនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងប្រមូលនិន្នន័យដើម្បីគាំទ្រដល់ការអនុវត្តដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ

### សូចនាករ ២៧.ក. ៖ ក្របខណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃ ត្រូវបានអនុវត្ត

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៧.១. មានក្របខណ្ឌការងារពិនិត្យតាមដាន និងវាយតម្លៃគ្រប់ជ្រុងជ្រោយសម្រាប់ផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ និងមានរបាយការណ៍ឆ្លើយតបទៅនឹងសូចនាករទាំង៣កម្រិត | ២៧.១.ក. សូចនាករត្រូវបានកំណត់ ហើយឧបករណ៍ប្រមូលទិន្នន័យ និងប្រព័ន្ធដើម្បីចងក្រង ប្រមូល និង ផ្ទៀងផ្ទាត់ទិន្នន័យត្រូវបានបង្កើត | ២៧.១.១. នេះគឺជាសកម្មភាពរួមមួយ៖ កំណត់សូចនាករសម្រាប់ការវាយតម្លៃនីមួយៗ ឧបករណ៍ប្រមូលទិន្នន័យ និងប្រព័ន្ធដើម្បីចងក្រង ប្រមូល និង ផ្ទៀងផ្ទាត់ទិន្នន័យ (អានកម្មវិធីយុទ្ធសាស្ត្រទី១) | UNICEF ក្រុមការងារអន្តរក្រសួង | X | | | | | | |
| | ២៧.១.ខ. ទិន្នន័យគោលមួយសម្រាប់ពិនិត្យមើលការចាប់ផ្តើមការអនុវត្តផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិត្រូវបានបង្កើតឡើង | ២៧.១.២. នេះគឺជាសកម្មភាពរួមមួយ៖ បង្កើតទិន្នន័យគោលមួយ សម្រាប់ការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ ដោយរួមមានការវិភាគលើការចំណាយនៃប្រព័ន្ធបច្ចុប្បន្ន (អានកម្មវិធីយុទ្ធសាស្ត្រទី១) | UNICEF ក្រុមការងារអន្តរក្រសួង | X | | | | | | |
| | ២៧.១.ខ. របាយការណ៍ត្រូវបានរៀបចំឡើងស្របតាមតម្រូវការ | ២៧.១.៣. រៀបចំទម្រង់របាយការណ៍ ដំណើរការ និងកាលវិភាគបោះពុម្ពផ្សាយប្រព័ន្ធនិងក្របខណ្ឌការងារតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិ | UNICEF ក្រុមការងារអន្តរក្រសួង | X | X | | | | | |

## សមិទ្ធផលទី ២៨ ពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធផ្នែកប្រព័ន្ធយុត្តិធម៌អនីតិជន ក្នុងការធ្វើផែនការគ្រប់គ្រងការផ្លាស់ប្តូរ ពិនិត្យតាមដានការអនុវត្ត និងប្រើប្រាស់វិធីសាស្រ្តផ្អែកលើភស្តុតាងក្នុងការសម្រេចចិត្ត។

### សូចនាករ២៨.ក.៖ ក្របខណ្ឌការងារតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្រ្តនិងប្រតិបត្តិ ត្រូវបានអនុវត្ត។

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៨.១. បានបង្កើនសមត្ថភាព ផ្នែកគ្រប់គ្រង និងពិនិត្យតាមដាន ឲ្យមានការផ្លាស់ប្តូរដែលច្បាប់ស្តីពីយុត្តិធម៌អនីតិជនតម្រូវ | ២៨.១.ក. %នៃការអនុវត្តអនុសាសន៍ | ២៨.១.១. ធ្វើរបាយការណ៍ស្តីពីការអនុវត្តផែនការ ដោយមានអនុសាសន៍សម្រាប់អនុវត្តដោយស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងតារាងកាតព្វកិច្ច | UNICEF ក្រុមការងារអន្តរក្រសួង | X | X | X | X | X | X | |
| | ២៨.១.ក. មានរបាយការណ៍វាយតម្លៃលើឧបសគ្គដែលរារាំងដល់ការផ្លាស់ប្តូរ ហើយឧបករណ៍ត្រូវបានបង្កើតឡើងដើម្បីពិនិត្យមើលឧបសគ្គនិងការគាំទ្រ | ២៨.១.២. ពិនិត្យតាមដាន និងវាយតម្លៃឧបសគ្គដែលរារាំងដល់ការផ្លាស់ប្តូរ និងបង្កើតឧបករណ៍ដើម្បីពិនិត្យមើលឧបសគ្គនិងការគាំទ្រ | ក្រុមការងារអន្តរក្រសួង | X | X | X | x | X | X | |
| ២៨.២. កិច្ចសហការអន្តរក្រសួងនៅគ្រប់ជាន់ថ្នាក់ត្រូវបានពង្រឹង ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេចចិត្ត និងគ្រប់គ្រងការអនុវត្តប្រព័ន្ធយុត្តិធម៌អនីតិជន | ២៨.២.ក. %នៃកិច្ចសហការនៅគ្រប់កម្រិត និង%នៃចំណុចដែលត្រូវកែលម្អ | ២៨.២.១. ធ្វើរបាយការណ៍ស្តីពីការអនុវត្តនៅគ្រប់កម្រិត ដោយមានបង្ហាញពីកម្រិតសហការ និងចំណុចដែលត្រូវកែលម្អ | ក្រុមការងារអន្តរក្រសួង | X | X | X | X | X | X | |
| | ២៨.២.ខ. %នៃការឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍វឌ្ឍនភាព | ២៨.២.២. ធ្វើរបាយការណ៍ស្តីពីការឆ្លើយតបទៅនឹងលទ្ធផលនៃរបាយការណ៍វឌ្ឍនភាព ដែលតម្រូវឲ្យមានកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ | UNICEF ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |

| លទ្ធផល | សូចនាករ | សកម្មភាព | ស្ថាប័ន ដឹកនាំ | តារាងពេលវេលា (ឆ្នាំ) | | | | | | ស្ថាប័ន ចូលរួមគាំទ្រ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | | ២ | | ៣ | | |
| ២៨.៣. ស្ថាប័នពាក់ព័ន្ធសំខាន់ៗមានការយល់ដឹងពីបទពិសោធន៍ និងការអនុវត្តល្អ នៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន | ២៨.៣.ក. %នៃស្ថាប័នពាក់ព័ន្ធដែលប្រើប្រាស់លទ្ធផលរបាយការណ៍នេះ ដើម្បីធ្វើសេចក្តីសម្រេចចិត្ត ធ្វើផែនការ និងរៀបចំគម្រោង | ២៨.៣.១. ធ្វើរបាយការណ៍ស្តីពីបទពិសោធន៍ក្នុងការអនុវត្តកន្លងមក ករណីសិក្សា និងការអនុវត្តល្អសម្រាប់ចែករំលែក | UNICEF<br>ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |
| | ២៨.៣.ខ. ចំនួនអ្នកដែលចូលអានរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ | ២៨.៣.២. ផ្សព្វផ្សាយលទ្ធផលនៃរបាយការណ៍តាមរយៈគេហទំព័រ ព្រឹត្តិបត្រសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយផ្សេងទៀត | UNICEF<br>ក្រុមការងារអន្តរក្រសួង | | X | X | X | X | X | |

# ឧបសម្ព័ន្ធ៤

# របាយការណ៍សិក្សាស្រាវជ្រាវ ស្តីអំពី យុត្តិធម៌អនីតិជន

២០១៨ - ២០២០

# មាតិកា

## ឧបសម្ព័ន្ធ៤


១. សេចក្តីសង្ខេបខ្លឹមសារ 216

២. សេចក្តីផ្តើម 217

៣. ភាពខុសគ្នារវាងកុមារ និងមនុស្សពេញវ័យ 219

៣.១. ការអភិវឌ្ឍប្រព័ន្ធសរសៃប្រសាទ 219

៣.២. ការចូលរួមប្រព្រឹត្តបទល្មើស 220

៣.៣. ការចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ 221

៣.៤. នៅក្នុងការស្តាប់ចម្លើយរបស់នគរបាល 221

៣.៥. សមត្ថភាពក្នុងការចូលរួមសវនាការ 222

៤. ការផ្លាស់ប្តូរឥរិយាបថ និងការអប់រំនៅក្នុងសហគមន៍ 224

៥. ការទប់ស្កាត់បទល្មើស យុត្តិធម៌សហគមន៍ និងនគរបាលសហគមន៍ 226

៥.១. ការទប់ស្កាត់បទល្មើស 226

៥.២. យុត្តិធម៌សហគមន៍ 229

៥.៣. នគរបាលសហគមន៍ 229

៦. ការចេញសេចក្តីព្រមាន 231

៧. ការបង្វែរចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ 234

៨. ការគ្រប់គ្រងសំណុំរឿង និងតុលាការ (ការរក្សាការសម្ងាត់ ភស្តុតាងបញ្ជាក់ពីអាយុ និងការសារភាពកំហុស) 238

៨.១. ការគ្រប់គ្រងសំណុំរឿង 238

៨.២. ការគ្រប់គ្រងតុលាការ 239

៨.៣. ភស្តុតាងបញ្ជាក់អំពីអាយុ 240

៨.៤. ការសារភាពកំហុសរបស់កុមារ 241

៨.៥. ការរក្សាការសម្ងាត់ 241

៩. ការអនុវត្តបែបកុមារមេត្រី និងការបង្កើតជំនាញវិជ្ជាជីវៈ 243

៩.១. ការបណ្តុះបណ្តាលជំនាញឯកទេសស្តីពីការអនុវត្តនីតិវិធីបែបកុមារមេត្រីសម្រាប់នគរបាល ព្រះរាជអាជ្ញា និង តុលាការ 245

សម្រាប់នគរបាល 245

ព្រះរាជអាជ្ញា 247

មេធាវីចុងចោទ 248

តុលាការ 248

បុគ្គលិកធ្វើការងារក្នុងតួនាទីសង្គមកិច្ច 249

១០. ការឃុំខ្លួនបណ្តោះអាសន្ន 250

ការធ្វើសមាហរណកម្ម 250

១១. ឯកសារយោង 253

# ១. សេចក្តីសង្ខេបខ្លឹមសារ

ឯកសារនេះលើកឡើងពីកិច្ចដំណើរការ និងគោលនយោបាយ ដែលនឹងគាំទ្រដល់ការអនុវត្តច្បាប់យុត្តិធម៌អនីតិជនកម្ពុជា។ គេគួរតែអានឯកសារនេះជាមួយនឹងតារាងសកម្មភាពផែនការប្រតិបត្តិ (នៃផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិច្បាប់យុត្តិធម៌អនីតិជន ២០១៨-២០២០) ។ ការបកស្រាយនៅក្នុងឯកសារនេះ គឺផ្អែកលើមាត្រាមួយចំនួននៃច្បាប់យុត្តិធម៌អនីតិជនជាភាសាអង់គ្លេស ហេតុដូចនេះក្នុងករណីដែលមានចំណុចមិនស្របគ្នា សូមយោងទៅខ្លឹមសារដើមជាភាសាខ្មែរ ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សិទ្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបានចុះហត្ថលេខា និងបញ្ញត្តិនៃច្បាប់យុត្តិធម៌អនីតិជន បញ្ជាក់យ៉ាងច្បាស់អំពីគោលបំណងដែលប្រទេសកម្ពុជាត្រូវការពារសិទ្ធិរបស់កុមារដែលជាប់ពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ កុមារគឺខុសពីមនុស្សពេញវ័យ ហើយបញ្ហានេះគួរត្រូវបានចែងឲ្យបានច្បាស់ទាំងនៅក្នុងច្បាប់ ក្នុងនីតិវិធី និងការអនុវត្តជាក់ស្តែង។ សិទ្ធិរបស់កុមារតម្រូវឲ្យរាល់ការសម្រេចចិត្តនីមួយៗ ត្រូវគិតអំពីឧត្តមប្រយោជន៍របស់កុមារនៅគ្រប់ដំណាក់កាលនៃនីតិវិធី៖ ពេលចាប់ខ្លួន ពេលស្តាប់ចម្លើយដោយនគរបាល ពេលផ្តល់ការណែនាំនិង ប្រឹក្សាយោបល់ដោយនគរបាលដើម្បីបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ពេលឃុំខ្លួនបណ្តោះអាសន្ន ពេលដំណើរការនីតិវិធីរបស់តុលាការ ពេលសម្រេចឃុំខ្លួន និងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ។

ចំណុចសំខាន់របស់ច្បាប់យុត្តិធម៌អនីតិជនគឺការទទួលស្គាល់សិទ្ធិទទួលបានជំនួយពីមេធាវី និងការទទួលស្គាល់តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច ដើម្បីគាំទ្រដល់ការស្តារនីតិសម្បទារបស់កុមារ និងការធ្វើសមាហរណកម្មកុមារទៅក្នុងសហគមន៍វិញ ។

# ២. សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានយកអនុសញ្ញាស្តីពីសិទ្ធិកុមារជាគោល ហើយធានាថា កម្ពុជាត្រូវការពារសិទ្ធិកុមារ (Teeuwen ២០០៦) ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីការប្រឆាំងទៅនឹងការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តដោយអមនុស្សធម៌ អំពើឃោរឃៅផ្សេងៗ និងការធ្វើទារុណកម្ម ។ គោលការណ៍របស់អនុសញ្ញាគឺដើម្បីធានាថា យុត្តិធម៌អនីតិជនត្រូវបានអនុវត្ត ដោយផ្អែកលើ «ឧត្តមប្រយោជន៍របស់កុមារ» និងដើម្បីធានាថា ដំណើរការ និងគោលនយោបាយនៃប្រព័ន្ធយុត្តិធម៌ គាំទ្រដល់កុមារ និងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមវិញប្រកបដោយប្រសិទ្ធភាព (Dunkel និង Pruin ២០១២) ។

បន្ទាប់ពីជំពូក១ ដែលបានកំណត់អំពីគោលបំណង គោលដៅ វិសាលភាព និងនិយមន័យដែលត្រូវបានប្រើនៅក្នុងច្បាប់ ជំពូក ២ នៃច្បាប់យុត្តិធម៌អនីតិជន ចែងអំពីគោលការណ៍ទូទៅដែលស្របទៅនឹងអនុសញ្ញាទាំងនេះ (មាត្រា ៥) ហើយចែងអំពីសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី (មាត្រា ៦) ។ បញ្ញត្តិនៃជំពូកផ្សេងទៀតនៃច្បាប់នេះ ត្រូវបានតាក់តែងស្របទៅនឹងគោលការណ៍អន្តរជាតិដែលបានយោងខាងលើ ។ មានបញ្ញត្តិខ្លះនៃច្បាប់នេះ អាចនឹងត្រូវបានបកស្រាយខុសៗគ្នា ដូចនេះគួរតែអានបញ្ញត្តិពាក់ព័ន្ធនៅក្នុងជំពូក១ និង២ នៃច្បាប់នេះ ។ បើយោងតាមច្បាប់កម្ពុជា គេសង្កេតឃើញថា នៅក្នុងរឿងស៊ីវិល នៅពេលដែលច្បាប់មានភាពមិនច្បាស់លាស់ ឬពេលដែលច្បាប់មានភាពចន្លោះប្រហោង តុលាការអាចដំណើរការរឿងក្តីនេះ ដោយផ្អែកលើទម្លាប់ពីមុន ប្រពៃណី មនសិកា និងសមធម៌ (Phallack ២០១២, ច្បាប់ស្តីពីការរៀបចំតុលាការ មាត្រា៤ ១៩៩៣)។ ជាការពិត «ទម្លាប់ ប្រពៃណី សម្បជញ្ញ និងសមភាព» ក្នុងករណីខ្លះ អាចនឹងមិនស្របទៅនឹងជំពូក ១ និង ២ នៃច្បាប់យុត្តិធម៌អនីតិជន ។

បើទោះបីជាច្បាប់យុត្តិធម៌អនីតិជន មិនបានបង្កើតឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់កុមារក៏ដោយ ក៏បញ្ញត្តិនៃច្បាប់នេះបានដាក់លក្ខខណ្ឌទទួលខុសត្រូវព្រហ្មទណ្ឌដែលអាចអនុវត្តចំពោះកុមារដែរ។ មាត្រា៧ចែងថា អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺចាប់ពី១៨ឆ្នាំឡើងទៅ។ ប៉ុន្តែ បញ្ញត្តិនេះលើកលែងត្រង់ចំណុចថា «តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនចាប់ពីអាយុ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈ ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ» ។ ដូចដែល Vanrath បានពន្យល់ (២០១២) នៅក្នុងប្រទេសកម្ពុជា «ជាគោលការណ៍ អនីតិជនមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌទេ» ។ មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ចែងថា «អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺចាប់ពី ១៨ ឆ្នាំ» ។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងច្បាស់ថា អនីតិជនដែលបានប្រព្រឹត្តបទល្មើស គួរទទួលបាននូវការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ។ វិធានការរួមមាន «ប្រគល់អនីតិជនឲ្យទៅឪពុក ម្តាយ ឬអាណាព្យាបាល អ្នកទំនុកបម្រុងអនីតិជន ឬអ្នកដែលអាចទុកចិត្តបាន ការប្រគល់អនីតិជនទៅឲ្យភ្នាក់ងារសង្គមកិច្ច ការប្រគល់អនីតិជនទៅឲ្យអង្គការឯកជនដែលមាននីតិសម្បទាទទួលអនីតិជន ការប្រគល់អនីតិជនទៅឲ្យមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ឬការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ»។

ចំពោះកុមារដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ក្រមព្រហ្មទណ្ឌចែងថា មូលទោសលើបទល្មើសត្រូវបន្ថយ (មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ)។ តើច្បាប់យុត្តិធម៌អនីតិជន មានវិសាលភាពកម្រិតណាសម្រាប់បទលហុ និងមជ្ឈិម?។ បទបញ្ញត្តិជាក់លាក់មួយចំនួន ក្នុងជំពូក ៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនគូសបញ្ជាក់ថា រឿងក្តីអនីតិជនត្រូវចាត់ជាអាទិភាព (មាត្រា ៤៥) មុនពេលសវនាការ តុលាការត្រូវត្រួតពិនិត្យរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន (មាត្រា ៤៦) សវនាការត្រូវធ្វើឡើងជាអសាធារណ (មាត្រា ៤៧) សវនាការត្រូវតែធ្វើឡើងដោយប្រើប្រាស់នីតិវិធីកុមារមេត្រី (មាត្រា ៤៨) កុមារអាយុក្រោម១៤ឆ្នាំ ត្រូវរួចផុតពីបទចោទប្រកាន់(មាត្រា ៤៩) អនីតិជនត្រូវទទួលបានកិច្ចការពារនិងថែទាំ (មាត្រា៤៩) ការផ្តល់ជំនួយមេធាវី (មាត្រា ៥០) ការផ្តល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជន (មាត្រា ៥១) និង អំណាចរបស់តុលាការក្នុងការបង្វែរកុមារអាយុចាប់ពី ១៤ ដល់ក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តបទលហុនិងមជ្ឈិម (មាត្រា ៥២) ។

បញ្ញត្តិទាំងនេះនៃច្បាប់យុត្តិធម៌អនីតិជន ស្របទៅនឹងការអនុវត្តល្អ ។

# ៣. ភាពខុសគ្នារវាងកុមារ និង មនុស្សពេញវ័យ

ក្រោមច្បាប់អន្តរជាតិ កុមារត្រូវបានចាត់ទុកថាខុសពីមនុស្សពេញវ័យឬនីតិជន ដែលចាំបាច់ត្រូវប្រព្រឹត្ត មកលើកុមារឲ្យខុសពីមនុស្សពេញវ័យ យ៉ាងដូច្នោះដែរ។ នេះគឺជាការឆ្លុះបញ្ចាំងទៅនឹងវិធាននៃបទដ្ឋានអប្បរមាសម្រាប់ការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានប៉េកាំង) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ហើយនេះក៏ឆ្លុះបញ្ចាំងទៅ នឹងច្បាប់យុត្តិធម៌អនីតិជននៅកម្ពុជា ជាពិសេសមាត្រា៥ និង៦ និងជំពូក៥ ៦ និង៧ ។ វិធានប៉េកាំងបញ្ជាក់អំពីសារៈសំខាន់នៃការបង្កើតច្បាប់ជាតិ។

ច្បាប់ វិធាន និងបញ្ញត្តិសម្រាប់អនុវត្តចំពោះអនីតិជនប្រព្រឹត្តបទល្មើស ស្ថាប័ន និងអង្គភាពត្រូវមានការទទួលខុសត្រូវក្នុងដំណើរការនៃការគ្រប់គ្រងយុត្តិធម៌អនីតិជន ហើយត្រូវរៀបចំឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អនីតិជនដែលប្រព្រឹត្តបទល្មើស និងការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេ។

មានហេតុផលជាច្រើនដែលបញ្ជាក់ពីភាពខុសគ្នារវាងអនីតិជននិងនីតិជន ដោយហេតុនេះ ការប្រព្រឹត្តមកលើអនីតិជនត្រូវតែខុសពីនីតិជន ។

## ៣.១. ការអភិវឌ្ឍប្រព័ន្ធសរសៃប្រសាទ

ការសិក្សាស្រាវជ្រាវស្តីពីការលូតលាស់ផ្នែកប្រព័ន្ធសរសៃប្រសាទខាងចិត្តសាស្ត្រនិងសរីរាង្គ បញ្ជាក់ថា ទង្វើរបស់កុមារទៅលើសង្គមគឺជាប់ទាក់ទងទៅនឹងការអភិវឌ្ឍប្រព័ន្ធសរសៃប្រសាទ។ ឥឡូវនេះ គេទទួលស្គាល់ថាខួរក្បាលរបស់កុមារបន្តលូតលាស់ទៅរកភាពជាមនុស្សពេញវ័យ។ ដូច្នេះហើយ ការចាប់ខ្លួនកុមារឲ្យទទួលខុសត្រូវព្រហ្មទណ្ឌឲ្យដូចមនុស្សពេញវ័យ នៅពេលដែលកុមារទាំងនោះពុំទាន់មានការអភិវឌ្ឍសមត្ថភាពពេញលេញក្នុងការគិត ឬក៏មិនទាន់អាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនបាន គឺជារឿងមួយអយុត្តិធម៌។ ការសិក្សាបានគូសបញ្ជាក់ឲ្យឃើញនូវ ភាពខុសគ្នារវាង កុមារ និងមនុស្សពេញវ័យ បានផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងដល់អ្នកដែលធ្វើការពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន ។ ដូចដែល Royal Society គូសបញ្ជាក់ (២០១១) ។

វិទ្យាសាស្ត្រផ្នែកប្រព័ន្ធសរសៃប្រសាទ ផ្តល់នូវព័ត៌មានសំខាន់ៗទាក់ទងនឹងការអភិវឌ្ឍខួរក្បាល ដោយបង្ហាញឲ្យឃើញថាចលនាអភិវឌ្ឍប្រព័ន្ធសរសៃប្រសាទ គឺមានយ៉ាងហោចណាស់រហូតដល់អាយុ ២០ឆ្នាំ។ ដំណើរការនៃការអភិវឌ្ឍខួរក្បាលនេះ គឺជាប់ពាក់ព័ន្ធនឹងដំណើរការនៃការគិត (ដូចជាកម្រិតនៃបញ្ញាភាពងាយនឹងអូសទាញ ការខ្វះការពិចារណា ការចងចាំ និងការសម្រេចចិត្ត) ហើយដែលដំណើរការនៃការអភិវឌ្ឍទាំងនេះមិនដូចគ្នាទេនៅក្នុងថតខួក្បាលនីមួយៗ។ ថតខួរក្បាលខាងមុខ (ដែលមានតួនាទីក្នុងការវិនិច្ឆ័យធ្វើការសម្រេចចិត្ត និងការគ្រប់គ្រងទង្វើ) មានការអភិវឌ្ឍយឺត។ ផ្ទុយទៅវិញ ផ្នែកខាងក្នុងនៃថតខួក្បាលកណ្តាល

ដែលហៅថា Amygdala ដែលមានតួនាទីគ្រប់គ្រងអារម្មណ៍ មានការអភិវឌ្ឍនៅពេលជិតចូលវ័យជំទង់។ គេបានគិតថា អតុល្យភាពនៃការអភិវឌ្ឍមិនស្មើគ្នារវាងខួរក្បាលផ្នែកខាងមុខ និង Amygdala នេះ អាចជាប់ពាក់ព័ន្ធនឹងភាពតានតឹងផ្លូវចិត្ត និងទង្វើប្រកបដោយគ្រោះថ្នាក់របស់កុមារ។

ភាពក្មេងខ្ចីរបស់កុមារ ត្រូវបានគេយកមកពិចារណាជាប្រចាំដើម្បីបន្ធូរបន្ថយទោស ដោយមិនមានការផ្តន្ទាទោសធ្ងន់ធ្ងរនោះទេ។ ប៉ុន្តែជាច្រើនឆ្នាំមកនេះ ចំនួនកុមារដែលជាប់ពាក់ព័ន្ធនឹងបទល្មើស ហើយដែលត្រូវបានគេបន្តនីតិវិធីតុលាការមានចំនួនច្រើនគួរឲ្យកត់សម្គាល់។ ការអភិវឌ្ឍយឺតនៃខួរក្បាលផ្នែកខាងមុខ (ដែលមានតួនាទីក្នុងការវិនិច្ឆ័យ ធ្វើការសម្រេចចិត្ត និងការគ្រប់គ្រងទង្វើ) គួរយកមកពិចារណាចំពោះបទល្មើសកុមារ។

ភាពមិនទាន់ចាស់ទុំរបស់កុមារ ត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ ។ សេចក្តីប្រកាសស្តីពីសិទ្ធិកុមារបានបញ្ជាក់យ៉ាងច្បាស់ថា៖ “ ដោយភាពមិនទាន់ចាស់ទុំខាងផ្នែករាងកាយនិងសតិបញ្ញា កុមារត្រូវការកិច្ចការពារនិងការថែទាំ រួមទាំងកិច្ចការពារតាមផ្លូវច្បាប់ទាំងមុននិងក្រោយពីកំណើត” ។ ឃ្លានេះត្រូវបានគេដកស្រង់ចេញពីបុព្វកថារបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកម្ពុជាគឺជាប្រទេសហត្ថលេខីមួយផងដែរ ។

## ៣.២. ការចូលរួមប្រព្រឹត្តបទល្មើស

កុមារតែងតែធ្វើអ្វីមួយទៅតាមចំណង់ចំណូលចិត្តដើម្បីឲ្យស្របនឹងមិត្តភក្តិរបស់ខ្លួន។ ដោយសារតែកត្តានេះហើយ ទើបបណ្តាលឲ្យកុមារងាយនឹងប្រព្រឹត្តបទល្មើស (Berndt ១៩៧៩ Costanzo & Shaw ១៩៦៦ Gardner & Steinberg ២០០៥)។ ហើយដោយសារតែកុមារងាយនឹងធ្វើតាមមិត្តភក្តិនេះហើយ ទើបបណ្តាលឲ្យកុមារច្រើនតែប្រព្រឹត្តបទល្មើសជាក្រុម ដែលខុសពីជនល្មើសជានីតិជន (Reiss & Farrington ១៩៩១) ។មានការសិក្សាស្រាវជ្រាវខ្លះលើកឡើងថា អនីតិជនងាយទទួលរងឥទ្ធិពលជាងនីតិជន ហើយថាអនីតិជនឆាប់ផ្លាស់ប្តូរចិត្ត ហើយពួកគេក៏ងាយនឹងប្រតិកម្មទៅតាមចំណង់របស់ខ្លួនដែរ (Reyna and Farley ២០០៦) Steinberge and Cauffman ១៩៩៦)។ អនីតិជនតែងមានអាកប្បកិរិយាងាយរងគ្រោះជាងនីតិជន។ អនីតិជនថ្លឹងថ្លែងពីហានិភ័យ និងផលប្រយោជន៍ខុសពីនីតិជន ។ ជាពិសេស អនីតិជនចូលចិត្តគិតពីផលប្រយោជន៍ជាជាងហានិភ័យ (Reyan and Farley ២០០៦ Steinberg ២០០៤)។ ចំណុចនេះអាចទាក់ទងនឹងការអភិវឌ្ឍយឺតនៃខួក្បាលផ្នែកខាងមុខដែលមានទំនាក់ទំនងទៅនឹងផ្នែកខាងក្នុងនៃថតខួរក្បាលកណ្តាល ដែលហៅថា Amygdala ដូចបានបញ្ជាក់ខាងលើ។ ការពិសោធន៍បានបង្ហាញថា សមត្ថភាពរបស់អនីតិជនលើការយល់ដឹងពីគ្រោះថ្នាក់មានដូចនឹងនីតិជនដែរ ប៉ុន្តែសមត្ថភាពនេះត្រូវបានថយទៅវិញនៅពេលដែលការរស់នៅជាក់ស្តែងរបស់អនីតិជនមានទំនាក់ទំនងនឹងបរិយាកាសប្រកបដោយគ្រោះថ្នាក់ (Reyna and Farley ២០០៦ Steinberg ២០០៤) ។

វាជារឿងដ៏សំខាន់ដែលថាអ្នកទទួលបន្ទុកខាងការបង្វែរ និងខាងការស្តារនីតិសម្បទា ត្រូវដឹងអំពីបញ្ហាចិត្តសាស្ត្រ និងវិធិសាស្ត្រអប់រំផ្លូវចិត្ត ដើម្បីជួយឲ្យកុមារយល់ដឹងពីកត្តាអូសទាញមួយចំនួនដែលមានដូចជាឥទ្ធិពលរបស់មិត្តភ័ក្រ និងទង្វើប្រកបដោយគ្រោះថ្នាក់ ដែលអាចនាំឲ្យកុមារប្រព្រឹត្តបទល្មើស (Scott, Repucci and Woolard, ១៩៩៥) ។

## ៣.៣. ការចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

ការសិក្សាស្រាវជ្រាវខាងលើ បានបញ្ជាក់ថា ការវិវឌ្ឍន៍ភាពក្មេងខ្ចីរបស់កុមារ តម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេសពីនគរបាល ព្រះរាជអាជ្ញា មេធាវីចុងចោទ ចៅក្រម មន្ត្រីតុលាការ និង «ភ្នាក់ងារសង្គមកិច្ច»។ នៅពេលដែលប្រព្រឹត្តចំពោះកុមារ (ច្បាប់យុត្តិធម៌អនីតិជន មាត្រា ៤ ៩ ១០ ១១ និង ជំពូក ៥ និង ១៥)។

## ៣.៤. នៅក្នុងការស្តាប់ចម្លើយរបស់នគរបាល

មានភស្តុតាងដ៏រឹងមាំបញ្ជាក់ថា កុមារងាយនឹងនិយាយសារភាពកំហុសទាំងមិនស្ម័គ្រចិត្ត នៅពេលដែលនគរបាលសាកសួរ (Redlich and Drizin ២០០៧) ។ ករណីដែលកុមារសារភាពបែបនេះ គឺមានចំនួនច្រើន៖ ការសិក្សាមួយ (Drizin and Lee ២០០៤) រកឃើញថា ៣៥% នៃចម្លើយសារភាពទាំងខុស គឺកើតឡើងចំពោះអនីតិជនអាយុតិចជាង១៨ឆ្នាំ ដែល៥៥% មានអាយុ១៥ ឆ្នាំ ឬតិចជាងនេះ។ កត្តាដែលនាំឲ្យកុមារសារភាពកំហុសទាំងនេះច្រើន រួមមាន ការផ្តល់យោបល់បែបបង្ខំ ការបង្ខំឲ្យត្រូវតែស្តាប់តាមអាជ្ញាធរ និងភាពក្មេងខ្ចីក្នុងការសម្រេចចិត្ត។ ភាពក្មេងខ្ចីក្នុងការសម្រេចចិត្តនេះ ក៏ទាក់ទងទៅនឹង «ការគិតខ្លី» របស់កុមារផងដែរ (Nurmi ១៩៩១ Greene ១៩៨៦) មានន័យថា កុមារចូលចិត្តអ្វីដែលឆាប់ទទួលបានលទ្ធផលដូចជាបន្ទាប់ពីស្តាប់ចម្លើយ កុមារអាចទៅផ្ទះបានជាដើម ជាជាងចំណាយពេលយូររហូតកុមារធុញទ្រាន់ហើយសារភាព។

មានការសិក្សាមួយដែលបានពិនិត្យទៅលើអត្រានៃការសារភាពកំហុសរបស់កុមារហើយបានធៀបការសារភាពកំហុសរបស់កុមារទៅនឹងមនុស្សពេញវ័យ។ ការសិក្សានេះបានបង្ហាញថា នៅពេលដែលមានការស្នើសុំឲ្យសារភាពកំហុស ការសម្រេចចិត្តសារភាពកំហុសរវាងកុមារនិងមនុស្សពេញវ័យ មិនមានភាពខុសគ្នាគួរឲ្យកត់សម្គាល់ទេ។ ប៉ុន្តែនៅពេលដែលសួរឲ្យឆ្លើយថាគ្មានកំហុស កុមារបែរជាឆ្លើយសារភាពថាមានកំហុសទៅវិញ ដែលចម្លើយសារភាពបែបនេះរបស់កុមារមានច្រើនជាងមនុស្សពេញវ័ ២.២៤ដង (Redich and Sheynberg ២០១៦) ។

បញ្ហាទាំងអស់នេះទាក់ទងនឹងការងាររបស់នគរបាលដែលស្តាប់ចម្លើយកុមារដូចមានចែងនៅក្នុងជំពូក ៥ នៃច្បាប់យុត្តិធម៌អនីតិជន ដែលមានបញ្ជាក់ពីតម្រូវការនៃកិច្ចការពារជាពិសេស រួមទាំងបច្ចេកទេសនៃការស្តាប់ចម្លើយ ការកំណត់ពេលវេលា មេធាវី ភ្នាក់ងារសង្គមកិច្ច និងអ្នកទំនុកបម្រុងមុនពេលស្តាប់ចម្លើយ (សូមមើលមាត្រា ២១ នៃច្បាប់នេះ)។ នៅក្នុងជំពូក៥ ក៏មាននិយាយពីនគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនផងដែរ (មាត្រា១២) ។ មាត្រា ២ នៃច្បាប់យុត្តិធម៌អនីតិជន កត់សម្គាល់ថា «ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រតិបត្តិតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអាទិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន» ។ ច្បាប់យុត្តិធម៌អនីតិជនក៏មានចែងពីគោលការណ៍ជាមូលដ្ឋាន (មាត្រា ៥) និងសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី (មាត្រា ៦) ដែលគ្របដណ្តប់លើច្បាប់នេះទាំងមូល រួមទាំងបញ្ញត្តិជាក់លាក់មួយចំនួនទាក់ទងនឹងការអនុវត្តរបស់នគរបាលក្នុងជំពូក ៥ផងដែរ ។

ការវិវឌ្ឍន៍នៃភាពក្មេងខ្ចីរបស់កុមារក៏ជាបញ្ហាសំខាន់សម្រាប់មេធាវី ដែលត្រូវយល់ដឹងផងដែរ ( សិទ្ធិទទួលបានជំនួយពីមេធាវី ដែលមានចែងនៅក្នុងមាត្រា ៦ ១៨ ២១ ២២ ២៣ និងបញ្ញត្តិមួយចំនួនទៀតនៃច្បាប់នេះ )។ ក្រៅពីនគរបាលនិងមេធាវី ព្រះរាជអាជ្ញាក៏ "គួរទទួលបានការបណ្តុះបណ្តាលជំនាញ ស្តីពីសិទ្ធិកុមារ ច្បាប់ និងបញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជនផងដែរ" ( មាត្រា ២៤ ) ។

## ៣.៥. សមត្ថភាពក្នុងការចូលរួមសវនាការ

ការសិក្សាស្រាវជ្រាវបានបង្ហាញថា កុមារមិនមានសមត្ថភាពដើម្បីចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌឲ្យមានប្រសិទ្ធភាពនោះទេដោយសារតែភាពក្មេងខ្ចីរបស់ខ្លួន។ អ្នកសិក្សាស្រាវជ្រាវខាងសមត្ថភាពចូលរួមរបស់កុមារក្នុងសវនាការ បានពិនិត្យឃើញថា ការអភិវឌ្ឍផ្លូវចិត្តនិងបញ្ញារបស់កុមារប៉ះពាល់ដល់សមត្ថភាពរបស់ខ្លួនក្នុងការយល់ដឹង និងចូលរួមឲ្យបានពេញលេញនៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ (Grisso ១៩៩៧ ទំព័រ ១៧) ។ ការសិក្សារបស់លោក MacArthur បានសង្កេតពីភាពខុសគ្នានៃសមត្ថភាពក្នុងការចូលរួមសវនាការរបស់កុមារចន្លោះពីចំនួន ៥៦៦ ទៅ ៩២៧ នាក់ ដែលមានអាយុចន្លោះពី ១១ ទៅ ១៧ ឆ្នាំ ដែលក្នុងនោះមានចំនួនពាក់កណ្តាលជាអ្នកដែលត្រូវបានគេឃុំខ្លួន (Grisso et al ២០០៣) ។ កុមារអាយុក្រោម ១៦ ឆ្នាំ ត្រូវបានគេវាយតម្លៃថាមានសមត្ថភាពខ្សោយ បើប្រៀបធៀបទៅនឹងកុមារដែលមានអាយុច្រើនជាងនេះ ( សូមអានសេចក្តីសង្ខេបរបស់ Watt, O'Leary and OToole ២០១៧ ) ។

សមត្ថភាពក្នុងការផ្តល់ហេតុផល និងយល់ដឹង កើតឡើងគួរឲ្យកត់សម្គាល់ ចាប់ពីជិតផុតវ័យកុមារភាពឆ្លងទៅវ័យជំទង់ និងនៅពាក់កណ្តាលវ័យជំទង់... (Keating ២០០៤) ។ ទោះជាយ៉ាងណាក៏កុមារវ័យជំទង់នៅតែមិនមានសមត្ថភាពក្នុងការគិតពិចារណាដូចយុវជនដែរ ដោយសារតែខ្វះបទពិសោធន៍ និងម្យ៉ាងកុមារមិនចង់រៀនសូត្រពីបទពិសោធន៍ដូចយុវជនឡើយ (Reyna and Farley ២០០៦ Ward and Overton ១៩៩០) ។

ការសិក្សាស្រាវជ្រាវនៅសាកលវិទ្យាល័យ La Trobe ទាក់ទងនឹងសមត្ថភាពនិយាយ (ជំនាញក្នុងការស្តាប់ និងនិយាយ) របស់កុមារដែលប្រព្រឹត្តបទល្មើសនៅប្រទេសអូស្ត្រាលី និងនៅប្រទេសផ្សេងទៀតបានបង្ហាញថា កុមារប្រព្រឹត្តបទល្មើស (ប្រហែលជា ៥០% តាមការសិក្សាស្រាវជ្រាវនៅប្រទេស Australia) ដែលមានបញ្ហាក្នុងការនិយាយ គឺមានចំនួនច្រើនគួរឲ្យកត់សម្គាល់ ប៉ុន្តែការកើនឡើងនេះគឺដោយសារតែការមិនបានយកចិត្តទុកដាក់ដោះស្រាយពីមុនមក (Snow & Powell ២០១២) ។ បញ្ហានេះមិនមែនទាក់ទងតែរឿងចូលរួមនៅក្នុងដំណើរការរឿងក្តីរបស់តុលាការតែប៉ុណ្ណោះទេ តែវាក៏ទាក់ទងនឹងការចូលរួមរបស់កុមារនៅក្នុងពេលស្តាប់ចម្លើយរបស់នគរបាល ពេលមានការអន្តរាគមន៍ផ្សេងៗ ក៏ដូចជាការប្រឹក្សាយោបល់ និងការចូលរួមកិច្ចប្រជុំដោះស្រាយបញ្ហាផងដែរ ។

ជាមួយនឹងគោលការណ៍រួមដែលមានចែងក្នុងលិខិតុបករណ៍ជាតិនិងអន្តរជាតិ ការសិក្សាស្រាវជ្រាវនេះ ផ្តល់ជាលទ្ធផលសម្រាប់ការអនុវត្តរបស់មេធាវី និងសម្រាប់តុលាការដើម្បីអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងដើម្បីពង្រឹងការអនុវត្តនីតិវិធីកុមារមេត្រីក្នុងការដំណោះស្រាយឧបសគ្គដែលកុមារកំពុងជួបប្រទះ

នៅក្នុងការចូលរួមដំណើរការរឿងក្តីព្រហ្មទណ្ឌ។ គួរកត់សម្គាល់ថា ច្បាប់យុត្តិធម៌អនីតិជនសំដៅជាពិសេសទៅលើ «នីតិវិធីកុមារមេត្រី» (មត្រា ៤.៧) គោលការណ៍ជាមូលដ្ឋាន(មាត្រា៥) សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី (មាត្រា ៦) និង បញ្ញត្តិជាគន្លឹះមួយទៀត (ជំពូក ៥ ដល់ ១៥) ត្រូវបកស្រាយជាលក្ខណៈកុមារមេត្រី ។

ស្ថានភាពក្នុងពេលកុមារភាព និងដំណើរការលូតលាស់ទៅរកភាពពេញវ័យរបស់កុមារ គួរឆ្លុះបញ្ចាំងនៅគ្រប់ផ្នែកនៃគោលនយោបាយយុត្តិធម៌អនីតិជន។ អ្វីដែលល្អគឺថា បុគ្គលិកលក្ខណៈរបស់កុមារមានការប្រែប្រួល។ ភស្តុតាងបានបង្ហាញថា កុមារជាច្រើនជាប់ពាក់ព័ន្ធនឹងបទល្មើសនៅក្នុងវ័យជំទង់ ប៉ុន្តែពួកគេលះបង់ទង្វើនេះនៅពេលជិតពេញវ័យ (Piguerio et al ២០០៣ Farrington ១៩៨៦)។ តាមការពិតកុមារាប្រព្រឹត្តទង្វើមិនត្រឹមត្រូវខ្លះ គ្រាន់ជាការសាកល្បងដើម្បីចង់ដឹងប៉ុណ្ណោះ (Moffitt ១៩៩៣) ។ បើពិនិត្យឲ្យច្បាស់លាស់ ទង្វើមិនត្រឹមត្រូវមួយចំនួនរបស់កុមារ គឺជារឿងធម្មតានៃជីវិតកុមារវ័យជំទង់។ ការសិក្សាស្រាវជ្រាវទៅលើការវិវឌ្ឍរបស់កុមារបង្ហាញថា ការប្រព្រឹត្តបទល្មើសភាគច្រើនរបស់កុមារវ័យជំទង់ គឺបណ្តាលមកពីការខ្វះការយល់ដឹង ហើយមានភាគរយតិចណាស់ដែលកុមារបន្តប្រព្រឹត្តបទល្មើសរហូតដល់ធំពេញវ័យ (D'Unger Land McCall និង Nagin ១៩៩៨ Moffitt ១៩៩៣)។ ការរកឃើញទាំងនេះជួយជម្រុញឲ្យមានការពង្រឹងប្រព័ន្ធយុត្តិធម៌អនីតិជនដោយផ្តោតលើការស្តារនីតិសម្បទា និងការបង្វែរ។ ការរកឃើញនេះក៏នាំឲ្យមានការពិចារណាឡើងវិញលើវិធានការបញ្ជូនករណីកុមារចូលក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដូចជាការឃុំខ្លួនកុមារជាមួយអ្នកទោសជានីតិជនដែលមានបទពិសោធន៍ប្រព្រឹត្តបទល្មើសច្រើនជាដើម ដែលវិធានការនេះបង្កឲ្យមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរដល់កុមារ ។

ចំណុចសំខាន់ៗដែលបានលើកឡើងក្នុងការសិក្សាស្រាវជ្រាវខាងលើនេះ អាចឆ្លើយតបទៅនឹងគោលបំណងនៃច្បាប់យុត្តិធម៌អនីតិជន (ការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ) នីតិវិធីកុមារមេត្រីដែលមានចែងក្នុងមាត្រា ៤.៧ ៥ និង ៦ និងបញ្ញត្តិស្តីពីភ្នាក់ងារសង្គមកិច្ច (ឧទាហរណ៍ មាត្រា ១១)។ ការសិក្សាស្រាវជ្រាវនេះក៏ឆ្លើយតបទៅនឹងបញ្ញត្តិផ្សេងទៀតនៃច្បាប់នេះ ដែលទាក់ទងនឹងការស្តាប់ចម្លើយ (មាត្រា ២១ ២២ ២៦ និង ៣៥) និងការបង្វែរ (មាត្រា ៥២ និងជំពូក ១០) ។

# ៤. ការផ្លាស់ប្តូរឥរិយាបថ និងការអប់រំនៅក្នុងសហគមន៍

ទស្សនៈស្តីពីការស្តានីតិសម្បទានិងធ្វើសមាហរណកម្មអនីតិជន ដែលមានចែងក្នុងច្បាប់យុត្តិធម៌អនីតិជន អាចប្រឈមនឹងជំនឿរបស់សហគមន៍ ដែលនៅតែគិតថាការដាក់ពិន័យនិងការផ្តន្ទាទោស គឺជាជម្រើសដ៏ល្អសម្រាប់អ្នកប្រព្រឹត្តបទល្មើស។ ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំសហគមន៍អំពីផលប្រយោជន៍នៃការបង្វែរ និងភាពអវិជ្ជមាននៃការផ្តន្ទាទោសដល់កុមារដែលប្រព្រឹត្តបទល្មើស។ វាច្បាស់ណាស់ថា ការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការស្តានីតិសម្បទា និងសមាហរណកម្ម ផ្តល់ផលប្រយោជន៍ជាច្រើនដល់កុមារ ។

ការស្រាវជ្រាវរបស់អង្គការអន្តរជាតិដ៏សំខាន់មួយបង្ហាញថា ការជ្រើសរើសយកវិធានការផ្តន្ទាទោសសម្រាប់យុត្តិធម៌អនីតិជន ដែលរួមមានការឃុំខ្លួនជាដើម មិនបានជួយកាត់បន្ថយអត្រាបទល្មើសនោះទេ ហើយថែមទាំងបរាជ័យក្នុងការដោះស្រាយឫសគល់នៃបញ្ហាដែលបណ្តាលឲ្យមានបទល្មើស ចំណាយថវិកាច្រើនក្នុងរយៈពេលយូរ និងធ្វើឲ្យកុមារក្លាយជាអ្នកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅពេលពេញវ័យទៀតផង។ សរុបសេចក្តីមក វិធានការផ្តន្ទាទោសអនីតិជន មិនបានកាត់បន្ថយការមិនរៀងចាល ហើយក៏អាចបង្ករការប៉ះពាល់ធ្ងន់ធ្ងរដល់កុមារ ដូចជាទទួលរងនូវការមាក់ងាយ បាត់បង់ការសិក្សា ខូចអនាគត និងឆ្លងរោគជាដើម ។ ជាអន្តរជាតិ គោលការណ៍យុត្តិធម៌អនីតិជនគឺត្រូវធានាថា កុមារមិនមែនជាកម្មវត្ថុនៃការផ្តន្ទាទោសនោះឡើយ (Cunnee និង White ២០១១)។

ដូចបានគូសបញ្ជាក់ខាងលើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា យោងយ៉ាងច្បាស់ទៅសិទ្ធិកុមារ។

### មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា៖

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញា កតិកាសញ្ញា ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិកុមារ និងសិទ្ធិស្ត្រី ។

### មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញចែងថា៖

- រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។
- រដ្ឋគាំពារប្រឆាំងនឹងកាងារទាំងឡាយណាដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

## មាត្រា ១ នៃច្បាប់យុត្តិធម៌អនីតិជន (ដែលស្របទៅនឹងបញ្ញត្តិទាំងនេះ និងលិខិតគុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស) ចែងដូចតទៅ៖

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និង សហគមន៍
- ធានាការពារផលប្រយោជន៍សង្គម និងសហគមន៍។

ខ្លឹមសារចំណុចទី៣នៃមាត្រា ១ នេះ ដែលចែងអំពីកិច្ចការពារសង្គម និង សហគមន៍ ត្រូវបកស្រាយឲ្យស្របនឹងរដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍អន្តរជាតិខាងលើ។ ច្បាប់យុត្តិធម៌អនីតិជនកម្ពុជាឆ្លុះបញ្ចាំងនូវទស្សនៈដែលស្របនឹងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ តាមច្បាប់អន្តរជាតិ កុមារត្រូវបានចាត់ទុកថាមានលក្ខណៈខុសពីមនុស្សពេញវ័យ ហើយក៏ត្រូវប្រព្រឹត្តចំពោះកុមារឲ្យខុសពីមនុស្សពេញវ័យដែរ។ បញ្ហានេះមានចែងក្នុងវិធានបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានប៉េកាំង) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ឥឡូវនេះ បញ្ហានេះ ក៏បានចែងក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជននៃប្រទេសកម្ពុជាផងដែរ ជាពិសេសមាត្រា ៥ និង ៦ និង ជំពូក ៥ ៦ និង ជំពូក ៧ ។

ការលំបាក គឺការអនុវត្តជាក់ស្តែងនូវគោលការណ៍សំខាន់ៗទាំងនេះ (Travers ២០១១)។ បុគ្គលិកជំនាញ ទីកន្លែង តុលាការ និង នីតិវិធីផ្សេងៗ គឺត្រូវការជាចាំបាច់ (Egger ២០០៥)។ កុមារមិនត្រូវបានគេឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរទេ មិនត្រូវបានគេយកមកជំនុំជម្រះនៅក្នុងតុលាការព្រហ្មទណ្ឌដូចគ្នានឹងមនុស្សពេញវ័យទេ មិនត្រូវបានគេផ្តន្ទាទោសដោយសារតែប្រព្រឹត្តបទលហុ មិនត្រូវជាប់ក្នុងពន្ធនាគារជាមួយនឹងមនុស្សពេញវ័យ ឬត្រូវបានបុគ្គលិកពន្ធនាគាររំលោភបំពាននោះឡើយ (Souad Al-Henshi, ២០០៩ LICADHO ២០១៣ TLBB ២០១៤)។

# ៥. ការទប់ស្កាត់បទល្មើស យុត្តិធម៌សហគមន៍ និងនគរបាលសហគមន៍

## ៥.១. ការទប់ស្កាត់បទល្មើស

គោលការណ៍ណែនាំសម្រាប់ការទប់ស្កាត់បទល្មើស បញ្ជាក់ថា៖

មានភស្តុតាងច្បាស់លាស់ដែលបង្ហាញថា ការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌដោយមានយុទ្ធសាស្ត្រត្រឹមត្រូវ មិនត្រឹមតែជួយទប់ស្កាត់បទល្មើស និងជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងបានជួយលើកកម្ពស់សុវត្ថិភាព និងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាពទៀតផង។ ការទប់ស្កាត់បទល្មើសប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ ជួយលើកកម្ពស់សុវត្ថិភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ការធ្វើបែបនេះទទួលបានផលយូរអង្វែងក្នុងការកាត់បន្ថយការចំណាយនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក៏ដូចជាការចំណាយលើសេវាសង្គមដែលបណ្តាលមកពីបទល្មើសនេះផងដែរ (Economic and Social Council resolution ២០០២/ឧបសម្ព័ន្ធ១៣)។

ដោយពិចារណាលើប្រធានបទស្តីពីការទប់ស្កាត់បទល្មើស និងសមាហរណកម្មកុមារដែលជាប់ពាក់ព័ន្ធនឹងច្បាប់ អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកការទប់ស្កាត់អំពើហិង្សាលើកុមារ បានផ្តល់នូវអនុសាសន៍ដ៏មានតម្លៃដូចខាងក្រោម៖

១. ច្បាប់និងគោលនយោបាយទប់ស្កាត់បទល្មើសចាំបាច់ត្រូវផ្អែកលើអភិក្រមសិទ្ធិកុមារ ដោយមានការគិតគូរជាពិសេសអំពីឧត្តមប្រយោជន៍របស់កុមារ ។

២. ច្បាប់ និងគោលនយោបាយទប់ស្កាត់បទល្មើស ចាំបាច់ត្រូវកាត់បន្ថយហិង្សាលើ កុមារ (នៅពេលដែលកុមារជាជនល្មើស ជាជនរងគ្រោះ និងជាសាក្សី) ជាមួយនឹង យុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ពួកគេ ។

៣. កម្មវិធី និងគោលនយោបាយទប់ស្កាត់បទល្មើស ចាំបាច់ត្រូវរៀបចំដោយផ្តោត លើតម្រូវការ សិទ្ធិ និងបុគ្គលិកលក្ខណៈរបស់កុមារ មានន័យថាការអន្តរាគមន៍ទាំងឡាយគួរពិចារណាលើកុមារជាមុន ទើបគិតថាអ្នកប្រព្រឹត្តជាក្រោយ ។

៤. អភិក្រមគ្រប់ជ្រុងជ្រោយសម្រាប់ការទប់ស្កាត់បទល្មើសគឺមានការបែងចែកកម្រិតនៃការអន្តរាគមន៍៖
   i. កម្រិតទី១៖ គិតដល់សិទ្ធិជាមូលដ្ឋាន
   ii. កម្រិតទី២៖ ផ្តោតលើ កុមារ និង គ្រួសារកុមាររងាយរងគ្រោះ
   iii. កម្រិតទី៣៖ កម្មវិធី និង កិច្ចអន្តរាគមន៍ ដែលធានាឲ្យមានការធ្វើសមាហរណកម្មឲ្យមានប្រសិទ្ធភាព ។

៥. អភិក្រមគ្រប់ជ្រុងជ្រោយក្នុងការទប់ស្កាត់បទល្មើស គឺជៀសវាងការប្រើប្រាស់កម្លាំងនគរបាលដើម្បីឃុំខ្លួនកុមារ ដែលវិធានការនេះពុំមានប្រសិទ្ធភាពនោះទេ។ ការប្រើប្រាស់កម្លាំងនគរបាលដើម្បីឃុំខ្លួនកុមារ គួរចាត់ទុកជាវិធានការចុងក្រោយនិងមានរយៈពេលខ្លីបំផុត ។

៦. ច្បាប់ និងគោលនយោបាយក្នុងការទប់ស្កាត់បទល្មើស ចាំបាច់ត្រូវតែផ្អែកលើទិន្នន័យ និងភស្តុតាង និងមានការពិនិត្យតាមដាន និងវាយតម្លៃឲ្យបានជាប្រចាំ ។

៧. សំខាន់គឺត្រូវដំណើរការទៅ ដោយមានទស្សនៈពហុវិស័យ (អប់រំ សុខភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈ នគរបាល យុត្តិធម៌) រួមទាំងអាជ្ញាធរមានសមត្ថកិច្ចផងដែរ ។

៨. គោលនយោបាយនៃការទប់ស្កាត់បទល្មើសបានជោគជ័យ ត្រូវអនុវត្តជាមួយនឹង សហគមន៍ គ្រួសារ សាលារៀន និងអាជ្ញាធរ ។

៩. កម្មវិធី និងគោលនយោបាយទប់ស្កាត់បទល្មើសដោយវិជ្ជមាន ត្រូវមានការចូលរួមពីកុមារ (និងសហគមន៍របស់ពួកគេ) តាមរយៈយុទ្ធសាស្ត្រ និងយន្តការ ដែលកុមារ ក្រុមគ្រួសាររបស់ពួកគេ និងសហគមន៍ អាចចូលរួមរក្សានូវវប្បធម៌នៃការថែទាំដោយខ្លួនឯង និងសេចក្តីថ្លៃថ្នូរ ។

១០. ការប៉ាន់ប្រមាណទាន់ពេលវេលានិងកិច្ចអន្តរាគមន៍ ជាការងារសំខាន់នៅក្នុង គោលនយោបាយ និងកម្មវិធីទប់ស្កាត់បទល្មើស ។ ទោះបីជាយ៉ាងណាក៏ដោយ ចាំបាច់ត្រូវយកចិត្តទុកផងដែរចំពោះផលអវិជ្ជមានដែលអាចកើតមាន ដូចជាការមាក់ងាយពីសង្គមជាដើម។

១១. បើទោះបីជាកម្មវិធីនិងគោលនយោបាយទប់ស្កាត់បទល្មើសមានសារៈសំខាន់យ៉ាងណាក៏ដោយ ក៏ត្រូវទាមទារឲ្យមានប្រព័ន្ធកិច្ចការពារកុមារគ្រប់ជ្រុងជ្រោយមួយដែរ ដែលត្រូវមានទំនាក់ទំនងជាប្រចាំរវាងការទប់ស្កាត់កម្រិតទី១ និងទី២ ។

## ការអនុវត្តយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសអាចមាន៣កម្រិត (ALCR, ២០០៣)៖

១. **យុទ្ធសាស្ត្រទប់ស្កាត់បទល្មើសកម្រិតទី១** គឺត្រូវការពារកុំឲ្យមានបទល្មើសកើតឡើងទាន់។ វិធានការនេះផ្តោតទៅលើកត្តាឥទ្ធិពលសង្គមដែលបណ្តាលឲ្យមានការប្រព្រឹត្តបទល្មើស។ កត្តាទាំងនេះរួមមានភាពក្រីក្រ ភាពគ្មានការងារធ្វើ កម្រិតនៃការអប់រំទាប និងបញ្ហាសុខភាពដែលត្រូវដោះស្រាយ ។ យុទ្ធសាស្ត្រកម្រិតទី១នេះ ក៏អាចផ្តោតលើកត្តាបរិស្ថានដែរ (តួយ៉ាងដូចជាការរៀបចំអគារ ប្រព័ន្ធភ្លើង និងផ្ទាំងរូបភាព) ។

២. **យុទ្ធសាស្ត្រទប់ស្កាត់បទល្មើសកម្រិតទី២** គឺត្រូវផ្តោតលើក្រុមដែលគិតថាងាយនឹងប្រព្រឹត្តបទល្មើស ។ យុទ្ធសាស្ត្រនេះអាចជាការធ្វើអន្តរាគមន៍ទាន់ពេលវេលា (ឧទាហរណ៍ កម្មវិធីអប់រំយុវជន) និងកម្មវិធីផ្សេងទៀតនៅទីកន្លែងដែលមានហានិភ័យខ្ពស់ (ឧទាហរណ៍ ការិយាល័យដោះស្រាយជម្លោះនៅសហគមន៍) ។

៣. **យុទ្ធសាស្ត្រទប់ស្កាត់បទល្មើសកម្រិតទី៣** គឺផ្តោតលើកិច្ចអន្តរាគមន៍ចំពោះអ្នកដែលធ្លាប់ប្រព្រឹត្តបទល្មើស ដើម្បីព្យាយាមទប់ស្កាត់ការប្រព្រឹត្តបទល្មើសជាថ្មី។ គំរូអនុវត្តមួយចំនួន រួមមានកិច្ចពិភាក្សាដោះស្រាយរឿងយុវជន និងវិធានការស្តារនីតិសម្បទានៅសហគមន៍ជាដើម។

យុទ្ធសាស្ត្រទប់ស្កាត់បទល្មើសកម្រិតនីមួយៗសុទ្ធតែមានសារៈសំខាន់។ បុគ្គលិកដែលធ្វើការងារនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ត្រូវមានភារកិច្ចទទួលខុសត្រូវសម្រាប់ការទប់ស្កាត់បទល្មើសកម្រិតទី៣ ដើម្បីការពារកុំឲ្យកុមារប្រព្រឹត្តបទល្មើសសារជាថ្មី ។ វិធានការសំខាន់ៗនៃការទប់ស្កាត់បទល្មើសកម្រិតទី៣ ក៏មានចែងក្នុងច្បាប់យុត្តិធម៌អនីតិជនដែរ នោះគឺការចេញសេចក្តីព្រមានរបស់នគរបាល ការបង្វែរ និងសមាហរណកម្ម ។

ប្រសិទ្ធភាពនៃវិធានការទប់ស្កាត់បទល្មើសទាំងនេះ នឹងត្រូវយកមកពិនិត្យនៅពេលក្រោយនៅក្នុងរបាយការណ៍នេះ។ សរុបសេចក្តីមក ការចេញសេចក្តីព្រមានរបស់នគរបាល (ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ) គឺជាយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាព បើទោះបីជាអាចមានការមិនពេញចិត្តពីសហគមន៍ព្រោះតែមិនឃុំខ្លួនក៏ដោយ។ ការសិក្សាបានបង្ហាញឲ្យឃើញថា ភាគច្រើននៃកុមារប្រព្រឹត្តបទល្មើសលើកដំបូង ដែលទទួលបានការព្រមាន គឺមិនសូវប្រព្រឹត្តបទល្មើសសារជាថ្មីទេ (Dennison Stewart and Hurren ២០០៦ Pteas et al:១៩៩០ O' Connor: ១៩៩២) ។

ការបង្វែរ គឺជាវិធានការទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាពបំផុត ហើយជាយន្តការបឋមដើម្បីគាំទ្រកុមារមិនឲ្យប្រព្រឹត្តបទល្មើសជាថ្មី។ ដូចគ្នានឹងការព្រមានដែរ ការបង្វែរមានគោលបំណង កាត់បន្ថយផលប៉ះពាល់ដែលកើតឡើងពីការផ្តន្ទាទោសក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោយអនុវត្តវិធានការផ្សេងដែលសមស្របសម្រាប់កុមារដែលប្រព្រឹត្តបទល្មើស។ ទាំងការព្រមានរបស់នគរបាល និងការបង្វែរ ទទួលស្គាល់ថា នៅពេលដែលកុមារត្រូវបានឃុំខ្លួន បើទោះជារយៈពេលខ្លីក៏ដោយ ពួកគេងាយនឹងប្រព្រឹត្តបទល្មើសជាថ្មី ឬក៏ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នៅពេលដែលពួកគេធំឡើង។ ការសម្រេចយកវិធានការបង្វែរកុមារជំនួសឲ្យការឃុំខ្លួន ជួយកាត់បន្ថយការប្រព្រឹត្តបទល្មើសនៅពេលពួកគេពេញវ័យ ជួយដល់សហគមន៍ ជួយដល់ប្រព័ន្ធយុត្តិធម៌និងកុមារខ្លួនឯង និងជួយកាត់បន្ថយលើការចំណាយនៅពេលមានការប្រព្រឹត្តបទល្មើសជាថ្មីដែរ។

ជាចុងក្រោយ ការធ្វើសមាហរណកម្មដោយមានការចាត់ចែងយ៉ាងម៉ត់ចត់ គឺជាយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសកម្រិតទី៣ ដែលស្របទៅនឹងច្បាប់យុត្តិធម៌អនីតិជន។ ការផ្តោតយកចិត្តទុកដាក់ ទៅលើការស្តារនីតិសម្បទារបស់មណ្ឌលស្តារនីតិសម្បទា ជាជាងការការផ្តន្ទាទោស មានបំណងដើម្បី ធានាថា កុមារដែលនឹងត្រូវបានដោះលែង គឺមានជំនាញ និងអត្តចរិតល្អដើម្បីក្លាយជាពលរដ្ឋល្អម្នាក់ក្នុងសង្គម។ ច្បាប់យុត្តិធម៌អនីតិជនចង្អុលបង្ហាញយ៉ាងច្បាស់ថា កម្មវិធីទាំងឡាយដែលនឹងត្រូវយកមកអនុវត្ត នៅក្នុងមណ្ឌល ត្រូវតែរៀបចំឲ្យបានល្អដើម្បីសម្រេចបាននូវគោលបំណងនៃការស្តារនីតិសម្បទា ។

ចំណុចខាងលើនេះនឹងមានរៀបរាប់លំអិតនៅក្នុងរបាយការណ៍នេះក្នុងផ្នែកបន្ទាប់។ សូមអានចំណុចនីមួយៗ *ទាក់ទងនឹង ការព្រមាន ការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងសមាហរណកម្ម*។

## ៥.២. យុត្តិធម៌សហគមន៍

ច្បាប់យុត្តិធម៌អនីតិជនចែងថា យុត្តិធម៌អាចធ្វើទៅបាននៅត្រឹមសហគមន៍ មិនចាំបាច់តែនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទេ។ ផ្នែកសំខាន់ៗជាច្រើននៃច្បាប់យុត្តិធម៌អនីតិជន ពឹងផ្អែកទៅលើការបង្កើតឲ្យមានអភិក្រមយុត្តិធម៌សហគមន៍ ដែលផ្តោតលើដំណោះស្រាយនៅថ្នាក់មូលដ្ឋាន។ ការចេញសេចក្តីព្រមានរបស់នគរបាល គឺជាឧទាហរណ៍មួយនៃដំណោះស្រាយនេះ។ ក្នុងតួនាទីជាអ្នកសម្រុះសម្រួលដើម្បីដោះស្រាយជម្លោះ នគរបាលត្រូវចូលរួមឲ្យមានប្រសិទ្ធភាពជាមួយនឹងកុមារប្រព្រឹត្តបទល្មើស ត្រូវបង្កើតទំនុកចិត្ត និងត្រូវការការគាំទ្រពីជនរងគ្រោះ និងសហគមន៍ផងដែរ ។

ការបង្វែរ គឺជាចំណុចសំខាន់មួយទៀតនៃច្បាប់យុត្តិធម៌អនីតិជន ។ ជោគជ័យនៃការបង្វែរ តម្រូវឲ្យមានការរៀបចំវិធានការបង្វែរនៅនឹងសហគមន៍ដោយរួមបញ្ចូលដំណោះស្រាយនៅថ្នាក់មូលដ្ឋានផងដែរ។ វិធានការនៃការបង្វែរមានច្រើនទម្រង់ ដូចជាសន្ទានកម្ម (ការសម្រុះសម្រួល) ដែលដឹកនាំដោយជនរងគ្រោះ ការប្រជុំដោះស្រាយជម្លោះដោយមានការចូលរួមពីក្រុមគ្រួសារនិងសហគមន៍ ការជជែកជារង្វង់មូលរកដំណោះស្រាយ ការជួសជុលសំណងពីអ្នកប្រព្រឹត្តដោយមានការព្រមព្រៀងគ្នា ដែលទាំងអស់នេះសុទ្ធតែមានប្រសិទ្ធភាព។ កុមារដែលប្រព្រឹត្តកំហុស អាចតម្រូវឲ្យធ្វើការងារសហគមន៍ទៅតាមចំនួនម៉ោងដែលកំណត់ជាក់លាក់។ ការបង្វែរអាចជាដំណើរការមានលក្ខណៈស្មុគស្មាញ ហើយដែលតម្រូវឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងសហគមន៍ ។

## ៥.៣. នគរបាលសហគមន៍

«នគរបាលសហគមន៍» សំដៅដល់វិធីសាស្ត្រនានារបស់នគរបាលដែលមានបំណងចូលរួមយ៉ាងសកម្ម និងប្រកបដោយផ្លែផ្កាជាមួយនឹងអនីតិជន ដើម្បីបង្កើតវប្បធម៌នៃការទុកចិត្តគ្នា និងបង្កើនការអនុវត្តល្អក្នុងសង្គម។ ឧទាហរណ៍ ផ្សព្វផ្សាយបញ្ញត្តិច្បាប់ព្រហ្មទណ្ឌ បញ្ហាសុវត្ថិភាព និងការចែករំលែកព័ត៌មានល្អៗផ្សេងទៀត ដែលរៀបចំដោយនគរបាលសហការជាមួយនឹងអង្គការផ្សេងៗ ដើម្បីជាផលប្រយោជន៍ដល់កុមារ។ គោលបំណង គឺដើម្បីបង្កើតឲ្យមានទំនាក់ទំនងល្អរវាងនគរបាលនិងពលរដ្ឋ (Cunneen and White ២០១១)។

កម្មវិធីនគរបាលសហគមន៍ គឺផ្អែកទៅលើគំរូយុត្តិធម៌សហគមន៍ និងផ្អែកលើគោលការណ៍សហប្រតិបត្តិការគ្នាល្អរវាងនគរបាល និងសហគមន៍ក្នុងការអនុវត្ត។ កម្មវិធីនគរបាលសហគមន៍នេះ មិនមែនមានន័យថាលុបបំបាត់ ឬជំនួសរបៀបរបបអនុវត្តការងារពីមុនមករបស់នគរបាលនោះទេ។ វិធានការចុះអន្តរាគមន៍ពេលមានឧបទ្ទវហេតុកើតឡើង នៅតែជាការឆ្លើយតបយ៉ាងសំខាន់ទៅនឹងបទល្មើសផ្សេងៗ។ កម្មវិធីនគរបាលសហគមន៍នេះ គ្រាន់តែជាការបំពេញបន្ថែមទៅលើការងារចាស់របស់នគរបាល ធ្វើយ៉ាងណាឲ្យមានកិច្ចសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីដោះស្រាយជម្លោះ និងទប់ស្កាត់បទល្មើស ។

ជោគជ័យរបស់កម្មវិធីនគរបាលសហគមន៍ អាស្រ័យទៅលើសហប្រតិបត្តិការនិងទំនាក់ទំនងល្អរវាងនគរបាល និងសហគមន៍។ ទំនាក់ទំនង និងសហប្រតិបត្តិការនេះ នាំមកនូវការពង្រឹងសេចក្តីទុកចិត្តពីសាធារណជនចំពោះសេវាកម្មរបស់នគរបាល ហើយស្របពេលគ្នានេះដែរ ក៏អាចឈានទៅរកការរៀបវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហានៅក្នុងសហគមន៍ផងដែរ។ ឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស បានបញ្ជាក់អំពីតម្រូវការសំខាន់ៗសម្រាប់កម្មវិធីនគរបាលសហគមន៍ ដែលរួមមាន៖

- បង្កើតភាពជាដៃគូរវាងនគរបាល និងអ្នកពាក់ព័ន្ធឯទៀតក្នុងសហគមន៍
- បង្កើតឲ្យមានផែនការសកម្មភាព និងគោលនយោបាយទាក់ទងនឹងសហគមន៍
- ជ្រើសរើសអ្នកចូលរួមពីគ្រប់ផ្នែកដែលមាននៅក្នុងសហគមន៍
- បណ្តុះបណ្តាលមន្ត្រីនគរបាលឲ្យចេះធ្វើការជាមួយនឹងមនុស្សគ្រប់ប្រភេទ
- បង្កើតឲ្យមានការអប់រំផ្សព្វផ្សាយនៅសហគមន៍ និងកម្មវិធីព័ត៌មានសម្រាប់សាធារណៈជន
- ទំនាក់ទំនងជាប្រចាំជាមួយនឹងក្រុមប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍
- កសាងទំនាក់ទំនងជាមួយនឹងសហគមន៍តាមរយៈសកម្មភាពផ្សេងៗដោយមិនមានការបង្ខំ
- ចាត់តាំងមន្ត្រីឲ្យឃ្លាំមើលជម្លោះអ្នកជិតខាងឲ្យបានជាប្រចាំ
- បង្កើនការចូលរួមរបស់សហគមន៍នៅក្នុងសកម្មភាពរបស់នគរបាល និងកម្មវិធីសុវត្ថិភាពសាធារណៈ
- ឲ្យសហគមន៍ចូលរួមកំណត់បញ្ហា និងអ្វីដែលជាក្តីកង្វល់
- ប្រើប្រាស់វិធីសាស្ត្រដោះស្រាយបញ្ហាឲ្យសមស្រប ដើម្បីឆ្លើយតបទៅនឹងបញ្ហារបស់សហគមន៍ពិតប្រាកដ
- សម្របសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពជាមួយនឹងស្ថាប័នរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ។

*(ប្រភព៖ ឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ការអនុវត្ត និងបទដ្ឋានសិទ្ធិមនុស្សសម្រាប់នគរបាល សៀវភៅ Expanded Pocket សម្រាប់នគរបាល(២០០៤) ទំព័រ៥៨)។*

ការបណ្តុះបណ្តាលគឺចាំបាច់ ដើម្បីអប់រំមន្ត្រីនគរបាលនិងអ្នកពាក់ព័ន្ធនៅក្នុងសហគមន៍ឲ្យយល់ដឹងអំពីអត្ថប្រយោជន៍នៃកម្មវិធីនគរបាលសហគមន៍។ ការបណ្តុះបណ្តាលគួរធ្វើយ៉ាងណាឲ្យនគរបាលយល់ដឹងឲ្យបានច្បាស់ពីរបៀបនៃការឆ្លើយតប និងយុទ្ធសាស្ត្រដើម្បីឲ្យមានការចូលរួមក្នុងកម្មវិធីនេះ។ ការងារនេះតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មទាំងខាងនគរបាលនៅជួរមុខ និងសហគមន៍ ដោយហេតុថាត្រូវបង្កើត និងពង្រីកគំរូអនុវត្តល្អៗឲ្យបានច្រើន។ វិធីសាស្ត្រដោះស្រាយបញ្ហាដែលទាក់ទងនឹងការអនុវត្តកម្មវិធីនគរបាលសហគមន៍នេះ ក៏មាននៅក្នុងច្បាប់យុត្តិធម៌អនីតិជនដែរ គឺក្នុងបញ្ញត្តិស្តីពីការព្រមានរបស់នគរបាល (ជាពិសេសមាត្រា ១៣) និងកម្មវិធីបង្វែរ (ជំពូក១០)។

ច្បាប់យុត្តិធម៌អនីតិជនចង្អុលបង្ហាញពីវិធីសាស្ត្រថ្មីមួយដើម្បីឈានទៅបង្កើតឲ្យមានយុត្តិធម៌សហគមន៍ និងនគរបាលសហគមន៍ ដែលបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

# ៦. ការចេញសេចក្តីព្រមាន

នគរបាលដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ដោយសារតែនគរបាលជាមន្ត្រីជួរមុខនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលត្រូវជួបកុមារទំនាស់នឹងច្បាប់មុនគេ។ នគរបាលប្រើប្រាស់សិទ្ធិពិចារណាក្នុងការចាត់វិធានការពាក់ព័ន្ធនឹងកុមារ។ ដោយសាររតែការផ្តន្ទាទោសព្រហ្មទណ្ឌ បង្កឲ្យមានផលវិបាកដល់កុមារ ដូច្នេះការសម្រេចយ៉ាងណារបស់នគរបាលដែលជាអ្នកត្រូវជួបកុមារមុនគេនោះ នឹងផ្តល់ផលដល់ជីវិតរបស់កុមារយ៉ាងនោះដែរ ។

ទំនាក់ទំនងជាវិជ្ជមានរវាងកុមារទំនាស់នឹងច្បាប់ និងនគរបាលមូលដ្ឋាន ត្រូវបានបញ្ជាក់នៅក្នុងច្បាប់អន្តរជាតិ។ វិធានប៉េកាំង ចំណុច ១០.៣ ចែងថា ទំនាក់ទំនង «របស់នគរបាលជាមួយនឹងកុមារជាជនល្មើសត្រូវធ្វើឡើងដោយគោរពសិទ្ធិផ្លូវច្បាប់របស់កុមារ លើកកម្ពស់សុខុមាលភាពរបស់កុមារ ជៀសវាងការធ្វើឲ្យកុមារទទួលរងការឈឺចាប់ និងគិតអំពីស្ថានភាពនៃបទល្មើស»។ វិធាននេះទទួលស្គាល់ថា ការបញ្ជូនកុមារឲ្យចូលក្នុងនិតិវិធីតុលាការ អាចបង្កឲ្យមានការឈឺចាប់ដល់កុមារ។

សិទ្ធិសម្រេចរបស់នគរបាលនៅក្នុងការដោះស្រាយបញ្ហារបស់កុមារទំនាស់នឹងច្បាប់ គឺជាផ្នែកមួយដ៏សំខាន់នៃការឆ្លើយតបនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ដែលត្រូវធានាថាការឆ្លើយតបនេះត្រូវធ្វើឡើងដោយសមស្របទៅនឹងស្ថានភាពរបស់កុមារ និងកាលៈទេសៈនៃបទល្មើស។ វិធានប៉េកាំង ចំណុច ១១.២ បញ្ជាក់ថា «អង្គភាពនគរបាល អយ្យការ និងអង្គភាពដទៃទៀតដែលធ្វើការលើរឿងក្តីអនីតិជន គួរត្រូវបានផ្តល់អំណាចឲ្យដោះស្រាយរឿងក្តីបែបនេះ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនចាំបាច់ឆ្លងកាត់សវនាការទេ ដោយធ្វើយ៉ាងណាឲ្យស្របតាមលក្ខខណ្ឌផ្លូវច្បាប់របស់ខ្លួន និងតាមគោលការណ៍ក្នុងវិធាននេះ»។ សេចក្តីពន្យល់នៃវិធាននេះ បញ្ជាក់ទៀតថា ការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោយបញ្ជូនកុមារទៅទទួលសេវាគាំទ្រនៅតាមសហគមន៍ គឺជាដំណោះស្រាយដែលត្រូវបានគេអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ជាច្រើន។ ការចេញសេចក្តីព្រមានដោយនគរបាល គឺជាទម្រង់បង្វែរដំបូងគេបង្អស់។ ការព្រមាននេះ ត្រូវបានប្រើប្រាស់ដើម្បីបញ្ចៀសផលអវិជ្ជមាននៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះអនីតិជន និងបញ្ចៀសការមាក់ងាយលើកុមារដោយសារការផ្តន្ទាទោស ។

សេចក្តីពន្យល់របស់វិធាននេះក៏បានបញ្ជាក់បន្ថែមទៀតថា «នៅក្នុងករណីជាច្រើន ការមិនធ្វើអន្តរាគមន៍តាមផ្លូវច្បាប់ គឺជាការឆ្លើយតបដ៏ល្អបំផុត។ ដូច្នេះការបង្វែរកុមារនៅដំណាក់កាលដំបូង ដោយមិនចាំបាច់បញ្ជូនកុមារទៅរកសេវាសង្គម ក៏ជាជម្រើសនៃការឆ្លើយតបមួយដែរ។ វិធានការនេះ អាចអនុវត្តសម្រាប់បទល្មើសដែលពុំមានលក្ខណធ្ងន់ធ្ងរ ដែលទាំងគ្រួសារ សាលារៀន ឬអង្គភាពផ្សេងទៀត បានផ្តល់ការគាំទ្រ» ។

ការអនុម័តយកវិធានការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺជាការយកចិត្តទុកដាក់លើការលូតលាស់របស់កុមារជាជនល្មើស ដើម្បីទប់ស្កាត់កុមារកុំឲ្យប្រព្រឹត្តបទល្មើសនៅពេលធំពេញវ័យ។ ការសិក្សាបង្ហាញថា ការប្រព្រឹត្តបទល្មើសភាគច្រើនរបស់កុមារវ័យជំទង់ គឺបណ្តាលមកពីការខ្វះការយល់ដឹង

ហើយមានភាគរយតិចណាស់ដែលកុមារបន្តប្រព្រឹត្តបទល្មើសរហូតដល់ធំពេញវ័យ (D’Unger, Land, McCall and Nagin, ១៩៩៨ ; Moffitt, ១៩៩៣ )។

ការអនុវត្តវិធានការស្រាល ដូចជាការចេញសេចក្តីព្រមាន (ជំនួសឲ្យការបញ្ជូនសំណុំរឿងកុមារទៅតុលាការ និងការធ្វើឲ្យកុមារទទួលរងការប៉ះពាល់ផ្លូវចិត្តដ៏ធ្ងន់ធ្ងរក្នុងពន្ធនាគារនោះ) ជាការឆ្លើយតបទៅនឹងគោលការណ៍អន្តរាគមន៍អប្បរមា។ គោលការណ៍នេះមានបញ្ជាក់នៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០.៤ និងវិធានប៉េកាំងចំណុច ៥.១ ដែលច្បាប់អន្តរជាតិទាំងពីរតម្រូវថា ការឆ្លើយតបទៅនឹងបទល្មើសត្រូវតែសមាមាត្រទៅនឹងកាលៈទេសៈនៃបទល្មើស និងស្ថានភាពរបស់កុមារ។ ការអនុម័តយកវិធានការផ្សេងក្រៅពីការឃុំខ្លួន ដូចជាការចេញសេចក្តីព្រមានឲ្យបានច្រើនជាងវិធានការតឹងតែង ជួយកាត់បន្ថយការប៉ះពាល់ផ្លូវចិត្តរបស់កុមារ កាត់បន្ថយអត្រាប្រព្រឹត្តបទល្មើសជាថ្មី និងកាត់បន្ថយការចំណាយធនធាននៅក្នុងតុលាការ និងពន្ធនាគារ ។

ការចេញសេចក្តីព្រមានរបស់នគរបាល (ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ) គឺជាយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាព បើទោះបីជាអាចមានការមិនពេញចិត្តពីសហគមន៍ព្រោះតែមិនឃុំខ្លួនក៏ដោយ។ ការសិក្សាបានបង្ហាញឲ្យឃើញថា ភាគច្រើននៃកុមារប្រព្រឹត្តបទល្មើសលើកដំបូង ដែលទទួលបានការព្រមាន គឺមិនសូវប្រព្រឹត្តបទល្មើសសារជាថ្មីទេ (Dennison, Stewart and Hurren, ២០០៦ Poteas et al: ១៩៩០ O’Connor: ១៩៩៩២) ។

មាត្រា ១៣ នៃច្បាប់យុត្តិធម៌អនីតិជនរបស់កម្ពុជា ចែងថា ក្នុងករណីអនីតិជនដែលមានអាយុចាប់ពី១៤ ដល់ក្រោម១៨ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឲ្យអ្នកដំណាងដែលច្បាប់បានកំណត់។ ប្រសិនបើកុមារបានសារភាពថា ខ្លួនបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុ នគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ។

មាត្រា១៤នៃច្បាប់នេះចែងថា អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

គោលការណ៍ចេញសេចក្តីព្រមានរបស់នគរបាលនៅក្នុងច្បាប់យុត្តិធម៌អនីតជន មានបំណងបង្វែរកុមារឲ្យបានជោគជ័យចេញពីការប្រព្រឹត្តបទល្មើស ឬការប្រព្រឹត្តបទល្មើសជាថ្មី តាមបែបកុមារមេត្រីស្របទៅនឹងច្បាប់អន្តរជាតិ។ ការព្រមានអាចរួមមានដូចជា៖

- ការព្រមាន និងការណែនាំដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ
- មានវត្តមានជាមួយនឹងគ្រួសានៅពេលសម្ភាសជាមួយនឹងនគរបាល
- បញ្ជូនរកសេវា និងកម្មវិធីផ្សេងៗ
- ការព្រមានលើកចុងក្រោយ ដោយពុំមានជាលើកទី២។

មាត្រា១៣នៃច្បាប់នេះ ក៏បានចែងដែរថា នគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅកាន់ព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់។ ត្រង់ចំណុចនេះ បើពិនិត្យលើអត្ថន័យនៃចំណងជើងមាត្រា១៣នេះ គឺនិយាយពីអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការពិនិត្យ និងដោះស្រាយបទលហុ។ ដូច្នេះបញ្ញត្តិនេះគឺត្រូវបកស្រាយថាជាការផ្តល់សិទ្ធិអំណាចទៅនគរបាលក្នុងការដោះស្រាយបទលហុដោយមិនចាំបាច់បញ្ជូនទៅតុលាការឡើយ។ ចំណែកឯ សំណុំរឿងដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា អាចមានន័យថាព្រះរាជអាជ្ញានឹងពិនិត្យមើលលើសេចក្តីសម្រេចរបស់នគរបាលពីភាពត្រឹមត្រូវតាមច្បាប់។ ឧទាហរណ៍ ចំពោះបទលហុដែលបានកើតឡើង បើយោងតាមការអនុវត្តល្អ ពាក្យថា «ត្រូវ» នៅក្នុងកថាខណ្ឌ៣នៃមាត្រា ១៣ គួរតែត្រូវបានគេបកស្រាយថាជានីតិវិធីក្នុងការពិនិត្យមើលឡើងវិញ ជាជាងការផ្តល់ឱកាសដល់ព្រះរាជអាជ្ញាដើម្បីទាត់ចោលការសម្រេចចិត្តរបស់នគរបាល លើកលែងតែមានការស្នើសុំពីនគរបាលឲ្យព្រះរាជអាជ្ញាពិចារណា បញ្ហាឡើងវិញ ដោយសារតែមិនអាចសម្រុះសម្រួល ឬមិនកែប្រែបន្ទាប់ពីមានការអប់រំណែនាំ ឬការព្រមានរបស់នគរបាល។

របាយការណ៍ស្តីពីការព្រមាន ឬការសម្រុះសម្រួល មិនគួរយកមកប្រើជាផ្នែកមួយនៃលិខិតថ្កោលទោសរបស់កុមារឡើយ។ ជាគំនិត ប្រព័ន្ធចេញសេចក្តីព្រមានគួរតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់នគរបាល។ ការបញ្ជូនរបាយការណ៍អំពីការព្រមានជូនព្រះរាជអាជ្ញា ចាំបាច់ត្រូវមានការទុកដាក់ឲ្យបានត្រឹមត្រូវ ដើម្បីធានាថារបាយការណ៍នេះនឹងមិនត្រូវយកមកធ្វើជាលិខិតថ្កោលទោសសម្រាប់កុមារឡើយ។

# ៧. ការបង្វែរចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

បើយោងទៅតាមឯកសាររបស់យូនីសេហ្វស្តីពី *ការបង្វែរនិងជម្រើសផ្សេងក្រៅពីការឃុំខ្លួន* ការបង្វែរមានន័យថា ៖

> «ជាការបង្វែរអនីតិជនទំនាស់នឹងច្បាប់ដោយមានលក្ខខណ្ឌ ចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ តាមរយៈការបង្កើតនិងអនុវត្តនីតិវិធី និងកម្មវិធីដែលអនុញ្ញាតឲ្យរឿងក្តីអនីតិជនត្រូវបានដោះស្រាយដោយអង្គភាពផ្សេងក្រៅពីតុលាការ ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានដល់អនីតិជននិងជាប់ក្នុងបញ្ជីថ្កោលទោស»។

ក្រៅពីការចេញសេចក្តីព្រមានដោយនគរបាលដែលមានចែងក្នុងមាត្រា១៣ ក៏មានវិធានការបង្វែរដែលត្រូវអនុវត្តដោយអាជ្ញាធរបង្វែរ(រួមមានព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះរបស់សាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍) ដែលមានចែងក្នុងជំពូក ១០ នៃច្បាប់នេះ ។

ការបង្វែរគឺជាយន្តការទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាព ហើយក៏ជាយន្តការដំបូងដើម្បីគាំទ្រ ដល់កុមារមិនឲ្យប្រព្រឹត្តបទល្មើសជាថ្មីដែរ។ ការបង្វែរមានគោលបំណង កាត់បន្ថយផលប៉ះពាល់ដែលកើតឡើងពីការផ្តន្ទាទោសក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោយអនុវត្តវិធានការផ្សេងដែលសមស្របសម្រាប់កុមារដែលប្រព្រឹត្តបទល្មើស។ ការបង្វែរទទួលស្គាល់ថា នៅពេលដែលកុមារត្រូវបានឃុំខ្លួន បើទោះជារយៈពេលខ្លីក៏ដោយ ពួកគេងាយនឹងប្រពឹត្តបទល្មើសជាថ្មី ឬក៏ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នៅពេលដែលពួកគេធំឡើង។ ការសម្រេចយកវិធានការបង្វែរកុមារជំនួសឲ្យការឃុំខ្លួន ជួយកាត់បន្ថយការប្រព្រឹត្តបទល្មើសនៅពេលពួកគេពេញវ័យ ជួយដល់សហគមន៍ ជួយដល់ប្រព័ន្ធយុត្តិធម៌និងកុមារខ្លួនឯង និងជួយកាត់បន្ថយលើការចំណាយនៅពេលមានការប្រព្រឹត្តបទល្មើសជាថ្មីដែរ។ នៅក្នុងទ្រឹស្តី បើទោះបីជាការបង្វែរអាចយកមកអនុវត្តចំពោះគ្រប់បទល្មើសនិងគ្រប់ជនល្មើសក៏ដោយ ក៏ក្នុងការអនុវត្តជាក់ស្តែង ការបង្វែរមិនអាចអនុវត្តចំពោះបទល្មើសធ្ងន់ធ្ងរ និងជនល្មើសមិនរាងចាលបានទេ។

វិធានការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺជាការយកចិត្តទុកដាក់លើការលូតលាស់របស់កុមារជាជនល្មើស ដោយហេតុថាមានការសិក្សាដែលបង្ហាញថា ការប្រព្រឹត្តបទល្មើសភាគច្រើនរបស់កុមារវ័យជំទង់ គឺបណ្តាលមកពីការខ្វះការយល់ដឹង ហើយមានភាគរយតិចណាស់ដែលកុមារបន្តប្រព្រឹត្តបទល្មើសរហូតដល់ធំពេញវ័យ ( D’Unger, Land McCall and Nagin, ១៩៩៨ Moffitt ១៩៩៣ )។

## វិធានប៉េកាំង ចំណុច ១១.១ បានបញ្ជាក់ថា៖

នៅពេលដែលសមស្រប កុមារជាជនល្មើសគួរត្រូវបានគេយកមកពិចារណា ដោយមិនចាំបាច់បញ្ជូនទៅតុលាការឡើយ។

## ចំណុចនេះក៏មានចែងនៅក្នុងមាត្រា ៤០.៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ផងដែរ៖

«រដ្ឋភាគីត្រូវខិតខំលើកស្ទួយការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នសម្រាប់អនុវត្ត ជាពិសេសទៅលើកុមារដែលជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថាបានរំលោភច្បាប់ព្រហ្មទណ្ឌ...ក្នុងករណីសមស្របនិងចាំបាច់ វិធានការសម្រាប់ដោះស្រាយចំពោះកុមារទាំងនេះ មិនចាំបាច់ឆ្លងកាត់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឡើយ ដោយធានាថាសិទ្ធិមនុស្សនិងការការពារផ្លូវច្បាប់ត្រូវបានគោរពពេញលេញ»។

## មាត្រា ៤០.៤ នៃអនុសញ្ញានេះ ចែងថា៖

«ចំណាត់ការមួយចំនួនដូចជា ការថែទាំ ការណែនាំ ដីកាតាមដាន ការពិគ្រោះយោបល់ ការសាកល្បងឲ្យនៅក្រៅឃុំ ការថែទាំដោយឪពុកម្តាយធម៌ កម្មវិធីអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងទៀតក្រៅពីការថែទាំតាមស្ថាប័ន ត្រូវធ្វើឲ្យមាន ដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្របចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមាមាត្រទៅនឹងស្ថានភាពរបស់កុមារនិងបទល្មើស»។

## ក្រៅពីអនុសញ្ញានេះ ចំណុចនេះក៏មានចែងនៅក្នុងមាត្រា៩ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ ( Keyzer ២០១០ ) និងនៅក្នុងចំណុច ៥.១ នៃវិធានប៉េកាំងផងដែរ៖

ប្រព័ន្ធយុត្តិធម៌អនីតិជន ត្រូវផ្តោតលើសុខុមាលភាពរបស់កុមារ និងត្រូវធានាថារាល់វិធានការចំពោះកុមារជាជនល្មើស ត្រូវតែធ្វើឡើងឲ្យសមាមាត្រទៅនឹងស្ថានភាពរបស់កុមារនិងបទល្មើស ។

នៅក្នុងការអនុវត្តជាក់ស្តែង គួរបង្កើតឲ្យមានវិធានការឲ្យបានច្រើនសម្រាប់ជ្រើសរើស ដោយហេតុថាកុមារ និងប្រភេទនៃបទល្មើសមិនដូចគ្នាទេ ។

## ផ្អែកលើរបាយការណ៍ដែលមានចំណងជើងថា «ការឆ្លើយតបទៅនឹងអាទិភាពយុត្តិធម៌អនីតិជននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក» ( ទំព័រ ២៨ ) គោលបំណងសំខាន់ៗនៃការបង្វែរ ឬវិធានការផ្សេងៗក្រៅពីការឃុំខ្លួន គឺ៖

- ផ្សះផ្សារវាងជនរងគ្រោះ និងជនល្មើស
- បញ្ចៀសការដកហូតសេរីភាពរបស់កុមារ
- លើកទឹកចិត្តឲ្យមានការចូលរួមពីសហគមន៍
- ធ្វើឲ្យកុមារមានការទទួលខុសត្រូវ។

ការបង្កើតឲ្យមានវិធានការច្រើនក្នុងការបង្វែរ តម្រូវឲ្យមានអភិក្រមយុត្តិធម៌សហគមន៍ ដោយផ្អែកលើដំណោះស្រាយថ្នាក់មូលដ្ឋាន។ វិធានការនៃការបង្វែរមានច្រើនទម្រង់ ដូចជាសន្ទានកម្ម (ការសម្រុះសម្រួល) ដែលដឹកនាំដោយជនរងគ្រោះ ការប្រជុំដោះស្រាយជម្លោះដោយមានការចូលរួមពីក្រុមគ្រួសារ និងសហគមន៍ ការជជែកជារង្វង់មូលរកដំណោះស្រាយ ការជួសជុលសំណងពីអ្នកប្រព្រឹត្តដោយមានការព្រមព្រៀងគ្នា ដែលទាំងអស់នេះសុទ្ធតែមានប្រសិទ្ធភាព។ កិច្ចប្រជុំដោះស្រាយជម្លោះ ទទួលបាននូវការផ្លាស់ប្តូរគំនិតគ្នាដ៏មានប្រសិទ្ធភាព ទទួលបាននូវកិច្ចព្រមព្រៀង និងលើកកម្ពស់ការចូលរួមយ៉ាងសកម្មពីកុមារ និងស្ថាប័នពាក់ព័ន្ធ។ ការចូលរួមយ៉ាងសកម្មរបស់កុមារ និងស្ថាប័នពាក់ព័ន្ធ នាំឲ្យមានជោគជ័យនៃវិធានការបង្វែរ។ ការសម្រេចយកវិធានការណាក៏ដោយ ក៏ត្រូវមានការយល់ព្រមពីកុមារដែរ។ វិធានប៉េកាំង ១១.៣ បញ្ជាក់អំពីភាពចាំបាច់ដែលត្រូវមានការយល់ព្រមពីកុមារជាជនល្មើស (ឬក៏ឪពុកម្តាយ ឬអាណាព្យាបាល) មុននឹងសម្រេចយកវិធានការបង្វែរណាមួយ ។ សេចក្តីពន្យល់នៃវិធាននេះ បញ្ជាក់ថា «ត្រូវយកចិត្តទុកដាក់លើការថែទាំកុមារនៅគ្រប់ដំណាក់កាលនៃការបង្វែរ ដើម្បីកុំឲ្យកុមារមានការភ័យខ្លាច ។ កុមារមិនគួរទទួលនូវសំពាធផ្លូវចិត្ត (ឧទាហរណ៍ ដូចជានិយាយថានឹងត្រូវបង្ហាញមុខនៅតុលាការ) ឬ ការបង្ខំឲ្យយល់ព្រមទទួលយកវិធានការណាមួយនៃការបង្វែរជាដើម»។

យោងតាមគណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ១០ ស្តីពីសិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន កុមារត្រូវតែទទួលបានការអនុញ្ញាតឲ្យរកជំនួយរបស់មេធាវី ឬ ជំនួយសមស្របដទៃទៀតដើម្បីវាយតម្លៃភាពសមស្រប និងវត្ថុបំណងនៃការបង្វែរ។ សេចក្តីពន្យល់ទូទៅលេខ ១០ ក៏តម្រូវដែរថា នៅពេលការបង្វែរត្រូវបានបញ្ចប់ដោយជោគជ័យ សំណុំរឿងរបស់កុមារគួរត្រូវបិទបញ្ចប់ ហើយរបាយការណ៍សម្ងាត់នៃការបង្វែរនេះ មិនត្រូវយកទៅធ្វើជា «លិខិតថ្កោលទោស» ទេ។ ការធ្វើបែបនេះគឺជារឿងសំខាន់ណាស់ ពីព្រោះបើឲ្យកុមារជាប់ក្នុងបញ្ជីថ្កោលទោស ការមាក់ងាយនឹងកើតមានដល់កុមារ ហើយធ្វើឲ្យកុមារបាត់បង់ឱកាសក្នុងការកសាងជីវិតដែលនេះគឺសិទ្ធិរបស់កុមារដែលត្រូវទទួលបានដូចមនុស្សពេញវ័យដែរ ។

ការរៀបចំបង្វែរអាចជួបការលំបាកខ្លះ ដោយសារកាបង្វែរតែងតែប្រឈមនឹងទំនៀមទម្លាប់របស់សហគមន៍ ដែលនៅតែគិតថាមានតែវិធានការផ្តន្ទាទោសទេដែលសមស្របសម្រាប់អ្នកប្រព្រឹត្តបទល្មើស។ ស្ថាប័នពាក់ព័ន្ធត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំដល់សហគមន៍អំពីអត្ថប្រយោជន៍នៃការបង្វែរ និងភាពអវិជ្ជមាននៃការផ្តន្ទាទោសដល់កុមារដែលប្រព្រឹត្តបទល្មើស ។

វិធានការបង្វែរ ក្នុងជំពូក ១០ នៃច្បាប់យុត្តិធម៌អនីតិជន ស្របទៅនឹងបទដ្ឋានគតិយុត្តិអន្តរជាតិ។ ផ្អែកតាមច្បាប់នេះ ក្នុងករណីដែលកុមារមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលសង្ស័យថាបានប្រព្រឹត្តបទលហុ ឬ បទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាដល់ការបង្វែរជាបឋម។ ការបង្វែរអាចនឹងត្រូវយកមកពិចារណាផងដែរនៅគ្រប់ដំណាក់កាលរបស់តុលាការ ដោយចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះរបស់សាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះរបស់សាលាឧទ្ធរណ៍។ មាត្រា ៦២ នៃច្បាប់នេះចែងយ៉ាងច្បាស់អំពីគោលបំណងនៃការបង្វែរ គឺឲ្យកុមារទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ក៏ដូចជាលើកកម្ពស់ការផ្សះផ្សាជាមួយនឹងជនរងគ្រោះ។ វិធានការបង្វែរត្រូវបានរៀបចំឲ្យសមទៅនឹងកាលៈទេសៈនៃបទល្មើសរបស់កុមារ។ ឧទាហរណ៍ អាជ្ញាធរទទួលបន្ទុកបង្វែរ អាចជ្រើសរើសវិធានការដែលមានគោលបំណងអប់រំ កែប្រែអាកប្បកិរិយារបស់កុមារ និងលើកកម្ពស់ការធ្វើសមាហរណកម្មកុមារទៅក្នុងគ្រួសារ សហគមន៍ និងសង្គមវិញ។ មាត្រា ៦២ ក៏បានចែងច្បាស់

ផងដែរថា គោលបំណងនៃការបង្វែរគឺ កាត់បន្ថយការប្រព្រឹត្តបទល្មើសសារជាថ្មី ក៏ដូចជាទប់ស្កាត់កុមារមិនឲ្យប្រព្រឹត្តបទល្មើសក្នុងពេលកំពុងទទួលទោសដែរ ។ ការពារមិនឲ្យមានការរើសអើងលើកុមារ ដោយមិនឲ្យមានជាប់នៅក្នុងបញ្ជីថ្កោលទោស ។

ច្បាប់យុត្តិធម៌អនីតិជនទទួលស្គាល់អំពីសារៈសំខាន់នៃការចូលរួមដ៏សកម្មរបស់កុមារ និងស្ថាប័ន ពាក់ព័ន្ធដើម្បីធានាឲ្យវិធានការបង្វែរទទួលបានជោគជ័យ ។ មាត្រា ៦៣ ចែងពីលក្ខខណ្ឌអប្បបរមានៃការបង្វែរដែលមានដូចជា អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសដល់ជនរងគ្រោះ អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាពនិងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ។ វិធានការបង្វែរនៅក្នុងច្បាប់យុត្តិធម៌អនីតិជន បានឆ្លុះបញ្ចាំងអំពីការអនុវត្តអភិក្រមយុត្តិធម៌សហគមន៍ដោយផ្អែកលើដំណោះស្រាយនៅក្នុងសហគមន៍។ ដំណោះស្រាយនៅក្នុងសហគមន៍មានចែងនៅក្នុងមាត្រា៦៥ នៃច្បាប់នេះ។

ក្នុងការបង្កើតផែនការបង្វែរ ភ្នាក់ងារសង្គមកិច្ច ត្រូវពិចារណាទៅលើកត្តាមួយចំនួនដូចជា ទស្សនៈរបស់អនីតិជន សាវតារ វប្បធម៌ សាសនា កម្រិតសិក្សា អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជនជាដើម (មាត្រា ៦៦) ។ មាត្រា ៦៦ដដែលក៏បានចែងទៀតថា ផែនការបង្វែរ ត្រូវធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនិងអ្នកដទៃទៀត និងមិនត្រូវមានការដកហូតសេរីភាពនៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។

មាត្រា ៥២ ចែងថា ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ចំណុចនេះជាចំណុចសំខាន់មួយដែលចាំបាច់ត្រូវតែអនុវត្តដើម្បីសម្រេចបាននូវគោលដៅមួយក្នុងចំណោមគោលដៅផ្សេងទៀតនៃវិធានការបង្វែរ នោះគឺការបញ្ចៀសមិនឲ្យមានការរើសអើងដោយសារជាប់នៅក្នុងបញ្ជីថ្កោលទោស ។

ការសម្រេចទទួលយកការបង្វែរជាជាងការផ្តន្ទាទោសតាមផ្លូវតុលាការ គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាពបំផុត និងមិនគួរគិតថាធ្វើបែបនេះនាំឲ្យកុមារ «គេចវេះពីការប្រព្រឹត្តរបស់ខ្លួននោះឡើយ»។

មាត្រា ៦៧ ដល់ ៧១ មានចែងពី និទ្ទេសដែលត្រូវចុះនៅក្នុងផែនការបង្វែរ ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ ការអនុវត្តផែនការបង្វែរ ការកែប្រែវិធានការបង្វែរ និងបរាជ័យក្នុងការអនុវត្តវិធានការបង្វែរ។ ភ្នាក់ងារសង្គមកិច្ចត្រូវផ្តល់របាយការណ៍ស្តីពីការមិនគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ជូនទៅអាជ្ញាធរទទួលបន្ទុកបង្វែរ។ អាជ្ញាធរបង្វែរត្រូវពិនិត្យឡើងវិញ និងស្វែងរកមូលហេតុដែលបណ្តាលឲ្យបរាជ័យក្នុងការអនុវត្តតាមផែនការបង្វែរ ។ បន្ទាប់មកអាជ្ញាធរបង្វែរ អាចចេញដីការបង្វែរជាថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

# ៨. ការគ្រប់គ្រងសំណុំរឿង និងតុលាការ (ការរក្សាការសម្ងាត់ ភស្តុតាងបញ្ជាក់ពីអាយុ និងការសារភាពកំហុស)

## ៨.១. ការគ្រប់គ្រងសំណុំរឿង

អ្នកដែលមានតួនាទី និងភារកិច្ចត្រូវចូលរួមក្នុងដំណើរការយុត្តិធម៌អនីតិជន មានចែងនៅក្នុងច្បាប់យុត្តិធម៌អនីតិជន ។ ស្របតាមការអនុវត្តល្អរបស់អន្តរជាតិ ច្បាប់យុត្តិធម៌អនីតិជន តម្រូវឲ្យមានការគ្រប់គ្រងសំណុំរឿងដោយអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន (មាត្រា ១២)។

មាត្រា ១៨ បញ្ជាក់ពីអ្នកសំខាន់ៗ ដែលត្រូវចូលរួមក្នុងដំណាក់កាលចាប់ខ្លួនឬឃុំខ្លួនអនីតិជន។ អ្នកទាំងនោះរួមមានមន្ត្រីនគរបាលយុត្តិធម៌ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច និងមេធាវី ។ នគរបាលដើរតួនាទីយ៉ាងសំខាន់ ដោយសារតែពួកគេគឺជាអ្នកដែលមានទំនាក់ទំនងរវាងប្រព័ន្ធយុត្តិធម៌ និងកុមារទំនាស់នឹងច្បាប់ ។ កុមារអាយុក្រោម ១៤ឆ្នាំដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ១៤) ។ ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវ «ជៀសវាងការធ្វើឲ្យអាម៉ាសមុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន» (មាត្រា១៥)។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន (មាត្រា ១៧)។

មាត្រា ២៣ ចែងពីសិទ្ធិមួយចំនួននៅក្នុងនីតិវិធី ដែល «មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ (ការចាប់ខ្លួន និងការស៊ើបអង្កេត) នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី» ។ សិទ្ធិទាំងនេះមានដូចជា មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរឡើយ ក្នុងករណីគ្មានការយល់ព្រមជាមុនពីអនីតិជនដោយមានការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែល ច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ។ ក្នុងករណីមានការយល់ព្រម ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតម្រាមដៃ។ ជាងនេះទៅទៀត មាត្រា ២៣ចែងថា កុមារដែលត្រូវបានចាប់ខ្លួន ត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ ។ អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬធ្វើណាមួយដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ។

ក្រៅពីសិទ្ធិក្នុងនីតិវិធី ព្រះរាជអាជ្ញាត្រូវតែផ្ទៀងផ្ទាត់អាយុរបស់កុមារ (មាត្រា ២៥)។ ព្រះរាជអាជ្ញាត្រូវប្រាប់កុមារអំពីសិទ្ធិរបស់ខ្លួនដែលមានចែងក្នុងមាត្រា ៦ ត្រូវប្រើភាសានិងអាកប្បកិរិយាសមស្របទៅនឹងកម្រិតយល់ដឹងរបស់អនីតិជនពេលធ្វើការស្តាប់ចម្លើយ ត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជន ប្រសិនបើអនីតិជនមិនមានមេធាវី ត្រូវសម្ភាសកុមារដោយមានវត្តមានរបស់មេធាវី ហើយព្រះរាជអាជ្ញាត្រូវធានា

ថាកុមារបានយល់អំពីកំណត់ហេតុនៃការសាកសួរនេះ (មាត្រា ២៦)។ ដូចមាត្រា ២៣ ដែរ វិធានដែលបានចែងនៅក្នុងមាត្រា២៦នេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

ព្រះរាជអាជ្ញាមានអំណាចក្នុងការបង្វែរកុមារ (មាត្រា ២៨) ស្របទៅនឹងជំពូក ១០ (ការបង្វែរ)។ ពាក់ព័ន្ធនឹងអំណាចនេះ មាត្រា២៤នៃច្បាប់នេះ បានបង្ហាញថា តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជនត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ។

ច្បាប់យុត្តិធម៌អនីតិជនក៏បានបង្កើតឲ្យមានតួនាទីដ៏សំខាន់របស់ភ្នាក់ងារសង្គមកិច្ច ។ មាត្រា ១១ រៀបរាប់ពីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច ដែលជាអ្នកមានតួនាទីជួយគ្រប់គ្រងសំណុំរឿង(ឬករណី)នៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ។ ភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ចរួមមាន៖

- ជួបជាមួយអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ចាប់ពីការឃាត់ខ្លួន រហូតដល់បញ្ជូនទៅពន្ធនាគារ និងផ្តល់សេវាដល់អនីតិជន
- ប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដើម្បីរៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម ព្រះរាអាជ្ញា និងតុលាការ
- ផ្តល់ការគាំទ្រខាងផ្លូវចិត្តដល់កុមារនៅគ្រប់ដំណាក់កាលនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ
- រៀបចំ និងផ្តល់ផែនការបង្វែរជូនអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីពិនិត្យនិងសម្រេច
- ផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជន
- ទទួលភារកិច្ចចាំបាច់ផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ។

## ៨.២. ការគ្រប់គ្រងតុលាការ

ស្របតាមការអនុវត្តល្អរបស់អន្តរជាតិ ច្បាប់យុត្តិធម៌អនីតិជនតម្រូវឲ្យមានតុលាការឯកទេសខាងកុមារ (មាត្រា ៤៤) ។ ច្បាប់យុត្តិធម៌អនីតិជនរៀបរាប់អំពីការផ្តល់អាទិភាពនៃរឿងក្តីទាក់ទងនឹងកុមារនៅក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ន និងការដោះលែងឲ្យនៅក្រៅឃុំ ដើម្បីគិតដល់ឧត្តមប្រយោជន៍របស់កុមារ (មាត្រា ៤៥) ។ មាត្រា ៤៦ តម្រូវឲ្យចៅក្រមជំនុំជម្រះ អនុវត្តតួនាទីរបស់ខ្លួន យ៉ាងសកម្មដើម្បីធានាថា របាយការណ៍និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ត្រូវបានរៀបចំដោយភ្នាក់ងារសង្គមកិច្ច ។ មាត្រា ៥១ តម្រូវឲ្យតុលាការប្រាប់ដល់កុមារអំពីសិទ្ធិរបស់ខ្លួន។ មាត្រា ៤៨ តម្រូវឲ្យតុលាការប្រើប្រាស់នីតិវិធីបែបកុមារមេត្រី ។ នីតិវិធីបែបកុមារមេត្រីរបស់តុលាការក៏មានលើកយកមកពិភាក្សានៅក្នុងឯកសារនេះដែរ(សូមអានត្រង់ចំណុច៖ ការបណ្តុះបណ្តាលពិសេសក្នុងការអនុវត្តនីតិវិធីកុមារមេត្រីសម្រាប់នគរបាល ព្រះរាជអាជ្ញា និងតុលាការ ។

## ៩.៣. ភស្តុតាងបញ្ជាក់អំពីអាយុ

ភស្តុតាងបញ្ជាក់ពីអាយុ គឺចាំបាច់ដើម្បីធានាដំណើរការប្រព័ន្ធយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព ទាំងការធានាថា កុមារមិនត្រូវបានកាត់ទោស និងមិនត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូចមនុស្សពេញវ័យ ហើយក៏ធានាផងដែរថាមនុស្សពេញវ័យនឹងមិនឆ្លៀតយកលក្ខខណ្ឌពិសេសនេះមកអនុវត្តចំពោះខ្លួនឡើយ (Smith and Bronless: ២០១១)។

ប្រសិនបើរឿងក្តីកុមារត្រូវបានដំណើរការដូចមនុស្សពេញវ័យនោះ កុមារនឹងប្រឈមនឹងហានិភ័យខ្ពស់ ដោយសារតែភាពខុសគ្នាទាំងស្ថានភាពអាយុ ឬភាពក្មេងខ្ចីរបស់កុមារ ។ កុមារមិនទាន់គ្រប់អាយុទទួលខុសត្រូវព្រហ្មទណ្ឌ ដែលត្រូវបានគេកំណត់អត្តសញ្ញាណច្រលំ ត្រូវឆ្លងកាត់ប្រព័ន្ធតុលាការ ដែលតាមការពិតកុមារនោះគួរទទួលបានកិច្ចការពារនិងថែទាំ។ ដូច្នេះការកំណត់អាយុរបស់មនុស្សម្នាក់ដែលជាប់ពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ គឺជារឿងសំខាន់ណាស់ដើម្បីធានាថា ទាំងកុមារ និងនីតិជនត្រូវបានគេកំណត់ និងប្រព្រឹត្តមកលើខ្លួនឲ្យបានត្រឹមត្រូវ (យូនីសេហ្វ ១៩៩៥ ទំព័រ ២០) ។

មាត្រា ៩ បានចែងអំពីភស្តុតាងនៃការកំណត់អាយុ ដែលត្រូវតែធ្វើឡើងដោយផ្អែកលើសំបុត្រកំណើត ឬ «ឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ឬមធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន» ។ ការកំណត់អាយុនេះ ត្រូវធ្វើឡើង «ឲ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន» ។ ក្នុងករណីដែលមានភាពមិនច្បាស់លាស់អំពីអាយុរបស់កុមារ វិមតិសង្ស័យត្រូវបានជា «ប្រយោជន៍ដល់កុមារ» ។ នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលពុំមានសំបុត្រកំណើត ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់កុមារនោះ (មាត្រា ២៥)។ ការវាយតម្លៃអាយុរបស់កុមារគឺជារឿងស្មុគស្មាញ ហើយពុំមានវិទ្យាសាស្ត្រ ឬវិធីសាស្ត្រពេទ្យដែលអាចកំណត់អាយុកុមារឲ្យបានត្រឹមត្រូវនោះឡើយ ។ ដូចដែល Smith and Brownless បានបញ្ជាក់៖

«មានភស្តុតាងបង្ហាញថា នៅពេលមានការប៉ាន់ប្រមាណអាយុរបស់កុមារ តែងតែមានការព្យាយាមកំណត់អាយុពិតរបស់កុមារឲ្យបាន បើទោះបីជាការប៉ាន់ប្រមាណនោះមិនត្រឹមត្រូវ១០០%ក៏ដោយ។ អ្នកផ្តល់យោបល់ផ្នែកនេះ ទទួលស្គាល់ថា បើទោះជាប្រើវិធីសាស្ត្រណាក៏ដោយ ក៏នៅតែមានចំណុចលំអៀងតិចតួចកើតឡើងដែរ...។ នៅក្នុងការអនុវត្តជាក់ស្តែង ការកំណត់ដោយមើលនឹងភ្នែក ដែលជារឿយៗធ្វើឡើងដោយមន្ត្រីខ្វះសមត្ថភាពនោះ ចេះតែមានច្រើនឡើងៗ។ បច្ចុប្បន្ននេះ ការប៉ាន់ប្រមាណតាមបែបវិជ្ជសាស្ត្រពេទ្យត្រូវបានគេទទួលស្គាល់ថា ជាមធ្យោបាយត្រឹមត្រូវ និងអាចជឿទុកចិត្តបាន ។ ប៉ុន្តែ... មានការសន្និដ្ឋានរបស់លោក Eizenberger (២០០៣ ទំព័រ ៤៤) ថា «ទាំងគ្រូពេទ្យ និង អ្នកជំនាញដទៃទៀត មិនអាចកំណត់អាយុកុមារឲ្យបានត្រឹមត្រូវនោះទេ» យើងគ្រាន់តែអាចប៉ាន់ប្រមាណអាយុបានដោយផ្អែកលើ កត្តាខាងក្នុងនិងខាងក្រៅប៉ុណ្ណោះ ប៉ុន្តែមិនអាចកំណត់អាយុបានទេ (Eizenberger, ២០០៣ ទំព័រ ៤៤).»» (Smith and Brownlees:២០១១ ទំព័រ ៤១) ។

ដោយសារតែមានការលំបាកបែបនេះហើយ ទើបតម្រូវឲ្យមានការអនុវត្តប្រព័ន្ធចុះសំបុត្រកំណើតឲ្យមានប្រសិទ្ធភាព ហើយការងារនេះត្រូវដាក់វាឲ្យទៅជាកាតព្វកិច្ច មិនបង់ប្រាក់ ហើយសហគមន៍អាចទៅរកសេវានេះបានដោយងាយស្រួល ។ ឪពុក ម្តាយ និងសហគមន៍ ចាំបាច់ត្រូវទទួលបានការអប់រំណែនាំឲ្យយល់ពីសារៈសំខាន់នៃការចុះសំបុត្រកំណើតនេះ ។

ទាក់ទងនឹងការពិនិត្យគ្រប់ជ្រុងជ្រោយអំពីការអនុវត្តលើការប៉ាន់ប្រមាណអាយុ សូមចូលអានឯកសារដែលរៀបចំដោយ Smith និង Brownless, UNICEF, ២០១១ តាមគេហ ទំព័រនេះ https://www.unicef.org/protection/Age_Assessment_Practices_2010.pdf

## ៩.៤. ការសារភាពកំហុសរបស់កុមារ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចែងថា តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាការសារភាពកំហុសរបស់អនីតិជនគឺធ្វើឡើងដោយស្ម័គ្រចិត្ត មិនមានការគំរាមកំហែង ឬបង្ខិតបង្ខំឡើយ ។ ដើម្បីវាយតម្លៃលើការសារភាពកំហុស សំខាន់ត្រូវពិនិត្យមើលលើការសិក្សាស្រាវជ្រាវផ្នែកចិត្តសាស្ត្រដែលបានអះអាងថា កុមារងាយនឹងសារភាពកំហុសដោយមិនត្រឹមត្រូវ ដោយសារតែការលូតលាស់ និងការយល់ដឹងរបស់កុមារនៅមានកម្រិត។ ពួកគេងាយនឹងធ្វើតាមការណែនាំរបស់មន្ត្រីមានសមត្ថកិច្ច (Kassin ២០១០)។ ដោយហេតុនេះហើយ ទើបតម្រូវឲ្យមានសិទ្ធិទទួលបានការប្រឹក្សាយោបល់ ដែលមានបញ្ជាក់ក្នុងមាត្រា ៦ ១៨ ២០ ២១ ២២ និង ២៣ នៃច្បាប់យុត្តិធម៌អនីតិជន ។ បញ្ហាគឺថាកុមារពេលខ្លះបានសារភាពថាបានប្រព្រឹត្តបទល្មើស ដែលខ្លួនមិនបានប្រព្រឹត្ត ហើយដោយសារតែបញ្ហានេះ ទើបមាត្រា៥៣ តម្រូវឲ្យតុលាការផ្ទៀងផ្ទាត់ពីភាពស៊ីសង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។ បញ្ហានេះក៏មានបកស្រាយបន្ថែមក្នុងចំណុចៈ កម្មវិធីបណ្តុះបណ្តាលអ្នកជំនាញនៅក្នុងការអនុវត្តកុមារមេត្រីសម្រាប់នគរបាល ព្រះរាជអាជ្ញា និងតុលាការ ។

ដូចបានគូសបញ្ជាក់ខាងលើ តុលាការត្រូវប្រាប់ដល់កុមារអំពីសិទ្ធិរបស់ខ្លួន (មាត្រា ៥១) ។ តុលាការត្រូវវាយតម្លៃ និងបញ្ជាក់អំពីការសារភាពកំហុសដោយស្ម័គ្រចិត្ត ហើយការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ (មាត្រា ៥៣) ។ សវនាការត្រូវធ្វើ ជាអសាធារណៈ (មាត្រា៤៧)។

## ៩.៥. ការរក្សាការសម្ងាត់

គោលការណ៍សំខាន់មួយក្នុងចំណោមគោលការណ៍សំខាន់ជាច្រើននៃយុត្តិធម៌អនីតិជន គឺធានាថាកុមារនឹងមិនមានស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍ដោយសារតែការប្រព្រឹត្តបទល្មើសនោះទេ។ នៅពេលដែលសវនាការធ្វើជាសាធារណៈចំពោះកុមារដែលបានប្រព្រឹត្តបទល្មើស ជាពិសេសបទល្មើសធ្ងន់ធ្ងរ ស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍នឹងកើតមានដល់កុមារយ៉ាងខ្លាំង ហើយមានរយៈពេលយូរអង្វែងទៀតផង។ ជាការពិតស្លាកស្នាមអាក្រក់ក្នុងអារម្មណ៍នេះ នឹងស្ថិតនៅយូរអង្វែងក្នុងចិត្តរបស់កុមារ ដែលខុសពីមនុស្សពេញវ័យដែលបានប្រព្រឹត្តបទល្មើស ។

ដោយហេតុផលនេះហើយ ទើបច្បាប់យុត្តិធម៌អនីតិជនរក្សាការសម្ងាត់របស់កុមារ និងបញ្ចៀសកុមារមិនឲ្យចូលពាក់ព័ន្ធក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ តាមរយៈវិធានការផ្សេងៗ។ នគរបាលអាចរក្សាកំណត់ហេតុពាក់ព័ន្ធនឹងបទល្មើសរបស់កុមារ (មាត្រា ១២) រីឯតុលាការនឹងត្រូវបើកសវនាការជាអសាធារណៈជាធម្មតា (មាត្រា ៤៧) ហើយអត្តសញ្ញាណរបស់កុមារត្រូវបានការពារតាមរយៈការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬវិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ (មាត្រា ៤៨) ។ ការប្រកាសសាលក្រមត្រូវធ្វើជាអសាធារណៈ (មាត្រា ៥៤) ។មាត្រា ៥៩ ចែងថា នីតិវិធីដូចគ្នា (ត្រូវធ្វើជាអសាធារណៈ ដោយយោងលើមាត្រា ៤៧) នឹងត្រូវយកទៅអនុវត្ត នៅសាលាឧទ្ធរណ៍ ឬ តុលាការកំពូលផងដែរ ។

ច្បាប់ចម្លងនៃផែនការបង្វែរ ត្រូវរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច (មាត្រា៦៧)។

# ៩. ការអនុវត្តបែបកុមារមេត្រី និងការបង្កើតជំនាញវិជ្ជាជីវៈ

ការវិភាគស៊ីជម្រៅគ្រប់ជ្រុងជ្រោយមួយស្តីពីផលប៉ះពាល់នៃការធ្វើអន្តរាគមន៍លើកុមារជាជនល្មើសបាន បង្ហាញយ៉ាងច្បាស់អំពីប្រសិទ្ធភាពនៃវិធីសាស្ត្រដោះស្រាយបញ្ហា លើវិធីសាស្ត្រគ្រប់គ្រងបញ្ហា ( Lipsey et al. ២០១៥ ទំព័រ ៦ )។ វិធីសាស្ត្រដោះស្រាយបញ្ហានេះ គឺផ្តោតទៅលើការអភិវឌ្ឍបុគ្គលិកលក្ខណៈ តាមរយៈ ការកែលម្អទំនាក់ទំនង ជំនាញ ការយល់ដឹងឫសគល់នៃបញ្ហា និងការឃោគយល់ ( BAAF, 2015, p6 )៖

ទស្សនៈដោះស្រាយបញ្ហា រួមានវិធានការស្តារឡើងវិញ ( ដូចជាការជួសជុលសំណង ការសម្រុះសម្រួល រវាងជនល្មើស និងជនរងគ្រោះ ) ការបង្កើតជំនាញ ( ឧទាហរណ៍ វិធីយល់ដឹងពីគំនិត-ចិត្ត-ទង្វើ ទំនាក់ទំនង ជាមួយនឹងសង្គម ការកសាងជំនាញវិជ្ជាជិវៈ និងអប់រំ ) ប្រឹក្សាយោបល់ ( ប្រឹក្សាយោបល់ជាបុគ្គល ជាគ្រួសារ ឬជាក្រុម ការរៀនសូត្រពីអ្នកមានបទពិសោធន៍ ) និងពហុសេវាដែលពាក់ព័ន្ធ ( ដូចជាការគ្រប់គ្រង សំណុំរឿង និងស្វែងរកសេវាកម្ម )។

ច្បាប់យុត្តិធម៌អនីតិជនសំដៅដល់ នីតិវិធី និងការអនុវត្ត បែប «កុមារមេត្រី» ដែលត្រូវបង្កើតឡើង ដើម្បីលើកកម្ពស់ឲ្យមានការចូលរួមយ៉ាងពេញលេញ និងលើកកម្ពស់សិទ្ធិកុមារ ។ ដូច្នេះ ការបណ្តុះ បណ្តាល ឲ្យមានអ្នកជំនាញ ពិតជាមានសារៈសំខាន់ដើម្បីឲ្យមន្ត្រីសំខាន់ៗអាចកែសម្រួលការប្រើប្រាស់ភាសា នីតិវិធី និងបរិយាកាសរបស់តុលាការ ។ សមត្ថភាព និង ការបណ្តុះបណ្តាលមន្ត្រី ជំនាញ ត្រូវបង្កើតឡើងសម្រាប់ នគរបាល ចៅក្រម ព្រះរាជអាជ្ញា និងសម្រាប់អ្នកបម្រើការងារនៅក្នុងតួនាទីគាំទ្រផ្នែកសង្គម ។

### គណៈកម្មការកែទម្រង់ច្បាប់របស់ប្រទេសអូស្ត្រាលីបានកត់សម្គាល់ដូចខាងក្រោម( ១៩៩៧ )៖

គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ បានគូសបញ្ជាក់ពីតម្រូវការនៃកម្មវិធីបណ្តុះ បណ្តាលជាប្រព័ន្ធដល់ក្រុមមន្ត្រីដែលធ្វើការងារជាមួយឬដើម្បីកុមារ ក្នុងផ្នែកគ្រប់គ្រង យុត្តិធម៌អនីតិជន។ មន្ត្រីទាំងនោះរួមមានៈ ចៅក្រម ព្រះរាជអាជ្ញា បុគ្គលិកសង្គមកិច្ច មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីអន្តោប្រវេសន៍។ ព្រះរាជអាជ្ញាគួរទទួលបានការបណ្តុះបណ្តាលពិសេសអំពីបញ្ហាកុមារ ជាពិសេសទាក់ទងនឹងការប្រើប្រាស់ ឆន្ទានុសិទ្ធិក្នុងការលើកលែងការចោទប្រកាន់ នៅក្នុងរឿង ក្តីកុមារ ។

វិធានប៉េកាំងចែងថា ដំណើរការរឿងក្តីព្រហ្មទណ្ឌគួរតែធ្វើឡើងដោយគិតដល់ឧត្តម ប្រយោជន៍របស់កុមារ ហើយត្រូវប្រព្រឹត្តទៅក្នុងបរិយាកាសមួយដែលអនុញ្ញាតឲ្យកុមារចូលរួមនៅក្នុងដំណើរការរឿងក្តីនោះជាមួយនឹងការ បញ្ចេញមតិដោយសេរី ។ អ្នកអនុវត្តច្បាប់ និងចៅក្រមខ្លះលើកទឹកចិត្តមិនឲ្យមានការរៀបចំជាលក្ខណៈផ្លូវការនៅ ក្នុងតុលាការកុមារ ដូចជានៅក្នុងតុលាការមនុស្សពេញវ័យនោះទេ ។ ការប្រើប្រាស់ភាសា និងពាក្យបច្ចេកទេស ធ្វើឲ្យកុមារពិបាកយល់ពីដំណើរការរឿងក្តី ហើយអាចជាមូលហេតុដែលនាំឲ្យកុមារមិនចង់ចូលរួមក្នុងតុលាការ ។

នេះគឺជាបញ្ហា ធ្ងន់ធ្ងរ នៅក្នុងបញ្ហាដែលពិបាកបញ្ចៀស ដូចជា ករណីឃាតកម្ម និងការរំលោភបំពានផ្លូវភេទ ដែលត្រូវធ្វើឡើងនៅក្នុងតុលាការជាន់ខ្ពស់ ។

វិធីមួយដែលអាចបង្កើនការយល់ដឹងរបស់កុមារអំពីដំណើរការរឿងក្តីព្រហ្មទណ្ឌ និងដើម្បីឲ្យកុមារចូលរួមពេញលេញនោះ គឺត្រូវធានាថាកុមារមានមេធាវីតាំងពីដំណាក់កាលដំបូង។ វិធីមួយទៀតត្រូវផ្តល់ឲ្យកុមារនូវសិទ្ធិទទួលបានអ្នកទំនុកបម្រុងក្នុងតុលាការ ។

ចាំបាច់ត្រូវមានការកែសម្រួលប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីស្របនឹងនីតិវិធី និងការអនុវត្តបែប កុមារមេត្រី ដែលមានចែងនៅក្នុងច្បាប់យុត្តិធម៌អនីតិជន។ មាត្រា ៤ នៃច្បាប់យុត្តិធម៌អនីតិជន កំណត់ពី «នីតិវិធីកុមារមេត្រី» ជាដំណើរការដែលលើកទឹកចិត្តដល់ការចូលរួមយ៉ាងពេញលេញ របស់កុមារតាមរយៈការប្រើប្រាស់អត្តចរិត និងភាសាសមស្របទៅតាមកម្រិតនៃការយល់ដឹងរបស់កុមារ នៅក្នុងបរិយាកាសដែលផ្តល់ឲ្យកុមារនូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងសេចក្តីត្រូវការ ជាមូលដ្ឋាន ។

ដោយបានបញ្ជាក់ពីតម្រូវការក្នុងការបណ្តុះបណ្តាលមន្ត្រីដែលធ្វើការពាក់ព័ន្ធជាមួយនឹងកុមារ ដើម្បីឲ្យពួកគេមានជំនាញក្នុងការងាររបស់ខ្លួននោះ ឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស បទដ្ឋានសិទ្ធិមនុស្ស និងការអនុវត្តសម្រាប់នគរបាល បានកំណត់នូវវិធានមួយចំនួនសម្រាប់បង្កើតជាមូលដ្ឋានក្នុងការបណ្តុះបណ្តាលដល់អ្នកដែលធ្វើការងារផ្នែកប្រព័ន្ធយុត្តិធម៌អនីតិជន។ បទដ្ឋានសិទ្ធិមនុស្ស និងការអនុវត្តសម្រាប់នគរបាល រួមមានៈ

- កុមារត្រូវតែទទួលបានផលប្រយោជន៍ពីការធានាការគោរពសិទ្ធិមនុស្សដែលមានចំពោះមនុស្សពេញវ័យ ។ ជាងនេះទៅទៀត វិធានខាងក្រោមគួរតែត្រូវអនុវត្តចំពោះកុមារៈ
- ត្រូវប្រព្រឹត្តចំពោះកុមារក្នុងលក្ខណៈដែលលើកកម្ពស់ដល់ តម្លៃ និង សេចក្តីថ្លៃថ្នូរបស់ កុមារ ជួយដល់ការធ្វើសមាហរណកម្មរបស់កុមារទៅក្នុងសហគមន៍ ឆ្លុះបញ្ចាំងពីឧត្តមប្រយោជន៍របស់កុមារ និងគិតគូរអំពីតម្រូវការរបស់កុមារ ។
- កុមារមិនមែនជាកម្មវត្ថុនៃការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ ការបន្ថោកបន្ទាប ការដាក់ទណ្ឌកម្មផ្នែករាងកាយ ឬ ការផ្តន្ទាទោសដាក់គុកមួយជីវិតដោយគ្មានឱកាសដោះលែងនោះទេ ។
- ការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ គួរតែត្រូវប្រើសម្រាប់តែជាជម្រើសចុងក្រោយ ប៉ុណ្ណោះ ហើយការឃុំខ្លួនត្រូវធ្វើក្នុងរយៈពេលដ៏ខ្លីបំផុត ។
- កុមារត្រូវតែដាក់ឲ្យនៅដោយឡែកពីមនុស្សពេញវ័យ
- កុមារដែលត្រូវឃុំខ្លួនគួរទទួលបានការមកសួរសុខទុក និងការឆ្លើយឆ្លងលិខិតពីសមាជិក គ្រួសាររបស់ខ្លួន។
- ជម្រើសផ្សេងក្រៅពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនិងក្រៅពីការថែទាំក្នុងមណ្ឌលត្រូវតែផ្តល់ឲ្យកុមារ។

- ភាពឯកជនរបស់កុមារត្រូវតែទទួលបានការគោរព ហើយរបាយការណ៍ស្តីពីកុមារត្រូវរក្សាទុកជាសម្ងាត់ ។
- ការប្រើប្រាស់កម្លាំង និងការបង្ខិតបង្ខំលើរូបរាងកាយរបស់កុមារ ត្រូវតែជៀសវាង
- មិនត្រូវប្រើប្រាស់អាវុធនៅក្នុងស្ថាប័នដែលធ្វើការលើរឿងកុមារទេ
- ត្រូវមានការគោរពចំពោះសេចក្តីថ្លៃថ្នូរបស់កុមារ និងត្រូវមានសុភវិន័ថ្ង័យ ការគោរព ខ្លួនឯង និងការគោរពសិទ្ធិមនុស្សក្នុងរឿងកុមារ ។
- មន្ត្រីដែលធ្វើកាជាមួយនឹងកុមារ ត្រូវទទួលបានការបណ្តុះបណ្តាលជាពិសេស ដើម្បីឲ្យស្របតាមគោលបំណងនៃការងាររបស់ខ្លួន ។
- ក្រុមអធិការកិច្ចត្រូវចុះត្រួតពិនិត្យកន្លែងគ្រប់គ្រងអនីតិជន ជាទៀងទាត់ ឬដោយមិនមានការជូនដំណឹងមុន
- ត្រូវជូនដំណឹងទៅឳពុកម្តាយនៅពេលមានការចាប់ខ្លួន ឃុំខ្លួន ផ្ទេរ ឈឺ របួស ឬស្លាប់

*ប្រភព: ឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស បទដ្ឋានសិទ្ធិមនុស្ស និងការអនុវត្តសម្រាប់នគរបាល Expanded Pocket Book ស្តីពីសិទ្ធិមនុស្សសម្រាប់នគរបាល (២០០៤) ទំព័រ ៣៨ ។*

បន្ថែមទៅលើការបណ្តុះបណ្តាលដែលបានរៀបរាប់ខាងលើ បុគ្គលិកទាំងអស់គួរត្រូវបានអប់រំឲ្យយល់ដឹងអំពីភាពខុសគ្នាខាងការលូតលាស់និងចិត្តគំនិត រវាងកុមារ និងមនុស្សពេញវ័យ និងយល់ដឹងអំពីកត្តាផ្សេងៗដែលជះឥទ្ធិពលដល់អាកប្បកិរិយារបស់កុមារ ជាពិសេស ទង្វើដែលនាំឲ្យកុមារប្រព្រឹត្តបទល្មើស។ ចំណុចទាំងអស់នេះមិនត្រឹមតែពាក់ព័ន្ធនឹងនគរបាល មេធាវី និងចៅក្រម ប៉ុន្តែក៏ទាក់ទងនឹងភ្នាក់ងារសង្គមកិច្ច និងអ្នកដទៃទៀតដែលធ្វើការផ្នែកសង្គមកិច្ចផងដែរ ។

ជាងនេះ ទៅទៀត ការអប់រំផ្សព្វផ្សាយអំពីភាពខុសគ្នានៃចិត្តសាស្ត្រ និងការអភិវឌ្ឍរវាងកុមារ និងមនុស្ស ចាស់គឺជារឿងសំខាន់ ដោយចាំបាច់ត្រូវឲ្យមានការកែសម្រួលពីការប្រើប្រាស់ ភាសា និងនីតិវិធីដើម្បីបង្កើនការយល់ដឹងរបស់កុមារ និងដើម្បីជំរុញឲ្យមានការចូលរួមរបស់គេនៅក្នុងប្រព័ន្ធ យុត្តិធម៌អនីតិជនផងដែរ ។

## ៩.១. ការបណ្តុះបណ្តាលជំនាញឯកទេសស្តីពីការអនុវត្តនីតិវិធីបែបកុមារមេត្រីសម្រាប់នគរបាល ព្រះរាជអាជ្ញា និង តុលាការ

### សម្រាប់នគរបាល

នគរបាលដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ដោយសារតែនគរបាលជាមន្ត្រីជួរមុខនៅក្នុងប្រព័ន្ធយុត្តិធម៌ ដែលត្រូវជួបកុមារទំនាស់នឹងច្បាប់មុនគេ។ នគរបាល ត្រូវមានជំនាញច្បាស់លាស់

ដើម្បីធ្វើការជាមួយនឹងកុមារទំនាស់នឹងច្បាប់ឲ្យមានប្រសិទ្ធិភាព។ ដូចបានលើកឡើងពីខាងដើមនៃឯកសារនេះ (សូមមើលត្រង់ចំណុច ការចេញ សេចក្តីព្រមាន) នគរបាលប្រើប្រាស់សិទ្ធិ ពិចារណាក្នុងការចាត់វិធានការពាក់ព័ន្ធនឹងកុមារ។ ដោយសារតែការផ្តន្ទាទោសព្រហ្មទណ្ឌ បង្កឲ្យមានផលវិបាកដល់កុមារ ដូច្នេះការសម្រេចយ៉ាងណារបស់នគរបាលដែលជាមន្ត្រីត្រូវជួបកុមារមុនគេនោះ នឹងនាំឲ្យមានផលប៉ះពាល់ច្រើនដល់ជីវិតរបស់កុមារ ។

ដូចបានជំរាបជូនពីខាងដើម វិធានប៉េកាំង ចំណុច ១០.៣ ចែងថា ទំនាក់ទំនង «របស់អាជ្ញាធរមានសមត្ថកិច្ចជាមួយនឹងកុមារជាជនល្មើស ត្រូវធ្វើឡើងដោយគោរពសិទ្ធិផ្លូវច្បាប់របស់កុមារ លើកកម្ពស់សុខុមាលភាពរបស់កុមារ ជៀសវាងការធ្វើឲ្យកុមារទទួលរងការឈឺចាប់ និងគិតអំពីស្ថានភាពនៃបទល្មើស» ។ សេចក្តីពន្យល់នៃវិធាននេះលើកឡើងពីសារៈសំខាន់នៃអន្តរាគមន៍លើកដំបូងរបស់អាជ្ញាធរមានសមត្ថកិច្ចចំពោះកុមារដែលប្រព្រឹត្តបទល្មើសលើកទី១។ ប្រសិនបើអន្តរាគមន៍លើកដំបូងនេះត្រូវបានធ្វើឡើងដោយមានអាកប្បកិរិយាហិង្សារបស់អាជ្ញាធរមានសមត្ថកិច្ច នោះវានឹងអាចជះឥទ្ធិពលមិនល្អលើអាកប្បកិរិយារបស់កុមារផងដែរ។ ដូច្នេះ ការអត់អោន គឺមានសារៈសំខាន់សម្រាប់ស្ថានភាពកុមារទាំងអស់នេះ។» ដោយហេតុថានគរបាលដើរតួនាទីយ៉ាងសំខាន់ដែលអាចជះឥទ្ធិពលលើកុមារទំនាស់នឹងច្បាប់បែបនេះហើយ បាននគរបាលគួរទទួលបានការបណ្តុះបណ្តាលជំនាញ ដើម្បីលើកកម្ពស់ការអនុវត្តបែបកុមារមេត្រី ។

ជំនាញខាងសន្ធានកម្ម( សម្រុះសម្រួល )គឺផ្នែកមួយដែលនគរបាលគួរទទួលបានការបណ្តុះបណ្តាល។ នៅពេលដែលកុមារបានសារភាពថាបានប្រព្រឹត្តបទលហុ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិសម្រុះសម្រួលរវាងភាគីទាំងពីរ ដើម្បីដោះស្រាយជម្លោះ (មាត្រា ១៣) ។ នៅក្នុងតួនាទីជាអ្នក សម្រុះសម្រួល នគរបាលចាំបាច់ត្រូវតែមានសមត្ថភាពចូលរួមដោះស្រាយជាមួយនឹងកុមារជាជន ល្មើស ក៍ដូចជាជនរងគ្រោះឲ្យមានប្រសិទ្ធភាព ។ សៀវភៅមេរៀនបណ្តុះបណ្តាលរបស់អង្គការ UNODC ដែលមានចំណងជើងថា Policing Urban Space (2013) ទទួលស្គាល់តម្លៃនៃការសម្រុះសម្រួល ជាជំនាញដ៍សំខាន់សម្រាប់មន្ត្រីនគរបាល ៖

«ជំនាញសំខាន់មួយសម្រាប់មន្ត្រីនគរបាល ដើម្បីចូលរួមក្នុងកម្មវិធីនគរបាលសហគមន៍ គឺការសម្រុះសម្រួល។ ការសម្រុះសម្រួលគឺជាដំណើរការមួយដែលមន្ត្រីនគរបាលដើរតួជាភាគីទី៣ មិនលំអៀងដើម្បីជួយដោះស្រាយបញ្ហា។ ជាទូទៅនគរបាលដឹកនាំ និងសម្រុះសម្រួលដំណើរការនេះ។ គោលបំណង គឺដើម្បីលើកកម្ពស់ការចូលរួមរបស់សហគមន៍ ក្នុងការដោះស្រាយបញ្ហាដោយសុវត្ថិភាព ដោយផ្តល់សិទ្ធិអំណាចដល់អ្នកចូលរួមទាំងអស់ក្នុងការដាក់ចេញនូវអនុសាសន៍ដើម្បីអនុវត្ត» ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីជំនាញសម្រុះសម្រួល សូមអាន ឯកសារបណ្តុះបណ្តាលរបស់អង្គការ UNODC ដែលមានចំណងជើងថា Alternative Dispute Resolution and Restorative Justice (ជម្រើសផ្សេងៗក្នុងការដោះស្រាយជម្លោះ និងយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ) និងសៀវភៅរបស់ UNODC ដែលមានចំណងជើងថា Handbook on Restorative Justice Programmes, 2006 (កម្មវិធីយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ)។

ផ្នែកសំខាន់មួយទៀតដែលត្រូវបណ្តុះបណ្តាលដល់មន្ត្រីនគរបាលឲ្យយល់ដឹងដែរ គឺផលប៉ះពាល់ដោយសារតែភាពក្មេងខ្ចីរបស់កុមារ និងតម្រូវការថែទាំពិសេសនៅពេលស្តាប់ចម្លើយកុមារ។ ដោយហេតុថាកុមារកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការលូតលាស់ខួរក្បាល កុមារមានភាពងាយរងគ្រោះជាងមនុស្សពេញវ័យនៅគ្រប់ដំណាក់កាលនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ នគរបាលត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់ចំពោះកុមារទំនាស់នឹងច្បាប់ ជាពិសេសពេលស្តាប់ចម្លើយ និងពេលទទួលយកការសារភាពរបស់កុមារ ដោយហេតុថា តាមការសិក្សាស្រាវជ្រាវ កុមារងាយនឹងនិយាយសារភាព នូវអ្វីដែលខ្លួនមិនបានប្រព្រឹត្តបើធៀបជាមួយនឹងមនុស្សពេញវ័យ ។

ដូចដែលបានលើកឡើងពីខាងដើមនៅក្នុងឯកសារនេះ (សូមមើលចំណុចភាពខុសគ្នារវាងកុមារ និងមនុស្សពេញវ័យ) មានភស្តុតាងដ៏រឹងមាំបញ្ជាក់ថា កុមារងាយនឹងនិយាយសារភាពកំហុសទាំងមិនស្ម័គ្រចិត្តនៅពេលដែលនគរបាលសាកសួរ (Redlich និង Drizin ២០០៧)។ ករណីដែលកុមារសារភាពបែបនេះគឺមានចំនួនច្រើន (Drizin និង Lea ២០០៤) ។ ការសារភាពបែបនេះ កើតឡើងដោយសារ មានការផ្តល់យោបល់របៀបបង្ខំឲ្យឆ្លើយ ការបង្ខំឲ្យស្តាប់តាមអាជ្ញាធរ ហើយរួមផ្សំជាមួយនឹងសមត្ថភាពក្មេងខ្ចីរបស់កុមារក្នុងការសម្រេចចិត្តផង។ នគរបាលក៏ត្រូវយល់ផងដែរថា កុមារចូលចិត្តអ្វីដែលឆាប់ទទួលបានលទ្ធផលដូចជាបន្ទាប់ពីស្តាប់ចម្លើយ កុមារអាចទៅផ្ទះបានជាដើម ជាជាងចំណាយពេលយូរហួតកុមារធុញទ្រាន់ហើយសារភាព។

ដោយសារហេតុផលទាំងអស់នេះហើយ ទើបមន្ត្រីនគរបាលគួរទទួលបានការបណ្តុះបណ្តាលជំនាញក្នុងការស្តាប់ចម្លើយ ហើយគួរបង្កើតឲ្យមានបច្ចេកទេសក្នុងការស្តាប់ចម្លើយសម្រាប់អនុវត្ត។ ជាការល្អ គួរបង្កើតឲ្យមានការបណ្តុះបណ្តាលថ្នាក់ជំនាញមួយ ដើម្បីឲ្យនគរបាលមានជំនាញក្នុងការស្តាប់ចម្លើយកុមារ ដូចដែលមានចែងនៅក្នុងមាត្រា ២២ គឺការស្តាប់ចម្លើយត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជននិងជាសម្ងាត់ ។ ដោយហេតុថា កុមារងាយរងគ្រោះពេលស្តាប់ចម្លើយ នគរបាលគួរកំណត់ពេលវេលាឲ្យខ្លីៗក្នុងពេលស្តាប់ចម្លើយ ហើយត្រូវមានសម្រាកឲ្យបានច្រើនដង។ ម្យ៉ាងវិញទៀត កុមារមានភាពឯកោ នៅពេលដែលខ្លួនមិនមានអ្នកជាទីស្រលាញ់នៅក្បែរ ហេតុនេះនគរបាលត្រូវយល់អំពីសិទ្ធិក្នុងនីតិវិធី ដែលមានដូចជាសិទ្ធិទទួលបានជំនួយពីមេធាវី និងអ្នកទំនុកបម្រុងក្នុងពេលស្តាប់ចម្លើយជាដើម។

## ព្រះរាជអាជ្ញា

ចំណុចជាច្រើនដែលបានលើកឡើងខាងលើ ក៏ត្រូវយកមកអនុវត្តចំពោះព្រះរាជអាជ្ញាដែរ ។ ព្រះរាជអាជ្ញាចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញខាងកុមារ ដូចដែលមានចែងនៅក្នុងមាត្រា ២៤ នៃច្បាប់នេះ ដែលចែងថា តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជនត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន ។

មាត្រា ២៦ តម្រូវឲ្យព្រះរាជអាជ្ញាប្រាប់កុមារអំពីសិទ្ធិរបស់ខ្លួនដែលចែងក្នុងមាត្រា ៦ ប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតយល់ដឹងរបស់អនីតិជនពេលធ្វើការស្តាប់ចម្លើយ។ មាត្រានេះចែងផងដែរថា ការស្តាប់ចម្លើយត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី។ ចំណុចដែលបានលើកឡើងខាងលើ

ជុំវិញការសារភាពរបស់កុមារ ដែលថាកុមារងាយនឹងសារភាពកំហុសដែលខ្លួនមិនបានធ្វើនោះ ក៏ពាក់ព័ន្ធនឹងព្រះរាជ្ញាផងដែរ (សូមពិនិត្យមើលភាពខុសគ្នារវាងកុមារ និងមនុស្សពេញវ័យ) ។

ព្រះរាជអាជ្ញាមានតួនាទីសំខាន់ណាស់ ក្នុងការពិចារណាជាបឋមលើការបង្វែរ ចំពោះកុមារដែលមានអាយុ ពី ១៤ ដល់ក្រោម ១៨ឆ្នាំ ដែល បានប្រព្រឹត្តបទលហុ ឬមជ្ឈឹម (មាត្រា ២៨) ។ ព្រះរាអាជ្ញាគួរទទួលបានការអប់រំឲ្យយល់ពីផលប្រយោជន៍នៃការបង្វែរ ពីព្រោះថាអត្រានៃការប្រព្រឹត្តបទល្មើសារជាថ្មីដោយអនីតិជនដែលទទួលបានការបង្វែរ មានកម្រិតទាបបើធៀបទៅនឹងអនីតិជនដែលត្រូវបានបញ្ជូនទៅតាមនីតិវិធីតុលាការ។

## មេធាវីចុងចោទ

មេធាវីចុងចោទចាំបាច់ត្រូវយល់ដឹងអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីការវិវឌ្ឍន៍ភាពក្មេងខ្ចីរបស់កុមារ ពីព្រោះឯកសារនេះជារឿយៗគឺពាក់ព័ន្ធនឹងស្ថានសំរាលទោសរបស់កុមារ។ ជាពិសេស ការរីកលូតលាស់យឺតនៃខួរក្បាលផ្នែកខាងមុខ ដែលមានតួនាទីក្នុងការវិនិច្ឆ័យ ធ្វើការសម្រេចចិត្ត និងការគ្រប់គ្រងទង្វើ គឺជាអំណះអំណាងដែលត្រូវពន្យល់ទៅតុលាការថាជាហេតុផលដែលនាំឲ្យកុមារចូលរួមក្នុងបទល្មើស។ ឥទ្ធិពលអូសទាញពីមិត្តភ័ក្ររបស់កុមារ ក៏ជាកត្តាជំរុញឲ្យកុមារប្រព្រឹត្តបទល្មើសជាមួយអ្នកដទៃដែរ។

មេធាវីចុងចោទចាំបាច់ត្រូវដឹងអំពីភាពងាយរងគ្រោះរបស់កុមារនៅពេលមានការស្តាប់ចម្លើយដោយនគរបាល ដឹងអំពីសារសំខាន់នៃការអនុវត្តតាមសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីពេលស្តាប់ចម្លើយ និងពីភាពចាំបាច់ក្នុងការពិនិត្យឲ្យបានម៉ត់ចត់នូវកាលៈទេសៈជុំវិញការសារភាពរបស់កុមារ ជាពិសេសនៅពេលដែលមិនមានភស្តុតាងបញ្ជាក់ ។

ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារនៅក្នុងកិច្ចដំណើរការរឿងក្តីរបស់កុមារ ចាំបាច់ត្រូវដឹងអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលបានបង្ហាញថាកុមារមិនមានសមត្ថភាពពេញលេញក្នុងការចូលរួមសវនាការដោយសារតែភាពក្មេងខ្ចីរបស់ខ្លួន។ មេធាវីចុងចោទមានតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យមើល ថាតើកុមារយល់អំពីនីតិវិធីតុលាការ និងត្រូវជួយដល់កុមារឲ្យចូលរួមប្រកបដោយប្រសិទ្ធិភាព។

## តុលាការ

មាត្រា ៣១ នៃច្បាប់នេះ ចែងថា ការស៊ើបអង្កេតត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរ ដែលមានជំនាញខាងកុមារ។ ការបណ្តុះបណ្តាលផ្នែកជំនាញខាងកុមារដល់ចៅក្រម ក៏ត្រូវដាក់បញ្ចូលផងដែរ នូវប្រធានបទដូចដែលបានលើកឡើងខាងលើ ដែលទាក់ទងនឹងផលប៉ះពាល់ដល់ការវិវឌ្ឍន៍នៃភាពក្មេងខ្ចីរបស់កុមារ ពេលចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ មាត្រា ៥៣ តម្រូវឲ្យតុលាការពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថា ចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់អំពីផលវិបាកនៃការសារភាពនេះ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែង ការបង្ខិតបង្ខំ និងមិនយល់ដឹងអំពីផលវិបាកនៃការសារភាព មិនត្រូវចាត់ទុកថាជាភស្តុតាងនៃ

ពិរុទ្ធភាពឡើយ។ ដើម្បីវាយតម្លៃលើចម្លើយសារភាពកំហុស វាជារឿងសំខាន់ដែលចៅក្រមយល់ជ្រាបអំពីការសិក្សាស្រាវជ្រាវផ្នែកចិត្តសាស្ត្រដែលបានអះអាងថា កុមារងាយនឹងសារភាពកំហុសដោយមិនត្រឹមត្រូវ ដោយសារតែការលួតលាស់ និងការយល់ដឹងរបស់កុមារនៅមានកម្រិត។ ពួកគេងាយនឹងធ្វើតាមការណែនាំរបស់មន្ត្រីមានសមត្ថកិច្ច (Kassin ២០១០) ។

ការពិតដែលថាពេលខ្លះកុមារឆ្លើយសារភាពទាំងខ្លួនមិនបានប្រព្រឹត្តខុសនោះ មានការទទួលស្គាល់យ៉ាងច្បាស់នៅក្នុងមាត្រា ៥៣ ដោយតម្រូវឲ្យមានភស្តុតាងបញ្ជាក់បន្ថែមចំពោះចម្លើយសារភាព នៅពេលសវនាការ។ នេះគឺជាការការពារដ៏សំខាន់មួយ។

ជាទូទៅ ចៅក្រមដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានាថា មន្ត្រីបម្រើការងារនៅក្នុងតុលាការទទួលយកការអនុវត្ត និងការប្រើភាសាបែបកុមារមេត្រី។ ការសិក្សាស្រាវជ្រាវគូសបញ្ជាក់ថា កុមារមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមសវនារឿងក្ដីព្រហ្មទណ្ឌឲ្យមានប្រសិទ្ធភាពទេ ។ ដូចបានលើកឡើងខាងលើ (សូមអានចំណុច ភាពខុសគ្នារវាងកុមារ និង មនុស្សពេញវ័យ) មានការសិក្សាជាច្រើនបានបង្ហាញថា ដោយសារតែភាពក្មេងខ្ចីរបស់កុមារ ធ្វើឲ្យកុមារមិនអាចយល់និងចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌបានទេ។

ក្រៅពីនេះ ក៏គួរដឹងផងដែរអំពីការសិក្សាស្រាវជ្រាវស្ដីពីសមត្ថភាពក្នុងការនិយាយ (ជំនាញស្ដាប់និងនិយាយ) របស់អនីតិជនប្រព្រឹត្តបទល្មើស។ បញ្ហាទាំងនេះអាចកើតមានផលវិបាកចំពោះបុគ្គលិកតុលាការដែលចាំបាច់ត្រូវពង្រឹងការអនុវត្តបែបតុលាការកុមាមេត្រី ដើម្បីដោះស្រាយនូវឧបសគ្គដែលរារាំងកុមារមិនឲ្យយល់ដឹងនិងចូលរួមយ៉ាងពេញលេញក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌបាន។ ការអប់រំណែនាំឲ្យយល់ដឹងអំពីការប្រើប្រាស់ភាសានិយាយជាមួយកុមារ ក៏សំខាន់ណាស់ដែរនៅពេលមានការពិភាក្សាពីការបង្វែរ ការផ្ដល់ប្រឹក្សាយោបល់ ឬ ពេលមានកិច្ចពិភាក្សារកដំណោះស្រាយ។ កុមារអាចមិនមានសមត្ថភាពចូលរួមឲ្យបានពេញលេញ ដូច្នេះវាតម្រូវឲ្យមានការជួយគាំទ្រដល់កុមារដើម្បីឲ្យកុមារអាចបញ្ចេញយោបល់បានត្រឹមត្រូវ។

## បុគ្គលិកធ្វើការងារក្នុងតួនាទីសង្គមកិច្ច

វាជារឿងសំខាន់សម្រាប់អ្នកដែលទទួលខុសត្រូវផ្ដល់ការគាំទ្រនិងស្ដារនីតិសម្បទារបស់កុមារប្រព្រឹត្តបទល្មើស បានយល់ដឹងអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវស្ដីអំពីការវិវឌ្ឍផ្លូវចិត្តរបស់កុមារ (សូមអានត្រង់ចំណុច ភាពខុសគ្នា រវាងកុមារ និងមនុស្សពេញវ័យ) និងពីវិធីសាស្ត្រអប់រំផ្លូវចិត្ត ដើម្បីជួយឲ្យកុមារយល់ដឹងពីកត្តាអូសទាញមួយចំនួនដែលមានដូចជាឥទ្ធិពលរបស់មិត្តភក្តិ និងទង្វើប្រកបដោយគ្រោះថ្នាក់ ដែលអាចនាំឲ្យកុមារប្រព្រឹត្តបទល្មើស។ ការអប់រំណែនាំឲ្យយល់ដឹងអំពីការប្រើប្រាស់ភាសានិយាយជាមួយកុមារក៏សំខាន់ណាស់ដែរ សម្រាប់អ្នកដែលធ្វើការងារលើការស្ដារនីតិសម្បទានេះ ក៏ដូចជាអ្នកដែលចូលរួមរៀបចំការបង្វែរ ពីព្រោះថាអសមត្ថភាពរបស់កុមារក្នុងការយល់ដឹងពេលចូលរួមក្នុងពេលប្រឹក្សាយោបល់ សន្ទានកម្ម កិច្ចពិភាក្សារកដំណោះស្រាយ អាចនឹងនាំឲ្យមានបរាជ័យនៅពេលអនុវត្ត។

# ១០. ការឃុំខ្លួនបណ្ដោះអាសន្ន

មានភស្តុតាងដែល មិនអាចបដិសេធបានថា «ការឃាត់ខ្លួន និងឃុំខ្លួនកុមារអាចជាទង្វើអមនុស្សធម៌ដ៏ធ្ងន់ធ្ងរ» ដែលជាការរំលោភលើគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ ហើយដែលអាចនាំឲ្យបរាជ័យក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ និងរារាំងដល់ឱកាសរីកចម្រើននៃជីវិតរបស់កុមារ (BAAF ២០១៥ ទំព័រ ២)។ ការឃុំខ្លួនមុនពេល ឬក្រោយពេលផ្តន្ទាទោសគួរតែជាជម្រើសចុងក្រោយ សម្រាប់កុមារ ។

គោលការណ៍នេះមានចែងនៅក្នុងច្បាប់យុត្តិធម៌អនីតិជនកម្ពុជា និងស្របទៅនឹងច្បាប់អន្តរជាតិ និងការអនុវត្តន៍ល្អរបស់អន្តរជាតិ ។ មាត្រា ៥ នៃច្បាប់យុត្តិធម៌អនីតិជន ចែងថា ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសកុមារគួរតែជាជម្រើសចុងក្រោយ និង សម្រាប់តែរយៈពេលខ្លីតែប៉ុណ្ណោះ។

មាត្រា ៧៩ នៃច្បាប់នេះ ចែងថា «ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណង ស្តារនីតិសម្បទា ជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ» ។ គោលបំណងទាំងនេះនឹងសម្រេចទៅបានតាមរយៈការគាំទ្រពីបញ្ញត្តិដែលចែងអំពីការផ្តល់សេវាដ៏សមរម្យ (មាត្រា ៨១) បែងចែកកុមារចេញពីមនុស្សពេញវ័យ និងមានការប្រព្រឹត្តស្របតាមលក្ខណៈជាកុមារ (មាត្រា ៨២) ចំណាត់ថ្នាក់សន្តិសុខឲ្យទាបបំផុត (មាត្រា ៨៣) និង ស្ថិតនៅក្នុងទីកន្លែងដែលមានធ្វើអធិការកិច្ចជាទៀងទាត់ (មាត្រា ៨៥) ។ ខណៈពេលដែលស្នាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទា មាត្រា ៨១ចែងថា៖ កុមារមានសិទ្ធិចូលរៀនតាមកម្មវិធីអប់រំ ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីដទៃ ដែលអាចជួយដល់ពួកគេ ដើម្បីអភិវឌ្ឍសក្តានុពលរបស់ខ្លួនឲ្យក្លាយជាពលរដ្ឋល្អរបស់សង្គម និងដើម្បីជួយដល់ការធ្វើសមាហរណកម្មត្រឡប់ទៅក្នុងសង្គមវិញនៅពេលដោះលែង។

ច្បាប់យុត្តិធម៌អនីតិជនតម្រូវឲ្យបុគ្គលិកដែលបម្រើការងារនៅក្នុងមណ្ឌលស្តារនីតិសម្បទា ផ្តោតយកចិត្តទុកដាក់លើការស្តារនីតិសម្បទា ជាជាងការផ្តន្ទាទោស ។ មាត្រា៨៤នៃច្បាប់នេះចែងថា ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលឃុំនីតិសម្បទា ជាអាទិ៍ មន្ត្រីមណ្ឌលឃុំនីតិសម្បទា ភ្នាក់ងារសង្គមកិច្ច អ្នកជំនាញផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្រ្ត ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះបណ្តាលឲ្យបានត្រឹមត្រូវអំពីចិត្តសាស្រ្តកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

## ការធ្វើសមាហរណកម្ម

បញ្ញត្តិទាក់ទងនឹងការដោះលែងដោយមានលក្ខខណ្ឌ ត្រូវបានចែងនៅក្នុងជំពូក ១១ នៃច្បាប់យុត្តិធម៌អនីតិជន ។ ការស្នើសុំលើកលែងទោសអាចធ្វើទៅបានបន្ទាប់ពីបម្រើទោស បានមួយភាគបី ប្រសិនបើទោស

នោះតិចជាងឬស្មើមួយឆ្នាំ (មាត្រា ៧២)។ ការស្នើសុំលើកលែងទោសអាចធ្វើទៅបានបន្ទាប់ពីបម្រើទោសបានពាក់កណ្តាលនៃទោស ប្រសិនទោសមានរយៈពេលច្រើនជាងមួយឆ្នាំ (មាត្រា ៧២) ។ បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌរួមមាន៖ ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់អនីតិជននោះ អ្នកតំណាងដែលច្បាប់បានកំណត់ ប្រធានមណ្ឌលយុវនីតិសម្បទា ភ្នាក់ងារសង្គមកិច្ចដែលជាប់ពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ បេសកកម្មការទូត ឬកុងស៊ុលបរទេសក្នុងករណីអនីតិជនជាជនបរទេស (មាត្រា ៧៣)។ ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញ អាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ៖ ២ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៦ខែចំពោះបទមជ្ឈិម និង១ខែចំពោះបទលហុ រយៈពេលទាំងនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល (មាត្រា៧៤)។

តួនាទីរបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវបានបញ្ជាក់នៅក្នុងច្បាប់នេះ។ ច្បាប់យុត្តិធម៌អនីតិជនបានផ្តល់តួនាទីដល់ភ្នាក់ងារសង្គមកិច្ចក្នុងការគ្រប់គ្រងកុមារឲ្យរួចផុតពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។  គោលបំណងនៃច្បាប់នេះដែលមានចែងក្នុងមាត្រា ១ គឺដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និងគាំទ្រការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គម និងសហគមន៍វិញ។

យោងតាមមាត្រា ១១ ភ្នាក់ងារសង្គមកិច្ចទទួលបន្ទុកការងារជាច្រើនរួមទាំងការផ្តល់សេវាស្តារនីតិសម្បទា និងសមាហរណកម្មកុមារផង។ ចំណែកឯ អ្នកដំណាងដែលច្បាប់បានកំណត់ ក៏ដើរតួរនាទី យ៉ាងសំខាន់ដែរក្នុងការធានាឲ្យមានការធ្វើសមាហរណកម្មដោយជោគជ័យ។ លទ្ធភាពរបស់អ្នកទាំងនេះ ក្នុងការធានាការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌលឲ្យបានជោគជ័យនោះ វាអាស្រ័យទៅលើអ្វីដែលកុមារទទួលបានពេលរស់នៅក្នុងមណ្ឌល កាលៈទេសៈសង្គម រួមទាំងកន្លែងរស់នៅសមរម្យ ការអប់រំ និងការងារ ដែលកុមារនឹងជួបប្រទះក្រោយពេលដោះលែង។ មណ្ឌលយុវនីតិសម្បទាផ្តោតយកចិត្តទុកដាក់លើការស្តារនីតិសម្បទាជាជាងការផ្តន្ទាទោស ដើម្បីធានាថាកុមារទទួលបានជំនាញ និងមានអាកប្បកិរិយាល្អ ហើយក្លាយខ្លួនជាសមាជិកល្អក្នុងសង្គមនៅពេលដោះលែង។ កម្មវិធីទាំងឡាយនៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវរៀបចំយ៉ាងណាដើម្បីឲ្យការធ្វើសមាហរណកម្មទទួលបានជោគជ័យ (មាត្រា៨១)។ ភ្នាក់ងារសង្គមកិច្ចនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ ត្រៀមកុមារមុនពេលដោះលែង ដូចជាការរៀបចំសេវាដែលមាននៅនឹងសហគមន៍ ជាមួយនឹងការផ្តល់ការគាំទ្រសំខាន់ៗ និងនៅក្នុងពេលបញ្ជូនកុមារចេញពីមណ្ឌលត្រឡប់ទៅក្នុងសង្គមវិញ។

## សេចក្តីសង្ខេប

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនកម្ពុជា បង្ហាញផ្លូវសម្រាប់បង្កើតប្រព័ន្ធយុត្តិធម៌អនីតិជន ដោយផ្អែកលើការអនុវត្តល្អដែលនេះជាការឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់ខ្លួនចំពោះសិទ្ធិមនុស្ស។ គោលបំណងនៃគោលការណ៍របស់អនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន គឺដើម្បីធានាថា យុត្តិធម៌របស់កុមារគួរត្រូវបានអនុវត្តដោយឈរលើឧត្តមប្រយោជន៍របស់កុមារ  និងដើម្បីធានាថាគោលនយោបាយ និងដំណើរការយុត្តិធម៌អនីតិជន គាំទ្រកុមារ និងការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពទៅក្នុងសង្គម (Dunkel and Pruin ២០១២) ។

បញ្ញត្តិច្បាប់យុត្តិធម៌អនីតិជនត្រូវបានតាក់តែងឡើងស្របតាមគោលការណ៍ «ឧត្តមប្រយោជន៍របស់កុមារ» និងស្របទៅនឹងគោលការណ៍ច្បាប់អន្តរជាតិផ្សេងទៀត ដែលបានរៀបរាប់លំអិតនៅក្នុងឯកសារនេះ។ ផ្អែកតាមច្បាប់អន្តជាតិ កុមារត្រូវបានគេចាត់ទុកថាខុសពីមនុស្សពេញវ័យ ដូច្នេះត្រូវប្រព្រឹត្តមកលើកុមារទៅតាមនោះដែរ។ ដូចបានលើកឡើងខាងលើ គឺមានហេតុផលច្បាស់លាស់ ដែលបញ្ជាក់ពីភាពខុសគ្នានេះ នោះគឺពាក់ព័ន្ធនឹងរយៈពេលនៃការអភិវឌ្ឍខួរក្បាលរបស់កុមាររហូតជិតពេញវ័យដែលក្នុងរយៈពេលនេះកុមារពុំទាន់មានការយល់ដឹងពេញលេញដូចមនុស្សពេញវ័យទេ។ ដូច្នេះ ប្រសិនបើឲ្យកុមារទទួលខុសត្រូវព្រហ្មទណ្ឌដូចមនុស្សពេញវ័យ ក្នុងខណៈដែលកុមារពុំទាន់មានសមត្ថភាពពេញលេញក្នុងការគិត សម្រេច ឬគ្រប់គ្រងអារម្មណ៍របស់ខ្លួននោះ វាគឺជារឿងអយុត្តិធម៌។ បញ្ញត្តិច្បាប់យុត្តិធម៌អនីតិជនបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយដែលមាននីតិវិធីកុមារមេត្រី ដែលលើកកម្ពស់យុត្តិធម៌សហគមន៍ ភាពត្រឹមត្រូវ និងមានការចូលរួមពីកុមារដោយប្រសិទ្ធភាព។

ទស្សនៈស្តីពីការស្តារនីតិសម្បទានិងធ្វើសមាហរណកម្មអនីតិជន ដែលមានចែងក្នុងច្បាប់យុត្តិធម៌អនីតិជន អាចប្រឈមនឹងជំនឿរបស់សហគមន៍ ដែលនៅតែគិតថាការដាក់ពិន័យនិងការផ្តន្ទាទោស គឺជាជម្រើសដ៏ល្អសម្រាប់អ្នកប្រព្រឹត្តបទល្មើស ។ ទោះយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវអន្តរជាតិ បង្ហាញថាការជ្រើសរើសយកវិធានការផ្តន្ទាទោសសម្រាប់យុត្តិធម៌អនីតិជនដែលរួមមានការឃុំខ្លួនជាដើម មិនបានជួយកាត់បន្ថយអត្រាបទល្មើសនោះទេ ហើយថែមទាំងបរាជ័យក្នុងការដោះស្រាយឫសគល់នៃបញ្ហាដែលបណ្តាលឲ្យមានបទល្មើស ចំណាយថវិកាច្រើនក្នុងរយៈពេលយូរ និងធ្វើឲ្យកុមារក្លាយជាអ្នកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅពេលពេញវ័យទៀតផង ។

វាច្បាស់ណាស់ទៅហើយដែលថា វិធីសាស្ត្រផ្តោតយកចិត្តទុកដាក់លើការបង្វែរកុមារចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការស្តារនីតិសម្បទា ផ្តល់ផលប្រយោជន៍ជាច្រើន។ ការនិយមអនុវត្តវិធានការចេញសេចក្តីអប់រំណែនាំនិងព្រមានដោយនគរបាល រួមជាមួយនឹងវិធានការបង្វែរ គឺពិតជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើស ហើយវិធីសាស្ត្រនេះចាំបាច់ត្រូវទទួលស្គាល់និងលើកកម្ពស់។ ដូចគ្នានេះដែរ ការធ្វើសមាហរណកម្ម និងការស្តារនីតិសម្បទា ក៏ត្រូវទទួលស្គាល់ និងលើកកម្ពស់ផងដែរ ព្រោះវាជាយុទ្ធសាស្ត្រទប់ស្កាត់បទល្មើសដ៏មានប្រសិទ្ធភាព និងជួយកាត់បន្ថយការប្រព្រឹត្តបទល្មើសជាថ្មីដែរ ។

# ១១. ឯកសារយោង


Australian Law Reform Commission, Children in the Legal Process, 1997

Berndt, T., Developmental changes in conformity to peers and parents. Developmental Psychology. 1979; 15: 608–616

BAAF (British Association for Adoption and Fostering), Alternatives to Custody. Daphne III Funding Programme of the European Union, 2015

Costanzo P, Shaw M. Conformity as a function of age level. Child Development. 1966; 37:967–975

Cunneen, C. and White, R., Juvenile justice: youth and crime in Australia, Oxford University Press, 2011

Dennison S, Stewart A & Hurren E 2006. Police cautioning in Queensland: The impact on juvenile offending pathways. Trends & Issues in Crime and Criminal Justice no. 306. Canberra: Australian Institute of Criminology

Drizin, S. and Leo, R., The Problem of False Confessions in the Post-DNA World, 82 North Carolina Law Review, 891 (2004)

D'Unger A., Land K., McCall P., Nagin D. (1998). How many latent classes of delinquent/criminal careers? Results from mixed Poisson regression analyses. American Journal of Sociology, 103, 1593–1630.

Dunkel, F. and Pruin, I., 2012. Young adult offenders in juvenile and criminal justice systems in Europe. In (Friedrich L¨osel, Anthony Bottoms, and David P. Farrington, eds.), Young Adult Offenders: Lost in Transition? London, U.K.: Routledge

Egger, S., 2005. An Assessment of the Situation of Children in Conflict with the Law in the Kingdom of Cambodia. The Research Institute for Asia and the Pacific, University of Sydney.

Farrington D 1986. Age and crime, in Tonry M & Morris N (eds), Crime and justice: An annual review of research. Chicago: University of Chicago Press: 189–250

Gardner M, Steinberg L. Peer influence on risk taking, risk preference, and risky decision making in adolescence and adulthood: An experimental study. Developmental Psychology. 2005; 41: 625–635.

Greene, 1986. Future-time perspective in adolescence: The present of things future revisited. Journal of Youth and Adolescence. 15, 99–113.

Grisso, 1997. The Competence of Adolescents as Trial Defendants. Psychology, Public Policy and Law, 3: 3-32.

Grisso T, Steinberg L, Woolard J, Cauffman E, Scott E, Graham S, et al. Juveniles' competence to stand trial: A comparison of adolescents' and adults' capacities as trial defendants. Law and Human Behavior. 2003; 27:333–363.

Kassin, S., et al., 2010. Police-Induced Confessions: Risk Factors and Recommendations, Law and Human Behavior, 34: 3-48.

Keating D. 2004. Cognitive and brain development. In Handbook of Adolescent Psychology, ed. R Lerner, L Steinberg, pp. 45–84. New York: Wiley. 2nd ed.

LICADHO, 2013. Human Rights: The Year in Review.

Moffitt, T. E. (1993). Adolescence-limited and life-course-persistent antisocial behavior: A developmental taxonomy. Psychological Review, 100(4), 674-701

Nurmi J. 1991. How do adolescents see their future? A review of the development of future orientation and planning. Developmental Review, 11:1–59

O'Connor, I., Youth, crime and justice in Queensland: an information and issues paper, Brisbane : Criminal Justice Commission, Research and Co-ordination Division, 1992

Phallack, L., 2012. "Overview of the Cambodian Legal and Judicial System", in Peng, Phallack and Menzel, Introduction to Cambodian Law, Konrad Adfenauer Stiftung, 2012

Piquero, A.R., Farrington, D.P., Blumstein, A. The criminal career paradigm: Background and recent developments. In: Tonry M, editor. Crime and justice: A review of research. Chicago, IL: University of Chicago Press; 2003.

Potas, I., Vining, A. & Wilson, P. 1990, Young People and Crime: Costs and Prevention, Australian Institute of Criminology, Canberra.

Redlich, A.D, and Drizin, S., "Police interrogation of youth", in The Mental Health Needs of Young Offenders: Forging Paths Toward Reintegration and Rehabilitation, 2007.

Redlich, A.D, and Shteynberg, R.V., To plead or not to plead: A comparison of juvenile and adult true and false plea decisions. 2016; 40: 611-625.

Reiss A.J., Farrington, D.P., Advancing knowledge about co-offending: Results from a prospective longitudinal survey of London males. The Journal of Criminal Law and Criminology. 1991; 82: 360–395.

Reyna, V. F., & Farley, F. (2006). Risk and rationality in adolescent decision making: Implications for theory, practice, and public policy. Psychological Science in the Public Interest, 7, 1–44.

The Royal Society, 2011. Brain Waves Module 4: Neuroscience and the Law.

Scott, E., Reppucci, N., & Woolard, J. (1995). Evaluating adolescent decision-making in legal contexts. Law and Human Behavior 19, 221–244.

Smith, T. and Brownlees, L., 2011, Age assessment practices: a literature review and annotated bibliography, UNICEF.

Snow PC & Powell MB 2011a. Oral language competence in incarcerated young offenders: Exploring links with offending severity. Report to the Criminology Research Council on Project 10/08–09. Melbourne: Monash University

Steinberg, L. and Cauffman, E., 1996. Maturity of judgment in adolescence: Psychosocial factors in adolescence in decision-making. Law and Human Behavior, 20: 249-272

Steinberg, L. (2004). Psychosocial development in late adolescence: Suggestions for a research agenda. Unpublished manuscript, Department of Psychology, Temple University, Philadelphia.

Teeuwen, A., 2006. "The State of Juvenile Justice in Cambodia" in A Measure of Last Resort? Raoul Wallenberg Institute

This Life Cambodia, This Life Beyond Bars, 2014.

Travers, E., 2011. Upholding children's rights in the judicial system: An NGO's experience of working for juvenile justice in Cambodia.

UNICEF, 2009. Toolkit on Diversion and Alternatives to Detention

UN High Commission for Human Rights, Human Rights Standards and Practice for the Police,

United Nations Office on Drugs and Crime, Training Manual on Policing Urban Space, 2013

United Nations Office on Drugs and Crime, Handbook on Restorative Justice Programmes, 2006

Vanrath, "The Basics of Substantial Cambodian Criminal Law", in Peng, Phallack and Menzel, Introduction to Cambodian Law, Konrad Adfenauer Stiftung, 2012.

Ward, S. L., & Overton, W. F.,(1990). Semantic familiarity, relevance and the development of deductive reasoning. Developmental Psychology, 26, 488-493

Watt, B., O'Leary, J. and O'Toole, S., Juvenile Fitness for Trial: Lawyer and Youth Justice Officer Professional Survey, 2017: 24, 191-204.

ចូលរួមផ្តល់ជំនួយជាថវិកានិងបច្ចេកទេស៖

unicef
for every child

ចូលរួមផ្តល់ជំនួយបច្ចេកទេស៖

PLAN INTERNATIONAL

LEGAL AID of CAMBODIA

Children's Rights International CRI

ចូលរួមឧបត្ថម្ភថវិកាបោះពុម្ព៖

Australian Aid